# សម្មាគិហិប្រតិបត្តិ

ផ្សាយចេញពី : **វត្តព្រះពុទ្ធអណ្ដែត**

សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល

ប្រមូលរៀបរៀងដោយ

ព្រះឋានចារី **អ៊ុក ថុល** (ឋានចារី)

បោះពុម្ពផ្សាយលើកទី ១ ចំនួន ៣.000 ក្បាល

**សម្រាប់ជាធម្មទាន**

**ព.ស.២៥៥៣**

**គ.ស. ២០០៩**

# មាតិកាធម៌

ពាក្យឧទ្ទិស .................................................................
អក្ខរវិធី និងពន្យល់របៀបអាន ........................................ ១
ទេវតាបកាសនគាថា........................................................៤
បទសរភញ្ញ និង នមស្សការ ..............................................៥
រតនត្តយបូជា ឥមេហិ......................................................... ៦
ពុទ្ធរតនប្បណាម..............................................................៧
ធម្មរតនប្បណាម ...........................................................១២
សង្ឃរតនប្បណាម ..........................................................១៧
ពន្យល់បំភ្លឺ ..................................................................... ២៣
រតនប្បណាម បែបសង្ខេប ............................................... ២៤
នមស្សការព្រះរតនត្រ័យ................................................២៧
នមស្សការព្រះរតនត្រ័យ ប្រែបទកាព្យសុទ្ធ ..................៣០
នមស្សការបូជនីយវត្ថុជាទីគោរព ................................. ៣២
នមស្សការស្មាមព្រះបាទព្រះពុទ្ធ....................................៣៣
នមស្សការ ធាតុចេតិយ៍ ..................................................៣៥
ចតុរារក្ខកម្មដ្ឋាន............................................................. ៤២
នមស្សការានុភាព..........................................................៤៤
សុភមង្គលគាថា...............................................................៤៥
ផ្សាយមេត្តាចំពោះសត្វក្នុងទិសទាំង ១០........................ ៤៧
គាថាសូមសេចក្ដីសុខ ..................................................... ៥២
បត្តិទានគាថា យាទេវតា...................................................៥៥

បត្តិទានគាថា សេចក្តីប្រែជាកាព្យ .................................. ៥៨
បត្តិទានគាថា សំរាយពាក្យកាព្យ.................................... ៦០
បត្តិទានគាថា សំរាយពាក្យកាព្យ.................................... ៦១
បត្តិទានគាថា ក្នុងធម្មទាន............................................... ៦២
តេជះខ្ញុំសាង.............................................................. ៦២
បត្តិទានគាថា យំ កិញ្ចិ................................................... ៦៣
បត្តិទានគាថា សេចក្តីប្រែជាពាក្យកាព្យ.......................... ៦៦
បត្តិទានគាថា ឥមិនា....................................................... ៦៧
បត្តិទានគាថា ឥមិនា....................................................... ៦៨
ខមាបនគាថា យេកេចិ..................................................... ៧០
បុព្វភាគបប្បដិបត្តិ ម.ឧ.កៅ ឈឿន..................................... ៧១
សីលនៃឧបាសក.............................................................. ៨៤
អាជីវៈនៃឧបាសក............................................................ ៨៤
វិបត្តិនៃឧបាសក-សម្បត្តិនៃឧបាសក............................... ៨៦
គុណនៃឧបាសក.............................................................. ៨៩
វិធីសមាទាននិច្ចសីល ....................................................... ៩២
វិធីសមាទានឧបោសថសីល............................................ ១០១
ឯកជ្ឈសមាទាន............................................................ ១១០
អង្គនៃនិច្ចសីល............................................................ ១១៨
អង្គនៃឧបោសថសីល..................................................... ១២០
អកុសលកម្មបថ.............................................................១២៣
កុសលកម្មបថ .............................................................. ១២៨

សំដែងអំពីវិធីវេរភត្ត ១៤ប្រការ ............................... ១៣១
វេរគ្រឿងសេនាសនៈ ។ល។...................................... ១៤៨
បរិត្តភាសនាយាចនគាថា........................................... ១៥៣
ធម្មទេសនាយាចនគាថា ............................................ ១៥៦
សុខាភិយាចនគាថាសង្ខេប បសន្នា ហោន្តុ.................... ១៥៩
ប្រស្នាពុទ្ធគុណ ............................................................ ១៦១
ប្រស្នាធម្មគុណ............................................................ ១៨៧
ប្រស្នាសង្ឃគុណ........................................................... ១៩៧
សំនួរ-ចម្លើយ បឋមសញ្ញាណ...................................... ២១៤
កុសលកម្មបថ ៤០...................................................... ២៣០
អកុសលកម្មបថ ៤០.................................................... ២៣៧
ពុទ្ធឱវាទ ៣ បទ........................................................ ២៤៣
សំនួរក្នុងបទទី ១ ( ពាក្យថាបាប)............................... ២៤៥
សំនួរក្នុងបទទី ២ ( ពាក្យថាបុណ្យ)............................. ២៥០
សំនួរក្នុងបទទី ៣ ( ពាក្យថាជំរះចិត្ត) ......................... ២៥៧
សត្តមហាឋាន បឋមំ ពោធិ .......................................... ២៦៦
អដ្ឋមហាឋាន បឋមំ លុម្ពិនី.......................................... ២៦៧
សិរិឱន........................................................................ ២៦៩
ភាសិតោវាទ យោ បន.................................................. ២៧០
បច្ឆិមពុទ្ធវចនៈ........................................................... ២៨២
របៀបធ្វើមាឃបូជា-វិសាខបូជា................................... ២៨៥
ពុទ្ធបាទលក្ខណៈ.......................................................... ៣១២

ពុទ្ធបទចេតិយ........................................................... ៣១៣
មហាបុរិសលក្ខណៈ ៣២ ប្រការ.................................. ៣១៥
ពុទ្ធភាសិត សម្តេច ជួន ណាត ជោតញ្ញាណោ.............. ៣២០
គារវបុគ្គល ១០ ជំពូក.................................................... ៣២៤
ឃរាវាសធម៌................................................................ ៣២៧
ពុទ្ធសាសនសុភាសិត ព្រឹទ្ធាចារ្យ ទុយ អឿន............... ៣៣៤
ព្រះឆាយាល័ក្ខណ៏..........................................................
ជីវប្រវត្តិព្រះឋានចារី អ៊ុក ថុល ( ថានចារី) ........................ ក
ប្រវត្តិ វត្តព្រះពុទ្ធអណ្តែត................................................... ច

# ពាក្យឧទ្ទិស

ខ្ញុំសូមឧទ្ទិសនូវបុញ្ញកម្មនៃការប្រមូលចងក្រង រៀបរៀងសៀវភៅនេះផង នូវបុញ្ញកម្មនៃសៀវភៅនេះផង នូវធម្មទាន ឬ ធម្មបណ្ណាការនៃសៀវភៅនេះផង ជូនចំពោះបុព្វបុរសទាំងឡាយមានមាតា បិតាជាដើម ទាំងមានជីវិតនៅក្នុងលោកនេះ ទាំងការបាត់បង់ជីវិតទៅកើតក្នុងលោកខាងនាយ ។ ដោយអំណាចនៃកុសលកម្មនេះ សូមជួយរំដោះទុក្ខដល់ជនទាំងនោះ ប្រសិនបើមាន នឹងជួយបន្ថែមសេចក្ដីសុខ ប្រសិនបើមិនទាន់មានគ្រប់គ្រាន់ ។

ជាពិសេស សូមឧទ្ទិសកុសលទាំងអស់នេះ សម្រាប់ពុទ្ធ-បរិស័ទ ទូទាំងព្រះរាជាណាចក្រកម្ពុជា និងសព្វសត្វទាំងមនុស្ស ទាំងអមនុស្ស សូមប្រកបដោយជន្មាយុយឺនយូរ សុភមង្គល វឌ្ឍនភាព សុខុមាលភាព សមភាព ភាតរភាព និង សុខសន្តិភាព រុងរោចន៍ ជានិរន្តរ៍ ។

*សព្វសត្វទាំងពួង ស្ថិតនៅក្នុងកាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ និង លោកុត្តរភូមិ អាស្រ័យមកអំពីចិត្ត សូម ព្រះពុទ្ធសាសនា ស្ថិតជាអមតៈ ក្នុងចិត្តពុទ្ធបរិស័ទទូទៅ ។*

សូមព្រះតេជគុណ ព្រឹទ្ធាចារ្យ ធម្មកោវិទ
អត្ថកោវិទ នរជនទាំងឡាយ អ្នកមានឧបការៈ
ចំពោះសៀវភៅ " សម្មាហតិហិប្រតិបត្តិ " នេះ

# អក្ខរវិធី

ជាបឋម សូមអញ្ជើញពុទ្ធបរិស័ទអានអក្សរ ជារបៀបភាសាបាលី រួមជាមួយខ្ញុំព្រះករុណាអាត្មាភាព ដូចមានក្នុងខាងក្រោមនេះ :

## ផ្នែកព្យញ្ជនៈ មាន ៣៣ តួ

ក = កៈ អានថា " កាក់ "

ខ = ខៈ អានថា " ខាក់ "

គ = គៈ អានថា " គាក់ "

ឃ = ឃៈ អានថា "ឃាក់ "

ង = ងៈ អានថា " ងាក់ "

ច = ចៈ អានថា " ចាក់ "

ឆ = ឆៈ អានថា " ឆាក់ "

ជ = ជៈ អានថា " ជាក់ "

ឈ = ឈៈ អានថា " ឈាក់ "

ញ = ញៈ អានថា " ញាក់ "

ដ = ដៈ អានថា " ដាក់ "

ឋ = ឋៈ អានថា " ឋាក់ "

ឌ = ឌះ អានថា " ឌាក់ "

ឍ = ឍះ អានថា " ឍាក់ "

ណ = ណះ អានថា " ណាក់ "

ត = តះ អានថា " តាក់ "

ថ = ថះ អានថា " ថាក់ "

ទ = ទះ អានថា " ទាក់ "

ធ = ធះ អានថា " ធាក់ "

ន = នះ អានថា " នាក់ "

ប = បះ អានថា " ប៉ាក់ "

ផ = ផះ អានថា " ផាក់ "

ព = ពះ អានថា " ពាក់ "

ភ = ភះ អានថា " ភាក់ "

ម = មះ អានថា " មាក់ "

យ = យះ អានថា " យាក់ "

រ = រះ អានថា " រាក់ "

ល = លះ អានថា " លាក់ "

វ = វះ អានថា " វាក់ "

ស = សៈ អានថា " សាក់ "

ហ = ហៈ អានថា " ហាក់ "

ឡ = ឡៈ អានថា " ឡាក់ "

អ = អៈ អានថា " អាក់ "

## ផ្នែកស្រៈ មាន ៨ តួ

អ = អៈ អានថា " អាក់ "

អា = អា អានថា " អា "

ឥ = ឥ អានថា " អ៊ិ "

ឦ = ឦ អានថា " អ៊ី "

ឧ = ឧ អានថា " អ៊ុ "

ឩ = ឩ អានថា " អ៊ូ "

ឯ = ឯ អានថា " អេ "

ឱ = ឱ អានថា " អោ "

*សូមអានគាថាខាងក្រោម :*

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**

សាប់ពាក់ប៉ាប៉ាស់សាក់ អាក់កាក់រាក់ណាំង កុសាក់លាស់ សូប៉ាក់ សាំប៉ាក់ទា ។

**សចិត្តបរិយោទបនំ ឯតំ ពុទ្ធានសាសនំ**

សាក់ចិតតាក់ប៉ាក់រ៉ុយ៉ោទាក់ប៉ាក់នាំង អេតាំង ពុតធានាក់សាសាក់នាំង ។

**“កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ” ។**

## ទេវតាបកាសនគាថា

ពាក្យប្រារព្ធអញ្ជើញទេវតា

**សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា**
**សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ ។**

ប្រែថា :ទេវតាទាំងឡាយដោយជុំវិញ ចូរមកប្រជុំគ្នាក្នុងទី-នេះ ចូរស្តាប់ព្រះសទ្ធម្មជាធម៌អាចឱ្យនូវសួគ៌ និង ព្រះនិព្វាន ( របស់ព្រះអនាវរណញ្ញាណ ) ជាស្តេចនៃអ្នកប្រាជ្ញ ។

## បទសរភញ្ញ

១.សូមថ្វាយបង្គំព្រះសម្ពុទ្ធ ប្រសើរបំផុតក្នុងលោកា
ជាគ្រូនៃមនុស្សនិងទេវា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ
ចង្អុលឱ្យដើរផ្លូវកណ្តាល មាគ៌ាត្រកាលអាចកំចាត់

ទុក្ខភ័យចង្រៃឱ្យខ្ចាយបាត់ អាចកាត់សង្សារទុក្ខបាន ។
២. សាសនាព្រះអង្គនៅសព្វថ្ងៃ សត្វមាននិស្ស័យពីបូរាណ
ប្រឹងរៀនប្រឹងស្តាប់ចេះចាំបាន កាន់តាមលំអានបានក្តីសុខ
ឥតមានសុខណាស្មើក្តីស្ងប់ បញ្ចប់ត្រឹមសុខឃ្លាតចាកទុក្ខ
តាំងពីលោកនេះតទៅមុខ ក្តីសុខនឹងមានព្រោះធម៌ស្ងប់ ។
៣.ខ្ញុំសូមបង្គំឆ្ពោះព្រះធម៌ ព្រះសង្ឃបវរទាំងសព្វគ្រប់
រួមជាត្រៃរត្ន័គួរគោរព ជាម្លប់ត្រជាក់នៃលោកា
ព្រះរូបព្រះធាតុនៃព្រះពុទ្ធ វិសុទ្ធិតាមអង្គព្រះសាស្តា
សូមគុណត្រៃរត្ន័ជួយខេមរា ឱ្យបានសុខាតរៀងទៅ ។

# **រតនត្តយបូជា**

ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតាទីនំ គុណវន្តានញ្ច ម~ យ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

ប្រែថា ៖ ខ្ញុំព្រះករុណា សូមបូជាចំពោះនូវ { ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ }

ជាម្ចាស់ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូប ជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

[១] ត្រង់បទព្រះបាលី គួរសូធ្យ ៣ បទគឺ ពុទ្ធំ ១, ធម្មំ ១, សង្ឃំ ១, រឺឯសេចក្តីប្រែ សូធ្យរួមតែបទ ១ ក៏បាន ។

## ពុទ្ធរតនប្បណាម

ថ្វាយបង្គំព្រះពុទ្ធរតនៈ

**នមោ តស្ស ភគវតោ អរហតោ**

**សម្មាសម្ពុទ្ធស្ស[១] ៗ (៣ ចប់)**

ប្រែថា ៖ វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូលមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជា ព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

**នមស្សការព្រះសម្ពុទ្ធដោយសង្ខេប,រួម ៖**

**យោ សន្និសិន្នោ វរពោធិមូលេ**
**មារំ សសេនំ មហតឹ វិជេយ្យោ**
**សម្ពោធិមាគច្ឆិ អនន្តញាណោ**

**លោកុត្តមោ តំ បនមាមិ ពុទ្ធំ ១**

ប្រែថាៈ ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអានាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្កក្រោមម្លប់ ពោធិ-ព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

ក្រាបថ្វាយបង្គំម្តង

**នមស្សការព្រះសម្ពុទ្ធពិស្តារ , ញែកកាលចេញជា ៣ ៈ**

---

១. សូមសូធ្យព្រះបាលី ៣ ចប់ , ឯសេចក្តីប្រែ សូធ្យតែមួយចប់ ក៏បាន ។

**យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា**
**អនាគតា បច្ចុប្បន្នា ច យេ ពុទ្ធា**
**អហំ វន្ទាមិ សព្វទា ។**

ប្រែថា: ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធ ទាំងឡាយនោះគ្រប់កាលទាំងពួង ។

ក្រាបថ្វាយបង្គំម្តង

**នមស្សការព្រះសម្ពុទ្ធរួចហើយ ត្រូវតម្កល់ចិត្តរឭកដល់ ពុទ្ធគុណទាំង ១០ ព្រះនាម ដោយបង្អោនកាយ វាចា ថា :**

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ**
**វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ**
**អនុត្តរោ បុរិសទម្មសារថិ សត្ថាទេវមនុស្សានំ**
**ពុទ្ធោ ភគវាតិ ។**

ប្រែថា: **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅ កាន់សុន្ទរស្ថាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាន នូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះ

ព្រះអង្គត្រាស់ដឹងនូវ ចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឱ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

ក្រាបថ្វាយបង្គំម្តង

**រឭកដល់ពុទ្ធគុណរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួន ដោយពាក្យសច្ចៈថា :**

**នត្ថិ មេ សរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គលចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវ ពាក្យសច្ចៈនេះ ។

ក្រាបថ្វាយបង្គំម្តង

**ប្តេជ្ញាខ្លួនរួចហើយ គប្បីសូធ្យសូមខមាទោស ចំពោះព្រះពុទ្ធជាម្ចាស់ថា :**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ**
**ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។**

ប្រែថា : **ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណាដែលខ្ញុំ ព្រះ-ករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់ **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់ អត់នូវ ទោសនោះដល់ខ្ញុំព្រះករុណា ។

ក្រាបថ្វាយបង្គំម្តង

## ធម្មរតនប្បណាម

ថ្វាយបង្គំព្រះធម្មរតន :

**នមស្សការព្រះសទ្ធម្មដោយសង្ខេប , រួម :**

**អដ្ឋង្គិការិយបថោ ជនានំ**
**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**
**ធម្មោ អយំ សន្តិករោ បណីតោ**
**និយ្យានិកោ តំ បនមាមិ ធម្មំ ។**

ប្រែថា : ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញុំាងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់

ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធម៌ដ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះ ដោយគោរព ។

ក្រាបថ្វាយបង្គំម្តង

**នមស្សការព្រះសទ្ធម្មពិស្តារ , ញែកកាលចេញជា ៣ :**

**យេ ច ធម្មា អតីតា ច  យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ៗ**

ប្រែថា: ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

**ក្រាបថ្វាយបង្គំម្តង**

**នមស្សការព្រះសទ្ធម្មរួចហើយ ត្រូវតម្កល់ចិត្តរឭកដល់ធម្មគុណដោយបង្អោនកាយវាចាថា:**

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។**

ប្រែថា : **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ដោយល្អ (**ធម្មោ** ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃទនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គ កើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបាន យឺតយូរឡើយ **ឯហិបស្សិកោ** ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបាន សម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គល ដទៃឱ្យចូលមកមើលបាន **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃ

ភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

ក្រាបថ្វាយបង្គំម្តង

**រឭកដល់ធម្មគុណរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួន ដោយពាក្យសច្ចៈថា ៖**

**នត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថា៖ **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរឭកដ៏ប្រសើរ របស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវ ពាក្យសច្ចៈនេះ ។

ក្រាបថ្វាយបង្គំម្តង

**ប្តេជ្ញាខ្លួនរួចហើយ គប្បីសូត្រសូមខមាទោស ចំពោះព្រះធម៌ជាម្ចាស់ថា ៖**

**ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ**

**យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។**

ប្រែថា: **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះធម៌ជាម្ចាស់ **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់ អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ក្រាបថ្វាយបង្គំម្តង

## សង្ឃរតនប្បណាម

ថ្វាយបង្គំព្រះសង្ឃរតន :

**នមស្សការព្រះអរិយសង្ឃដោយសង្ខេប , រួម :**

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ សន្តិន្ទ្រិយោ**
**សព្វមលប្បហីនោ គុណេហិនេកេហិ សមិទ្ធិបត្តោ**
**អនាសវោ តំ បនមាមិ សង្ឃំ ។**

ប្រែថា : ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិ-ណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួង បន្សាត់បង់ហើយ ជា

ព្រះសង្ឃដល់ហើយ នូវកិរិយាសម្រេចដោយគុណ ទាំង-ឡាយដ៏ច្រើន ជាព្រះសង្ឃមានអាសវៈធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

ក្រាបថ្វាយបង្គំម្តង

**នមស្សការព្រះអរិយសង្ឃពិស្តារ , ញែកកាលចេញជា ៣ :**

**យេ ច សង្ឃា អតីតា ច យេ ច សង្ឃា អនាគតា បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ៗ**

ប្រែថា : ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល កន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផល ក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

ក្រាបថ្វាយបង្គំម្តង

នមស្សការព្រះសង្ឃរួចហើយ ត្រូវតម្កល់ចិត្តរឭកដល់សង្ឃគុណដោយបង្អោនកាយវាចាថា:

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ**

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ**

**យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។**

ប្រែថា : **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរ-ធម៌ **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយ-បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេមផុតចាកទុក្ខទាំងពួង

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃ ជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់ សាមីចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផល ជាគូ ១ អរហត្តមគ្គ និងអរហត្តផល ជាគូ ១ **អដ្ឋបុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃ ដែលបានសម្រេចនូវ សោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង

ដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោន ចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជា បុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

ក្រាបថ្វាយបង្គំម្តង

**វព្ទកដល់សង្ឃគុណរួចហើយ គប្បីប្រកាសប្តេជ្ញាខ្លួន ដោយពាក្យសច្ចៈថា ៈ**

**នត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ**
**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ។**

ប្រែថាៈ **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរព្ទក នៃខ្ញុំព្រះករុណាមិនមានឡើយ **សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរព្ទក ដ៏ប្រសើររបស់ខ្ញុំព្រះករុណា **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវ ពាក្យសច្ចៈនេះ ។

ក្រាបថ្វាយបង្គំម្តង

**ប្តេជ្ញាខ្លួនរួចហើយ គប្បីសូធ្យសូមខមាទោស ចំពោះព្រះសង្ឃជាម្ចាស់ថា ៖**

**ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ**

**តំ មមំ ។**

ប្រែថា៖ **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវៈយវៈដ៏ឧត្តមគឺត្បូង **សង្ឃេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់ **សង្ឃោ ខមតុ តំ មមំ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះ ដល់ខ្ញុំព្រះករុណា ។

ក្រាបថ្វាយបង្គំម្តង

## <u>ពន្យល់បំភ្លឺ</u>

វិធីនមស្សការថ្វាយបង្គំនូវព្រះរតនត្រ័យមិនចំពោះកាល (សង្ខេប), ថ្វាយបង្គំនូវព្រះរតនត្រ័យ ក្នុងកាលទាំង ៣ , សេចក្តីរឭកគុណព្រះរតនត្រ័យ, ពាក្យប្តេជ្ញាខ្លួនចំពោះព្រះរតនត្រ័យ, ថ្វាយបង្គំសូមខមាទោសចំពោះព្រះរតនត្រ័យ,

ទាំង ៥ ន័យ ដែលបានពោលមកហើយ ក្នុងខាងដើមនោះ គឺជាសេចក្ដីពិស្ដារ ,ពុទ្ធបរិស័ទ អ្នកដែលមានសេចក្ដី ជ្រះថ្លា ប្រាថ្នាដើម្បីនមស្សការដល់ព្រះរតនត្រ័យ , បើមានឱកាស ល្មមគ្រប់គ្រាន់នឹងសូធ្យ នមស្សការទាំង ៣ បទ ដោយ សេចក្ដីពិស្ដារដូចបានរៀបរាប់ខាងដើម គឺជាការឧត្ដម ប្រពៃក្រៃពេក , តែបើឱកាសពេលខ្លី មិនអាចនឹងសូធ្យ ឱ្យ ចប់សព្វគ្រប់បាន , គ្រាន់តែ សូធ្យរឭក ពុទ្ធគុណ ធម្មគុណ សង្ឃគុណ , ថ្វាយបង្គំ , សូធ្យថ្វាយសក្ការៈបូជា ដោយ សេចក្ដីសង្ខេបខ្លី ៧ ដូចន័យខាងក្រោមនេះ ក៏ជាការស្រេច ។

# រតនប្បណាម បែបសង្ខេប

ព្រមទាំងបូជាគ្រឿងសក្ការៈ

**ឥតិបិ សោ ភគវា អរហំ ។ល។ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា: **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនាគឺកាយបយោគនិងវចីបយោគ ។ ល ។ **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយគឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ **តំ អរហាទិ~គុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា អរហំ ជាដើមនោះដោយសិរសាគឺត្បូង **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះសម្មា

សម្ពុទ្ធជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

ក្រាបថ្វាយបង្គំម្តង

**ស្វាក្ខាតោ ភគវតា ធម្មោ ។ល។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តព្វ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា : **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ ។ ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើមគប្បីដឹងគប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា ស្វាក្ខាតោ ជាដើមនោះដោយសិរសាគឺត្បូង **តព្វ ធម្មំ ឥមេហិ សក្ការេហិ**

**អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

ក្រាបថ្វាយបង្គំម្តង

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ ។ល។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នា-ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែថា : **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តធម៌

។ល។ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន **តំ សុបដិបន្នាទិ-គុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយ

ដោយគុណ មានគុណថា សុបដិបន្នោ ជាដើមនោះ ដោយសិរសាគីត្បូង **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមាន ប្រមាណប៉ុណ្ណេះ ។

ក្រាបថ្វាយបង្គំម្តង

## នមស្ការព្រះរតនត្រ័យ

**យោ កប្បកោដីហិបិ អប្បមេយ្យំ កាលំករោន្តោ អតិទុក្ករានិ ខេទំ គតោ លោកហិតាយ នាថោ នមោ មហាការុណិកស្ស តស្ស ។**

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៏ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់

ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុទ្ធំ ពុទ្ធនិសេវិតំ យំ ភវាភវំ គច្ឆតិ ជីវលោកោ នមោ អវិជ្ជាទិក្កិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស ។**

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូច និងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្សការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់អវិជ្ជា គឺបណ្តាញកិលេសហើយ ។

**គុណេហិ យោ សីលសមាធិបញ្ញា វិមុត្តិញ្ញា~ណប្បភុតីហិ យុត្តោ ខេត្តញ្ញនានំ កុសលត្ថិកានំ**

**តមរិយសង្ឃំ សិរសា នមាមិ ។**

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល

ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន**

**ហតន្តរាយោ ៗ**

ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំង ៣ ខ្ពស់លើសលុបត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

ក្រាបថ្វាយបង្គំម្តង

## នមស្សការព្រះរតនត្រ័យ ប្រែជាបទភាព្យសុទ្ធ

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ

បានត្រាស់ជាសព្វញ្ញូ ត្រាស់ជាគ្រូលើភពឋាន ។
ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៏ដល់សព្វសត្វ ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។
សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល
ឱ្យវិលវល់អន្ទោល ក្នុងភពតូច និងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្សការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់អវិជ្ជា គឺបណ្ដាញកិលេសហើយ ។
ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។
ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី
បង្គំគុណទាំង ៣ ខ្ពស់លើសលុបត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា

ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្សការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ឋាននិព្វានហោង ។

ក្រាបថ្វាយបង្គំម្តង

## នមស្សការបូជនីយវត្ថុជាទីគោរព

**វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេសុ បតិដ្ឋិតំ**
**សារីរិកធាតុ មហាពោធិំ ពុទ្ធរូបំ សកលំ សទាឣ**

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី រីកធាតុនៃព្រះពុទ្ធ ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំឱនចិត្តបរិសុទ្ធ លើកកំបង់អញ្ជលី ។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលឋិតនៅគ្រប់ទី ឋាននានានោះទាំងអស់ ។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ ។

សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្រ ។
សូមទាន់ព្រះអរិ- យមេត្រេយ្យថ្លៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង ។

ក្រាបថ្វាយបង្គំម្តង

## នមស្សការ ស្តាមព្រះបាទព្រះពុទ្ធ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេ-
កនាថំ យោ លោកសេដ្ឋោ សកលំ កិលេសំ
ឆេត្វាន ពោធេសិ ជនំ អនន្តំ ៗ**

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា គ្មានមនុស្ស ឬទេវតា
ព្រហ្មាណាប្រដូចបាន ។ កំចាត់នូវកិលេស គ្មានឱ្យសេស
នៅសល់ខាន ញុំាងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។
ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង ព្រះអង្គឆ្លងផុតស្ទឹង
បានដល់ច្រាំងនៃភពហើយ ។ ព្រះអង្គជាទង់ជ័យ ធំត្រៃឃេ-
បង្ហាញត្រើយ តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។

មារព្រហ្មទាំងទេព្តា និងមនុស្សាតែងគោរព
ចូលជ្រកនូវក្រោមម្លប់ ពោធិញ្ញាណបានសុខា ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ យំ តត្ថ យោនក-បុរេ មុនិនោ ច បាទំ តំ បាទលញ្ឆនមហំ សិរសា នមាមិ ៕**

សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្នាមព្រះបាទា ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឱ្យជាស្ថានថ្លៃ ។ បាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ បាទមួយទ្រង់ជាន់ទុកនៅឰដ៏ភ្នំគិរីសច្ចព័ន្ធ ។ បាទមួយនៅភ្នំសុមនកូដ រហូតកំពូលដ៏សោភ័ណ ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ ទុកនៅនាយោនកបុរី ។ ខ្ញុំសូមបន្ទន់ កាយ វាចា និងចិត្តជ្រះថ្លាឱនសិរសី បង្គំព្រះបាទព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ៕**

ខ្ញុំសូមនមស្សការអំពីចម្ងាយ នូវឋានទាំងឡាយដែលមានព្រះបាទ ទាំង ៥ កន្លែងដែលព្រះមុនីនាថ ទ្រង់ឈានព្រះ -

បាទលើកំពូលភ្នំ ។ សុវណ្ណមាលិកមួយនោះជាធំ មួយនៅលើភ្នំសុវណ្ណបពិត មួយនៅលើភ្នំសុមនកូដប្រាកដ មួយនៅរាជរដ្ឋយោនកបុរី ។ មួយនៅក្បែរស្ទឹងនម្មទាជលធី ទាំង ៥ នាទីដែលទ្រង់ប្រទាន ទុកឱ្យសព្វសត្វប្រតិបត្តិជាស្ថាន ដោយព្រះទ្រង់ញាណប្រទានទុកឱ្យ ។

ក្រាបថ្វាយបង្គំម្តង

## នមស្សការធាតុចេតិយ

**មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ**

ខ្ញុំសូមបង្គំប្រណម្យអភិវាទ ព្រះសារីរិកធាតុមហាគោតម
ដែលទ្រង់និព្វានក្រោមសាលព្រឹក្សធំ ជិតទីប្រជុំក្រុងកុសិនារា ។
កិរិយាផ្សាយនូវព្រះធាតុនានា ផ្សេងៗពីគ្នាក្នុងទីទាំងឡាយ
ខ្ញុំសូមបង្គំប្រណម្យក្រាបថ្វាយ ព្រះធាតុទាំងឡាយគ្រប់ទីនោះៗ ។

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា**

**អសម្ភិន្នា វ តា សត្ត សេសា ភិន្នា វ ធាតុយោ**

ព្រះសារីរិកធាតុល្អទាំងនោះ មិនដែលបែកសោះប្រាំពីរអង្គ
គឺព្រះឧណ្ហីស[១] ធាតុបញ្ចង់ មានមួយព្រះអង្គនៅគង់ល្អស្អាត ។
និងព្រះទាឋា[២] ធាតុព្រះលោកនាថ ទាំងបួនអង្គស្អាតគ្មានឃ្លាតបែកចេញ

ព្រះអក្ខក[៣] ធាតុនៅស្អាតពេញលេញ  គ្មានបែកបាក់ចេញទាំងពីរព្រះអង្គ។

ព្រះសារីរិកធាតុភ្លឺស្អាតត្រចង់  ទាំងពីរព្រះអង្គគង់នៅទាំងអស់

ព្រះសារីរិកធាតុដ៏សេសពីនោះ  បែកចេញចំពោះបំណែកតូចធំ ។

**មហន្តា បញ្ចនាឡី ច មជ្ឈិមា ច ឆ នាឡិយោ**

**ខុទ្ទកា បញ្ចនាឡី ច សម្ភិន្នា តិវិធា មតា**

ព្រះបរមមុនីនាថសាស្តា  ដែលបែកចេញជាបំណែកតូចធំ

លោកបានពោលទុកថាមានទំហំ  មានតូចមានធំមានខ្នាតកណ្តាល។

ព្រះធាតុខ្នាតធំចំនួនប្រាំនាឡិ  ព្រះធាតុកណ្តាលប្រាំមួយនាឡិគត់

ព្រះធាតុខ្នាតតូចប្រាំនាឡិប្រាកដ  ដោយលោកកំណត់បីយ៉ាងដូច្នេះ។

**មហន្តា ភិន្នមុគ្គា ច  មជ្ឈិមា ភិន្នតណ្ឌុលា**

**ខុទ្ទកា សាសបមត្តា  ឯវំ ធាតុប្បមាណិកា**

---

[១] ឆ្អឹងថ្ងាស [២] ព្រះចង្កូមកែវ [៣] ឆ្អឹងដងកាំបិត

ឯព្រះបរមធាតុមានខ្នាតបីយ៉ាង  លោកបានពោលអាងទុកជាលំដាប់

ព្រះធាតុខ្នាតធំទំហំប៉ុនគ្រាប់  សណ្តែកបាយកាប់កាត់មួយកំណាត់។

ព្រះធាតុកណ្តាលដូចកាលគេកាត់  ប៉ុនមួយកំណាត់នៃគ្រាប់អង្ករ

ព្រះធាតុខ្នាតតូចស្រេវស្រួចបវរ  លោកបានព្យាករថាប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា**

**ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ**

ព្រះសារីរិកធាតុនៃព្រះភគវា  មានពណ៌ផ្សេងគ្នាទាំងបីវិសាល

ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ពន្លឺឱភាសវិសេសពេកក្កាត់ ។
ព្រះធាតុកណ្តាលវិសាលដូចរត្ន័ កែវផលិតប្រាកដស្មើរចាប់ច្រឡំ
ព្រះធាតុខ្នាតតូចដូចផ្កាថ្កុលសម ពណ៌សស្រគាំពុំគួរងឿងឆ្ងល់ ។
ខ្ញុំសូមបង្គំប្រណមទៅដល់ ព្រះធាតុមង្គលទាំងឡាយនោះផង
តែជះខ្ញុំថ្វាយឱនកាយរាប់រង វាចាចិត្តផងសូមឆ្លងទៅដល់ ។
នៃព្រះបរមធាតុមុនីនាថទសពល សូមជាមង្គលសុខសព្វវេលា
សូមឱ្យខ្ញុំបានដល់ឋានសួគ៌ា រហូតដល់នាព្រះនិព្វានហោង ។

**ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ**
**ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ**
**ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ**

ព្រះសថូបមួយមានប្រតិស្ឋាននា រាជគ្រឹះភារាមហាបុរី
មួយប្រតិស្ឋានក្រុងវេសាលី មួយនៅបុរីកបិលភ័ស្តុសក្កៈ ។
ព្រះសថូបមួយនៅអលកប្បកៈ ព្រះសថូបសោភៈមួយនៅរាមគ្រាម
មួយនៅវេដ្ឋទីបកៈដោយនាម ពួកក្សត្រ និងព្រាហ្មណ៍ទុកជាសរណៈ ។
មួយនៅនាក្រុងបាវេយ្យក នៅក្នុងមល្លរដ្ឋជនបទ
ព្រះសថូបមួយមានទីឋានប្រាកដ នៅក្នុងរាជរដ្ឋកុសិនារា ។

**ឯតេ សារីរិកា ថូបា ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះសថូបទាំងឡាយទាំងប្រាំបីនោះ ជាទីបញ្ចុះព្រះសារីរិកធាតុ
ក្នុងជម្ពូទ្វីបខ្ញុំសូមអភិវាទ នូវព្រះបរមធាតុទាំងឡាយទាំងនោះ ។

ក្នុងព្រះសថូបប្រាំបីចំពោះ ដែលពួកសប្បុរសលោកតែងបូជា
ខ្ញុំសូមបង្គំប្រណម្យវន្ទា ទាំងមនុស្សទេវាបូជាសព្វកាល ។

**ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ**

ព្រះទាឋាធាតុមុនីនាថមួយអង្គ ប្រសើរបញ្ជូង់នៅត្រៃត្រឹង្សា
ព្រះទាឋាធាតុមួយអង្គថ្លៃថ្លា ប្រតិស្ឋានពិភពនាគនាយ ។
ព្រះទាឋាធាតុមួយអង្គព្រោងព្រាយ ឋិតនៅនគរនាយគន្ធាររដ្ឋ
ព្រះទាឋាធាតុមួយអង្គប្រាកដ ឋិតនៅរាជរដ្ឋក្រុងសីហឡទ្វីប ។

**ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុទាំងឡាយឯណា ដែលព្រះសាស្តាទ្រង់ប្រតិស្ឋាន
ទាំងបួនកន្លែងនោះឯងមែនមាន ទ្រង់ទុកប្រទានឱ្យមនុស្សទេព្តា ។
ជាទីគោរពប្រតិបត្តិបូជា ខ្ញុំសូមវន្ទាក្រាបថ្វាយបង្គំ
អំពីចម្ងាយឱនកាយប្រណម្យ ចំពោះព្រះបរមធាតុនោះហោង ។

**ឧន្ឋំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា**
**អធោ ទក្ខិណទាឋា សីហឡទីបេ បតិដ្ឋិតា**
**វាមទាឋា ច ឧន្ឋម្ហិ គន្ធាររដ្ឋេ បតិដ្ឋិតា**
**វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុខាងលើខាងស្តាំ ព្រះឥន្ទទ្រង់នាំទៅត្រៃត្រឹង្សា
ព្រះទាឋាស្តាំខាងក្រោមសោភា ប្រតិស្ឋាននាសីហឡបូរី ។

ព្រះទាឋាឆ្វេងខាងលើពិសី          នៅនាបុរីដែនគន្ធារ
ទាឋាឆ្វេងក្រោមនៃព្រះឈ្នះមារ      នៅក្នុងភារាពិភពនាគនោះ ។
ខ្ញុំព្រះអង្គសូមវន្ទាចំពោះ          នូវព្រះធាតុនោះគ្រប់ទិសទាំងឡាយ
ដែលមនុស្សទេវតាតែងបូជាថ្វាយ      ព្រះធាតុទាំងឡាយក្នុងទីនោះៗ ។

**ព្រហ្មលោកេ ទុស្សធាតុ          វាមអក្ខកធាតុយោ**
**សព្វេ ព្រហ្មាភិបូជេន្តិ          ថូបំ ទ្វាទស យោជនំ**

ព្រះទុស្សធាតុ[៤] មុនីនាថឧត្តម          ដែលព្រះមហាព្រហ្មឈ្មោះឃដិកា
ទទួលយកពីព្រះសាស្តាចារ្យ      ទៅទុកនមស្សការក្នុងឋានព្រហ្មលោក ។
និងអក្ខកធាតុ[៥] ឆ្វេងព្រះមានជោគ      នៅក្នុងព្រហ្មលោកទាំងពីរព្រះអង្គ
មានព្រះសថូបកំពស់ខ្ពស់ខ្ពង់          ដប់ពីរយោជន៍លង់បញ្ចុះព្រះធាតុ ។
ខ្ញុំសូមបង្គំព្រះលោកនាថ          ចំពោះព្រះធាតុនៅព្រហ្មលោកនាយ ។

**តាវតឹសម្ហិ ទេវានំ          ចូឡាមណិម្ហិ កេសកំ**
**សព្វេ ទេវាភិបូជេន្តិ          បសន្នា ពុទ្ធសាសនេ**
**បូជិតា នរទេវេហិ          អហំ វន្ទាមិ ធាតុយោ**

ទេវតាទាំងឡាយជាអ្នកជ្រះថ្លា          ក្នុងពុទ្ធសាសនាបូជាចំពោះ
នូវព្រះកេសធាតុនៃព្រះទ្រង់យស      នៅក្នុងទីខ្ពស់ឋានត្រៃត្រឹង្សា ។
ព្រះចូឡាមណីចេតិយនោះណា          ខ្ញុំសូមវន្ទាក្រាបថ្វាយបង្គំ
ចំពោះព្រះធាតុនៃព្រះបរម          ទេវតាកុះកុំមូលមកបូជា ។

**ចត្តាឡីស សមានន្តា          កេសា លោមា នខា បិច**
**ទេវាហរន្តិឯកេកំ          ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ          អហំ វន្ទាមិ ធាតុយោ**

ខ្ញុំសូមបង្គំប្រណម្យអភិវាទ　　នូវព្រះទន្តធាតុទាំងសែសិបផង
និងព្រះកេសធាតុមុនីនាថជាច្បង　　ព្រះលោមធាតុ និងនខធាតុ ។

[៤] ព្រះទុស្សធាតុ គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញហើយទ្រង់សំពត់កាសាវៈ
[៥] ត្រូវមើល អក្ខធាតុ វិញ ។

ដែលពួកទេវតានាំគ្នាខ្ទីឃ្មាត　　នាំយកព្រះធាតុមួយអង្គៗ
ទៅកាន់ចក្រវាឡដទៃពុំលង់　　មួយអង្គៗ ក្នុងចក្រវាឡមួយ ។
ខ្ញុំព្រះអង្គសូមវន្ទាលើកស្ទួយ　　បង្គំមួយៗ គ្រប់ទាំងចក្រវាឡ
ដែលពួកទេវតាមនុស្សាត្រកាល　　បូជាគ្រប់កាលដោយក្តីជ្រះថ្លា ។

**អដ្ឋារស ទេ្វ វស្សសតេ　　ធម្មាសោកោ តទា អហុ**
**ចតុរាសីតិសហស្សា　　ចេតិយា ច ការាបិតា**
**បូជិតា នរទេវេហិ　　អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធសករាជបាន　　ដោយលោកពោលអានទុកជាកំណត់
ពីររយដប់ប្រាំបីឆ្នាំកំណត់　　នោះមានមហាក្សត្រព្រះនាមហៅថា ។
ព្រះធម្មាសោកព្រះទ័យជ្រះថ្លា　　ក្នុងពុទ្ធសាសនាបានសាងចេតិយ
ប្រាំបីម៉ឺនបួនពាន់ធួនជាថ្មី　　ថ្វាយព្រះជិនស្រីក្នុងពុទ្ធសាសនា ។
ជាទីត្រេកអរទាំងមនុស្សទេវតា　　តែងទៅបូជាចេតិយទ្រង់យស
ព្រោះមានព្រះធាតុប្រសើរខ្ពង់ខ្ពស់　　ជាទីអនុគ្រោះដល់មនុស្សទេវតា ។
ខ្ញុំសូមបង្គំព្រះបរមសាស្តា　　ឆ្ពោះព្រះមហាព្រះធាតុទាំងឡាយ
នៅក្នុងចេតិយដែលស្តេចសាងថ្វាយ　　ខ្ញុំសូមឱនកាយក្រាបថ្វាយវន្ទា ។
តេជៈបារមីនៃព្រះភគវា　　ទុក្ខរោគភយាកុំបីកើតមាន
សូមសុខសព្វកាលត្រកាលក្សេមក្សាន្ត　　សម្បត្តិធនធានចំរើនឥតអាក់ ។
ព្រមទាំងកូនចៅញាតិផៅរួមរ័ក្ស　　កុំឱ្យបែកបាក់និរាសព្រាត់ព្រាយ

ក្នុងវង្សត្រកូលមិត្រមូលសប្បាយ សម្បត្តិទាំងឡាយកុំបីខ្វះខាត ។
តាំងពីពេលនេះរៀង១ រាល់ជាតិ កុំឱ្យឃ្លៀងឃ្លាតពីក្តីប្រាថ្នា
សូមឱ្យខ្ញុំបានដល់ឋានទេវតា និងព្រះមហានិព្វាននាយហោង ។

ក្រាបថ្វាយបង្គំម្តង

## ចតុរារក្ខកម្មដ្ឋាន

កម្មដ្ឋានគួរចម្រើនរឿយ ៗ ៤ យ៉ាង

**ពុទ្ធានុស្សតិ មេត្តា ច អសុភំ មរណស្សតិ ឥច្ចេតា ចតុរារក្ខា ភាវេតព្វា បុនប្បុនំ ។ វន្ទាមិ ពុទ្ធំ គុណសាគរន្តំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិគុច្ឆោ សកលោ ទុគន្ធោ គច្ឆន្តិ សព្វេ មរណំ តថាហំ ។**

អារក្ខកម្មដ្ឋាន ៤ យ៉ាងនេះ គឺ ពុទ្ធានុស្សតិ ១ មេត្តា ១ អសុភៈ ១ មរណស្សតិ ១ គួរសាធុជនចម្រើនរឿយៗ ថា ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់មានព្រះគុណ ដ៏ធំធេងដូចសាគរ , សូមសត្វទាំងឡាយមានតែសេចក្តីសុខ មិនមានពៀរនឹងគ្នាសព្វកាល , រាងកាយទាំងមូល(នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់ , សព្វសត្វ

ទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ , ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

**វន្ទាមិ ធម្មំ សុគតេន ទេសិតំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិគុច្ឆោ សកលោ ទុគ្គន្ធោ គច្ឆន្តិ សព្វេ មរណំ អហញ្ច ។**

ខ្ញុំសូមថ្វាយបង្គំចំពោះព្រះធម៌ ដែលព្រះសុគតទ្រង់ត្រាស់សម្ដែងហើយ , សូមសត្វទាំងឡាយមានតែសេចក្ដីសុខ មិនមានពៀរនឹងគ្នាសព្វកាល , រាងកាយទាំងមូល( នេះ ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់ , សព្វសត្វទាំងអស់ រមែងដល់នូវសេចក្ដីស្លាប់ , ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

**វន្ទាមិ សង្ឃំ មុនិរាជបុត្តំ សត្តា សទា ហោន្តុ សុខី អវេរា កាយោ ជិគុច្ឆោ សកលោ ទុគ្គន្ធោ គច្ឆន្តិ សព្វេ មរណំ អហញ្ច ។**

ខ្ញុំសូមថ្វាយបង្គំចំពោះព្រះសង្ឃ ដែលជាបុត្រនៃព្រះសម្ពុទ្ធ ជាស្ដេចនៃអ្នកប្រាជ្ញ , សូមសត្វទាំងឡាយមានតែសេចក្ដីសុខ , មិនមានពៀរនឹងគ្នាសព្វកាល , រាងកាយទាំងមូល (នេះ) មានក្លិនអាក្រក់ គួរខ្ពើមរអើមក្រៃពេកណាស់ , សព្វ

សត្វទាំងអស់រមែងដល់នូវសេចក្តីស្លាប់ , ទាំងខ្លួនអាត្មាអញ ក៏ដូច្នោះដែរ ។

ក្រាបថ្វាយបង្គំម្តង

## នមស្សការានុភាព

**នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។**

ដោយអានុភាពនៃកិរិយានមស្សការថ្វាយបង្គំ សូមឱ្យ កម្ចាត់បង់នូវ ឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្ត-រាយទាំងឡាយជាអនេក ក៏ចូលឱ្យវិនាសទៅ កុំបីមានសេស សល់ឡើយ ។

ក្រាបថ្វាយបង្គំម្តង

## សុភមង្គលគាថា

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ ។**

ប្រែថា: **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្តី ចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា**

ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វពុទ្ធានុ-ភាវេន** ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់-ពេល កុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ ៗ**

ប្រែថាៈ **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វធម្មានុភា-វេន** ដោយអានុភាពនៃព្រះធម៌ទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

**ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ ៗ**

ប្រែថាៈ **ហោតុ សព្វំ សុមង្គលំ** សុមង្គលគឺសេចក្ដីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមានដល់ខ្ញុំ **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ **សព្វសង្ឃា-**

**ន្ទុភាទេន** ដោយអានុភាពនៃព្រះសង្ឃទាំងពួង **សោត្ថិ ហោត្វ និរន្តរំ** សូមសិរីសួស្ដីចូរមានដល់ខ្ញុំ ឱ្យបាន គ្រប់ពេល កុំបីមានចន្លោះឡើយ ។

ក្រាបថ្វាយបង្គំម្ដង

# ផ្សាយមេត្តាចំពោះសត្វ ក្នុងទិសទាំង ១០

សព្វេ បុរត្ថិមាយ ទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ បុរត្ថិមាយ អនុទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ ទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ អនុទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ ទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ អនុទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ ទិសាយ
សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ អនុទិសាយ
សត្តា អវេរា សុខី ហោន្តុ

**សព្វេ ហេដ្ឋិមាយ ទិសាយ**
**សត្តា អវេរា សុខី ហោន្តុ**
**សព្វេ ឧបរិមាយ ទិសាយ**
**សត្តា អវេរា សុខី ហោន្តុ**

**សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។ ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។**

ប្រែថា: **សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង(ដែលស្ថិតនៅ) ក្នុងទិសបូព៌ា សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។ **សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង(ដែលស្ថិតនៅ) ក្នុងទិសអាគ្នេយ៍ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។ **សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី**

**ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសទក្សិណ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង(ដែលស្ថិតនៅ) ក្នុងទិសនិរតី សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសបស្ចិម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសពាយ័ព្យ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសឧត្តរ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង(ដែលស្ថិតនៅ) ក្នុងទិសឦសាន សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្តីសុខ ។

**សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងក្រោម សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** សត្វទាំងឡាយទាំងពួង (ដែលស្ថិតនៅ) ក្នុងទិសខាងលើ សូមកុំឱ្យមានពៀរនឹងគ្នា មានតែសេចក្ដីសុខ ។

**សព្វេ សត្តា អវេរា ហោន្តុ** សូមសត្វទាំងឡាយទាំងពួង កុំមានពៀរនឹងគ្នា **សុខិតា ហោន្តុ** សូមឱ្យបាននូវសេចក្ដីសុខ **និទ្ទុក្ខា ហោន្តុ** សូមកុំឱ្យមានទុក្ខ **អព្យាបជ្ឈា ហោន្តុ** សូមកុំឱ្យបៀតបៀនដល់គ្នា នឹងគ្នា **អនីឃា ហោន្តុ** សូមកុំឱ្យមានសេចក្ដីព្រួយលំបាក **ទីឃាយុកា ហោន្តុ** សូមឱ្យមានអាយុវែង **អរោគា ហោន្តុ** សូមកុំឱ្យមានរោគ **សម្បត្តីហិ សមិជ្ឈន្តុ** សូមឱ្យសម្រេចដោយសម្បត្តិគ្រប់យ៉ាង **សុខី អត្តានំ បរិហរន្តុ** សូមឱ្យរក្សានូវខ្លួនជាសុខស្រួលចុះ ។

**ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ៚**

មួយទៀត សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ ។

ក្រាបថ្វាយបង្គំម្តង

# គាថាសូមសេចក្ដីសុខ

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ៕**
**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ៕**
**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ៕**
**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ ៕**
**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា ៕**

ប្រែថា៖ **អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ** ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្ដី ស្ថិតនៅលើផែនដីក្ដី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្ដី ចូរអនុមោទនា នូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវ

ព្រះពុទ្ធសាសនា (ឱ្យបានសុខចម្រើន) អស់កាលជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវមហារាជទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាល ជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវញាតិទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាល ជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា**
**បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ បាណិនោ**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវសត្វទាំងឡាយ

(ឱ្យបានសុខចម្រើន) អស់កាល ជាយូរអង្វែងទៅ ។

**អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោ សទា**

ទេវតាទាំងឡាយ ស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី នាគទាំងឡាយ មានឥទ្ធានុភាពច្រើនក្តី ចូរអនុមោទនានូវបុណ្យនៃយើងទាំងឡាយ ចូររក្សានូវយើងទាំងឡាយ (ឱ្យបានសុខចម្រើន) អស់កាល ជាយូរអង្វែងទៅ ។

ក្រាបថ្វាយបង្គំម្តង

# បត្តិទានគាថា

ពុទ្ធសាសនិកជនបានបំពេញកុសលកម្មពេញលេញហើយ សូមចម្រើនផលានិសង្ស ជាទ្វេគុណ ដោយការឧទ្ទិសកុសលកម្មនោះ ដល់សព្វសត្វទាំងឡាយ តាមរយៈបុញ្ញកិរិយាវត្ថុមួយយ៉ាងឈ្មោះ "**បត្តិទាន**" កិរិយាឱ្យនូវចំណែកបុណ្យ ដល់អ្នកដទៃដោយ "**បត្តិទានគាថា**" ដូច្នេះថា ៖

**យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ តា ធម្មទានេន ភវន្តុ បូជិតា សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ ថេរា ច មជ្ឈា នវកា ច ភិក្ខវោ សារាមិកា ទាន-បតី ឧបាសកា គាមា ច ទេសា និគមា ច ឥស្សរា សប្បាណភូតា សុខិតា ភវន្តុ តេ ជលាពុជា យេបិច អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ ឋាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា សង្ឃោ ហោតុ ស-**

**មគ្គោទ អត្ថាយ ច ហិតាយ ច អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ វុឌ្ឍឹ សម្បាបុ-ណេយ្យាម ធម្មារិយប្បវេទិតេ ។**

ប្រែថា: **យា ទេវតា សន្តិ វិហារវាសិនី ថូបេ ឃរេ ពោធិឃរេ តហឹ តហឹ** ទេវតាទាំងឡាយឯ-ណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះសថូប ឰដ៏ខឿនព្រះពោធិព្រឹក្ស ក្នុងទីនោះ ៗ **តា ធម្ម-ទានេន ភវន្តុ បូជិតា** ទេវតាទាំងឡាយនោះ ជាបុគ្គលគឺយើងទាំងឡាយបូជាហើយ ដោយធម្មទាន **សោត្ថឹ ករោន្តេធ វិហារមណ្ឌលេ** ចូរធ្វើនូវសួស្តី ក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ **ថេរា ច មជ្ឈា នវកា ច ភិក្ខវោ** ភិក្ខុទាំងឡាយ ជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសថ្មីក្តី **សារាមិកា ទានបតី ឧបាសកា** ឧបាសកនិងឧបាសិកាទាំងឡាយ ដែលជាម្ចាស់ នៃទាន ព្រមទាំងអារាមិកជន គឺក្មេងវត្តក្តី **គាមា ច ទេសា និគមា ច ឥស្សរា** ជនទាំង-ឡាយ ដែលជា អ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈ ជាធំក្តី **សប្បាណភូតា សុខិតា**

**ភវន្តុ តេ** សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ **ជលាពុជា យេបិច អណ្ឌសម្ភវា សំសេទជាតា អថ វោបបាតិកា** មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបាតិកៈកំណើតក្តី **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ** សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ ដ៏ប្រសើរជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ ជាគ្រឿងអស់ទៅនៃទុក្ខចុះ **ឋាតុ ចិរំ សតំ ធម្មោ** សូមឱ្យធម៌របស់សប្បុរសទាំងឡាយ ស្ថិតនៅអស់កាល យូរអង្វែងទៅ **ធម្មធរា ច បុគ្គលា** បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ចូរស្ថិតនៅអស់កាល យូរអង្វែងទៅ **សង្ឃោ ហោតុ សមគ្គោ ច** សូមព្រះសង្ឃព្រមព្រៀងគ្នា **អត្ថាយ ច ហិតាយ ច** ដើម្បីសេចក្តីចំរើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៏ផង **អម្ហេ រក្ខតុ សទ្ធម្មោ សព្វេបិ ធម្មចារិនោ** សូមព្រះសទ្ធម្មរក្សានូវ យើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំង-

អស់ផង **ទុឡ្លឹ សម្បាបុណ្ណោយហ្សាម ធម្មារិ-យប្បវេទនិតេ** សូមឱ្យយើងទាំងឡាយ បានដល់នូវសេចក្ដីចំរើន ក្នុងធម៌ ដែលព្រះអរិយទាំងឡាយ លោកសំដែងហើយ ។

ក្រាបថ្វាយបង្គំម្ដង

## សេចក្ដីប្រែ ជាពាក្យភាព្យ

យើងខ្ញុំទាំងអស់គ្នា សូមបូជាផលធម្មទាន
ដល់ទេវតាដែលមាន នៅទីស្ថាន( ភូមិ,វត្ត) នេះក្ដី ។
នាខឿនព្រះសថូប ឬនៅនាខឿនចេតិយ
សូមមានចិត្តមេត្រី ធ្វើទឹកដី ទី( ភូមិ.វត្ត) នេះ។
សូមឱ្យសុខសួស្ដី ទុក្ខអ្វីៗ កុំមានមោះ
ម្យ៉ាងទៀតសង្ឃទាំងអស់ ដែលមានផ្នួសជាថេរៈ ។
ឬក៏ជាមជ្ឈិម ឬក៏ត្រឹមជានវៈ
ឬក៏ឧបាសក ដែលអ្នកជាម្ចាស់នៃទាន ។
ព្រមទាំងអ្នកនិគម ឬអ្នកធំអម្បាលម៉ាន
គ្រប់ស្រុកប្រទេសឋាន សូមឱ្យបានសុខឯកអាក់ ។
ម្យ៉ាងទៀត សត្វឯណា ដែលកើតជា ជលាពុជៈ

ឬក៏ អណ្ឌជៈ សំសេទជៈ កំណើតក្តី ។
ឬក៏ ឧបាសក គ្រប់ជាន់ថ្នាក់ក្នុងលោកិយ
ដោយអំណាចសេចក្តី ធម៌បាលី ដ៏បវរ ។
កុំឱ្យមានទុក្ខសោក ក្តីវិយោគសង្សារចរ
ម្យ៉ាងទៀត សូមឱ្យធម៌ ព្រះបវរស្ថិតនៅវែង ។
នឹងអ្នកចេះធម្មំ សូមឱ្យតាំងនៅអង្វែង
នឹងសូមឱ្យតម្លែង សង្ឃម៉ឺនសែនសាមគ្គីធម៌ ។
ដើម្បីប្រយោជន៍ច្រើន នឹងចម្រើនកុសលធម៌
សូមឱ្យធម៌បវរ ជួយគាំទ្រយើងរាល់គ្នា ។
ហើយសូមអស់យើងខ្ញុំ ចេះចាំគ្រប់កងធម្មា
ដែលអង្គព្រះភគវា ទ្រង់ទេសនាតាំងទុកមក ។

ក្រាបថ្វាយបង្គំម្តង

# បត្តិទានគាថា សំរាយពាក្យកាព្យ

ទានដែលខ្ញុំធ្វើហើយ ព្រះគុណន្តើយខ្ញុំសទ្ធា
ឧទ្ទិសផលនេះណា ជូនមាតាបិតាខ្ញុំ ។
ជីដូន និងជីតា គ្រូអាចារ្យទាំងតូចធំ
ញាតិមិត្តគ្រប់និគម មកជួបជុំទទួលផល ។
ទានដែលកូនចៅធ្វើ នូវអំពើជាកុសល

សូមទានឱ្យបានដល់ ទោះមណ្ឌលឆ្ងាយយ៉ាងណា ។
កូនចៅទាំងអស់ហ្នឹង សូមទីពឹងលើទេវតា
សូមមានចិត្តមេត្តា នាំផលាទាំងអស់នេះ ។
បញ្ជូនឱ្យខ្ញុំផង ដូចបំណងកុំបីធ្វេស
កូនចៅនៅឯនេះ មិនប្រហែសបញ្ជូនមក ។
សូមមានចិត្តរីករាយ ដោយសប្បាយទទួលយក
កូនចៅបានលៃលក បញ្ជូនមកលោកគ្រប់គ្នា ។
ដើម្បីសោយកំសាន្ត សូមឱ្យបានសុខសួគ៌ា
កូនចៅទាំងអស់គ្នា សូមបូជាគ្រានេះហោង ។

ក្រាបថ្វាយបង្គំម្តង

## បត្តិទានគាថា សំរាយពាក្យកាព្យ

រីផលទានសីល ខ្ញុំសូមផ្តាច់ផ្តិល
មន្ទិលទោសា ធ្វើបុណ្យថ្មី១ ដោយក្តីជ្រះថ្លា ។
ដោយកាយវាចា ចិត្តឥតហ្មងសៅ
រីផលទាននោះ ខ្ញុំលើកឧទ្ទិសចំពោះជូនទៅ ។
មាតាបិតាគ្រូអាចារ្យ ញាតិផៅទោះស្លាប់ឬនៅ
បានដូចបំណង រីផលទាននេះ
ទុកជាជំនិះ ជិះកាត់ចម្លង ។
ឱ្យបានផុតទុក្ខ ទាំង ១២ កង

សោយសុខកន្លង ដល់និព្វាននាយ ។

ក្រាបថ្វាយបង្គំម្តង

# បត្តិទាន ក្នុងធម្មទាន

ធម្មទាន[១] យើងទាំងឡាយ សូមចែកផ្សាយដល់ញាតិមិត្ត
ទោះកើតទីឆ្ងាយជិត មានវិបត្តិយ៉ាងណាក្ដី ។
សូមឱ្យរួចរដោះ ចាកទុក្ខទោសគ្រោះចង្រៃ
បានសុខរៀងរាល់ថ្ងៃ សមដូចក្ដីឧទ្ទិសហោង ។

ក្រាបថ្វាយបង្គំម្ដង

## តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតអំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីល និងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា ។

(១) បើក្រោយពេលធម្មទេសនា ត្រូវសូធ្យថា "ធម្មទាន" តែបើក្រោយពេលភត្តផ្សេងៗមានសង្ឃភត្តជាដើម ត្រូវសូធ្យថា "ផលទាន" វិញ ។

សូមជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា

ប្រាំពីរសន្តាន ។
ជីដូនជីតា　　　រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
សូមជូនមគ្គផល　　　កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ក្រាបថ្វាយបង្គំម្តង

## បត្តិទានគាថា

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន វាចា មនសា តិទសេ សុគតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។**

ប្រែថា: **យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ **កាយេន**

**វាចា មនសា** ដោយទ្វារទាំង ៣ គឺ កាយ វាចា ចិត្ត **តិទសេ សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងស្ថានត្រៃត្រឹង្ស សួគ៌បាន **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយបានឧទ្ទិសផ្សាយឱ្យទៅនេះចុះ **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែល ខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយ នូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ **យេ ច តត្ថ ន ជានន្តិ** ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ត្វា និវេទយុំ** សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះ

ឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយគេឧទ្ទិសផ្សាយផលបុណ្យនោះ មកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ ។

**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យ នូវអាហារហើយរស់នៅ **មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ** សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

ក្រាបថ្វាយបង្គំម្តង

# សេចក្តីប្រែ ជាពាក្យកាព្យ

កម្មកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយទ្វារកាយ វាចា ចិត្ត ។
កុសលទាំងអស់នោះ អាចជួយដោះ ជួយបង្ខិត
នាំសត្វឱ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា មនុស្ស ទេវតា ឬ ឥន្ទ ព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេវតាទៅប្តឹង ឱ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯនុ៎ះ ស្រី ឬ ប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្ថុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ ដោយសប្បាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលនៅរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ

អាហារយ៉ាងចំណាន សូមឱ្យបានកុំខានឡើយ ។

ក្រាបថ្វាយបង្គំម្តង

## បត្តិទានគាថា

**ឥមិនា បុញ្ញកម្មេន ឧបជ្ឈាយា គុណុត្តរា អាច~
រិយូបការា ច មាតាបិតា បិយា មមំ សុរិយោ
ចន្ទិមា រាជា គុណវន្តា នរាបិច ព្រហ្មា មារា
ច ឥន្ទ្រា ច លោកបាលា ច ទេវតា យមោ
មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិច សព្វេ
សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ វោមតំ ។**

ប្រែថាៈ ដោយបុញ្ញកម្មនេះ ឧបជ្ឈាយ៍ទាំងឡាយ មានគុណ ដ៏ខ្ពង់ខ្ពស់ , អាចារ្យទាំងឡាយ មានឧបការៈ , មាតាបិតា ជាទីស្រឡាញ់នៃខ្ញុំ , ព្រះអាទិត្យ ព្រះចន្ទ ព្រះរាជា នរជន អ្នកមានគុណទាំងឡាយ , ព្រះព្រហ្មមារាធិរាជ ព្រះឥន្ទ ទាំងឡាយ , លោកបាលមហារាជ និងទេវតាទាំងឡាយ , ព្រះយមរាជ និងមនុស្សទាំងឡាយ ជាមិត្តនឹងគ្នាក្តី មានចិត្ត ជាកណ្តាលក្តី មានពៀរនឹងគ្នាក្តី

(រួបរួមសេចក្តីថា) សូមឱ្យ សព្វសត្វទាំងឡាយ មានសេចក្តីសុខរាល់គ្នា បុណ្យទាំងឡាយ ដែលខ្ញុំបានកសាងសន្សំហើយ ចូរឱ្យនូវសេចក្តីសុខទាំង ៣ ប្រការ , សូមឱ្យអ្នកទាំងឡាយបានដល់នូវ អមតមហានិព្វាន ឱ្យបានឆាប់រស់រាន់ទាន់សេចក្តីប្រាថ្នាហោង ។

ក្រាបថ្វាយបង្គំម្តង

## បត្តិទានគាថា

**ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច ខិប្បាហំ សុលភេចេវ តណ្ហុបាទានឆេទនំ យេ សន្តានេ ហីនាធម្មា យាវ និព្វានតោ មមំ នស្សន្តុ សព្វទាយេវ យត្ថ ជាតោ ភវាភវេ ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វីរិយោម្ហិ វា មារា លភន្តុ នោកាសំ កាតុញ្ច វីរិយេសុ មេ ពុទ្ធោ ធីបវរោ នាថោ ធម្មោ នាថោ វរុត្តមោ នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ តេសោត្តមានុភាវេន មារោកាសំ លភន្តុ មា ៕**

ប្រែថា៖ ដោយបុញ្ញកម្មនេះផង ដោយការឧទ្ទិសនេះផង, សូមឱ្យខ្ញុំបានដោយងាយ យ៉ាងរស់រាន់ទាន់ចិត្ត នូវមគ្គផល ជាគ្រឿងផ្តាច់បង់នូវតណ្ហា និងឧបាទាន , ធម៌ទាំងឡាយណា ជាធម៌ថោកទាប គឺអកុសលធម៌ នៅក្នុងសន្តានចិត្តខ្ញុំ សូមឱ្យ (ហីនធម៌ ជាអកុសល ទាំងនោះ) វិនាសបាត់រឿងរាល់កាលទៅ រហូតដល់ខ្ញុំ បានសម្រេចព្រះនិព្វាន (ក្នុង បច្ឆិមជាតិ) , (បើ) ខ្ញុំអន្ទោលទៅចាប់កំណើត ក្នុងភពតូច និងភពធំណា ៗ ,សូមឱ្យខ្ញុំជាបុគ្គលមានចិត្ត ត្រង់ មានសតិ និងបញ្ញា មានចិត្តស្អាតផូរផង់ ទាំងសូមឱ្យមានព្យាយាមផង (ក្នុងភពនោះ ៗ) , មារទាំងឡាយចូរកុំបាននូវឱកាស ដើម្បីឱ្យខូចព្យាយាមខ្ញុំឡើយ , ព្រះពុទ្ធដូចជាប្រទីប ឬ កោះដ៏ប្រសើរ ជាទីពឹងនៃខ្ញុំ ព្រះធម៌ ជាទីពឹងដ៏ខ្ពង់ខ្ពស់នៃខ្ញុំ ទាំងព្រះបច្ចេកពុទ្ធក៏ជាទីពឹងនៃខ្ញុំដែរ, ព្រះសង្ឃក៏ជាទីពឹង ដ៏ខ្ពង់ខ្ពស់នៃខ្ញុំដែរ , ដោយឧត្តមានុភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃនោះ មារចូរកុំបាននូវឱកាស ចូលមកជ្រៀតជ្រែកឡើយ ។

ក្រាបថ្វាយបង្គំម្តង

**ខមាបនគាថា**

**យេ កេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា យេ បាណោកេ បមាទេន កាយវាចាម-នេហិ វា បុញ្ញំ មេ អនុមោទន្តុ គណ្ហន្តុ ផលមុត្តមំ វេរិនោ ចេ បមុញ្ចន្តុ សព្វទោសំ ខមន្តុ មេ ៕**

ប្រែថា: សត្វទាំងឡាយណាមួយ ទោះតូចក្តី ធំក្តី ដែលខ្ញុំបានបៀតបៀនហើយ , មួយទៀត សត្វទាំងឡាយ ពួកខ្លះ (ដែលខ្ញុំធ្វើទុក្ខបុកម្នេញហើយ) ព្រោះសេចក្តីប្រមាទភ្លាំង-ភ្លាត់ ដោយកាយ វាចា ចិត្ត , (សត្វទាំងឡាយនោះ) ចូរអនុមោទនានូវបុណ្យរបស់ខ្ញុំចុះ , ចូរទទួលយក នូវផលបុណ្យដ៏ឧត្តមចុះ , បើសត្វទាំងឡាយណា មានពៀរ នឹងគ្នា ចូររួចរដោះ(ចាកពៀរនោះ)ចុះ, សូមអត់ទោស ទាំងពួងផង ។

ក្រាបថ្វាយបង្គំម្តង

## បុព្វភាគប្បដិបត្តិ

**(ដោយ : ម,ឧ. កៅ-ឈឹន)**

បុរសស្ត្រីដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានប្រាថ្នាប្តេជ្ញាខ្លួន

ជាឧបាសក ឬឧបាសិកា ជាបុព្វភាគបដិបត្តិ គឺសេចក្តីប្រតិ-បត្តិជាចំណែកខាងដើម ឱ្យបានពេញស័ប់ជាអ្នកកាន់ព្រះពុទ្ធសាសនា ឬជាអ្នកតម្កល់ក្នុងព្រះពុទ្ធសាសនានោះ ដំបូងបង្អស់ ត្រូវបញ្ចេញវចីភេទ សូមខមាទោសនឹងព្រះរតន-ត្រ័យ ក្នុងទីចំពោះព្រះភក្ត្រ័ព្រះពុទ្ធរូបក៏បាន ចំពោះនឹងព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះមុខបុគ្គល ឬគណៈ ឬ សង្ឃក៏បាន លុះសូមខមាទោសរួចហើយ ត្រូវបញ្ចេញ វចីភេទ ពោលគឺប្រកាសប្តេជ្ញាខ្លួនឱ្យជាអ្នកបានដល់ព្រះត្រៃ សរណ-គមន៍ ជាឧបាសក ឬឧបាសិកា ក្នុងព្រះពុទ្ធសាសនា ជាខាងក្រោយ រួចហើយ ត្រូវសមាទាននិច្ចសីលរក្សាឱ្យខ្ជាប់តទៅ បើមានសទ្ធាជ្រះថ្លា ក៏គប្បីរក្សាឧបោសថសីល តាមការកំណត់ ដែលត្រូវរក្សាម្តងៗនោះផង នឹងមានផលានិសង្សច្រើនដោយលំដាប់ៗឡើង ។ ឯពាក្យសូមខមាទោសនឹងព្រះរតនត្រ័យនោះ បើ បុរសតែម្នាក់ ឬស្ត្រីតែម្នាក់ត្រូវសូធ្យថា :

**អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ**

**យថាមុឡ្ហំ យថាអកុសលំ** យោ / យា } **ហំ ភន្តេ**

**កាយេន វា វាចាយ វា មនសា វា**

ភគវតោ / ពុទ្ធស្ស } **វា ធម្មស្ស វា សង្ឃស្ស វា**

**អគារវំ អកាសឹ ត** ស្ស / ស្សា } **មេ ភន្តេ** { ភគវា / អយ្យោ / អយ្យា / សង្ឃោ }

**អច្ចយំ អច្ចយតោ បដិគ្គណ្ហ** តុ / តុ / ន្តុ / តុ } **អាយតឹ**

**សំវរាយ ។**

ប្រែថា : បពិត្រព្រះ { ដ៏មានព្រះភាគ / ករុណា / ករុណាទាំងឡាយ / សង្ឃ } ដ៏ចម្រើន ទោស

កំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយខ្ញុំព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិត្រ-

ព្រះ
ដ៏មានព្រះភាគ
ករុណា
ករុណាទាំងឡាយ
សង្ឃ
ដ៏ចម្រើន ក្រែងខ្ញុំព្រះករុណា

បានធ្វើហើយ នូវសេចក្តីល្មើសមិនគោរពដល់

ព្រះ
ដ៏មានព្រះភាគ
ពុទ្ធជាម្ចាស់
ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី

ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី

បពិត្រព្រះ
ដ៏មានព្រះភាគ
ករុណា
ករុណាទាំងឡាយ
សង្ឃ
ដ៏ចម្រើន សូម

ព្រះ
ដ៏មានព្រះភាគ
ករុណា
ករុណាទាំងឡាយ
សង្ឃ
អត់នូវទោសកំហុសនោះដល់

ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្ដីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្តឱ្យល្អ តទៅក្នុងខាងមុខនោះហោង ។

រួចបើជាបុគ្គល ឬគណៈ ឬសង្ឃ ដែលនៅជាប្រធាន នៅទីនោះ ត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

បើបុរសត្រូវសូធ្យថា **យោហំ** ថា **តស្ស មេ** បើស្ត្រីត្រូវសូធ្យថា **យាហំ** ថា **តស្សា មេ** តាមគួរដល់បាលីភាសា ដែលត្រូវផ្លាស់តាមបុរស-ស្ត្រី ទោះបុរសក្ដីស្ត្រីក្ដី បើសូមខមាទោសក្នុងទីចំពោះ ព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះនឹងព្រះស្តូបព្រះចេតិយដែលមាន បញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធ ត្រូវសូធ្យថា **ភគវតោ វា** ថា **ភន្តេ ភគវា** ថា **បដិគ្គណ្ហតុ** បើចំពោះនឹងភិក្ខុមួយរូប ត្រូវសូធ្យថា **ពុទ្ធស្ស វា** ថា **ភន្តេ អយ្យោ** ថា **បដិគ្គណ្ហតុ** បើចំពោះគណៈគឺភិក្ខុ ២ រូប ឬ ៣ រូប ត្រូវសូធ្យថា **ពុទ្ធស្ស វា** ថា **ភន្តេ អយ្យា** ថា **បដិគ្គណ្ហន្តុ** បើចំពោះព្រះសង្ឃ ត្រូវសូធ្យថា **ពុទ្ធស្ស វា** ថា **ភន្តេ សង្ឃោ** ថា **បដិគ្គណ្ហតុ**

ត្រង់សេចក្តីប្រែ ក៏មានរបៀបតាមជួរបាលី ដែលតាងនោះដែរ ។

បើសុទ្ធតែបុរស ឬសុទ្ធតែស្ត្រីច្រើននាក់ ឬបុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅហើយ សូធ្យសូមខមាទោស ព្រមគ្នានោះ ត្រូវសូធ្យថា :

**អច្ចយោ នោ ភន្តេ អច្ចគមា**

**យថាពា** { លេ / លា } **យថាមូ** { ឡ្ហេ / ឡ្ហា } **យថា**

**អកុស** { លេ / លា } { យេ / យា } **មយំ ភន្តេ កាយេន វា**

**វាចាយ វា មនសា វា** { ភគវតោ / ពុទ្ធស្ស } **វា ធម្មស្ស**

**វា សង្ឃស្ស វា អករិម្ហា** { តេសំ / តាសំ } **នោ ភន្តេ**

{ ភគវា / អយ្យោ / អយ្យា / សង្ឃោ } **អច្ចយំ អច្ចយតោ បដិគ្គណ្ហ** { តុ / តុ / ន្តុ / តុ }

**អាយតី សំវរាយ ៥** (សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា "ខ្ញុំព្រះករុណា" នោះ ក្នុងទីនេះ ត្រលប់ប្រែថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នោះវិញ ក្រៅអំពីនោះ នៅដូចគ្នាទាំងអស់)។

បើបុរសត្រូវថា **យថាពាលេ យថាមូឡ្ហេ យថាអកុសលេ យេ មយំ** ថា **តេសំ នោ**, បើស្ត្រីត្រូវថា **យថាពាលា យថាមូឡ្ហា យថាអកុសលា យា មយំ, តាសំ នោ** បើទុកជាគ្នាច្រើន មានបុរសមានស្ត្រីលាយគ្នា ហើយសូធ្យសូមខមាទោស ព្រមគ្នានោះក៏ត្រូវសូធ្យខុសគ្នាត្រង់ បទដែលគាបនោះដែរ វៀរលែងតែត្រង់បទដែលគាប ៣ អន្លើ គឺត្រង់បទថា **ភគវតោ វា ពុទ្ធស្ស វា,ភគវា អយ្យោ អយ្យា សង្ឃោ បដិគ្គណ្ហាតុ បដិគ្គណ្ហន្តុ** នេះត្រូវសូធ្យដូចគ្នាទាំង បុរសទាំងស្ត្រី តែបើគ្នាច្រើនហើយ សូធ្យសូមខមាទោសព្រមទាំងអស់គ្នានោះ បើមិនបាច់សូធ្យដោយពាក្យជា ពហុវចនៈតាមបែបខាងក្រោយនេះ នឹងសូធ្យដោយពាក្យជា ឯក-

វចនៈ តាមបែបមុននោះក៏បាន ព្រោះសូធ្យខមាទោស ព្រមគ្នាទាំងអស់ ។ លុះបានសូម ខមាទោស នឹងព្រះរតនត្រ័យ ដូច្នោះរួចហើយ គប្បីបញ្ចេញវចីភេទ ប្ដេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរឭក ដើម្បីនឹងឱ្យឡើងនាមបញ្ញត្តិ ជាឧបាសក ឬឧបាសិកា ក្នុងព្រះពុទ្ធសាសនាតទៅ ឯប្ដេជ្ញាខ្លួននោះ នឹងប្ដេជ្ញាក្នុងទីចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ក៏បាន ចំពោះព្រះស្តូប ឬព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃក៏បាន បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ សូធ្យប្ដេជ្ញាខ្លួនចំពោះមុខបុគ្គល ឬគណៈ ឬសង្ឃនោះ ត្រូវប្ដេជ្ញាដោយពាក្យថា :

**ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ**

**ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា** { សកំ / សិកំ } **មំ** { អយ្យោ / អយ្យា / សង្ឃោ }

**ធារេ** { តុ / ន្តុ / តុ } **អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។**

ប្រែថា : បពិត្រព្រះ { ករុណា / ករុណាទាំងឡាយ / សង្ឃ } ដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក

សូមព្រះ { ករុណា / ករុណាទាំងឡាយ / តរង្ឃ } ជ្រាប នូវខ្ញុំព្រះករុណាថាជា ឧបា { សក / សិកា } បានដល់ហើយនូវព្រះរតនត្រ័យ ជាទីពឹងទីរឭក ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

រូបបុគ្គល ឬគណៈ ឬសង្ឃ ត្រូវទទួលថា **សាធុ** ប្រែដូចមុន ។

បើបុរសត្រូវថា **ឧបាសកំ** បើស្ត្រីត្រូវថា **ឧបាសិកំ** ត្រង់ពាក្យថា **អយ្យោ ធារេតុ,អយ្យា ធារេន្តុ, សង្ឃោ ធារេតុ** នេះមានសេចក្តីអធិប្បាយដូចក្នុងវិធីសូធ្យខមាទោសខាងដើម។

បើគ្នាច្រើន តាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរស ក្ដី សុទ្ធតែស្ត្រីក្ដី បុរសនិងស្ត្រីលាយគ្នាក្ដី ត្រូវសូធ្យថា ៈ

**ឯ** តេ / តា } **មយំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច**

**ឧបា** សកេ / សិកាយោ } **នោ** អយ្យោ / អយ្យា / សង្ឃោ } **ធារេ** តុ / ន្តុ / តុ } **អជ្ជតគ្គេ**

**បាណុបេ** តេ / តា } **សរណំ គ** តេ / តា } **២**

សេចក្ដីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យ មុនថា "ខ្ញុំព្រះករុណានោះ" ក្នុងទីនេះថា "ខ្ញុំព្រះករុណាទាំងឡាយ" ដូច្នោះវិញ ក្រៅអំពីនេះ នៅដូចគ្នាទាំងអស់។ បើបុរសតែម្នាក់ ឬស្ត្រីតែម្នាក់ ហើយសូធ្យប្ដេជ្ញាខ្លួន ចំពោះព្រះពុទ្ធរូប ឬព្រះស្ដូបព្រះចេតិយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យ នោះត្រូវពោលប្ដេជ្ញា ដោយពាក្យថាៈ

**ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ**

**ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបា** សកំ / សិកំ **មំ ភគវា**

**ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ៗ**

ប្រែថា ៖ បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគផង នូវព្រះធមិផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបនូវខ្ញុំព្រះករុណាថាជា ឧបា សក / សិកា បានដល់ហើយ នូវព្រះរតនត្រ័យជាទីពឹងទីរឭកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

បើគ្នាច្រើន ក៏ត្រូវសូធ្យដូចន័យមុន ខុសគ្នាតែត្រង់ពាក្យថា៖ **ភគវន្តំ** ថា **ភគវា**, ប៉ុណ្ណោះ បើគ្នាច្រើនហើយនឹងសូធ្យប្តេជ្ញាខ្លួនព្រមគ្នា ដោយពាក្យជាឯកវចនៈក៏បាន ព្រោះសូធ្យព្រមទាំងអស់គ្នា ។

បុរស ឬស្ត្រី កាលបើបានពោលពាក្យប្តេជ្ញាខ្លួនជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាទីពឹងទីរឭកដូច្នេះរួចហើយ ក៏បាននាមបញ្ញត្តិថា "ឧបាសក " ឬ "ឧបាសិកា" ក្នុងខណៈនោះឯង ។

វិធីសូធ្យខមាទោសក្តី វិធីប្តេជ្ញាខ្លួនជាឧបាសកជាឧបា-សិកាក្តី បើអ្នកមិនចេះសូធ្យជាបាលី នឹងសូធ្យជាសេចក្តីសម្រាយតាមភាសារបស់ខ្លួននោះក៏បាន បើចេះសូធ្យទាំងបាលី ទាំងសេចក្តីប្រែជាសម្រាយផង ដូចបានពោលមកហើយនោះ ជាការប្រពៃពិត តែកុំសូធ្យតែបាលីទទេ ដោយមិនដឹងថាជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូធ្យខមាទោសនិងប្តេជ្ញាខ្លួននោះ ចំពោះយកសទ្ធា គឺសេចក្តីជឿជាក់ នឹងបញ្ញា ជាសម្មាទិដ្ឋិ ដែលដឹងពិត យល់ត្រូវពិតជាប្រមាណ ។

**ចប់បុព្វភាគបដិបត្តិតែប៉ុណ្ណេះ**

## សីលនៃឧបាសក

**បញ្ចាវិរតិចេតនា** គឺចេតនាដែលវៀរចាកវេរា ៥ ឈ្មោះថា "សីលនៃឧបាសក" ដូចពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សម្ដែងចំពោះនឹងមហានាមសក្យរាជថា "ម្នាលមហានាម! ឧបាសកឯណា បានវៀរចាក **បាណា - តិបាត** គឺមិនសម្លាប់សត្វ ១ វៀរចាក**អទិន្នាទាន** គឺមិនលួចទ្រព្យសម្បត្តិ អ្នកដទៃ ១ វៀរចាក**កាមេសុមិច្ឆាចារ** គឺមិនប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ១ វៀរចាក **មុសា-វាទ** គឺមិននិយាយកុហក ១ វៀរចាក **សុរាមេរយៈ** គឺមិនផឹក សុរា និងមេរ័យ ១ ឧបាសកនោះឈ្មោះថា "ឧបាសក មានសីល" ។

## អាជីវៈនៃឧបាសក

កិរិយាលះបង់នូវជំនួញខុស ៥ ប្រការ ហើយប្រកបកិច្ចការចិញ្ចឹមជីវិតដោយត្រឹមត្រូវតាមធម៌ឈ្មោះថា "អាជីវៈនៃឧបាសក" ដូចមានពុទ្ធប្បញ្ញត្តិ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងហាមចំពោះនឹងភិក្ខុទាំងឡាយថា៖

**បញ្ចិមា ភិក្ខវេ វណិជ្ជា ឧបាសកេន អករណីយា** ម្នាលភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ ៥ ប្រការ ឧបាសកមិនគប្បីធ្វើឡើយ ។

## ជំនួញខុស ៥ ប្រការនោះគឺ

**១~ សត្ថវណិជ្ជា** ជួញដូរគ្រឿងសាស្ត្រាវុធ សម្រាប់ប្រហារ គឺធ្វើគ្រឿងសាស្ត្រាវុធនោះដោយខ្លួនឯង ឬ ឱ្យអ្នកដទៃទេគេធ្វើឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់គ្រឿងសាស្ត្រាវុធនោះ ។

**២~ សត្តវណិជ្ជា** ជួញដូរមនុស្ស ។

**៣~ មំសវណិជ្ជា** ជួញសាច់ គឺចិញ្ចឹមនូវសត្វ ទាំង-ឡាយមានជ្រូកជាដើម លុះដល់សត្វទាំងឡាយនោះចម្រើនធំឡើង ក៏សម្លាប់យកសាច់លក់ ។

**៤~មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយ ឱ្យកើតឡើងជាទឹកស្រវឹង ដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ ។

**៥-វិសវណិជ្ជា** ជួញថ្នាំពិស គឺចាត់ចែងថ្នាំពិសឱ្យកើតឡើងដោយខ្លួនឯង ឬឱ្យគេផ្សំឱ្យ ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវថ្នាំពិស ។

ឧបាសក កាលវៀរចាកជំនួញខុសទាំង ៥ ប្រការនេះ ហើយបានប្រតិបត្តិ ការចិញ្ចឹមជីវិតដោយធមិ ឈ្មោះថា មានអាជីវធមិដោយប្រពៃ ។

## វិបត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីលនិងអាជីវធមិនៃឧបាសក ឱ្យវិនាស ឈ្មោះថា "វិបត្តិ" វិបត្តិនោះមាន ៥ យ៉ាងគឺ :

**១- អស្សទ្ធោ ហោតិ** ឧបាសកមិនជឿគុណ ព្រះរតនត្រ័យ ។

**២- ទុស្សីលោ ហោតិ** ឧបាសកទ្រុស្តសីល ។

**៣- កោតូហលមង្គលិកោ ហោតិ** ឧបាសក ប្រកបដោយមង្គលភ្ញាក់ផ្អើល ។

**៤- មង្គលំ បច្ចេតិ នោ កម្មំ** ឧបាសក ប្រកាន់ជឿថាមង្គលមានឫក្សពារវេលាជាដើមឱ្យផល មិនប្រកាន់ជឿថាកម្មជាកុសល និងកម្មជាអកុសលឱ្យផលឡើយ ។

**៥- ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ** ឧបាសកស្វែងរកតែទក្ខិណេយ្យបុគ្គល គឺ បដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនា ហើយធ្វើទានដល់ ទក្ខិណេយ្យ-បុគ្គល ខាងក្រៅព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណា ប្រកបដោយវិបត្តិ ៥ យ៉ាងនេះត្រង់វិបត្តិឯណាមួយហើយ ឧបាសកនោះឈ្មោះថា "ឧបាសកចណ្ឌាល" គឺឧបាសកដូចជាមនុស្សចណ្ឌាលផង ឈ្មោះថា "ឧបាសកកមលៈ" គឺឧបាសកមានធមិជាមន្ទិលសៅហ្មងផង ឈ្មោះថា "ឧបាសក បដិកិដ្ឋ " គឺឧបាសកដែលអ្នកប្រាជ្ញទាំងឡាយ លោកតិះដៀលផង។

# សម្បត្តិនៃឧបាសក

ធម្មជាតិដែលញ៉ាំងសីលនិងអាជីវធម៌នៃឧបាសកឱ្យបរិបូណ៌ ឱ្យបរិសុទ្ធប្រពៃ ឈ្មោះថា "សម្បត្តិ" សម្បត្តិនោះមាន ៥ យ៉ាងគឺ :

**១~ សទ្ធោ ហោតិ** ឧបាសកមានសេចក្ដី ជឿជាក់ច្បាស់ ក្នុងគុណព្រះរតនត្រ័យ ។

**២~ សីលវា ហោតិ** ឧបាសកមានសីល ។

**៣~ ន កោតូហលមង្គលិកោ ហោតិ** ឧបាសកមិនប្រកបដោយ មង្គលភ្ញាក់ផ្អើល ។

**៤~ កម្មំ បច្ចេតិ នោ មង្គលំ** ឧបាសកប្រកាន់ជឿថា កម្មជាកុសល និងអកុសលឱ្យផល មិនប្រកាន់ជឿថាមង្គលមានឫក្សពារវេលាជាដើម ឱ្យផលឡើយ ។

**៥~ ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** ឧបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈ អ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេយ្យបុគ្គលក្នុងព្រះពុទ្ធសាសនានោះ ។

ឧបាសកឯណាប្រកបដោយសម្បត្តិ ៥ យ៉ាងនេះ ហើយឧបាសកនោះឈ្មោះថា "ឧបាសករតនៈ" គឺឧបាសកដូចជា

រតនៈវត្ថុមានកែវជាដើមផង ឈ្មោះថា "ឧបាសកបទុមៈ"គឺ ឧបាសកដូចជាផ្កាឈូកមានពណ៌ក្រហមផង ឈ្មោះថា "ឧបាសកបុណ្ឌរីក" គឺឧបាសកដូចជាផ្កាឈូកមានពណ៌សផង ។

## គុណនៃឧបាសក

ធម៌សម្រាប់ឧបាសក ឧបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងឱ្យកើតឱ្យចម្រើន នូវសម្បត្តិទាំងពួងឈ្មោះថា "គុណ" គុណនេះជារបស់ឧបាសក ឧបាសិកាហៅថា "ឧបាសកគុណ" មាន ១០ យ៉ាងគឺ :

**១- សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ** ឧបាសកអ្នករួមសេចក្តីសុខទុក្ខ មួយអន្លើដោយភិក្ខុសង្ឃ គឺថា បើភិក្ខុសង្ឃមានសេចក្តីសុខ ក៏ត្រេកអរ បើភិក្ខុសង្ឃមានទុក្ខព្រួយ ក៏ព្រួយជាមួយផង ។

**២- កាយិកវាចសិកញ្ច សុរក្ខិតំ ហោតិ** ឧបាសកមានកាយកម្ម និង វចីកម្មរក្សាហើយដោយប្រពៃ ។

**៣- ធម្មោ អធិបតេយ្យោ ហោតិ** ឧបាសកមាន ធម៌ជាអធិបតី គឺថាបើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់យក

ធម៌ជាធំ ជាទីតាំង ជាទីអាងមាំ មិនឱ្យខុស មិនឱ្យឃ្លៀង ឃ្លាត អំពីធម៌ឡើយ ។

**៤~ យថាថាមេន សំវិភាគរតោ ច ហោតិ** ឧបាសកជាអ្នកត្រេកអរ ក្នុងការបរិច្ចាកទាន តាមសមគួរ ដល់កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និង ច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនក៏ធ្វើច្រើន មិនមាន មច្ឆរិយធម៌ គ្របសង្កត់សន្តានចិត្តឡើយ ។

**៥~ ជិនសាសនំ ជានិតុញ្ញ វាយមតិ** ឧបាសក ឧស្សាហ៍ ព្យាយាម ដើម្បីឱ្យដឹងច្បាស់នូវសាសនៈ គឺពាក្យ ប្រៀនប្រដៅ ពាក្យបណ្ដាំ នៃព្រះជិនស្រី ។

**៦~ សម្មាទិដ្ឋិកោ ច ហោតិ** ឧបាសកជា សម្មា-ទិដ្ឋិ គឺមានប្រាជ្ញា ឃើញត្រូវតាមសេចក្ដីពិត ។

**៧~ អបគតោ កោតុហលមង្គលិកោ ច ហោតិ** ឧបាសក ប្រាសចាកមង្គលភ្ញាក់ផ្អើល ហើយជាអ្នកមិន ប្រកាន់ជឿថាមង្គល មានឫក្សពារវេលាជាដើម ឱ្យផល ប្រកាន់ជឿតែកម្មជាកុសល និងអកុសល ថាឱ្យផល ។

**៨~ ជីវិតហេតុបិ អញ្ញំ សត្ថារំ ន ឧទ្ទិសតិ** ឧបាសកបើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតក្ដី

ក៏មិនលះបង់ព្រះរតនត្រ័យ ហើយត្រឡប់ទៅជាកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថា ប្រសើរជាងព្រះរតនត្រ័យ នោះឡើយ ។

**៩. សមគ្គារាមោ ច ហោតិ** ឧបាសកមានសេចក្ដីត្រេកអរ ក្នុងសាមគ្គីធម៌ គឺសេចក្ដីព្រមព្រៀងគ្នា ។

**១០. សាសនេ ចរតិ** ឧបាសកប្រព្រឹត្តល្អក្នុង ព្រះពុទ្ធសាសនា គឺប្រព្រឹត្តតែធម៌វិន័យជាពុទ្ធសាសនា។

ឧបាសកគុណទាំង ១០ យ៉ាងនេះ ឧបាសក ឧបាសិកាគប្បីប្រព្រឹត្តតាមកុំឱ្យឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចធ្វើឱ្យចិត្តឧបាសក ឧបាសិកាអ្នកប្រតិបត្តិ ឱ្យសុចរិតផូរផង់ក្នុងព្រះពុទ្ធសាសនា ហើយឱ្យបានជាបច្ច័យ នៃសម្បត្តិព្រះនិព្វានផង ។

**ចប់ឧបាសកនិទ្ទេសដោយសង្ខេបប៉ុណ្ណេះ ។**

# វិធីសមាទាននិច្ចសីល

ពុទ្ធសាសនិកជនដែលបានដល់ព្រះត្រៃសរណគមន៍ បានឡើងនាមបញ្ញត្តិ ជាឧបាសក ឬឧបាសិកាហើយ កាលបើ

សមាទាន នូវនិច្ចសីល គឺសីល ៥ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃគឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យ នមស្សការ-ថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យ ដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវនិច្ចសីល ព្រមទាំងព្រះត្រៃសរណ-គមន៍ ចំពោះនឹងភិក្ខុ ឬសាមណេរដែលខ្លួន នឹងសមាទាន នោះថា :

**ឱកាស** (អហំ / មយំ) **ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា** (មិ / ម)

(ទុតិ / តតិ) **យម្បិ** (អហំ / មយំ) **ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចា** (មិ / ម) **៕**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន

ខ្ញុំព្រះ (ករុណា / ករុណាទាំងឡាយ) សូមនូវសីល ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា

បពិត្រ ព្រះករុណាដ៏ចម្រើន ខ្ញុំព្រះ (ករុណា / ករុណាទាំងឡាយ) សូម

នូវសីលទាំងឡាយ ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍

ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នាជាគម្រប់ { ពីរដងផង / បីដងផង }។
ឬនឹងសូមថា :

**ឱកាស { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**

**យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ ទេថ { មេ / នោ } ភន្តេ**

**{ ទុតិ / តតិ } យម្បិ { អហំ / មយំ } ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

**តិសរណេន សហ បញ្ចង្គសមន្នាគតំ និច្ចសីលំ**

**យាចា { មិ / ម } អនុគ្គហំ កត្វា សីលំ ទេថ { មេ / នោ } ភន្តេ។**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន

{ ករុណា / ករុណាទាំងឡាយ }

ខ្ញុំព្រះ                    សូមនូវនិច្ចសីលប្រកបព្រមដោយ
អង្គ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បី
ប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចម្រើន
សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់

ខ្ញុំព្រះ ករុណា / ព្រះ ករុណាទាំងឡាយ } បពិត្រព្រះករុណាដ៏ចម្រើនខ្ញុំ សូមនូវនិច្ចសីលប្រកបដោយអង្គ ៥

មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ និង

រក្សាផ្សេងៗគ្នា ជាគម្រប់ ពីរដងផង / បីដងផង } បពិត្រព្រះករុណា ដ៏
ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវ
សីលដល់ខ្ញុំព្រះ ករុណា / ករុណាទាំងឡាយ } ។

(សូមដូច្នេះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម)

បើអ្នកសមាទានតែម្នាក់ ត្រូវថា **អហំ** ថា **យាចាមិ** ត្រង់ប្រែត្រូវថា "ខ្ញុំព្រះករុណា" សូមថា **មេ** ត្រង់ប្រែត្រូវថា "ដល់ខ្ញុំព្រះករុណា" បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ នឹងសូមតែម្នាក់ថា **មយំ** ថា **យាចាម** ក៏បានត្រង់ប្រែ ត្រូវថា "ខ្ញុំព្រះករុណាទាំងឡាយ" សូមថា **នោ**

ត្រង់ប្រែថា"ដល់ខ្ញុំព្រះករុណាទាំងឡាយ" តែ បើគ្នាច្រើន ហើយសូធ្យ សូមព្រមទាំងអស់គ្នានោះ សូមសូធ្យថា **អហំ** ថា **យាចាមិ** ថា **មេ** ក៏បាន ព្រោះសូធ្យ សូមទាំងអស់គ្នា លុះសូមដូច្នេះរួចហើយ លោកអ្នកឱ្យសីល លោកសូធ្យ **នមោ** ៣ ចប់ ហើយលោកឱ្យព្រះត្រៃ-សរណគមន៍ និង និច្ចសីល អ្នកសមាទាន ត្រូវទទួល ថាតាមលោក ដោយបញ្ចេញវិចីភេទឱ្យច្បាស់លាស់ កុំទទួលខ្សឹបៗ ។

លោកសូធ្យថា: **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។** (៣ដង)

ប្រែថា : វីកិរិយានមស្សការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះ អរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះ ពុទ្ធ ជាទីពឹងទីរឭក ។

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះ ធម៌ ជាទីពឹងទីរឭក ។

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរឭក ។

**ទុតិយម្បិ** { ពុទ្ធំ / ធម្មំ / សង្ឃំ } **សរណំ គច្ឆាមិ** ខ្ញុំព្រះករុណាសូម

ដល់នូវព្រះ { ពុទ្ធ / ធម្ម / សង្ឃ } ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង ។

**តតិយម្បិ** { ពុទ្ធំ / ធម្មំ / សង្ឃំ } **សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា

សូមដល់នូវព្រះ { ពុទ្ធ / ធម្ម / សង្ឃ } ជាទីពឹងទីរឭក ជាគម្រប់បីដងផង ។

ហើយលោកថា **តិសរណគ្គហណំ បរិបុណ្ណំ**

ប្រែថា : កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណោះ ។

ត្រូវទទួលថា **អាម ភន្តេ** ប្រែថា ករុណាលោកម្ចាស់ ។ ហើយលោកឱ្យសីល ជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិ-យាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេ មិនឱ្យដោយកាយ ឬដោយវាចា ។

**កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមា-ទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខា-បទំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាន

នូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។

រួចហើយលោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭកថា : **ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

ប្រែថា: អ្នក
អ្នកទាំងឡាយ } គប្បីរក្សានូវសិក្ខាបទទាំងឡាយ ៥ នេះ ឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ចដោយសេចក្ដីមិនប្រមាទ គឺថាកុំធ្វេសប្រហែសឡើយ ។

បើអ្នកសមាទានតែម្នាក់ ត្រូវថា "អ្នក" បើគ្នាច្រើនត្រូវថា "អ្នកទាំងឡាយ" ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** ប្រែដូចមុន។

ហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀតថា: **សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធ~យេ ។**

ប្រែថា : សត្វទាំងឡាយទៅកាន់ស្ថានសួគ៌បាន ក៏ព្រោះ

សីល សត្វទាំងឡាយបានបរិបូណ៌ដោយភោគ ក៏ព្រោះសីល សត្វទាំងឡាយបានទៅកាន់ទីរលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនេះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឱ្យបរិសុទ្ធ កុំឱ្យសៅហ្មង ។

អ្នកសមាទាន ត្រូវទទួលថា **សាធុ** ប្រែថា ប្រពៃហើយ ។

## វិធីសមាទាននិច្ចសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណេះ

## វិធីសមាទានឧបោសថសីល

ឧបាសក ឧបាសិកាជាអ្នករក្សានូវឧបោសថសីល កាលបើដល់ថ្ងៃ ជិតនឹងរក្សាឧបោសថសីល គឺថ្ងៃមុនមួយថ្ងៃដែលកំណត់ថា ព្រឹកឡើងនឹងរក្សានូវឧបោសថសីលនោះ គប្បីចាត់ចែងការងារដែលគួរនឹងចាត់ចែង មានវិធីចាត់ចែងនូវអាហារជាដើម ដែលជាការងារដែលគួរនឹងចាត់ចែង ឬនឹងត្រូវប្រើគេធ្វើក្នុងថ្ងៃស្អែក គឺក្នុងថ្ងៃឧបោសថកាលឱ្យហើយក្នុងថ្ងៃនោះមុន តែកុំចាត់ចែងការងារដែលមិនប្រកបដោយធម៌ដែលជាការងារ គឺខ្លួនឧបាសក-ឧបាសិកាមិនគួរនឹងចាត់ចែងនោះឡើយ លុះដល់ព្រឹកឡើងជាថ្ងៃឧបោសថ-

កាល ត្រូវរក្សាឧបោសថសីល គប្បីភ្ញាក់ឡើងពីព្រលឹម ហើយខ្ពុរមាត់ ជម្រះធ្មេញឱ្យស្អាតរួចហើយ បើសមាទាននូវឧបោសថសីលក្នុងវេលានោះ គឺជាការប្រពៃ បើឃើញថានឹងសមាទានពីព្រលឹមនោះមិនទាន់ទេ ក៏គប្បីកំណត់នូវ ឧបោ-សកាល គឺកាលជាទីរក្សានូវឧបោសថសីលក្នុងមួយថ្ងៃមួយយប់នោះ ដោយបញ្ចេញវាចាអធិដ្ឋានថា :

**អជ្ជ ឧបោសថោ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ**

**ឧបោសថិ** កោ / កា **ភវិស្សាមិ** ប្រែថា : ថ្ងៃនេះជាថ្ងៃត្រូវរក្សានូវឧបោសថសីល ខ្លួនអញនឹងជាអ្នក រក្សានូវឧបោសថសីលអស់ថ្ងៃនេះនិងយប់នេះ ។

បើឧបាសកត្រូវថា **ឧបោសថិកោ** បើឧបាសិកាត្រូវថា **ឧបោសថិកា** ។ បើមិនចេះបាលី នឹងអធិដ្ឋានតាមភាសារបស់ខ្លួនៗ ក៏គួរដោយការពិត លុះអធិដ្ឋានកំណត់កាលដូច្នេះរួចហើយ ត្រូវតាំងវិរតិចេតនាវៀរចាកសីលភេទ គឺហេតុដែលជាទីទម្លាយនូវសីលនោះៗ ឱ្យគ្រប់សិក្ខាបទទាំង ៨ កាលបើបានអធិដ្ឋានដូច្នេះរួចហើយ តអំពីនោះមកក៏គប្បីសមាទាននូវឧបោសថសីល អំពីបុគ្គលដទៃ មានភិក្ខុ

ជាដើម តាមកាលដ៏គួរចុះ បើទុកជាដល់ពេលព្រះអាទិត្យរះខ្ពស់ឡើង ប្រមាណពេញពន្លឺធំ ទើបបានសមាទានក្តីក៏ឈ្មោះថាបានសមាទានដោយប្រពៃឈ្មោះថា បានរក្សានូវឧបោសថសីលពេញកាលកំណត់ មួយថ្ងៃមួយយប់ ដោយបរិបូណ៌ ព្រោះអ្នកសមាទាន បានធ្វើនូវឧបោសថកាលមិនឱ្យខ្វះខាត ទាំងវិរតិចេតនាសោតក៏កើតឡើងបរិបូណ៌ក្នុងសន្តាន និងបានផលានិសង្សច្រើន ។

កាលបើឧបាសក ឧបាសិកា នឹងសមាទាននូវឧបោសថសីល ប្រកបដោយអង្គ ៨ ជាបច្ចេកសមាទាន អំពីបុគ្គលដទៃគឺភិក្ខុ ឬសាមណេរនោះ គប្បីសូធ្យនមស្សការថ្វាយបង្គំរឭកដល់គុណព្រះរតនត្រ័យដោយសង្ខេបជាមុន រួចហើយត្រូវសូមនូវឧបោសថសីល ព្រមទាំងព្រះត្រ័យសរណគមន៍ចំពោះភិក្ខុ ឬសាមណេរ ដែលខ្លួននឹងសមាទាននោះថា:

**ឱកាស** (អហំ / មយំ) **ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋ សីលានិ យាចា** (មិ / ម)

(ទុតិ / តតិ) **យម្បិ** (អហំ / មយំ) **ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ**

(មិ / ម)

**តិសរណេន សហ អដ្ឋ សីលានិ យាចា ២**

ប្រែដូចក្នុងវិធីសូមនិច្ចសីលខាងដើម ប្លែកគ្នាត្រង់ថា **អដ្ឋ សីលានិ** ប្រែថា នូវសីលទាំងឡាយ ៨។

ឬនឹងសូមថា :

**ឱកាស** {អហំ / មយំ} **ភន្តេ វិសុំ វិសុំ**

**រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ**

**ឧបោសថំ យាចា**{មិ / ម} **អនុគ្គហំ កត្វា សីលំ**

**ទេថ** {មេ / នោ} **ភន្តេ** {ទុតិ / តតិ} **យម្បិ** {អហំ / មយំ} **ភន្តេ វិសុំ**

**វិសុំ រក្ខនត្ថាយ តិសរណេន សហ**

**អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា**{មិ / ម}

**អនុគ្គហំ កត្វា សីលំ ទេថ** {មេ / នោ} **ភន្តេ ២**

ប្រែថា : សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន

ខ្ញុំព្រះ ករុណា / ករុណាទាំងឡាយ } សូមនូវឧបោសថសីល

ប្រកបដោយអង្គ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ នឹងរក្សាផ្សេងៗគ្នា បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវ

សីលដល់ខ្ញុំព្រះ ករុណា / ករុណាទាំងឡាយ } បពិត្រព្រះករុណាដ៏

ចម្រើនខ្ញុំព្រះ ករុណា / ករុណាទាំងឡាយ } សូមនូវឧបោសថសីល

ប្រកបព្រមដោយអង្គ ៨ មួយអន្លើ ដោយព្រះត្រៃ

សរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សា ផ្សេងៗគ្នា

ជាគម្រប់ ពីរដងផង / បីដងផង } បពិត្រព្រះករុណា ដ៏ចម្រើន សូមព្រះ

ករុណាមេត្តាធ្វើនូវ សេចក្តីអនុគ្រោះ ឱ្យនូវសីលដល់ ខ្ញុំ

ព្រះ ករុណា / ករុណាទាំងឡាយ } ។

សូមដូច្នោះក៏បាន តាមសេចក្តីពេញចិត្តរបស់អ្នកសូម។

សេចក្តីអធិប្បាយ អំពីអ្នកសូមតែម្នាក់ និងច្រើននាក់នោះ ដូចគ្នានឹងវិធីសូមនិច្ចសីលខាងដើម។

រួចហើយលោកអ្នកឱ្យសីល លោកតាំង **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** ។ (៣ចប់) ហើយឱ្យព្រះត្រៃសរណគមន៍ អ្នកសមាទាន ត្រូវទទួលថាតាមលោក ដូចវិធីសមាទាននិច្ចសីលខាងដើម រួចហើយលោកឱ្យនូវឧបោសថសីលជាបច្ចេកសមាទានថា :

**បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ**
(ប្រែដូចនិច្ចសីល)

**អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ**
(ប្រែដូចនិច្ចសីល)

**អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិ-យាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តិនូវធមិមិនប្រសើរ គឺសេពនូវ មេថុនធម្ម ។

**មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ**
(ប្រែដូចនិច្ចសីល) ។

**សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** (ប្រែដូចនិច្ចសីល) ។

**វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិ~យាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។

**នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធ វិលេប~នធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយារាំ និងច្រៀង និងប្រគំ និងមើលល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់និងប្រដាប់ តាក់តែង ស្អិតស្អាង រាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ។

**ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។

រួចហើយ អ្នកសមាទាន សូធ្យកំណត់ឧបោសថកាល ថា :

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធបញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ប្រែថា :ខ្ញុំព្រះករុណា សូមសមាទាន នូវឧបោសថសីលដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាលកំនត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យច្បាស់នូវព្រះនិព្វាន ព្ធដ៏អនាគតទៅឯមុខនោះហោង ។

បាលីនេះ គ្រាន់តែជាពាក្យពោលសម្រាប់កំណត់កាល ឱ្យដឹងឧបោសថសីល ទាំង ៨ សិក្ខាបទនេះ អ្នកសមាទានត្រូវរក្សាតែត្រឹមមួយថ្ងៃមួយយប់នោះប៉ុណ្ណោះ ហេតុនេះ បើអ្នកសមាទានបានចេះដឹងច្បាស់ ប្រាកដក្នុងឧបោសថកាលហើយ មិនបាច់សូធ្យក៏បាន តែបើទុកជាចេះដឹងច្បាស់ប្រាកដហើយ នឹងសូធ្យបាលីនេះ ជាហេតុនាំឱ្យរឹតតែចេះស្ទាត់ប្រាកដទាំងអស់គ្នាឡើង ។

រួចហើយ លោកអ្នកឱ្យសីល លោកពោលដាស់តឿនក្រើនរំឭក ថា :

**ឥមានិ អដ្ឋ សិក្ខាបទានិ ឧបោសថ-សីលវសេន ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។**

ប្រែថា : អ្នក / អ្នកទាំងឡាយ } គប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អដោយអំណាចនៃ ឧបោសថសីល អស់កាលកំណត់ត្រឹម ១ ថ្ងៃ ១ យប់នេះ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទាន ត្រូវទទួលថា **អាម ភន្តេ** ប្រែដូចមុន។

ហើយលោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀតថា

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។** (ប្រែដូចមុន)

អ្នកសមាទាន ត្រូវទទួលថា **សាធុ** ប្រែដូចមុន ។

**វិធីសមាទានឧបោសថសីលជាបច្ចេកសមាទាន ចប់តែប៉ុណ្ណោះ**

## ឯកជ្ឈសមាទាន

បើឧបាសក ឧបាសិកា នឹងសមាទាននិច្ចសីល ជាឯកជ្ឈ-សមាទាន ព្រមទាំង ព្រះត្រៃសរណគមន៍ផងនោះ ត្រូវ

សូមដូច្នេះថា :

**ឱកាស** {អហំ / មយំ} **ភន្តេ តិសរណេន សហ ឯកជ្ឈំ**

**កត្វា បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា** {មិ / ម}

**អនុគ្គហំ កត្វា សីលំ ទេថ** {មេ / នោ} **ភន្តេ** {ទុតិ / តតិ} **យម្បិ**

{អហំ / មយំ} **ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា**

**បញ្ចង្គសមន្នាគតំ និច្ចសីលំ យាចា** {មិ / ម} **អនុគ្គហំ**

**កត្វា សីលំ ទេថ** {មេ / នោ} **ភន្តេ ។**

ប្រែថា : សូមគោរព ព្រះករុណាដ៏ចម្រើន ខ្ញុំ

ករុណា

ករុណាទាំងឡាយ

ព្រះ } សូមនូវនិច្ចសីលប្រកបដោយអង្គ ៥

ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើដោយ ព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តីអនុគ្រោះ ឱ្យនូវសីលដល់

ខ្ញុំព្រះ ករុណា / ករុណា / ករុណាទាំងឡាយ } បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំ

ព្រះ ករុណាទាំងឡាយ } សូម និច្ចសីលប្រកបព្រមដោយ

អង្គ ៥ ធ្វើឱ្យជាឯកជ្ឈៈ គឺសមាទានរួមតែម្តង មួយអន្លើ

ដោយព្រះត្រៃសរណគមន៍ជាគម្រប់ ពីរដងផង / បីដងផង } បពិត្រព្រះ

ករុណាដ៏ចម្រើន សូមព្រះករុណាមេត្តាធ្វើនូវសេចក្តី

អនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះ ករុណា / ករុណាទាំងឡាយ }។

រួចលោកអ្នកឱ្យនូវសីល លោកតាំង **នមោ** ៣ចប់ ហើយលោកឱ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យក

នូវព្រះត្រៃសរណគមន៍ដូចក្នុងវិធីបច្ចេកសមាទានខាងដើម រួចហើយលោកឱ្យសីលជាឯកជ្ឈសមាទានថា :

**បញ្ចង្គសមន្នាគតំ និច្ចសីលំ សមាទិយាមិ**

ប្រែថា :ខ្ញុំព្រះករុណាសូមសមាទាននូវនិច្ចសីលប្រកប ដោយអង្គ ៥ ។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឱ្យថា **បញ្ចសីលានិ សមាទិយាមិ** ប្រែថា : ខ្ញុំព្រះករុណាសូមសមាទាននូវនិច្ចសីលទាំងឡាយ ៥ (ដូច្នេះក៏បាន) ។

អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយលោកពោលដាស់តឿនក្រើនរំឭកថា :

**ឥមំ បញ្ចង្គសមន្នាគតំ និច្ចសីលំ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។**

ប្រែថា : អ្នក / អ្នកទាំងឡាយ } គប្បីធ្វើនូវនិច្ចសីលប្រកបដោយអង្គ ៥ នេះឱ្យប្រពៃ ត្រូវរក្សាឱ្យល្អអស់កាលជានិច្ច ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** (ប្រែដូចមុន) ។

រួចហើយ លោកសម្តែងអានិសង្សសីលឱ្យស្តាប់តទៅទៀត ដូចក្នុងវិធី បច្ចេកសមាទានខាងដើម ។

សមាទានតែប៉ុណ្ណោះក៏ជាការស្រេច ឥតមានសូធ្យញែក ឈ្មោះ សិក្ខាបទទាំង ៥ រាយម្តងមួយៗ ដូចបច្ចេកសមាទាន នោះឡើយ សមាទានតែប៉ុណ្ណោះហើយ ត្រូវរក្សាដោយ តាំងវិរតិចេតនា វៀរឱ្យគ្រប់សិក្ខាបទក្នុងនិច្ចសីលទាំង ៥ ដែលខ្លួនចេះចាំស្ទាត់ហើយនោះទៅ ។

បើឧបាសក ឧបាសិកា នឹងសមាទានឧបោសថសីល ជា ឯកជ្ឈសមាទាន ព្រមទាំងព្រះត្រៃសរណគមន៍ផងនោះ ត្រូវសូមដូច្នេះថា :

**ឱកាស** {អហំ / មយំ} **ភន្តេ តិសរណេន សហ ឯកជ្ឈំ**

**កត្វា អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា** {មិ / ម}

**អនុគ្គហំ កត្វា សីលំ ទេថ** {មេ / នោ} **ភន្តេ** {ទុតិ / តតិ} **យម្បិ**

{អហំ / មយំ} **ភន្តេ តិសរណេន សហ ឯកជ្ឈំ កត្វា**

{មិ / ម}

**អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចា អនុគ្គហំ**

**កត្វា សីលំ ទេថ** មេ / នោ } **ភន្តេ ៖**

(ប្រែដូចវិធីសូមនិច្ចសីលជាឯកជ្ឍសមាទានខាងដើម ប្លែកគ្នាត្រង់បទថា)

**អដ្ឋង្គសមន្នាគតំ ឧបោសថំ** ប្រែថា ៖នូវឧបោសថសីល ប្រកបដោយអង្គ ៨ ប៉ុណ្ណោះ (ក្រៅពីនេះ ដូចគ្នាទាំងអស់)រួចលោកអ្នកឱ្យសីល លោកតាំង **នមោ** ៣ចប់ហើយ ឱ្យព្រះត្រៃសរណគមន៍ រួចប្រាប់អំពីកិច្ចកាន់យកនូវព្រះត្រៃសរណគមន៍ដូចន័យមុន រួចហើយលោកឱ្យ ឧបោ-សថសីលជាឯកជ្ឍសមាទានថា ៖

**អដ្ឋង្គសមន្នាគតំ ឧបោសថំ សមាទិយាមិ**
ប្រែថា ៖ ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ប្រកបព្រមដោយអង្គ ៨ ។

អ្នកសមាទានត្រូវទទួលថាតាមលោក ឬលោកនឹងឱ្យថា

**អដ្ឋសីលានិ សមាទិយាមិ** ប្រែថា ៖ ខ្ញុំព្រះករុណា សូមសមាទាននូវ សីលទាំងឡាយ ៨ (ដូច្នេះក៏បាន) ។

អ្នកសមាទាន ត្រូវទទួលថាតាមលោក រួចហើយអ្នកសមាទានសូធ្យកំណត់ ឧបោសថកាលថា

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធប្បញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សមទេវ អភិរក្ខិតុំ សមាទិយាមិ** (ប្រែដូចមុន) ។

រួចហើយ លោកពោលដាស់តឿនក្រើនរំឭកថា :

**ឥមំ អដ្ឋង្គសមន្នាគតំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សាធុកំ កត្វា អប្បមាទេន**

**សម្មារក្ខិតព្វំ** ប្រែថា : អ្នក<br>អ្នកទាំងឡាយ } គប្បីធ្វើនូវឧបោសថ

សីលប្រកបព្រមដោយអង្គ ៨ នេះដោយប្រពៃត្រូវរក្សាឱ្យល្អ អស់កាលកំណត់ត្រឹមមួយថ្ងៃមួយយប់នេះ ដោយសេចក្ដីមិនប្រមាទ គឺថា កុំធ្វេសប្រហែសឡើយ ។

អ្នកសមាទានត្រូវទទួលថា **អាម ភន្តេ** (ប្រែដូចមុន) ។

ហើយលោកសម្ដែងអានិសង្សសីលឱ្យស្ដាប់តទៅទៀតដូចន័យមុន។ សមាទានតែប៉ុណ្ណោះក៏ជាការស្រេច ឥតមានសូធ្យញែកឈ្មោះសិក្ខាបទទាំង ៨ រាយមួយម្ដងៗ ដូចបច្ចេកសមាទាននោះឡើយ សមាទានតែប៉ុណ្ណោះហើយ ត្រូវរក្សាដោយតាំងវិរតិចេតនាវៀរចាកឱ្យគ្រប់សិក្ខាបទទាំង ៨ ក្នុងឧបោសថសីលដែលខ្លួនបានចេះចាំស្ទាត់ហើយនោះទៅ។

## វិធីសមាទានសីលជាឯកជ្ឈសមាទានចប់តែប៉ុណ្ណេះ ។

សូម្បីឧបាសក ឧបាសិកា នឹងអធិដ្ឋាននិច្ចសីល ឬ ឧបោសថសីលដោយខ្លួនឯងក្តី ក៏ត្រូវបញ្ចេញវចីភេទអធិដ្ឋានតាមបែបជាបច្ចេកៈ ឬជាឯកជ្ឈៈ ដូចបានពោលមកហើយនោះចុះ ។

ត្រង់វិធីដែលលោក សម្តែងអានិសង្សសីលឱ្យអ្នកសមាទានស្តាប់នោះ បើលោកអ្នកឱ្យសីលលោកឈ្លាសចេះចាំច្រើន ហើយអាចសម្តែងក្នុងពេលនោះបាន ក៏គួរនឹងសម្តែងតាមន័យប្លែកៗដោយអាងដល់ព្រះពុទ្ធភាសិត ឱ្យអ្នកសមាទានស្តាប់ នេះក៏ជាការប្រពៃក្រៃពេក អ្នកសមាទានបានស្តាប់ហើយ ក៏នឹងកើតមានសេចក្តីជ្រះថ្លា ព្រមទាំងចម្រើនសតិបញ្ញាដោយក្រៃលែងឡើងទៀត ហើយនឹងមានផលានិសង្សច្រើន ឱ្យដល់លោកអ្នកឱ្យសីល និងអ្នកសមាទាន ។

### ចប់វិធីសមាទានសីលតែប៉ុណ្ណេះ

## អង្គនៃនិច្ចសីល

## បាណាតិបាត មានអង្គ ៥

**១~ បាណោ** សត្វមានជីវិត ។

**២~ បាណសញ្ញិតា** សេចក្តីដឹងថាសត្វមានជីវិត ។

**៣~ វធកចិត្តំ** គិតនឹងសម្លាប់ ។

**៤~ ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

**៥~ តេន មរណំ** សត្វស្លាប់ដោយព្យាយាមនោះ ។

## អទិន្នាទាន មានអង្គ ៥

**១~ បរបរិគ្គហិតំ** ទ្រព្យដែលមានម្ចាស់របស់គេ ហួង-ហែងរក្សា ។

**២~ បរបរិគ្គហិតសញ្ញិតា** សេចក្តីដឹងថាទ្រព្យមានម្ចាស់របស់គេហួងហែងរក្សា ។

**៣~ ថេយ្យចិត្តំ** គិតនឹងលួច ។

**៤~ ឧបក្កមោ** ព្យាយាមនឹងលួច ។

**៥~ តេន ហរណំ** លួចបានមកដោយព្យាយាមនោះ ។

## កាមេសុមិច្ឆាចារ មានអង្គ ៤

**១~ អគមនីយដ្ឋានំ** ស្ត្រីដែលមិនគួរនឹងគប់រក គឺស្ត្រី ដែលមានគេហួងហែងរក្សា ។

**២~ តស្មិំ សេវនចិត្តំ** គិតនឹងសេពនូវមេថុនធម្មនឹងស្រ្តីនោះ ។

**៣~ ឧបក្កមោ** ព្យាយាមសេពនូវមេថុនធម្មនោះ ។

**៤~ មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនឹងមគ្គឱ្យដល់គ្នា ។

## មុសាវាទ មានអង្គ ៤

**១~ អតថំវត្ថុ** វត្ថុមិនពិត ។

**២~ វិសំវាទនចិត្តំ** គិតនឹងពោលឱ្យខុស ។

**៣~តជ្ជោ វាយាមោ** ព្យាយាមនឹងពោលឱ្យខុស ។

**៤~បរស្ស តទត្ថវិជាននំ** ញុំាងអ្នកដទៃឱ្យដឹងច្បាស់នូវសេចក្តីនោះ ។

## សុរាមេរយ មានអង្គ ៤

**១~ មជ្ជនីយវត្ថុ** វត្ថុជាទីតាំងនៃសេចក្តីស្រវឹងគឺ សុរា និង មេរ័យ ។

**២~ បាតុកម្យតាចិត្តំ** ចិត្តបំរុងនឹងផឹក ។

**៣~ តជ្ជោ វាយាមោ** ព្យាយាមនឹងផឹកនូវទឹកស្រវឹងនោះ ។

៤~ **តស្ស ធានំ** បានផឹកនូវទឹកស្រវឹងនោះឱ្យកន្លង
បំពង់កចូលទៅ ។

## អង្គនៃឧបោសថសីល

អង្គនៃបាណាតិបាត និងអទិន្នាទាន ដូចនិច្ចសីលខាងដើម

## អព្រហ្មចរិយា មានអង្គ ៤

១~ **អជ្ឈាចរណីយវត្ថុ** វត្ថុជាទីទម្លាយនូវសីលគឺទ្វារទាំង
៣០ ចំពោះត្រង់ទ្វារណាមួយ ។

២~ **សេវនចិត្តំ** គិតនឹងសេព ។

៣~ **តជ្ជោ វាយាមោ** ព្យាយាមនឹងសេពនូវមេថុន
ធម្មនោះ ។

៤~**មគ្គេន មគ្គប្បដិបាទនំ** ញុំាងមគ្គនិងមគ្គឱ្យដល់គ្នា។

អង្គនៃមុសាវាទ និងសុរាមេរ័យដូចនិច្ចសីលខាងដើម។

## វិកាលភោជន មានអង្គ ៣

១~ **វិកាលោ** កាលខុសគឺព្រះអាទិត្យជ្រេ
ទៅហើយដរាបទល់នឹងអរុណរះ ។

២~ **យាវកាលិកំ** របស់ដែលគួរបរិភោគបានក្នុង
កាលគឺតាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់។

**៣~ អជ្ឈោហរណំ** បានលេបចូលទៅក្នុងបំពង់ក ។

**នច្ចគីត ព្រមទាំង មាលា រួមគ្នាជាសិក្ខាបទ ១ មានអង្គ ៦**

**១~ នច្ចគីតាទិ** ការល្បែង មានរាំ និងច្រៀងជាដើម ។

**២~ ភត្តកម្យតាចិត្តំ** គិតបម្រុងនឹងធ្វើ ។

**៣~ សុតទស្សនត្ថាយគមនំ** ទៅដើម្បីនឹងស្តាប់ឬមើល ហើយបានស្តាប់ឬមើល ។

**៤~ មាលាទិ** វត្ថុសម្រាប់ប្រដាប់កាយ មានផ្កាកម្រងជាដើម ។

**៥~ធារណច្ឆន្ទតា** សេចក្តីប្រាថ្នានឹងប្រដាប់តាក់តែង ។

**៦~តស្ស ធារណំ** បានប្រដាប់តាក់តែងនូវវត្ថុសម្រាប់ប្រដាប់ កាយ មានផ្កាកម្រងជាដើមនោះ ។

**ឧច្ចាសយន មានអង្គ ៣**

**១~ឧច្ចាសយនមហាសយនំ** ទីដេក ទីអង្គុយ ដ៏ខ្ពស់ ដ៏ប្រសើរ ហួសប្រមាណ ។

**២~ បរិភោគចិត្តំ** គិតនឹងដេក ឬ អង្គុយ ។

**៣~ បរិភោគករណំ** បានដេក ឬ អង្គុយ ។

កាលបើឧបាសកឧបាសិកា ប្រព្រឹត្តឱ្យកន្លងនូវសិក្ខាបទណា១ លុះតែព្រមដោយអង្គក្នុងសិក្ខាបទនោះ១ ទើបបានឈ្មោះថាកន្លង បើមិនទាន់ព្រមដោយអង្គនោះ១ទេ ក៏មិនបានឈ្មោះថា កន្លងនូវសិក្ខាបទនោះ១ឡើយ ។

**អង្គនៃនិច្ចសីល និងឧបោសថសីល**

**ចប់តែប៉ុណ្ណេះ ។**

## អកុសលកម្មបថ

គន្លងឬជាផ្លូវនៃអំពើជាអកុសល ហៅថា អកុសលកម្មបថ មាន ១០ យ៉ាងគឺ **កាយកម្ម** អំពើដែលសម្រេចដោយ កាយ មាន ៣ យ៉ាង **វចីកម្ម** អំពើដែលសម្រេចដោយវាចា មាន ៤ យ៉ាង **មនោកម្ម** អំពើដែលសំរេចដោយចិត្តមាន ៣ យ៉ាង រួមត្រូវជា ១០ យ៉ាង ។

### កាយកម្ម ៣ យ៉ាង

**១~បាណាតិបាតោ** កិរិយាសម្លាប់សត្វ ដោយកាយរបស់ខ្លួនឬប្រើឱ្យគេសម្លាប់ដោយវាចា ។

**២~អទិន្នាទានំ** កិរិយាលួចលាក់ឆក់ដណ្ដើមទ្រព្យគេដោយកាយរបស់ខ្លួន ឬប្រើគេ ឱ្យលួចលាក់ឆក់ដណ្ដើមដោយវាចា ។

**៣~កាមេសុ មិច្ឆាចារោ** កិរិយាប្រព្រឹត្តខុស ក្នុងកាមទាំងឡាយគឺធ្វើនូវមេថុនសេវនៈនឹងស្ត្រី ដែលមានគេហួងហែងរក្សា ។

## វចីកម្ម ៤ យ៉ាង

**១~មុសាវាទោ** កិរិយាពោលនូវពាក្យ កុហក ។

**២~បិសុណាវាចា** កិរិយាពោលនូវពាក្យញុះញង់បំបែកអ្នកដទៃ ។

**៣~ផរុសវាចា** កិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃ ជាដើម ។

**៤~សម្ផប្បលាបោ** កិរិយាពោលនូវ ពាក្យរោយរាយឥតប្រយោជន៏ ។

## មនោកម្ម ៣ យ៉ាង

**១~ អភិជ្ឈា** ចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ដោយគិតបំណង នឹងឱ្យបានមកជាទ្រព្យរបស់ខ្លួន ។

**២~ ព្យាបាទោ** ចិត្តចងគំនុំគុំគួន គឺប៉ងនឹងឱ្យអ្នកដទៃ ដល់នូវសេចក្ដីវិនាស ។

៣~ **មិច្ឆាទិដ្ឋិ** គំនិតយល់ខុស ហើយប្រកាន់ឡើង ថាជាត្រូវ ។

## អង្គនៃអកុសលកម្មបថ

អង្គនៃបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងមុ-សាវាទ ដូចបានពោលមកក្នុងនិច្ចសីលខាងដើមរួចហើយ ។

## បិសុណាវាចា មានអង្គ ៤

១~**ភិន្ទិតព្វោ បរោ** អ្នកដទៃដែលមានរូបគឺខ្លួនគប្បីញុះញង់បំបែក ។

២~**ភេទនបុរេក្ខារតា** គិតនឹងញុះញង់បំបែក អ្នកដទៃ ។

៣~**តជ្ជោ វាយាមោ** ព្យាយាមនឹងញុះញង់បំបែក អ្នកដទៃនោះ ។

៤~**តស្ស តទត្ថវិជ្ជាននំ** ញុំាងអ្នកដទៃនោះឱ្យដឹង ច្បាស់នូវដំណើរដែលខ្លួនញុះញង់បំបែកនោះ ។

## ផរុសវាចា មានអង្គ ៣

១~ **អក្កោសិតព្វោ បរោ** អ្នកដទៃដែលមានរូប គឺខ្លួន គប្បីជេរប្រទេច ។

២~ **កុប្បិតចិត្តំ** ចិត្តខឹងរន្ធត់ ។

៣~ **អក្កោសនា** បានជេរប្រទេចគេ ។

## សម្ផប្បលាប មានអង្គ ២

**១~ភារតយ្យុឆ្ឆសិតាហរណាធិនិរត្ថកថា** ពាក្យឥតប្រយោជន៏មានរឿងចម្បាំងនៃមហាភារតៈ និង រឿង រាពណ៍ លួចនាំនាងសីតាយកទៅជាដើម ។

**២~តថារូបីកថាភថនំ** បានពោលនូវពាក្យឥតប្រយោជន៏មានសភាព ដូច្នេះ ។

## អភិជ្ឈា មានអង្គ ២

**១~ បរភណ្ឌំ** ទ្រព្យជារបស់អ្នកដទៃ ។

**២~ អត្តនោ បរិណាមនំ** គិតចង់បង្អោនទ្រព្យរបស់អ្នកដទៃនោះឱ្យបានជារបស់ខ្លួនដោយកលឧបាយផ្សេងៗ ។

## ព្យាបាទ មានអង្គ ២

**១~បរសត្តោ** អ្នកដទៃក្រៅពីខ្លួន ។

**២~តស្ស តំ តំ វិនាសចិន្តា** គិតគុំគួនប្រុងឱ្យអ្នកនោះដល់នូវសេចក្ដីវិនាសដោយហេតុនោះៗ ។

## មិច្ឆាទិដ្ឋិ មានអង្គ ២

**១~ទត្ថុនោ ច គហិតាការវិបរិតតា** ចិត្តប្រែប្រួលដោយអាការខុសអំពី ព្រះរតនត្រ័យជាដើម ។

**២~យថា ច នំ គណ្ហាតិ តថាភាវេន តស្សុបដ្ឋានំ** គំនិតដែលយល់ខុសនោះ ឃើញខុសយ៉ាងណា ក៏ប្រកាន់យកសេចក្តីខុសនោះថាជាត្រូវវិញ ។

អកុសលកម្មបថទាំង ១០ប្រការ ដូចបានពោលរួចមកហើយនោះ ទោះត្រង់បទណាក្តី បើលុះតែព្រមដោយអង្គនោះៗ ទើបត្រូវទោសដល់អ្នកដែលប្រព្រឹត្តខុស អ្នកនោះនឹងបាននូវសេចក្តីទុក្ខ សេចក្តីវិនាសក្នុងលោកនេះ និងបរលោកនាយ បើទុកជាមិនទាន់ឱ្យផលឃើញច្បាស់ក្នុងលោកនេះ លុះដល់ទៅក្នុងបរលោកនាយ ក៏គង់ឱ្យផលដល់អ្នកនោះមិនខាន បើមិនទាន់ព្រមដោយអង្គនោះៗ គឺថាបើនៅខ្វះអង្គណាមួយនោះ ក៏មិនទាន់មានឈ្មោះថា មានទោសក្នុងអកុសលកម្មបថ ដល់អ្នកដែលប្រព្រឹត្តខុសនោះឡើយ ។

**អកុសលកម្មបថ ១០ ប្រការ ព្រមទាំងអង្គ**

**ចប់ដោយសង្ខេបតែប៉ុណ្ណេះ ៕**

# កុសលកម្មបថ

គន្លងឬផ្លូវជាកុសល ហៅថាកុសលកម្មបថ មាន ១០ យ៉ាង គឺ **កាយកម្ម** អំពើដែលសម្រេចដោយកាយមាន ៣ យ៉ាង **វចីកម្ម** អំពើដែលសម្រេចដោយវាចាមាន ៤ យ៉ាង **មនោកម្ម** អំពើដែលសម្រេចដោយចិត្តមាន ៣យ៉ាង រួមត្រូវជា ១០ យ៉ាង ។

## កាយកម្មមាន ៣ យ៉ាង

**១~បាណាតិបាតា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ។

**២~អទិន្នាទានា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឱ្យ ដោយកាយ ឬដោយវាចា ។

**៣~កាមេសុ មិច្ឆាចារា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយា ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## វចីកម្មមាន ៤ យ៉ាង

**១~មុសាវាទា វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក ។

**២.បិសុណាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យញុះញង់បំបែកបំបាក់អ្នកដទៃ ។

**៣.ផរុសាយ វាចាយ វេរមណី** ចេតនាជាហេតុវៀរចាកកិរិយាពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោកជេរប្រទេចអ្នកដទៃជាដើម ។

**៤.សម្ផប្បលាបា វេរមណី** ចេតនាជាហេតុ វៀរចាកកិរិយា ពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

## មនោកម្ម មាន ៣ យ៉ាង

**១.អនភិជ្ឈា** មិនមានចិត្តគិតសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃដោយ គិតបម្រុងនឹងឱ្យបានមកជាទ្រព្យរបស់ខ្លួនឡើយ ។

**២.អព្យាបាទោ** មិនមានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឱ្យអ្នកដទៃដល់នូវសេចក្តីវិនាសឡើយ ។

**៣.សម្មាទិដ្ឋិ** គំនិតយល់ឃើញត្រូវពិត ដោយប្រកាន់ឡើងថា ជាត្រូវមែន ។

អ្នកឯណាបានប្រព្រឹត្តត្រូវតាមកុសលកម្មបថទាំង ១០ ប្រការ ដូចបានពោលរួចមកហើយនោះ អ្នកនោះនឹងបាន

សេចក្តីសុខ សេចក្តីចម្រើន ក្នុងលោកទាំងពីរ គឺ ក្នុងលោកនេះ និងបរលោកនាយជាប្រាកដ ។

**កុសលកម្មបថ ១០ ប្រការ**
**ចប់ដោយសង្ខេបតែប៉ុណ្ណេះ**

## សម្តែងអំពីវិធីទេវភត្ត ១៤ ប្រការ

បើឧបាសកឧបាសិកាមានបសាទសទ្ធា គឺជំនឿប្រកបដោយសេចក្តីជ្រះថ្លាកើតឡើងក្នុងសន្តាន មានប្រាថ្នានឹងវេរនូវភត្តទាំង ១៤ ប្រការ ភត្តណាមួយក៏បានតាមប្រាថ្នា ។

**ឯភត្តទាំង ១៤ នោះគឺ**

១. **សង្ឃភត្តំ** វេរនូវភត្តដល់សង្ឃ ។

២. **ឧទ្ទេសភត្តំ** វេរនូវភត្តដល់ភិក្ខុមួយអង្គ ឬ ពីរអង្គ ឬក៏បីអង្គជាដើម តាមពាក្យដែលសង្ឃសម្តែងឱ្យ។

៣. **និមន្តនភត្តំ** វេរនូវភត្តដល់ភិក្ខុដែលខ្លួននិមន្តមកហើយប្រគេន ។

៤. **សលាកភត្តំ** វេរទូវភត្តដល់ភិក្ខុទាំងឡាយ ដែលខ្លួនសរសេរឈ្មោះក្នុងស្លាកហើយចាប់ ។

៥. **បក្ខិកភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងសុក្កបក្ខ គឺចំណែកនៅខាងខ្នើត ឬកាឡបក្ខ គឺចំណែកខាងរនោច តែក្នុងមួយបក្ខប្រគេនតែមួយថ្ងៃ មិនមានកំណត់ថ្ងៃណា ។

៦. **ឧបោសថិកភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃឧបោសថកាល ។

៧. **បាដិបទិកភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃមួយកើត ឬ មួយរោច ។

៨. **អាគន្តុកភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃ ដែលទើបមកដល់ថ្មី ។

៩. **គមិកភត្តំ** វេរទូវភត្តដល់ភិក្ខុដែលមានដំណើរនឹងទៅកាន់ទីណាមួយ ។

១០. **គិលានភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃ ដែលមានជម្ងឺ ។

១១. **គិលានុបដ្ឋាកភត្តំ** វេរទូវភត្តដល់ភិក្ខុសង្ឃជាអ្នករក្សាជម្ងឺភិក្ខុ សាមណេរផងគ្នា ។

**១២- និច្ចភត្តំ** វេរនូវភត្តដែលត្រូវប្រគេនជានិច្ច ដល់ភិក្ខុសង្ឃ ។

**១៣- កុដិភត្តំ** វេរនូវភត្តដល់ភិក្ខុសង្ឃនៅទីលំនៅ មានកុដិជាដើម ( ភត្តនេះហៅបានតាមឈ្មោះ ទីកន្លែង ដែល សង្ឃនៅ ) ។

**១៤- វារភត្តំ** វេរនូវភត្តដល់ភិក្ខុសង្ឃដោយចាត់ ចែងជាវេន ។

ភត្តទាំង ១៤ ប្រការនេះ បើទាយកប្រាថ្នានឹងវេរភត្តណាមួយ ត្រូវដាក់ឈ្មោះភត្តនោះត្រង់បាលីដែលវង់ក្រចក ( ) ទុកនោះចុះ ។

**នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស** ( ៣ចប់ ) ។

**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអា-ទិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (ឥត្ថន្នាមំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស**[(១)] **សង្ឃស្ស ទេម តេ**

(១) បើមានរៀបភោជនាហារដោយឡែកផ្សេងជាដង្វាយព្រះពុទ្ធរូប ក្នុងទីនោះ ទើបត្រូវដាក់បាលីថា "ពុទ្ធប្បមុខស្ស" នេះ បើមិនមានដង្វាយព្រះពុទ្ធរូបទេ កុំដាក់បាលីនេះ ។ ប៉ែកខាងសេចក្តីប្រែក៏ដូចគ្នាដែរ ។

ត្រង់បទថា "ឥត្ថន្នាមំ" ត្រូវបញ្ចូលឈ្មោះ "ភត្ត" តាមប្រាថ្នា យ៉ាងដូចជា "សង្ឃភត្ត" បញ្ចូលថា "សង្ឃភត្តំ" ( នូវសង្ឃភត្ត ) ។

**គុណវន្តានយោ ឥមំ (ឥត្ថន្នាមំ) អត្ថនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ.....។ តតិយម្បិ....។**

ប្រែថា ៖ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ វីចង្ហាន់បិណ្ឌបាតនៃខ្ញុំព្រះករុណាទាំងឡាយនេះ ប្រកបដោយធមិ បានមកដោយធមិ កើតឡើងដោយធមិ ហើយខ្ញុំព្រះករុណាទាំងឡាយសូមឧទ្ទិសចំពោះ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតា និងបិតាជាដើម ហើយខ្ញុំព្រះករុណាទាំងឡាយសូមវេរ (នូវភត្តមានប្រការនេះជាឈ្មោះ) នេះព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធ ជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ សម្គាល់ (នូវភត្តមានប្រការនេះជាឈ្មោះ) នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួចរដោះចាកទុក្ខទាំងពួង ឱ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ សម្បត្តិទេវតា ១ សម្បត្តិ

ព្រះនិព្វាន ១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហួរជូនទៅមិនដាច់នេះហោង ។.... អស់វារៈ ២ ដងផង ។...... អស់វារៈ ៣ ដងផង ។

## បើវេរចតុប្បច្ច័យ ជាសង្ឃទាន ថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ....។ តតិយម្បិ......។**

ប្រែថាៈបពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ ខ្ញុំព្រះករុណាទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកតម្កល់ ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ......អស់វារៈ ២ ដងផង ។ .....អស់វារៈ ៣ ដងផង ។

## បើវេរចតុប្បច្ច័យដល់ភិក្ខុមួយអង្គថាដូច្នេះ

**មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។ ទុតិយម្បិ...។ តតិយម្បិ..។**

ប្រែថា ៖ បពិត្រព្រះករុណាដ៏ចម្រើនអ្ហើយ ខ្ញុំព្រះករុណា ទាំងឡាយ បាននាំមកនូវបច្ច័យទាំងឡាយ ៤ នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះករុណា ដ៏មានអាយុ បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា ទទួលយក នូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៏ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះករុណា ទាំងឡាយ អស់កាលជាអង្វែងទៅហោង។.....អស់វារៈ ២ ដងផង។ ......អស់វារៈ ៣ ដងផង។

## វេរកឋិនទានដល់ព្រះសង្ឃថាដូច្នេះ

**ឥមំ ទុស្សំ (វត្ថំ) កឋិនចីវរំ សង្ឃស្ស ទេម ។ ទុតិយម្បិ....។ តតិយម្បិ.....។**

ប្រែថា៖បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអ្ហើយ ខ្ញុំព្រះករុណា ទាំងឡាយ សូមវេរនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ

ប្រគេនដល់ព្រះសង្ឃ ។...អស់វារៈ ២ ដងផង ។... អស់វារៈ ៣ ដងផង ។

ឬនឹងវេរថា : **ឥមំ កឋិនចីវរំ សង្ឃស្ស ទេម** ដូច្នេះក៏បាន សេចក្ដីប្រែដូចគ្នា "សូមវេរនូវកឋិនចីវរ ប្រគេនដល់ព្រះសង្ឃ" ។

## វេរគ្រឿងបរិក្ខារជាបរិវារកឋិនថាដូច្នេះ

**យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសង្សានិ តស្សេវ ទេមឌ ទុតិយម្បិ....ឌ តតិយម្បិ....ឌ**

ប្រែថា : បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ រីកឋិននៃខ្ញុំព្រះករុណាទាំងឡាយ គឺលោកម្ចាស់អង្គណាបានទទួលកាន់មក (១) ហើយខ្ញុំព្រះករុណាទាំងឡាយសូមវេរនូវគ្រឿងបរិក្ខារ ជាបរិវារនៃកឋិនទាំងឡាយ ប្រគេនលោកម្ចាស់អង្គនោះ ។.........អស់វារៈ ២ ដងផង ។....អស់វារៈ ៣ ដងផង ។

សំពត់៧ប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាត្តទុកឱ្យជាសំពត់សមណបរិក្ខារនោះ គឺសំពត់ត្រៃចីវរ ១ សំពត់សម្រាប់ងូតទឹកភ្លៀង ១ សំពត់សម្រាប់ទ្រាប់អង្គុយ ១ សំពត់សម្រាប់ក្រាលជាកម្រាល ១ សំពត់

សម្រាប់គ្របបូស ឬ គ្របដំបៅ ១ សំពត់សម្រាប់ជូតមុខ គឺកន្សែង ១ សំពត់តូច ឬធំជាប្រមាណហៅថា សំពត់បរិក្ខារចោឡៈ ១ បញ្ចូលសំពត់សម្រាប់ត្រង់ទឹក ១ សំពត់ចំណាំវស្សា ១ និងសំពត់អច្ចេកចីវរ ១ថែមទៀត ជា ១០ ។

សំពត់ទាំង ១០ប្រការនេះ បើទាយកមានប្រាថ្នានឹងវេរសំពត់ណាមួយដល់សង្ឃ តែសំពត់នោះមានតែ ១ត្រៃ ឬ

(១) បានទទួលកាន់យកហើយ

១ ផ្ទត់ ត្រូវឱ្យដាក់ឈ្មោះសំពត់នោះជា បាលីឯកវចនៈ បញ្ចូល វេរដូចមានសំណៅទុកបែបខាងមុខនេះទាំង ១០ ប្រការគឺ ។

**១~ ឥមំ តិចីវរំ** នូវត្រៃចីវរនេះ ។

**២~ ឥមំ វស្សិកសាដកំ** នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ ។

**៣~ ឥមំ និសីទនំ** នូវសំពត់សម្រាប់ទ្រាប់អង្គុយនេះ ។

**៤~ ឥមំ បច្ចត្ថរណំ** នូវសំពត់សម្រាប់ក្រាលនេះ ។

**៥~ ឥមំ កណ្ឌុប្បដិច្ឆាទិ** នូវសំពត់សម្រាប់គ្របបូស ឬ គ្របដំបៅនេះ ។

**៦~ ឥមំ មុខបុញ្ឆនចោឡំ** នូវសំពត់សម្រាប់ជូតមុខ គឺ កន្សែងនេះ ។

**៧~ ឥមំ បរិក្ខារចោឡំ** នូវសំពត់តូចឬធំជាប្រមាណ ជាបរិក្ខារនេះ ។

**៨~ ឥមំ បរិសាវនំ** នូវសំពត់សម្រាប់ត្រងទឹកនេះ ។

**៩~ ឥមំ វស្សាវាសិកំ** នូវសំពត់ចំណាំវស្សានេះ ។

**១០~ ឥមំ អច្ចេកចីវរំ** នូវសំពត់អច្ចេកចីវរនេះ ។

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការវេរប្រគេននូវសំពត់ណាមួយ ឱ្យយកឈ្មោះសំពត់ដែលមានសំណៅជាបែបទុកនុ៎ះ មកដាក់លើបាលីដែលសម្រាប់សូធ្យវេរត្រង់កន្លែងដែលមានវង់ក្រចកស្រាប់ហើយនោះ ។

## វេរត្រៃចីវរថា

**មយំ ភន្តេ ឥមំ (តិចីវរំ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមំ (តិចីវរំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ១ ទុតិយម្បិ...១តតិយម្បិ....១**

ប្រែថា៖ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើ្ហយ ខ្ញុំព្រះករុណាទាំងឡាយ បាននាំ(នូវត្រៃចីវរ)នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក (នូវត្រៃចីវរ)នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ......អស់វារៈ ២ ដងផង ។ ........អស់វារៈ ៣ ដងផង ។

សំពត់ទាំង ១០ ប្រការនេះ បើប្រាថ្នានឹងវេរសំពត់ណាមួយដល់ព្រះសង្ឃ តែសំពត់នោះមានច្រើនត្រៃឬច្រើនផ្ទត់ ត្រូវយកឈ្មោះបាលីនេះជាបាលីពហុវចនៈ មកដាក់បញ្ចូលវេរ ដូចមានសំណៅជាបែបទុកនៅខាងក្រោមនេះស្រាប់៖

**១~ ឥមានិ តិចីវរានិ** នូវសំពត់ត្រៃចីវរ ទាំងឡាយនេះ ។

**២~ ឥមានិ វស្សិកសាដិកាយោ** នូវសំពត់សំរាប់ងូតទឹកភ្លៀង ទាំងឡាយនេះ ។

**៣~ ឥមានិ និសីទនានិ** នូវសំពត់សំរាប់ទ្រាប់អង្គុយទាំងឡាយនេះ ។

៤~ **ឥមានិ បច្ចត្ថរណានិ** នូវសំពត់កម្រាល ទាំងឡាយនេះ ។

៥~ **ឥមានិ កណ្ឌុប្បដិច្ឆាទីនិ** នូវសំពត់សម្រាប់គ្រប់បូស ឬដំបៅទាំងឡាយនេះ ។

៦~ **ឥមានិ មុខបុញ្ឆនចោឡានិ** នូវសំពត់សម្រាប់ជូតមុខទាំងឡាយនេះ ។

៧~ **ឥមានិ បរិក្ខារចោឡានិ** នូវសំពត់បរិក្ខារចោឡៈទាំងឡាយនេះ។

៨~ **ឥមានិ បរិសាវនានិ** នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយនេះ ។

៩~ **ឥមានិ វស្សាវាសិកាយោ** នូវសំពត់ចំណាំវស្សាទាំងឡាយនេះ ។

១០~ **ឥមានិ**(១) **អច្ចេកចីវរានិ** នូវសំពត់អច្ចេកចីវរទាំងឡាយនេះ ។

ឯសំពត់ទាំង ១០ប្រការនេះ បើត្រូវការវេរសំពត់ណា

(១) "ឥមំ" ឬ "ឥមា,ឥមានិ" ប្រែថា "នេះ" ជាពាក្យចង្អុលរបស់ដែលនៅក្នុងហត្ថបាសនៃទាយកអ្នកវេរ , បើរបស់នៅក្រៅហត្ថបាសរបស់អ្នកវេរ ត្រូវថា "ឯតំ,ឯតា,ឯតានិ" ប្រែថា "នុ៎ះ" ។

មួយ ឱ្យយកឈ្មោះសំពត់នោះ មកដាក់ជាបាលីសម្រាប់សូធ្យវេរខាងមុខនោះចុះ ត្រង់កន្លែងដែលមានវង់ក្រចកស្រាប់ ។

## សំពត់សម្រាប់ងូតទឹកភ្លៀងថា

**មយំ ភន្តេ ឥមា (វស្សិកសាដិកាយោ) ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមា (វស្សិកសាដិកាយោ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ.....។ តតិយម្បិ......។**

ប្រែថា:បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអ្ហើយខ្ញុំព្រះករុណាទាំងឡាយ បាននាំ (នូវសំពត់សម្រាប់ងូតទឹកភ្លៀង ទាំង-ឡាយ)នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក (នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយ)នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះករុណាទាំងឡាយ

អស់កាលជាអង្វែងទៅហោង។...អស់វារៈ ២ ដងផង។ .........អស់វារៈ ៣ ដងផង។

# វេរសង្ឃទានថា

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សជ្ជេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ.....។ តតិយម្បិ.....។**

ប្រែថា : បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើ្ហយ ខ្ញុំព្រះ-ករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មាន ខាទនីយ និងភោជនីយាហារ គឺបង្អែម និងចង្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ពែងសង្ឃ ដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវវត្ថុទាំងឡាយ មាន បង្អែម និង ចង្អាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណា ទាំង-ឡាយ អស់កាលជាអង្វែងទៅហោង ។........អស់វារៈ ២ ដងផង ។.....អស់វារៈ ៣ ដងផង ។

## វេរគណទានថា

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានីនិ សង្ឃេត្វា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយភោជនីយានីនិ បដិគ្គណ្ហន្តុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។ ទុតិយម្បិ.....។ តតិយម្បិ......។**

ប្រែថា : បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើនអើ្ហយ ខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយ និងភោជនីយាហារ គឺបង្អែមនិងចង្អាបជាដើម នេះ ហើយវេរប្រគេនដល់លោកម្ចាស់អ្នកមានសីល ទាំងឡាយ បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន សូម លោកម្ចាស់ អ្នកមានសីលទាំងឡាយ ទទួលយកនូវវត្ថុ ទាំងឡាយ មានបង្អែបនិងចង្អាបជាដើមនេះ ដើម្បីសេចក្តី ចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំ ព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

...អស់វារៈ ២ ដងផង ។ .......អស់វារៈ ៣ ដងផង ។

## វេរបាដិបុគ្គលិកទានថា

**មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានីនិ សង្ឃេត្វា សីលវតោ ទេម សាធុ ភន្តេ សីលវា**

**ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ.....។ តតិយម្បិ......។**

ប្រែថា ៖ បពិត្រព្រះករុណាដ៏ចម្រើនអើ្ហយ ខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មាន ខាទនីយ និងភោជនីយាហារ គឺបង្អែម និងចង្អាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះករុណា បពិត្រព្រះករុណាដ៏ចម្រើន សូមលោកអ្នកមានសីល ទទួលយកនូវវត្ថុទាំងឡាយ មាន បង្អែម និងចង្អាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង។......អស់វារៈ ២ ដងផង។ .....អស់វារៈ ៣ ដងផង។

## វេរអង្ករដល់ព្រះសង្ឃថា

**មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ តណ្ឌុលានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ៕ ទុតិយម្បិ...៕ តតិយម្បិ..៕**

ប្រែថា ៖ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ ខ្ញុំព្រះ-ករុណាទាំងឡាយ បាននាំមកនូវអង្ករទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក នូវអង្ករ ទាំងឡាយនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៏ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។.........អស់វារៈ ២ ដងផង ។ ...........អស់វារៈ ៣ ដងផង ។

## វេរផ្លែឈើផ្សេងៗថា

**មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សង្ឃស្ស ទេម សាធុ ភន្តេ សង្ឃោ ឥមានិ នានាផលានិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ៕ ទុតិយម្បិ.....៕ តតិយម្បិ.......៕**

ប្រែថា : បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើ្ហយ ខ្ញុំព្រះ-ករុណាទាំងឡាយ បាននាំមកនូវផ្លែឈើផ្សេងៗទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយកនូវផ្លែឈើផ្សេងៗទាំងឡាយនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ .....អស់វារៈ ២ ដងផង ។..........អស់វារៈ ៣ ដងផង ។

## វេរគ្រឿងសេនាសនៈតទៅ
## បើវេររោងឧបោសថគឺ វិហារថា

**មយំ ភន្តេ ឥមំ (ឧបោសថាគារំ) ការេត្វា ឧបោសថបវារណាទិសង្ឃកម្មករណត្ថាយ ចាតុ-ទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (ឧបោសថាគារំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ.......។ តតិយម្បិ......។**

ប្រែថា:បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើ្ហយ ខ្ញុំព្រះករុណាទាំងឡាយបានចាត់ចែងធ្វើ (នូវរោងសម្រាប់ធ្វើនូវឧបោសថ) នេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ

ដែលមកពីទិសទាំងបួន ដើម្បីប្រយោជន៍ដល់កិរិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្ម និងបវារណាកម្ម ជាដើម បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃទទួលយក (នូវរោងសម្រាប់ធ្វើនូវឧបោសថ) នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះកុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។.....អស់វារៈ ២ ដងផង ។ ......អស់វារៈ ៣ ដងផង ។

## បើវេរសាលាថា

**ឥមំ សាលំ** នូវសាលានេះ ។

## បើវេរកប្បិយកុដិថា

**ឥមំ កប្បិយកុដឹ** នូវកប្បិយកុដិនេះ ។

## បើវេរកុដិតូច ឬ តូប ថា

**ឥមំ កុដឹ** នូវកុដិតូច ឬ នូវតូបនេះ ។

## បើវេរកុដិធំថា

**ឥមំ វិហារំ** នូវកុដិធំនេះ ។

## បើវេរបង្គន់ថា

**ឥមំ វច្ចកុដឹ** នូវបង្គន់នេះ ។

បើប្រាថ្នាវេរសាលាក្ដី កប្បិយកុដិក្ដី កុដិតូចឬតូបក្ដី កុដិធំក្ដី បង្គន់ក្ដី ទាំង ៥ យ៉ាងនេះ នឹងវេររបស់ណាមួយ ឱ្យយក

ឈ្មោះរបស់នោះ ទាំងបាលីទាំងសម្រាយ មកដាក់ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូធ្យវេរចុះ ។

## វេរគរុភណ្ឌថា

**មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ.....។ តតិយម្បិ.....។**

ប្រែថា:បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ ខ្ញុំព្រះករុណាទាំងឡាយ បាននាំមកនូវគរុភណ្ឌនេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយកនូវគរុភណ្ឌនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង។
........អស់វារៈ ២ ដងផង ។.......អស់វារៈ ៣ ដងផង ។

## វិធីវេរគ្រឿងភេសជ្ជៈ
## បើវេរទឹកឃ្មុំថា

**មយំ ភន្តេ ឥមំ (មធុំ) ឥធានេត្វា ភិក្ខុសង្ឃស្ស ទេម សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ (មធុំ) បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ**

**ហិតាយ សុខាយ ៗ ទុតិយម្បិ..ៗ តតិយម្បិ..ៗ**

ប្រែថា:បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ ខ្ញុំព្រះករុណាទាំងឡាយ បាននាំ(នូវទឹកឃ្មុំ)នេះ មកតម្កល់ទុកក្នុងទីនេះ សូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃទទួលយក(នូវទឹកឃ្មុំ)នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ ....អស់វារៈ ២ ដងផង ។.....អស់វារៈ ៣ ដងផង ។

## បើវេរប្រេងថា

**ឥមំ តេលំ** នូវប្រេងនេះ ។

## បើវេរទឹកអំពៅថា

**ឥមំ ផាណិតំ** នូវទឹកអំពៅនេះ ។

## បើវេរទឹកត្នោតថា

**ឥមំ តាលោទកំ** នូវទឹកត្នោតនេះ ។

## បើវេរថ្នាំរម្ងាប់រោគថា

**ឥមំ គិលានភេសជ្ជំ** នូវថ្នាំសម្រាប់រក្សានូវមនុស្ស ឈឺនេះ ។

បើប្រាថ្នានឹងវេរប្រេងក្តី ទឹកអំពៅក្តី ទឹកត្នោតក្តី ថ្នាំរក្សានូវជម្ងឺក្តី ទាំងបួននេះរបស់ណាមួយ ឱ្យយកឈ្មោះរបស់នោះ ទាំងបាលី ទាំងសម្រាយមកដាក់ត្រង់កន្លែង វង់ក្រចកនោះ ហើយសូធ្យវេរចុះ ។

## វិធីវេរបច្ច័យទាំងបួនប្រការ
## ចប់ដោយសង្ខេបតែប៉ុណ្ណេះ

## បរិត្តភាសនាយាចនគាថា
## ពាក្យអារាធនាព្រះភិក្ខុសង្ឃសូមឱ្យចម្រើនព្រះបរិត្ត

**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ ៗ**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ ៗ**
**វិបត្តិប្បដិពាហាយ សព្វសម្បត្តិសិទ្ធិយា**
**សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ៗ**

ប្រែថា: សូមព្រះករុណាទាំងឡាយ ចម្រើននូវព្រះបរិត្តជាជ័យមង្គល ដើម្បីនឹងការពារបញ្ចៀសនូវវិបត្តិ គឺសេចក្តី - អន្តរាយទាំងពួង ដើម្បីនឹងឱ្យសម្រេចនូវ សម្បត្តិគ្រប់យ៉ាង

ដើម្បីនឹងញុំាង { ទុក្ខ / ភ័យ / រោគ } ទាំងអស់ឱ្យវិនាសបាត់ទៅ ។

លុះលោកអាចារ្យអារាធនានិមន្តដូច្នេះហើយ ព្រះសង្ឃអ្នកចម្រើនព្រះបរិត្តនោះ ត្រូវសូធ្យធម៌"សគ្គេ កាមេ ។ល។ អយម្ភទន្តា" ប្រកាសអញ្ជើញពពួកទេវតារួចហើយ ទើបចំរើនព្រះបរិត្ត ជាពុទ្ធមន្តតាមគួរដល់ពុទ្ធានុញ្ញាតក្នុងខុទ្ទកវត្ថុក្ខន្ធកៈ ក្នុងព្រះវិន័យ ។

## ទេវតាបកាសនគាថា

## ពាក្យប្រកាសអញ្ជើញពពួកទេវតា

**សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្តលិក្ខេ វិមានេ ទីបេ រដ្ឋេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ ៚**

**ធម្មស្សវនកាលោ អយម្ភទន្តា ធម្មស្សវន-កាលោ អយម្ភទន្តា ធម្មស្សវនកាលោ អយម្ភ-ទន្តា ៕**

ប្រែថា : ទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភព និង រូបភពក្តី ភុម្មទេវតាទាំងឡាយដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ពួដ៏អាកាសក្តី នៅនាកោះ និងដែន និងស្រុកក្តី នៅនាដើមព្រឹក្សា និង ព្រៃញៀតស្បាត ឬទីស្រែចំការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយ ដែលស្ថិតនៅនាទីទឹកទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតក្តី សូមអញ្ជើញមកជួបជុំគ្នា (ក្នុងទីនេះ) ពាក្យឯណាដែលជាពាក្យព្រះសក្យមុនីដ៏ប្រសើរ (ដែលយើងនឹងសូធ្យឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយចូរស្តាប់នូវពាក្យនោះ(ដោយគោរព) ។

**ធម្មស្សវនកាលោ អយម្ភទន្តា** បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះជាវេលាគួរនឹងស្តាប់នូវព្រះធម៌ (ត្រូវសូធ្យបីដង) ។

## ធម្មទេសនាយាចនគាថា

## ពាក្យសូធ្យអារាធនាលោកអ្នកសម្តែងធម៌

ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អន្ធិវរំ អាយាចថ
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។
សទ្ធម្មតើរំ វិនយញ្ច កាយំ
សុត្តញ្ច ពន្ធំ អភិធម្មចម្មំ
អាកោដយន្តោ ចតុសច្ចទណ្ឌំ
បញ្ចេធ នេយ្យេ បរិសាយ មជ្ឈេ ។
ឯវំ សហម្បតី ព្រហ្មា ភគវន្តំ អាយាចថ
តុណ្ហីភាវេន តំ ពុទ្ធោ ការុញ្ញេនាធិវាសយ
តម្ហា វុដ្ឋាយ ឋានេន មិគទាយំ គតោ គតោ
បញ្ចវគ្យាទយោ នេយ្យេ អមំ ឋាយេសិ
ធម្មតោ តតោ បភូតិ សម្ពុទ្ធោ អនូនា
ធម្មទេសនំ មាយវស្សានិ ទេសេសិ សត្តានំ
អត្ថសិទ្ធកំ ។ តេន សាធុ អយ្យោ ភន្តេ
ទេសេតុ ធម្មទេសនំ សព្វាយិធ បរិសាយ
អនុកម្បម្បិកាតវេ ។

គ្រានោះសហម្បតី ព្រហ្មជាឥសូរលោកា ចូលគាល់ព្រះសាស្តា លើកហត្ថាសិរោរាប ។ ហើយពោលពាក្យទូលថា សូមករុណាស្តេចទ្រង់ជ្រាប ដ្បិតសត្វអន់ទន់ទាប ទុព្វលភាពបាបក្រៃក្រាស់ ។ ទន្ទឹងព្រះធម៌ថ្លៃ ជានិស្ស័យបច្ច័យច្បាស់ ឥឡូវទ្រង់បានត្រាស់ ត្រេកអរណាស់ពុំកន្តើយ ។ សត្វខ្លះក្រាស់ដោយកាម មិនយល់តាមត្រៃលក្ខណ៍ឡើយ ឥឡូវយល់ខ្លះហើយ ដោយអំណាចព្រះមានបុណ្យ ។ បើបានស្តាប់ទេសនា បញ្ញាក្លាខ្លាំងលើសមុន សូមព្រះដ៏មានបុណ្យ ទ្រង់និមន្តប្រោសទេសនា ។ ប្រោសសត្វបំបាត់សោក ទាំងរាគរោគរូបតណ្ហា ងងឹតប្រែប្រជ្រះថ្លា កើតបញ្ញាភិយ្យោយល់ ។ ត្រៃលោកគោតត្រៃលក្ខណ៍ សង្សារចក្រវិលមិនដល់អវិជ្ជាជាឫសគល់ ជាបច្ច័យនៃសង្ខារ ។ នាំសត្វឱ្យសោកសៅ លិចលង់ទៅក្នុងសង្សារ បញ្ចមារមោហន្ធការ រឹតរុំហ៊ុមជុំជាប់នៅ ។ ហេតុនោះសូមព្រះអង្គ ប្រោសស្រោចស្រង់ដាក់សំពៅ ចម្លងសត្វឆ្ពោះទៅ កាន់ត្រើយត្រានិព្វាននាយ ។ ដូចកល់ប្រទីបធំ សាយត្រសុំភ្លឺព្រោងព្រាត បំភ្លឺសត្វទាំងឡាយ ឱ្យសប្បាយក្សាន្តភិរម្យ ។ ព្រះសទ្ធម្មជាស្តរជ័យ ព្រះវិន័យជារាងធំ ព្រះសូត្រជាខ្សែរុំ ព្រះអភិធម្មជាស្បែកដាស់ ។ អរិយសច្ចជាអន្លូង សម្រាប់ទូងឱ្យឮច្បាស់ សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។

បរិស័ទ៤ជំពូក ដូចផ្កាឈូកក្នុងជលដ្ឋាន ខ្លះផុសចាំ សូរ្យឆាន
រះនិងរីកដោយរស្មី ។ ព្រះធម៌ជាសូរ្យសែងរះឡើង ចែងចាំង
រង្សី បំភ្លឺលោកទាំងបី ឱ្យយល់ផ្លូវឋានសុខា ។

សហម្បតីព្រហ្ម ឱនបង្គំអារាធនា សម្តេចព្រះភគវា
ដោយគាថាយ៉ាងនេះឯង ។ ព្រះពុទ្ធទ្រង់អនុកូល ព្រមទទួល
នឹងសម្តែង ដោយតុណ្ហីភាពថ្លែង តាមភារៈគុណករុណា ។
ទើបក្រោកចាកទីនោះ ភក្ត្រាឆ្ពោះព្រៃមិគទា យាងចេញ
ចរលីលា ពីទីនោះដោយព្រះបាទ ។ ញាំងសត្វចូលពុទ្ធចក្រ
មានបញ្ចវគ្គីយ៍ជាអាទិ៍ ឱ្យផឹកអម្រឹតជាតិ រសនិព្វានតាម
ធម្មតា ។ ចាប់ផ្តើមពីនោះឯង ទ្រង់សម្តែងធម៌ទេសនា ធ្វើ-
ពុទ្ធក្រឹត្យា អស់វស្សាសែសិបប្រាំ ។ ពុំថយពុំបន្ធូរ
ប្រយោជន៍យូរអង្វែងឆ្នាំ សម្រេចបុញ្ញកម្ម ដល់សព្វសត្វ
ទាំងភពត្រ័យ ។

ហេតុនុ៎ះឥឡូវនេះ យើងខ្ញុំនេះសាទរក្រៃ បពិត្រព្រះ
ករុណាថ្លៃ សូមនិមន្តប្រោសទេសនា ។ អនុគ្រោះពួកបរិស័ទ
ដែលជាប់ខាត់ ដោយមោហា ឱ្យកើតមានបញ្ញា ប្រាកដនាទី
នេះហោង ។

## សុខាភិយាចនគាថាសង្ខេប

**បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ**
**សម្មាធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ**
**វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ**
**មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ**
**ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា ។**

ប្រែថា : **បសន្នា ហោន្តុ សព្វេបិ បាណិនោ ពុទ្ធសាសនេ** សត្វទាំងឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា **សម្មាធារំ បវេច្ឆន្តោ កាលេ ទេវោ បវស្សតុ វុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ** សូមឱ្យភ្លៀងបង្អុរនូវធារទឹកដ៏ប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្ដាលឱ្យផែនដីសិរីទ្ធិ គឺថាឱ្យមានជីជាតិល្អឡើង ដើម្បីឱ្យកើតសេចក្ដីចម្រើនដល់សត្វទាំងឡាយ **មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ** មាតាក្ដី បិតាក្ដី បីបាច់រក្សាជានិច្ចនូវកូនតូច ជាកូនបង្កើត យ៉ាងណាមិញ **ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា** សូមព្រះបរមក្សត្រទាំងឡាយ រក្សានូវ

ប្រជាជនតាមគន្លងធម៌ ដូចជាមាតាបិតា បីបាច់កូនដូច្នោះ ឱ្យបានសព្វកាលទៅហោង ។

**សូធ្យនៅពេលចប់ធម៌ទេសនា ឬ ចប់ព្រះបរិត្ត**

# បំភ្លឺសេចក្ដីក្នុងគិហិប្រតិបត្តិ

(ដោយព្រះវិន័យធរ **ឯក ញ៉ឹម**)

## ប្រស្នាពុទ្ធគុណ

**១~ អរហំ** ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសិកសត្រូវ ពោលគឺ កិលេស ព្រមទាំងវាសនា គឺ កាយបយោគ និងវចីបយោគ។

**សួរថា** : ព្រះនាម អរហំ នេះ ហៅបានតែព្រះសព្វញ្ញុពុទ្ធមួយព្រះអង្គទេ ឬព្រះអរហន្ត ទាំងអស់ហៅបានដែរ?

**ឆ្លើយថា** : ព្រះនាម អរហំ នេះ ហៅបានតែព្រះសព្វញ្ញុពុទ្ធមួយអង្គទេ ព្រោះព្រះអង្គបានលះបង់វាសនា និងបយោគបាន ឯព្រះអរហន្តដទៃៗលះបង់មិនទាន់បាន ដូចជាព្រះសារីបុត្ត នៅជាប់កាយបយោគ ព្រះកច្ចាយនៈនៅជាប់វចីបយោគជាដើម។

**ស~** ព្រះនាមទាំង ១០ មាន អរហំ ជាដើមនេះ មានទូទៅគ្រប់ព្រះសព្វញ្ញុពុទ្ធទាំងអស់ឬអ្វី?

**ឆ~** ព្រះនាមទាំង ១០ មាន អរហំ ជាដើមនេះ មានទូទៅគ្រប់ព្រះសព្វញ្ញុពុទ្ធទាំងអស់ ព្រោះព្រះសព្វញ្ញុពុទ្ធទាំង-ឡាយ តែងប្រកបដោយគុណ មាន អរហំ ជាដើមនេះ។

**ស.** ព្រះនាមទាំង ១០ នេះ អ្នកណាថ្វាយដល់ព្រះអង្គ ?

**ឆ.** នេមិត្តិកនាម នាមកើតឯងដោយគុណនៃព្រះអង្គ ។

**ស.** កិលេសគឺអ្វី? ចូររាប់ខ្លះមកមើល ?

**ឆ.** កិលេសគឺ សេចក្តីសៅហ្មងរបស់ចិត្ត ដែលកើតអំពីអកុសលធម៌ទាំងពួង មានលោភៈ ទោសៈ មោហៈជាដើម ។

**ស.** វាសនាគឺអ្វី? ប្រែជាសេចក្តីថាដូចម្តេច ?

**ឆ.** វាសនាគឺ លំនៅ ឬលំនាំនៃចិត្តប្រែថា កន្លែងដែលចិត្តធ្លាប់អាស្រ័យ ឬធ្លាប់ប្រកបមកច្រើនជាតិណាស់ហើយកើតជាទម្លាប់នាំចិត្តឱ្យល្អិតទៅឯង ។

**ស.** បយោគគឺអ្វី ? ប្រែសេចក្តីថាដូចម្តេច ?

**ឆ.** បយោគគឺការប្រកប ប្រែថា សេចក្តីប្រកបរបស់ចិត្តដែលអាស្រ័យកាយនិងវាចា បើចិត្តប្រកបការមកនឹងកាយហៅថា កាយបយោគ បើចិត្តប្រកបការមកនឹងវាចា ហៅថា វចីបយោគ ។

**ស.** កាយគឺអ្វី? មានសេចក្តីអធិប្បាយថាដូចម្តេច ?

**ឆ.** កាយមាន ២ យ៉ាង គឺ ភូតកាយ ១ នាមកាយ ១ ។

**ស.** ភូតកាយគឺអ្វី? ចូររាប់គោលសេចក្តីខ្លះមកមើល!

**ឆ~** ភូតកាយគឺ ដី-ទឹក-ភ្លើង-ខ្យល់ ដែលហៅថា ចតុភូតរូប ឬហៅថា មហាភូតរូប ៤ ន័យខ្លះហៅថា ករជកាយ ទីប្រជុំធូលី គឺ សម្ភារភាគនៃមាតាបិតា ដែលបង្កើតបានជាបុត្រធីតា ។

**ស~** នាមកាយគឺជាឈ្មោះនៃធម៌អ្វី?

**ឆ~** នាមកាយ គឺឈ្មោះនៃធម៌គ្មានរូប មានចិត្តជាដើម ។

**ស~** វាចាឬវចីគឺអ្វី?ចូរទាញគោលខ្លះមកពន្យល់ខ្លីៗមើល ?

**ឆ~** វាចាក្តី វចីក្តី គឺសំដីពាក្យពោល ឬនិយាយឱ្យលាន់ឮ - ឡើង ជាបុណ្យខ្លះ ជាបាបខ្លះ ជាបុណ្យដូចសំដីថា យើងត្រូវនាំគ្នាធ្វើទាន សីល ភាវនា បើបាបដូចជា សំដីភូតកុហក ញុះញង់ស៊កសៀត ជេរបញ្ចោ ផ្ដុកកំប្លែងជាដើម ។

**២~ សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

**ស~** ញេយ្យធម៌គឺធម៌អ្វី? ចូររាប់គោលខ្លះមកមើល!

**ឆ~** ញេយ្យធម៌នោះ គឺធម៌ដែលបុគ្គលគប្បីដឹងមានខ័ន្ធ ៥ និង ធាតុ ៤ អាយតនៈ ១២ ឥន្ទ្រិយ៍ ៥ ជាដើម ។

**ស~** ខន្ធ ៥ នោះប្រែដូចម្តេច ? គឺអ្វីខ្លះ ?

**ឆ~ បញ្ចខន្ធា** ខន្ធ ៥ នោះប្រែថាគំនរ ៥ គឺ គំនររូប ១ គំនរវេទនា១ គំនរសញ្ញា១ គំនរសង្ខារ១ គំនរវិញ្ញាណ១ ។

**ស~** ចុះធាតុ ៤ នោះ ប្រែថាដូចម្តេច ? គឺអ្វីខ្លះ ?

**ឆ~ ចតុធាតុ ឬ ចតុភូត** ប្រែថា ធាតុ ៤ ឬ ភូត ៤ គឺ សភាវទ្រទ្រង់ទុកនូវសត្វ ឬកើតប្រាកដគឺដី ១ ទឹក ១ ភ្លើង ១ ខ្យល់ ១។

**ស~** ចុះអាយតនៈ ១២ ប្រែថាដូចម្តេច? គឺអ្វីខ្លះ ?

**ឆ~ ទ្វាទសាយតនានំ** ប្រែថា អណ្តូង ១២ ឬ ប្រឡាយ ១២ គឺកន្លែងជាទីកើតនៃអារម្មណ៍ហៅថា អាយតនៈ។នោះ ខាងក្នុងមាន ៦ គឺ ភ្នែក ១ ត្រចៀក ១ ច្រមុះ ១ អណ្តាត ១ កាយ ១ ចិត្ត ១។ ខាងក្រៅមាន ៦ គឺ **:**

រូប ១ សំឡេង ១ ក្លិន ១ រស ១ សម្ផស្ស ១ ធម៌ ១ (រួមជា ១២) អាយតនៈទាំង ១២ នេះ កើតឡើងជាគូ។ នឹងគ្នា។

**ស~** ឥន្ទ្រិយ៍ ៥ នោះ ប្រែថាដូចម្តេច ? គឺអ្វីខ្លះ ?

**ឆ~ បញ្ចិន្ទ្រិយានិ** ប្រែថា ធម្មជាតិជាធំ ៥ យ៉ាងដោយឡែក។ពីគ្នាហៅថា ឥន្ទ្រិយ៍ គឺភ្នែកធំខាងការឃើញរូប ១ ត្រចៀកធំខាងការឮសំឡេង ១ ច្រមុះធំខាងការធុំ

ក្លិន ១ អណ្តាតធំខាងការដឹងរស ១ កាយធំខាងការដឹងសម្ផស្ស ១ ( រួមជា ៥ ) ។

**៣~ វិជ្ជាចរណសម្បន្នោ :** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និង វិជ្ជា ៨ និងចរណៈ ១៥ ។

**ស~** វិជ្ជា ៣ គឺអ្វីខ្លះ? ចូររាប់ជាបាលីជាគោលអាងមកផង!

**ឆ~ បុព្វេនិវាសានុស្សតិញ្ញាណ :** ប្រាជ្ញារលឹកតាមឃើញច្បាស់ នូវបញ្ចក្ខន្ធ ដែលខ្លួនធ្លាប់អាស្រ័យនៅហើយ ក្នុងភពមុន ១ **ចុតូបបាតញ្ញាណៈ** ប្រាជ្ញាឃើញច្បាស់នូវចុតិនិងបដិ-សន្ធិនៃសត្វ ១ **អាសវក្ខយញ្ញាណៈ** ប្រាជ្ញាឃើញច្បាស់ នូវធម៌ជាគ្រឿងធ្វើឱ្យអស់ទៅនៃអាសវៈ ១ ( រួមជា៣ ) ។

**ស~** ចុះវិជ្ជាទាំង ៨ នោះ គឺវិជ្ជាអ្វីខ្លះ ? ចូររាប់ឈ្មោះឱ្យគ្រប់មកមើល !

**ឆ~** វិជ្ជា ៨ នោះ គឺ**បុព្វេនិវាសានុស្សតិញ្ញាណៈ** ប្រាជ្ញារលឹកតាមឃើញច្បាស់ នូវបញ្ចក្ខន្ធ ដែលខ្លួនធ្លាប់អាស្រ័យនៅហើយក្នុងភពមុន ១ **ចុតូបបាតញ្ញាណៈ** ប្រាជ្ញាឃើញច្បាស់នូវចុតិនិងបដិសន្ធិនៃសត្វ ១ **អាសវក្ខយញ្ញាណៈ** ប្រាជ្ញាពិចារណាឃើញច្បាស់ក្នុងសង្ខារ ១ **មនោមយិទ្ធិ** ឫទ្ធិ

សម្រេចដោយចិត្ត ១ **ឥទ្ធិវិធិ** ឫទ្ធិសម្រេចដោយអធិដ្ឋាន ១ **ទិព្វសោត** ព្រះសោតទិព្វ អាចឮសម្លេងក្នុងទីឆ្ងាយបាន ១ **ចេតោបរិញ្ញាណៈ** កំណត់ដឹងចិត្តរបស់អ្នកដទៃបាន ១ ( រួមជា ៨ ) ។

**ស~** ចុះចរណៈ ១៥ នោះគឺអ្វីខ្លះ? ចូររាប់ឱ្យគ្រប់មកមើល!

**ឆ~** ចរណៈ ១៥ នោះគឺ **សីលសំវរ** សង្រួមកាយនិងវាចាឱ្យរៀបរយ១ **ឥន្ទ្រីយសំវរ** សង្រួមឥន្ទ្រីយ៍ទាំង ៦ ឱ្យល្អ ១ **ភោជនមត្តញ្ញុតា** ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ **ជាគរិយានុយោគ** ប្រកបក្នុងការភ្ញាក់រលឹកនឹកឃើញរឿយៗ ១

**សទ្ធា** ជឿហេតុដែលគួរជឿ ១
**ហិរិ** សេចក្តីខ្មាសបាបអំពើទុច្ចរិត ១
**ឱត្តប្ប** សេចក្តីតក់ស្លុតខ្លាចបាបអំពើទុច្ចរិត ១
**ពាហុសច្ច** ភាពនៃខ្លួនជាពហុស្សូត្រ ១
**វិរិយ** សេចក្តីព្យាយាម ១
**សតិ** សេចក្តីរលឹកបាន ១
**បញ្ញា** សេចក្តីដឹងត្រូវ ១

**បឋមជ្ឈាន**: ឈានទី ១ លះនីវរណ ៥ គឺកាមឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ , ឧទ្ធច្ចកុក្កុច្ចៈ , វិចិកិច្ឆា ហើយប្រកបដោយអង្គ ៥ គឺវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ១

**ទុតិយជ្ឈាន**: ឈានទី ២ លះវិតក្កៈ វិចារៈ ប្រកបដោយបីតិ សុខៈ ឯកគ្គតា ១

**តតិយជ្ឈាន**:ឈានទី ៣ លះបីតិ ប្រកបដោយ សុខៈ ឯកគ្គតា ១

**ចតុត្ថជ្ឈាន**: ឈានទី ៤ លះ សុខៈ ប្រកបដោយឯកគ្គតា ឧបេក្ខា ១ (រួមជាចរណ ១៥) ។

**៤~ សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតមហានិព្វាន ។

**ស~** អមតមហានិព្វាន គឺអ្វី? ចូរប្រែប្រាប់មកមើល!

**ឆ~** គឺជាឈ្មោះនៃធម៌និងទីកន្លែង ដែលរំលត់ភ្លើងទុក្ខ ភ្លើងកិលេសរបស់សត្វបានហើយ មិនមានស្លាប់ មិនមានកើតទៀត ប្រែថាទីរំលត់ទុក្ខដ៏ប្រសើរឈ្មោះថា អមតៈ មិនមានស្លាប់ឡើយ ។

**ស~** និព្វានមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~ និព្វាន** មាន ៣ យ៉ាងគឺ **កិលេសនិព្វាន** រំលត់ភ្លើងកិលេសអស់ឥតសេសសល់ ១ **ខន្ធនិព្វាន** រំលត់ភ្លើងទុក្ខក្នុងខន្ធអស់មិនមានសេសសល់ ១ **ធាតុនិព្វាន** រំលត់ព្រះធាតុអស់ឥតមានសេសសល់ ១ ( រួមជា ៣ ) ឬនឹងហៅថា **ឧបាទិសេសនិព្វាន អនុបា្បទិសេសនិព្វាន សឧបាទិសេសនិព្វាន** ដូច្នេះវិញក៏បាន ។

**ស~** ព្រះអរហន្តទាំងអស់ លោកនិព្វានដូចគ្នា ឬប្លែកគ្នាដែរ?

**ឆ~** លោកនិព្វានប្លែកគ្នាជាពីរយ៉ាង គឺព្រះអរហន្តខ្លះលោកនិព្វានតែកិលេសនិងខន្ធនៅសល់ព្រះធាតុ ព្រះអរហន្តអង្គខ្លះ លោកនិព្វានទាំងធាតុផង ។

**ស~** ចុះព្រះសម្ពុទ្ធជាម្ចាស់យើងនេះ ព្រះអង្គនិព្វានអ្វីខ្លះហើយ?

**ឆ~** ព្រះអង្គនិព្វានកិលេស និងខន្ធអស់ហើយ នៅសល់តែព្រះបរមសារីរិកធាតុប៉ុណ្ណោះ ដែលទុកឱ្យសត្វធ្វើសក្ការៈបូជា លុះព្រះពុទ្ធសាសនាគ្រប់ ៥.០០០ ព្រះវស្សានឹងនិព្វានព្រះធាតុថែមទៀត ។

**ស~** ព្រះអរហន្តមានប៉ុន្មានពួក ដែលគួរដល់ការចូលព្រះនិព្វានបាន ?

**ឆ~** ព្រះអរហន្ត ៣ពួកគឺ **សុខវិបស្សកោ** ១ **តេវិជ្ជោ** ១ **ចតុប្បដិសម្ភិទា** ១ ( រួមជា ៣ ពួក) ។

**៥~ លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាប ច្បាស់នូវត្រៃយលោក ។

**ស~** ត្រៃយលោកគឺអ្វី? ប្រែជាសេចក្តីដូចម្តេច?

**ឆ~** ត្រៃយលោកគឺលោក ៣ ប្រែថាសភាវចំរើនឡើងហើយវិនាសទៅវិញ។

**ស~** ចុះលោក៣នោះគឺលោកអ្វីខ្លះ?ចូររាប់គោលមកផង ?

**ឆ~** លោក៣នោះ **សង្ខារលោក**គឺ **នាម និងរូប** ១ **សត្តលោក**គឺពពួកសត្វ ១ **ឱកាសលោក**គឺវត្ថុដែលមិនមានវិញ្ញាណមានតែឈ្មោះទទេៗបានដល់អរូបធម៌ គឺអាកាស ១ ( រួមលោក ៣) ។

**ស~** ចុះដីទឹកភ្លើងខ្យល់ទាំង ៤ នេះហៅថាអ្វី? សង្គ្រោះចូលលោកណា ?

**ឆ**~ ដីទឹកភ្លើងខ្យល់ទាំង ៤ នេះហៅថា **ភាជនលោក**គឺជាភាជន សម្រាប់ដាក់សត្វ ឬ ទ្រទ្រង់ទុកនូវសត្វទាំងពួងលោកសង្គ្រោះចូលក្នុងសង្ខារលោក ។

**ស**~ ទេវតា មនុស្ស និងសត្វតិរច្ឆានទាំងអស់នេះ ហៅថាអ្វី? លោករាប់សង្គ្រោះចូលក្នុងលោកណា?

**ឆ**~ ទេវតា មនុស្ស និងសត្វតិរច្ឆានទាំងអស់នេះ ហៅថាសត្វលោក លោកសង្គ្រោះចូលក្នុង **សត្តលោក** ឬ **សង្ខារលោក** ។

**ស**~ ចុះអាកាស គឺទីវាល៧ទទេនេះ រាប់សង្គ្រោះចូល ក្នុងលោកណា ?

**ឆ**~ អាកាសគឺទីវាលទទេនេះ លោកសង្គ្រោះចូលក្នុងឱកាសលោក បើនឹងហៅថាលោកបីគឺ**ខន្ធលោក** ១ **ភាជនលោក** ១ **ឱកាសលោក** ១ ដូច្នេះវិញក៏បាន ។

**ស**~ ចុះលោកចំរើនឡើងដោយអ្វី? វិនាសទៅវិញដោយអ្វី?

**ឆ**~ ចំរើនឡើងដោយធាតុ ៤ វិនាសទៅវិញក៏ដោយធាតុ ៤ ដដែល ។

**៦~អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន។

**ស~** គុណរបស់ព្រះពុទ្ធជាម្ចាស់មានប៉ុន្មានយ៉ាងគឺអ្វីខ្លះ?

**ឆ~** គុណព្រះពុទ្ធមានច្រើនយ៉ាងណាស់ មាន២យ៉ាងគឺ **អត្តហិតគុណ** គុណជាប្រយោជន៏ដល់ព្រះអង្គ១ **បរហិតគុណ** គុណជាប្រយោជន៏ដល់សត្វដទៃ ១ (រួមជាគុណមាន ២យ៉ាង) គុណមាន ៣យ៉ាងគឺ **បញ្ញាគុណ** គុណគឺបញ្ញាជ្រាបច្បាស់ក្នុងកងសង្ខារ ១ **ករុណាគុណ** គុណគឺសេចក្តីករុណាប្រណីដល់សព្វសត្វ ១ **វិសុទ្ធិគុណ** គុណគឺសេចក្តីបរិសុទ្ធិលះកិលេសព្រមទាំងវាសនា ១ (រួមជាគុណ ៣ យ៉ាង)។ ឯគុណដែលមានច្រើនរាប់មិនអស់នោះ ហៅថាអនន្តគុណ។

**ស~** ចូរសង្គ្រោះគុណទាំងអស់បញ្ចូលគ្នាឱ្យខ្លីចុះនៅត្រឹមតែពីរមកមើល ?

**ឆ~** ព្រះនាមទាំង ១០ គឺ**អរហំ** ១ **សម្មាសម្ពុទ្ធោ** ១ រាប់បញ្ចូលក្នុងបញ្ញាគុណ។នោះ សង្គ្រោះចូលក្នុងអត្តហិត គុណ **វិជ្ជាចរណសម្បន្នោ** ១ **សុគតោ** ១ **លោកវិទូ** ១ **អនុត្តរោ** ១ រាប់បញ្ចូលក្នុងវិសុទ្ធិគុណ **បុរិសទម្មសារថិ** ១

**សត្ថាទេវមនុស្សានំ ១ ពុទ្ធោ ១  ភគវា** ១ រាប់បញ្ចូលក្នុង
ករុណាគុណ៧ និងវិសុទ្ធិគុណសង្គ្រោះចូលក្នុងបរហិតគុណ ។
**ស~** មាតាបិតាបង្កើតយើង និងព្រះពុទ្ធជាម្ចាស់ណាមាន
គុណច្រើនជាងណា? ចូរឆ្លើយឱ្យមានគោលអាងមកផង!
**ឆ~** ព្រះពុទ្ធជាម្ចាស់ ព្រះអង្គមានគុណច្រើនជាងមាតា បិតា
ព្រោះព្រះអង្គប្រកបដោយសម្បទា ៣ យ៉ាង ។
**ស~** ចុះសម្បទា ៣ យ៉ាងនោះគឺអ្វីខ្លះ?
**ឆ~** សម្បទា ៣យ៉ាងនោះគឺ **ហេតុសម្បទា** ព្រះអង្គបរិបូណ៌
ដោយហេតុ ១ **ផលសម្បទា** ព្រះអង្គបរិបូណ៌ដោយ ផល ១
**សត្តូបការសម្បទា** ព្រះអង្គបរិបូណ៌ដោយឧបការ លើសត្វ ១ ។
**ស~** ចុះហេតុសម្បទានោះ ចែកទៅមានប៉ុន្មានយ៉ាងគឺ
អ្វីខ្លះ?
**ឆ~ ហេតុសម្បទា** ដែលថា ព្រះអង្គបរិបូណ៌ដោយហេតុ
នោះ គឺ ព្រះអង្គជ្រាបហេតុដើមកំណើតទុក្ខនៃសត្វលោក
ថាកើតមកអំពីមានឆន្ទៈជាពូជជាតិ មានភព ៣ជាផែនដី
ផ្សាំភ្ញាស់បណ្ដុះដាំនូវពូជទុក្ខទាំងពួង ទើបទ្រង់ព្រះមេត្តា
អាណិតអាសូរសត្វ ចង់ចម្លងសត្វនោះដោយធម្មនាវា ទៅ
ដាក់ដល់ត្រើយគឺព្រះនិព្វាន។ ហេតុសម្បទានេះចែកចេញ
ទៅមាន ២យ៉ាងគឺ

ក) **មហាករុណាសមាយោគៈ** ព្រះអង្គប្រកបដោយករុណាធំ ចំពោះសត្វឥតរើសមុខ ។

ខ) **ពោធិសម្ភារសម្ភរណៈ** ព្រះអង្គទ្រង់បំពេញពុទ្ធការកធមិ ១៨ ប្រការមានបារមី ១០ ជាដើមអស់កោដិ និងកប្បជាច្រើន ក្នុងការកសាងព្រះអង្គជាព្រះពុទ្ធ ហើយនឹងចម្លងសត្វឱ្យផុតទុក្ខ ដោយធម្មនាវាឆ្លងកាត់មហាសមុទ្រ គឺសំសារវដ្តទៅកាន់ត្រើយ គឺព្រះនិព្វាន ។

**ស-** ចុះផលសម្បទានោះ ចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ?

**ឆ-** ផលសម្បទានោះ ចែកទៅមាន ៤ យ៉ាងគឺ

**ក) ញាណសម្បទា** ព្រះអង្គប្រកបដោយញាណមានមគ្គញាណ ទសពលញ្ញាណ អនាវរណញ្ញាណ ចតុវេសារជ្ជញ្ញាណ ជាដើម ។

**ខ) បហានសម្បទា** ព្រះអង្គបរិបូណ៌ដោយការលះកិលេសព្រមទាំងវាសនា ។

**គ) អានុភាវសម្បទា** ព្រះអង្គបរិបូណ៌ដោយឥទ្ធានុភាពច្រើន ។

**ឃ) រូបកាយសម្បទា** ព្រះអង្គបរិបូណ៌ដោយរូបកាយ គឺប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនិងអនុព្យញ្ជនៈ ៨០គត់ ។

**ស~** ចុះសត្តូបការសម្បទានោះ ចែកទៅមានប៉ុន្មានអ្វីខ្លះ?

**ឆ~** សត្តូបការសម្បទានោះ ចែកទៅមាន ២ យ៉ាងគឺ

**ក) អាសយ** រង់ចាំអប់រំបន្ទំនិស្ស័យសត្វ ឱ្យចាស់ថ្លាឡើង មិនចេះប្រកាន់ទោសសត្វឡើយ ។

**ខ) បយោគ** ទ្រង់ប្រកបប្រយោជន៏ឱ្យសត្វទូទៅមាន ទាន សីល ភាវនាជាដើម។ ដោយហេតុនេះហើយ ទើបឆ្លើយថាព្រះពុទ្ធអង្គមានព្រះគុណធ្ងន់ជាងមាតាបិតាយើង។

**៧~ បុរិសទម្មសារថិ** ទ្រង់ព្រះនាមថា បុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន ។

**ស~** បុរសប្រែថាដូចម្តេច? ចែកដោយវេនេយ្យ និងបុរសមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~** បុរសប្រែថាបុគ្គលប្រុសស្រី ឬ ប្រែថាទេវតា មនុស្សប្រុសស្រី ដែលមាននិស្ស័យជាពុទ្ធវេនេយ្យគួរព្រះពុទ្ធជាម្ចាស់នឹងទូន្មានបាន ។

ឯវេនេយ្យនោះមាន ៣ យ៉ាងគឺពុទ្ធវេនេយ្យ សត្វមាននិស្ស័យត្រូវព្រះពុទ្ធទូន្មានទើបបាន ១ ។
សាវ័កវេនេយ្យ សត្វមាននិស្ស័យត្រូវសាវ័កទូន្មានទើប បាន ដូច"ឆន្នត្ថេរ" ជាដើម ១ ធាតុវេនេយ្យ សត្វមាននិស្ស័យត្រូវព្រះបរមសារីរិកធាតុទូន្មានទើបបាន ១ (រួមជាវេនេយ្យ(៣) ។បុរសនោះបើប្រែថាបុគ្គលប្រុសស្រីវិញនោះ ចែកនិស្ស័យទៅតាមបុគ្គលជាន់ខ្ពស់ទាបមាន ៤ យ៉ាងគឺ **ឧគ្ឃដិតញ្ញូបុគ្គល** ជាបុគ្គលជាន់ខ្ពស់ផុត ស្តាប់ធម៌តែមួយបទ ឬក្នុងបាទជាបឋម និងបាទជាគំរប់ពីរ ក៏បានសម្រេចមគ្គផល ១ **វិបច្ចិតញ្ញូបុគ្គល** ជាបុគ្គលជាន់កណ្តាលស្តាប់ធម៌ក្នុងបាទជាគំរប់ ៣ ឬបាទជាគំរប់ ៤ ចប់ ទើបបានសំរេចមគ្គផល ១ **នេយ្យបុគ្គល** ជាបុគ្គលជាន់ទាប បន្ទាប់ថ្នាក់កណ្តាលស្តាប់ធម៌ ចប់គាថាជាច្រើនលើកច្រើនគ្រា ហើយលុះតែចែកចេញដោយន័យផ្សេងៗ មានឧបមាឧបមេយ្យឱ្យស្តាប់ៗ ហើយខំចម្រើនធម៌តទៅទៀត ទើបបានសំរេចមគ្គផល ១ **បទបរមបុគ្គល** ជាបុគ្គលជាន់ទាបបំផុត ស្តាប់ធម៌ចប់ច្រើនបទបាទគាថា ហើយចែកដោយបទឧបមាឧបមេយ្យ យ៉ាងល្អិតឱ្យស្តាប់ៗហើយ លុះតែខំចម្រើនធម៌

នោះតៗទៅច្រើនជាតិទៅមុខទៀត ទើបបានសំរេចមគ្គផល ១ (រួមត្រូវជាបុគ្គល ៤ ពួក) ។

**ស~** ចុះឧបនិស្ស័យនោះ មានប៉ុន្មាន គឺអ្វីខ្លះ ?

**ឆ~** ឧបនិស្ស័យនោះមាន ៣ យ៉ាង គឺ**ទានូបនិស្ស័យ** និស្ស័យកើតអំពីទាន ១ **សីលូបនិស្ស័យ** និស្ស័យកើតអំពីរក្សាសីល ១ ភាវនូបនិស្ស័យ និស្ស័យកើតអំពីការធ្វើភាវនា ១ (រួមជា ៣ យ៉ាង)

**ស~** ឧបនិស្ស័យទាំង ៣ យ៉ាងនេះ ជានិស្ស័យនៃសត្វធ្វើដំណើរទៅកាន់ព្រះនិព្វានដូចគ្នា ប៉ុន្តែចង់ដឹងកម្លាំងនិស្ស័យ ៣នេះ ណាខ្លាំងជាងមួយណា ចូរឧបមាមកមើល ?

**ឆ~** ឧបនិស្ស័យទាំង ៣ យ៉ាងនេះ មានកម្លាំងខុសគ្នា លោកឧបមាដូចជាសត្វ ៣ ពួក គឺសត្វពួក ១ មានឆ្អឹងជាស្លាប ដូចជាភមរជាតិមាន កន្លង់ ឃ្មុំ កន្ធុំរុយជាដើម ហើរមិនសូវបានឆ្ងាយ នេះលោកប្រៀបដូចជាកម្លាំងទានូបនិស្ស័យ សត្វ១ពួកទៀតមានស្បែកជាស្លាបដូចជ្រឹងប្រចៀវជាដើម ហើរទៅបានមធ្យម នេះលោកប្រៀបដូចកម្លាំងសីលូបនិស្ស័យ សត្វ១ ពួកទៀត មានរោមជាស្លាបដូចជាសត្វត្មាត រនាល គ្រៀលជាដើម ហើរទៅកាន់ទីឆ្ងាយ

បានហើយ មានសន្ទុះលឿនណាស់ផង នេះលោកប្រៀបដូចកម្លាំង ភាវនូបនិស្ស័យ (រួមជា ៣ យ៉ាង) ។

**ស~** ឱ!បើដូច្នេះ យើងនាំគ្នាធ្វើតែភាវនាទៅ កុំបាច់ធ្វើទានសីលនាំឱ្យរវល់ច្រើន តើបានព្រះនិព្វានឬទេ ?

**ឆ~** បើនឹងកាត់យកតែភាវនូបនិស្ស័យមួយដូច្នេះ តាំងពីដើមទៅមិនបានទេ ព្រោះព្រះនិព្វាន គេបានដោយធ្វើទានសីល ភាវនា ឬបានដោយធ្វើសីល សមាធិ បញ្ញា លុះតែនិស្ស័យធម៌ ៣ នេះជុំគ្នាទើបបាន ប្រៀបដូចជាជ្រោងស្នាចឬមុំចង្ក្រានដាំបាយ បើខ្វះតែ ១ ក៏នឹងសម្រេច ប្រយោជន៍មិនបានឡើយ ។

**៨~ សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថាទេវមនុស្សានំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ។

**ស~** ព្រះអង្គជាសាស្តាចារ្យគឺព្រះអង្គធ្វើជាអ្វី ?

**ឆ~** គឺព្រះអង្គធ្វើជាគ្រូអាចារ្យ ប្រៀនប្រដៅធម៌វិន័យច្បាប់ពុទ្ធសាសនា ដល់ទេវតានិងមនុស្សទាំងឡាយក្នុងលោក ។

**ស~** ឱ! បើដូច្នេះ ព្រះអង្គជាសាស្ដាធំមែន ព្រោះបង្រៀនធម៌ទេវតាផង មនុស្សផង ហេតុទេវតានិងមនុស្សទាំងអស់ សុទ្ធតែជាកូនសិស្សរៀនធម៌នឹងព្រះពុទ្ធទាំងអស់គ្នា ឬនៅមានខ្លះដែរ ?

**ឆ~** មានសល់ខ្លះដែរ សល់ចំពោះតែសត្វដែលគ្មានឧប - និស្ស័យ ប្រៀបដូចជាមនុស្សធ្វើគ្រូបង្រៀន មនុស្សក្នុងលោកសព្វថ្ងៃនេះ មនុស្សខ្វាក់ភ្នែក ថ្លង់គ កំបុតដៃ ក៏ផុតនិស្ស័យនឹងចូលមករៀនអក្សរ ជាមួយលោកគ្រូនោះទៅយ៉ាងណា ន័យនេះដូចគ្នានឹងមនុស្សដែលនៅសល់ ក្រៅពីសិស្ស ព្រះសាស្ដានោះដែរ ។

**ស~** ចុះអាចារ្យមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~** អាចារ្យមាន ៤ យ៉ាងគឺ **បុព្វាចារ្យ** លោកអ្នកឱ្យត្រ័យសរណគមន៍ បំបួសសិស្ស ១ **និស្សយាចារ្យ** លោកអ្នកឱ្យ និស្ស័យដល់សិស្ស ១ **ឧបសម្បទាចារ្យ**លោកអ្នកសូត្រសូមឧបសម្បទាឱ្យសិស្ស(គឺគ្រូសូធ្យ)១ធម្មាចារ្យ ឬ **ឧទ្ទេស្សាចារ្យ** លោកអ្នកបង្រៀនធម៌វិន័យ ឬ លោកអ្នកបង្រៀនបាលីអដ្ឋកថា ១ (រួមត្រូវជា ៤) ។

**ស~** ចុះបើអាចារ្យមាន ៤ កូនសិស្ស តើមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

**ឆ~** សិស្សមាន ៤ យ៉ាងដែរគឺ **បព្វជ្ជន្តេវាសិក** សិស្សបំបួស ១ **និស្សយន្តេវាសិក** សិស្សសូមនិស្ស័យ ១ **ឧបសម្បទន្តេ-វាសិក** សិស្សសូត្រ ១ **ធម្មន្តេវាសិក ឬឧទ្ទេស្សន្តេវាសិក** សិស្សរៀន ១ (រួមជាសិស្ស ៤) ។

**៩~ ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង ។

**ស~ ពុទ្ធោ** ដែលប្រែថា ត្រាស់ដឹង តើលោកអ្នកត្រាស់ ដឹងមានប៉ុន្មានពួក គឺអ្វីខ្លះ ?

**ឆ~** លោកអ្នកត្រាស់ដឹងមាន ៣ ពួកគឺ **សព្វញ្ញុពុទ្ធ** លោកត្រាស់ដឹងនូវធមិទាំងពួងឥតមានសេសសល់ ១ **បច្ចេកពុទ្ធ** លោកត្រាស់ដឹងធមិចំពោះខ្លួន ១ **អនុពុទ្ធ** លោកត្រាស់ដឹងធមិតាម សព្វញ្ញុពុទ្ធ ១ (រួមជា ៣ ពួក) ។

**ស~** អរិយសច្ច ៤ នោះគឺអ្វីខ្លះ ?

**ឆ~ ទុក្ខសច្ច** កងទុក្ខទាំងពួងមានជាតិទុក្ខជាដើម ជារបស់ពិតនៃព្រះអរិយៈ ១ **សមុទយសច្ច** កងតណ្ហាទាំងពួងមានកាមតណ្ហាជាដើម ជារបស់ពិតនៃព្រះអរិយៈ ១ **និរោធសច្ច** ទីរំលត់ភ្លើងទុក្ខ ភ្លើងកិលេស គឺព្រះនិព្វានជារបស់ពិតនៃព្រះអរិយៈ ១ **មគ្គសច្ច** មគ្គប្រកបដោយអង្គ ៨ ប្រការ

មានសម្មាទិដ្ឋិជាដើម ជារបស់ពិតនៃព្រះអរិយៈ ១ (រួមជា ៤ ប្រការ ) ។

**ស~** ព្រះសព្វញ្ញុពុទ្ធ ព្រះអង្គកសាងប្រកបដោយធម៌ប៉ុន្មានយ៉ាង គឺអ្វីខ្លះ? ដែលជួយព្រះអង្គឱ្យបានត្រាស់ជាព្រះពុទ្ធ ?

**ឆ~** ព្រះអង្គប្រកបដោយពុទ្ធការកធម៌ ១៨ ប្រការ គឺ **មនុស្សត្តំ** ជាតិជាមនុស្ស ១ **លិង្គសម្បត្តិ** ភេទពេញជាប្រុស ១ **ឧបនិស្សយសម្បត្តិ** ហេតុមានឧបនិស្ស័យ គួរនឹងសំរេចព្រះអរហត្តផល ១ **សត្ថារទស្សនំ** បានជួបនឹងព្រះសាស្តាចារ្យ ១ **បព្វជ្ជា** បានបួសក្នុងព្រះពុទ្ធសាសនា ឬបួសជាតាបសឥសីក្រៅព្រះពុទ្ធសាសនា ១ **គុណសម្បត្តិ** ប្រកបដោយគុណមានឈានជាដើម ១ **អធិការោ** បានធ្វើទានដ៏ឧត្តមមានមហាបរិច្ចាគ ៥ ជាដើម ១ **ឆន្ទតា** ពេញចិត្តប្រាថ្នានូវពោធិញ្ញាណឥតមានចិត្តរួញរា ១ ធម៌ទាំង ៨ ប្រការ ឈ្មោះថា **ធម្មសមោធាន** អាចឱ្យសំរេចសេចក្តីប្រាថ្នាក្នុងពោធិញ្ញាណបាន ផ្សំនឹងបារមី ១០ ទៀតគឺ ទានៈ ការឱ្យទាន១ សីលៈ រក្សាសីល១ នេក្ខមៈ ចេញបួស១ បញ្ញា ប្រាជ្ញា១ វិរិយ ព្យាយាម១ ខន្តី អត់ធន១ សច្ចៈ

ពាក្យពិត១ អធិដ្ឋាន តាំងចិត្តកំណត់ទុកមាំ នៅក្នុងចិត្ត១ មេត្តា ផ្សាយចិត្តមេត្តាចិត្តអាណិតស្រលោះ ចំពោះសត្វទាំងអស់ទូទៅ១ ឧបេក្ខា ធ្វើចិត្តស្មើក្នុងសត្វ ដូចជា ទំនិញ និងកូនជញ្ជីងថ្លឹងស្មើៗគ្នាទូទៅ ឥតមានស្អប់ ឬស្រលាញ់សត្វណា១ (រួមធម្មសមោធាន ៨ រួមនឹងបារមី ១០ ត្រូវជា ១៨ )ហៅថា **ពុទ្ធការកធម៌**ៗនេះធ្វើមនុស្សឱ្យកើតជាព្រះពុទ្ធឡើងបាន ។

**ស~** ចុះបារមី ១០ នេះ ចែកជាបារមី ៣០ ដូចម្ដេច? ចូរចែកមកមើល!

**ឆ~** លោកយកបារមី ១០ មកចែកជាបារមី ១ ឧបបារមី ១ បរមត្ថបារមី ១ គ្រប់បារមីទាំង ១០ ក្នុងបារមីមួយៗ ចែកជាបី បី មានទានបារមីជាខាងដើម ដល់ទៅឧបេក្ខាបារមីខាងចុង ត្រូវជាបារមី ៣០ ។

**ស~** ចុះបរិច្ចាគ ៥យ៉ាងរបស់បុគ្គលសាងជាព្រះពុទ្ធនោះ គឺអ្វីខ្លះ ?

**ឆ~** គឺបរិច្ចាគទ្រព្យ ១ បុត្តធីតា ១ ភរិយា ១ ខ្លួន ឬ អវៈ-យវៈ តូចធំ ១ ជីវិត ១ (រួមត្រូវជា ៥ ) ។

**ស~** ចុះចរិយារបស់ព្រះពុទ្ធ ៣ យ៉ាងនោះ គឺអ្វីខ្លះ?

ឆ~ គឺ**លោកត្ថចរិយា** ប្រព្រឹត្តដើម្បីសត្វលោក ១ **ញាតិត្ថ-ចរិយា** ប្រព្រឹត្តដើម្បីញាតិ ១ **ពុទ្ធត្ថចរិយា** ប្រព្រឹត្តដើម្បីត្រាស់ជាព្រះពុទ្ធ ១ ( រួមជា ៣ ) ។

**ស~** ព្រះសព្វញ្ញូទាំងអស់អង្គផ្សេងគ្នាឬដូចគ្នា បើផ្សេងគ្នាតើផ្សេងដោយហេតុអ្វី? ដូចម្ដេចខ្លះ? ចូរឆ្លើយឱ្យមានអាង?

**ឆ~** ផ្សេងគ្នាដោយការកសាងជា ៣យ៉ាងដូច្នេះ គឺ**បញ្ញា-ធិក**ពោធិសត្ត១មានបញ្ញាច្រើនជាងសទ្ធានិងវីរិយៈកសាង ៤ អសង្ខេយ្យនិង១ សែនកប្បបានត្រាស់ជាព្រះពុទ្ធ **សទ្ធាធិក** ពោធិសត្ត១ មានសទ្ធាច្រើនជាងបញ្ញា និងវីរិយ កសាង ៨ អសង្ខេយ្យ និង១សែនកប្បបានត្រាស់ជាព្រះពុទ្ធ **វីរិយាធិក** ពោធិសត្ត១មានព្យាយាមច្រើនជាងបញ្ញានិងសទ្ធា កសាង ១៦ អសង្ខេយ្យ និង ១ សែនកប្បបានត្រាស់ជាព្រះពុទ្ធ។

**១០~ ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រ័យភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រលប់កើតទៀតឡើយ។

**ស~** ត្រ័យភព ៣នោះ គឺអ្វីខ្លះ ?

**ឆ~** ភព ៣នោះ គឺកាមភព ១ រូបភព ១ អរូបភព ១ ( រួមជា ៣ ) ។

**ស~** កាមភពនោះចែកចេញទៅទៀតមានប៉ុន្មាន គឺអ្វីខ្លះ?

**ឆ~** កាមភពគឺកន្លែងសត្វបរិភោគកាមគុណនៅ មាន ១១ កន្លែងគឺ អបាយភូមិ ៤ គឺនរក ១ ប្រេត ១ តិរច្ឆាន ១ អសុរកាយ ១ (រួមជា ៤ កន្លែង) និងកាមសុគតិ ៧ គឺ មនុស្ស១ និងឆកាមាសួគ៌៦ គឺចាតុម្មហារាជិកា១ តាវតឹង្សា១ យាមា ១ តុសិតា ១ និម្មានរតី ១ បរនិម្មិតវសវត្តី ១ (រួមជា ៧ កន្លែង) ផ្សំអបាយភូមិ ៤ នឹងកាមសុគតិ ៧ ចូលគ្នាត្រូវជាកាមភព ១១ កន្លែង ឬ ១១ ជាន់ ។

**ស~** ចុះរូបភពចែកចេញទៅជាប៉ុន្មានទៀត គឺអ្វីខ្លះ ?

**ឆ~** រូបភពគឺកន្លែងសត្វមានរូបនៅ ចែកចេញជា ១៦ កន្លែងទៀត គឺព្រហ្មបរិសជា ១ ព្រហ្មបរោហិតា ១ មហា-ព្រហ្មា ១ បរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ បរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហកា ១ វេហប្ផលា ១ អសញ្ញិសត្តា ១ អវេហា ១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋកា ១ ។

**ស~** ចុះអរូបភពនោះមានប៉ុន្មាន គឺអ្វីខ្លះ ?

**ឆ~** មាន ៤ គឺអាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ១ (រួមជា ៤ ) ។

# ប្រស្នាធម្មគុណ

**ស្វាក្ខាតោ ភគវតោ ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ។

**ស~** ព្រះត្រៃបិដក ប្រែថាដូចម្តេច? គឺអ្វីខ្លះ ?

**ឆ~** ប្រែថាកញ្ជើបី ឬល្អីបីឬក៏ភាជនៈបី, សម្រាប់ដាក់នូវពុទ្ធវចនៈ ៣ គឺព្រះវិន័យ ១ ព្រះសូត្រ ១ ព្រះអភិធម្ម ១ ។

**ស~** ចុះព្រះវិន័យបិដក ដែលជាភាជនៈ សម្រាប់ដាក់វិន័យ ៗនេះសម្រាប់ប្រដៅអ្វី? មានគោលបំណងដូចម្តេច?

**ឆ~** ព្រះវិន័យជាច្បាប់ សម្រាប់ប្រដៅផ្លូវកាយនិងវាចាឱ្យមានរបៀបរៀបរយល្អ ព្រោះកាយនិងវាចានេះ ជារបស់ខាងក្រៅជាគ្រឿងលោក គេមើលឃើញ គេឮបាន ដោយមានគោលបំណងឱ្យផុតពីលោក លើកទោសនិន្ទាដល់ពុទ្ធបរិស័ទ ។

**ស~** ចុះវិន័យនោះមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~** វិន័យនោះគោលដើមមាន ២ យ៉ាងគឺ គិហិវិន័យ ១ បព្វជិតវិន័យ១ ឬ នឹងហៅថាអាគារិយវិន័យ ១ អនាគារិយវិន័យ ១ ដូច្នេះវិញក៏បាន ។

**សៈ** គិហិវិន័យ ជាវិន័យសម្រាប់ពុទ្ធបរិស័ទថ្នាក់ណា ? មានប៉ុន្មានប្រការគឺអ្វីខ្លះ? ចូររាប់គោល៧មកមើល !

**ឆៈ** គិហិវិន័យ ជាច្បាប់សម្រាប់ប្រដៅពុទ្ធបរិស័ទ ថ្នាក់គ្រហស្ថ អ្នកនៅគ្រប់គ្រងផ្ទះសម្បែង ភូមិជាទាយកទាយិកា ឬជាឧបាសក ឧបាសិកា ច្បាប់នោះមាន ១០ ប្រការ គឺកម្មបថ ១០ រាប់ជាគោល៧គឺកាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ ( រួមជា ១០ ) ។

**សៈ** បព្វជិតវិន័យ ជាវិន័យសម្រាប់ពុទ្ធបរិស័ទថ្នាក់ណា? មានប៉ុន្មានប្រការ គឺអ្វីខ្លះ ?

**ឆៈ** បព្វជិតវិន័យ ជាច្បាប់សម្រាប់ប្រដៅពុទ្ធបរិស័ទថ្នាក់អ្នកបួស ភូមិជាសាមណេរឬភិក្ខុ វិន័យនោះមានចំណែកផ្សេងគ្នាបើជាសាមណេរភូមិត្រូវកាន់តាមវិន័យ របស់សាមណេរមាន ៣០ គឺសិក្ខាបទ ១០ ទណ្ឌកម្ម ១០ នាសនង្គៈ១០ ( រួមជា ៣០) បើជាភិក្ខុភូមិវិញត្រូវកាន់តាម**ចតុប្បារិសុទ្ធិសីល**គឺ បាតិមោក្ខសំវរសីល ១ ឥន្ទ្រិយសំវរ-សីល ១ អាជីវបារិសុទ្ធិសីល ១ បច្ចយសន្និស្សិតសីល ១ (រួមជា ៤ ប្រការ) ដែលចែកចេញជាសិក្ខាបទមាន ២២៧ សិក្ខាបទ ។

**ស~** ព្រះវិន័យ បើថាឱ្យខ្លីចុះទៅមានប៉ុន្មាន បើថាឱ្យច្រើនទៅតើមានប៉ុន្មាន ? ហៅដូចម្ដេច ?

**ឆ~** ព្រះវិន័យ បើថាឱ្យខ្លីចុះថាតែមួយមាត់ចប់ស្រេច "**សព្វបាបស្ស អករណំ**" ការហាមឃាត់មិនឱ្យធ្វើបាប គឺអំពើអាក្រក់គ្រប់យ៉ាងហៅថាវិន័យ បើថាឱ្យច្រើនគឺថាដោយចែកជាធម្មក្ខន្ធ ព្រះវិន័យមាន ២១,000 ធម្មក្ខន្ធ ។

**ស~** ព្រះពុទ្ធសាសនាទាំង ៣ គឺបរិយត្តិសាសនា ១ បដិបត្តិសាសនា ១ បដិវេធសាសនា ១ ឬក៏ហៅថាសីលសាសនា ១ សមាធិសាសនា ១ បញ្ញាសាសនា ១ ព្រះវិន័យនឹង សង្គ្រោះរាប់បញ្ចូលក្នុងសាសនាណា ? មានការសំខាន់ដូចម្ដេច ?

**ឆ~** ព្រះវិន័យសង្គ្រោះរាប់ចូលក្នុងបរិយត្តិសាសនា ឬសីលសាសនាៗនេះមានការសំខាន់បំផុត ព្រោះពុទ្ធសាសនាទាំង ៣ មានព្រះវិន័យជាឫសកែវយ៉ាងមាំអាចស្រូបយកជីជាតិនិងសំណើមទឹក គឺបច្ច័យ ៤ ដែលនៅជ្រៅក្នុងដី គឺ ហប្ចទ័យនៃទាយកមកឱ្យដើមឈើគឺព្រះពុទ្ធសាសនានេះរស់នៅគ្រប់ ៥.000 ព្រះវស្សាទៅបាន ។

**ស~** ចុះព្រះសុត្តន្តបិដក ដែលជាភាជនៈសម្រាប់ដាក់ព្រះសូត្រៗនេះសម្រាប់ប្រដៅអ្វី? មានគោលបំណងដូចម្ដេច ?

**ឆ~** ព្រះសូត្រនេះជាធមិសម្រាប់ប្រដៅផ្លូវចិត្ត ឱ្យចេះធ្វើបុណ្យទាន ធ្វើកុសលផ្សេងៗ មានគោលបំណងឱ្យដោះចិត្តចេញពីសេចក្ដីជាប់ជំពាក់ចិត្តក្នុងសម្បត្តិយស ឬ ក្នុងវត្ថុដែលខ្លួនមាន និងបញ្ចក្ខន្ធ ដើម្បីធ្វើចិត្តឱ្យស្អាតល្អ ។

**ស~** ចុះព្រះសូត្រនោះ មានតិចច្រើនប៉ុណ្ណា ? បើថាឱ្យខ្លីចុះមកវិញ ឬថាឱ្យច្រើនឡើងទៅត្រូវហៅដូចម្ដេច ?

**ឆ~** ព្រះសូត្រនេះបើថាឱ្យខ្លីចុះ ថាតែមួយមាត់ចប់ "**កុសលស្សូបសម្បទា**" ការញ៉ាំងកុសលឱ្យដល់ព្រម គឺទ្រង់ប្រដៅសត្វឱ្យបំពេញបុណ្យ កុសលគ្រប់យ៉ាងហៅថាព្រះសូត្រ បើថាឱ្យច្រើន គឺថាដោយចែកជាធម្មក្ខន្ធ ព្រះសូត្រមាន ២១,000 ធម្មក្ខន្ធ ។

**ស~** ចុះពុទ្ធសាសនាទាំង៣នោះ ព្រះសូត្រនេះ រាប់បញ្ចូលក្នុងសាសនាណា? មានគោលសំខាន់ដូចម្ដេច ?

**ឆ~** ព្រះសូត្រនេះ សង្គ្រោះរាប់ចូលក្នុងបដិបត្តិសាសនា ឬសមាធិសាសនា មានការសំខាន់បំផុតខាងការចងក្រងទុកនូវពុទ្ធវចនៈទាំង៣ មិនឱ្យរាត់រាយរលាយរលត់បាត់

ទៅបាន មិនឱ្យច្រឡំគ្នាបានប្រៀបបីដូចជាខ្សែស្រូត្រ ឬ អម្បោះរបស់នាយមាលាការ ដែលចងក្រងផ្កាឈើមាន ពណ៌ផ្សេងៗ តាក់តែងជារូបសត្វនោះឱ្យជាប់នៅយូរបាន មិនរបូតជ្រុះបាត់ ឬរាត់រាយឡើយ ។

**ស~** ព្រះអភិធម្មបិដក ដែលជាភាជនៈសម្រាប់ដាក់ព្រះ អភិធម្មៗនេះសម្រាប់ប្រដៅអ្វី? មានគោលបំណងដូចម្ដេច?

**ឆ~** ព្រះអភិធម្មនេះ ជាធម៌សម្រាប់ប្រដៅផ្លូវចិត្តឱ្យបរិ-សុទ្ធស្អាតផូរផង់ មានគោលបំណងនិងបំបែកចិត្តចេញពី បញ្ចក្ខន្ធ ឱ្យចូលទៅកាន់ព្រះនិព្វាន ។

**ស~** ចុះព្រះអភិធម្មនោះ មានតិចច្រើនប៉ុណ្ណា ? បើថាឱ្យ ខ្លីចុះមកវិញ ឬថាឱ្យច្រើនឡើងទៅ ត្រូវហៅដូចម្ដេច ?

**ឆ~** ព្រះអភិធម្មនេះ បើថាឱ្យខ្លីចុះ ថាតែមួយម៉ាត់ចប់គឺ "**សចិត្តបរិយោទបនំ**" ការញ៉ាំងចិត្តឱ្យស្អាតផូរផង់ ហៅថា ព្រះអភិធម្ម "**ចិត្តេ បសន្នេ សុគតិ បាដិកង្ខា**" កាលបើចិត្ត ស្អាតផូរផង់ហើយ ប្រាកដជាបានទៅកាន់សុគតិស្ថាន បើថា ឱ្យច្រើននោះ គឺថាដោយចែកជាធម្មក្ខន្ធ ព្រះអភិធម្មមាន ៤២,000 ធម្មខន្ធ ។

**ស~** ចុះក្នុងពុទ្ធសាសនា ទាំង៣នោះ ព្រះអភិធម្មនេះនឹងសង្គ្រោះរាប់បញ្ចូលក្នុងសាសនាណា? មានគោលសំខាន់ដូចម្តេច?

**ឆ~** ព្រះអភិធម្មនេះ សង្គ្រោះរាប់ចូលក្នុងបដិវេធសាសនា ឬបញ្ញាសាសនា មានការសំខាន់បំផុត ខាងលាងសំអាតចិត្ត ដោះចិត្តដែលជាប់ជំពាក់ក្នុងកាមារម្មណ៍ មានរូបជាដើម ឬក្នុងភព ៣ មានកាមភពជាដើម ឬក៏ជាប់ជំពាក់ចិត្តនៅក្នុងលោកនានា មានខន្ធលោកជាដើម ឱ្យស្អាតផូរផង់បាន ដោយបញ្ញាជាកាំបិត កាត់ខ្សែចំណងនៃចិត្ត ឬ បញ្ញាជាអាវុធកាប់ឆ្ការព្រៃស្តុក គឺកិលេសហើយដុតឱ្យឆេះដោយភ្លើង គឺតបៈសេចក្តីព្យាយាមរឹងមាំ ឬនឹងលាងចិត្តដែលប្រឡាក់នោះ ដោយទឹកថ្លា គឺសីល ដុសចិត្តដោយដុំសាប៊ូគឺតួបញ្ញាឬវិចារណញ្ញាណ ឱ្យជាចិត្តស្អាតផូរផង់បាន ហើយផ្ទុកចិត្តនោះ ពេញទៅដោយមគ្គផលគឺព្រះនិព្វាន ។

**ឆម្លោ** ព្រះនព្វលោកុត្តរធម៌ ៩ ប្រការគឺ មគ្គ ៤ ផល ៤ និព្វាន ១ ។

**ស~** ហេតុអ្វីបានជាធម៌ទាំង ៩ ប្រការហៅថា ព្រះនព្វលោកុត្តរធម៌?

**ឆ~** ព្រោះធម៌ទាំង ៩ប្រការមានសោតាបត្តិមគ្គជាដើម នេះជាធម៌សម្រាប់ចម្លងសត្វនាំសត្វឱ្យឆ្លងផុតពីលោកទាំង ៣ ប្រការ មានកាមលោកជាដើម ។

**ស~** មគ្គ ៤ ផល ៤ និញ្វន ១ នោះគឺអ្វីខ្លះ? ចូររាប់មកមើល?

**ឆ~** មគ្គ ៤ នោះគឺសោតាបត្តិមគ្គ ១ សកទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ ១ ឯផល ៤ នោះគឺ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ( រួមជា ៨ ) និងនិញ្វន ១ បូកផ្សំគ្នាត្រូវជា ៩ ប្រការ ។

**សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថា នឹងបានដឹងដោយស្ដាប់ដោយជឿបុគ្គលដទៃទៀតនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង ។

**ស~** ព្រះអរិយបុគ្គលមានប៉ុន្មានពួក គឺអ្វីខ្លះ ? ចូររាប់មកមើល !

**ឆ~** មាន ២ពួក គឺលោកដែលបានសម្រេចមគ្គ ៤ ជាពួក ១ លោកដែលបានសម្រេចផល ៤ ជាពួក ១ បើរាប់រាយ មាន ៨ពួកគឺរាប់តាមមគ្គផលដែលលោកបានសម្រេច ។

**អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏ កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ ។

**ស~** ធម៌ឱ្យនូវផលមិនរង់ចាំកាល តើឱ្យដូចម្ដេច? ព្រះអរិយមគ្គនិងព្រះអរិយផល កើតក្នុងលំដាប់គ្នា នោះតើ កើតដូចម្ដេច? ចូរឆ្លើយជាសេចក្ដីឧបមាមកមើល ?

**ឆ~** មិនរង់ចាំកាលដូចជាពាក្យថាមើល ឃើញជាដើម ក្នុងលំដាប់គ្នា ដូចពាក្យថាផ្កា ផ្លែ រៀន ចេះជាដើម ឬក៏ដូច ពាក្យថាកើត ចាស់ ឈឺ ស្លាប់ គឺជាពាក្យប្រាប់ថា ផលកើត តាមលំដាប់មគ្គ គឺសោតាបត្តិផល កើតទៅពីសោតាបត្តិមគ្គ ដូចជាផ្លែឈើណាកើតទៅពីផ្កាឈើនោះ ។

**ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើ ព្រះអរិយបុគ្គល ដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹង ហៅបុគ្គលដទៃឱ្យចូលមកមើលបាន ។

**ស~** ឯហិបស្សវិធី ដូចម្ដេច ? ហៅបុគ្គលដទៃឱ្យចូលមក មើលបាននោះ តើមើលដូចម្ដេច? ចូរឧបមាមកមើល !

**ឆ~** ឯហិបស្សវិធី គឺជាវិធីហៅអ្នកដទៃថា "អ្នកចូល មកៗឱ្យមើលបាននោះ គឺបង្ហាញរបស់ដែលខ្លួនមាន ឬខ្លួន ដែលទើបនឹងរកបាននោះ ឱ្យអ្នកដទៃឃើញ ប្រៀបដូចជា

អ្នកមានកូនហៅគេមកមើល ឬអ្នកទើបនឹងបានគ្រឿងប្រដាប់ថ្មី មានមាសប្រាក់ជាដើម ហៅគេឱ្យមើល ឯលោកអ្នកបានឈានហើយ ក៏អាចសំដែងឫទ្ធិបង្ហាញឱ្យគេឃើញបានដូចចុល្លបន្ថកត្ថេរ សំដែងឫទ្ធិនិម្មិតខ្លួនលោកតែ១ ឱ្យក្លាយទៅជារូបសង្ឃមានទាំងពាន់គង់ក្នុងវិហារ ឬក៏ដូចជាមហានាគត្ថេរ សំដែងសមាធិជារូបដំរីយ៉ាងធំមួយ ឱ្យធម្មទិន្នត្ថេរមើលដំរីនោះ ចេះទាំងស្រែក ទាំងបោលផងបាន ។ល។

**ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោន ចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា ។

**ស~** បង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនានោះ គឺបង្អោនដូចម្ដេច ?

**ឆ~** គឺលោកខំភាវនាចំរើនធម៌ណា ដែលមិនទាន់ឱ្យកើត-ឡើង ក្នុងខ្លួនលោក បើមគ្គធម៌ ឬផលធម៌ណា កើតមានហើយ ក៏លោករក្សាធម៌នោះ ទុកដោយភាវនា ។

**បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

**ស~** បច្ចត្តំ អត្ថធម៌នេះ សំដៅយកតែមគ្គ ៤ និងផល ៤ ប៉ុណ្ណោះទេឬអ្វី ?

**ឆ~** ធម៌នេះ ក្រៅពីមគ្គ ៤ ផល ៤ ទៀត មានច្រើនប្រការដែរ ដូចពាក្យថា អ្នកណារៀនអ្នកនោះចេះ អ្នកណារក្សាសីល អ្នកនោះបានសុខចំរើន ចំពោះខ្លួនម្នាក់ៗ រកអ្នកដទៃជួសមិនបានឡើយ ។

## ប្រស្នាសង្ឃគុណ

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**

ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ ។

**ស~** សាវ័កព្រះពុទ្ធជាម្ចាស់មានប៉ុន្មានពួក គឺអ្វីខ្លះ ?

**ឆ~** មានពីរពួក គឺបុថុជ្ជនសាវ័ក ១ អរិយសាវ័ក ១

**ស~** ពុទ្ធសាវក័ទាំង ២ ពួកនេះ ផ្សេងគ្នាដោយន័យដូចម្តេច?

**ឆ~** ផ្សេងគ្នាដូចនេះ បុថុជ្ជនសាវ័ក ឬ បោថុជ្ជនសាវ័ក នោះគឺបុគ្គលជាអ្នកស្តាប់តាម ជឿតាម ធ្វើតាមព្រះពុទ្ធដីកាដែរ ប៉ុន្តែ មានសន្តានចិត្តជាបុថុជ្ជននៅឡើយ ទាន សីល ភាវនា ធ្វើហើយតែមិនទាន់ទទួលមគ្គផល ឯរិយសាវ័កក្នុងទីនេះ សំដៅយកបុគ្គលដែលបានទទួលមគ្គផលឯណានីមួយ មានសោតាបត្តិមគ្គជាដើមរួចហើយ ហៅថា អរិយសាវ័ក ។

**ស~** ចុះគន្លងព្រះនព្វលោកុត្តរធមិគឺអ្វី? បានសេចក្តីថាដូចម្តេច ?

**ឆ~** គឺមគ្គប្រកបដោយអង្គ ៨ ឬធមិ ៩ប្រការមានសោតាបត្តិមគ្គជាដើម ដែលញ៉ាំងសត្វឱ្យឆ្លងចាកផុតលោកទាំង ៣ មានកាមលោកជាដើម ដែលជាផ្លូវដើរទៅកាន់ព្រះនិព្វាន ។

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក័ នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិ ជាមជ្ឈិមប្បដិបទា ។

**ស~** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ មានប៉ុន្មានពួក គឺអ្វីខ្លះ ?

**ឆ-** មាន ២ ពួក គឺសម្មតិសង្ឃ ១ ពួក ព្រះអរិយសង្ឃ ១ ពួក ។

**ស-** មជ្ឈិមប្បដិបទាដែលជាផ្លូវត្រង់ ផ្លូវកណ្តាលនោះ គឺផ្លូវណា ?

**ឆ-** គឺផ្លូវសីល សមាធិ បញ្ញា ដែលមានរាប់ឈ្មោះរាយទុកក្នុងមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិមគ្គជាដើម ។

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ**

ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹង នូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង ។

**ស-** លោកប្រតិបត្តិដូចម្តេច ឈ្មោះថា ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ?

**ឆ-** លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវសម្មាបដិបទាដែលជាផ្លូវប្រតិបត្តិសំរាប់ដឹងច្បាស់ ចាក់ធ្លុះនូវព្រះនិព្វានដែលជាគន្លងតម្រាយ របស់ព្រះអរិយៈជាម្ចាស់ទាំងឡាយ លោកតែងយាត្រាទៅកាន់ព្រះនិព្វាន យ៉ាងនេះទើបថា "ញាយបដិបន្នោ" ។

ម្យ៉ាងទៀត លោកប្រតិបត្តិដើម្បីចេញចាកសង្សារវដ្ត មិនប្រតិបត្តិដើម្បីលាភ យសនិងសេចក្តីសរសើរ ក្នុងបច្ចុប្បន្ន ឬ ដើម្បីស្ថានសួគ៌ឡើយ ។

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក័នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរ ដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិបញ្ញា ។

**ស~** លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម តើប្រតិបត្តិដូចម្តេច ?

**ឆ~** លោកប្រតិបត្តិត្រឹមត្រូវត្រង់តាមផ្លូវ សីល សមាធិបញ្ញា គឺលោកមានការកោតក្រែង ខ្លាចអំពើខុសជានិច្ចមិនហ៊ានកន្លងពុទ្ធប្បញ្ញត្តិ ឡើយ ។

**ស~** ព្រះសង្ឃទាំងអស់នេះ បើរាប់ជាគូ តើមានប៉ុន្មាន គូគឺអ្វីខ្លះ ?

**យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃទាំងនេះបើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ ១ សកទាគាមិមគ្គនិងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ

និង អនាគាមិផលជាគូ ១ អរហត្តមគ្គនិងអរហត្តផលជាគូ ១ ( រួមជា ៤ គូ) ។

**ស~** ចុះបើរាប់រៀងជាបុរសបុគ្គលទៅវិញ តើមានប៉ុន្មាន គឺអ្វីខ្លះ ?

**ឆ~ អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គល មាន ៨ គឺ ព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ( រួមជា ៨ ) ។

**ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា ។

**ស~** ចតុប្បច្ច័យ ប្រែថាដូចម្តេច គឺអ្វីខ្លះ ?

**ឆ~** ប្រែថា វត្ថុជាគ្រឿងអាស្រ័យ ៤ យ៉ាងរបស់បព្វជិត គឺចីវរប្បច្ច័យ គ្រឿងស្លៀកដណ្តប់ ១ បិណ្ឌបាតប្បច្ច័យ គ្រឿងបរិភោគ ១ សេនាសនប្បច្ច័យ គ្រឿងដេកនៅ ១ គិលានប្បច្ច័យ គ្រឿងភេសជ្ជៈជាថ្នាំការពាររោគ ១ ។

**អាហុនេយ្យោ** លោកគួរទទួលនូវអាគន្តុកទានគឺទាន ដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្តដែលមកអំពីទិស ផ្សេងៗ ហើយបង្អោនចូលមកបូជា ។

**ស-** អាគន្តុកទានគឺអ្វី ?

**ឆ-** គឺទានដែលបុគ្គលរៀបប្រគេនភិក្ខុដែលទើបនឹងមកដល់ថ្មី ។

**ស-** បូជាប្រែថាដូចម្តេច ? បើចែកទៅទៀតមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ-** បូជាប្រែថា ថ្វាយ ប្រគេន ជូន ឱ្យ បើចែកដោយប្រភេទនៃការបូជាផ្សេងគ្នាមាន ៤ យ៉ាង គឺសក្ការៈ ការតាក់តែងវត្ថុផ្សេងៗ មានផ្កាជាដើម ១ គរុការៈ ការគោរពដោយកាយវាចាចិត្ត ១ **មាននៈ** ការរាប់អានស្រលាញ់ស្មោះចំពោះ ហ៊ានលះរបស់ឱ្យ ១ **វណ្ណនៈ** ការពណ៌នា គឺពោលសរសើរគុណ ១ ( រួមជា ៤ )។ បើចែកដោយប្រភេទនៃបុគ្គល គួរបូជាវិញ មានច្រើនប្រការ មានព្រះសព្វញ្ញូពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសង្ឃជាសាវ័កនៃព្រះពុទ្ធ មាតាបិតា គ្រូអាចារ្យជាដើម ។

**ទក្ខិណេយ្យោ** លោកគួរទទួលនូវទានដែលបុគ្គល ជឿនូវកម្ម និងផលនៃកម្មហើយបូជា ។

**ស~** ដូចម្ដេចដែលហៅថាកម្ម ? កម្មនិងផលនៃកម្មប្លែកគ្នាដូចម្ដេច ?

**ឆ~** អំពើដែលបុគ្គលធ្វើដោយកាយវាចាចិត្ត ទោះបីអាក្រក់ក្ដី ល្អក្ដី ហៅថាកម្ម សេចក្ដីទុក្ខ ឬសុខ ដែលកើតអំ-ពីកម្មនោះៗ មានប្រាកដឡើងដល់រូបបុគ្គលអ្នកធ្វើហៅថាផល ។

**ស~** កម្មបើចែកទៅមានប៉ុន្មាន គឺអ្វីខ្លះ ?

**ឆ~** កម្ម បើចែកឱ្យខ្លីមានតែ ២ យ៉ាងគឺ បុញ្ញកម្ម ១ បាបកម្ម ១ ឬហៅថា កុសលកម្ម ១ អកុសលកម្ម ១ ដូច្នេះវិញក៏បាន អំពើល្អដែលជាហេតុនាំសត្វឱ្យបានសុខចំរើន ហៅថាកុសលកម្ម អំពើអាក្រក់ដែលជាហេតុនាំសត្វឱ្យបានទុក្ខ ឱ្យវិនាស ហៅថាអកុសលកម្ម ។

**អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ។

**ស~** លោកណាខ្លះ ដែលគួរដល់អញ្ជលិកម្មៗប្រែថា ដូចម្ដេច?

**ឆ~** លោកដែលបានរាប់ឈ្មោះមកខាងដើមរួចហើយ ដែលហៅថា សម្មតិសង្ឃក្ដី អរិយសង្ឃក្ដីនោះ ទោះបីលោកបានសម្រេចមគ្គផលហើយក្ដី លោកមានសន្ដានចិត្តជាបុថុជ្ជន

នៅឡើយក្តី ក៏គួរធ្វើអញ្ជលិកម្មដែលប្រែថា ថ្វាយបង្គំដល់លោកនោះៗដែរ ។

**ស-** ការធ្វើអញ្ជលិកម្មមានប្រយោជន៍ដូចម្តេចខ្លះ ដល់លោកទាំងនោះ ហើយមានប្រយោជន៍អ្វីខ្លះ ដល់អ្នកធ្វើអញ្ជលិកម្ម ?

**ឆ-** ការធ្វើអញ្ជលិកម្មនោះ មានប្រយោជន៍យ៉ាងសំខាន់ដល់លោកដោយបង្ហាញទឹកចិត្តស្មោះត្រង់ ដែលខ្លួនកោតខ្លាចគោរពរាប់អានបូជាលោកៗ ក៏បានប្រាស្រ័យនឹងខ្លួនបាន ឯខ្លួនអ្នកធ្វើអញ្ជលិកម្មនោះ ក៏នឹងមានប្រយោជន៍ដោយបុញ្ញកិរិយាវត្ថុផ្សេងៗ ទាំងបានសេចក្តីសុខចំរើនក្នុងជាតិនេះ និងជាតិមុខផង **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើង នៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

**ស-** បុញ្ញក្ខេត្តប្រែថាដូចម្តេច? មានសេចក្តីប្រៀបធៀបយ៉ាងណា ?

**ឆ-** បុញ្ញក្ខេត្តប្រែថា ស្រែបុណ្យមានសេចក្តីប្រៀបធៀបនឹងស្រែស្រូវៗហៅថា សាលិខេត្ត ឬធញ្ញខេត្ត ស្រូវក្នុងស្រែនោះ ដែលល្អទៅបានអាស្រ័យនឹងស្រែមានដីជាតិល្អ មានភ្លឺជិតទឹកដក់នៅមិនធ្លុះធ្លាយយ៉ាងណា ឯបុញ្ញខេត្តស្រែបុណ្យ

ក៏ដូចគ្នាដែរ គឺព្រះសង្ឃទុកជាស្រែ បច្ច័យ ៤ ទុកជាពូជស្រូវ ចតុប្បារិសុទ្ធិសីលទុកជាដីមានជីជាតិ និងសំណើម ទឹកយ៉ាងនោះដែរ ឯអ្នកស្រែធ្វើស្រូវក្នុងស្រែល្អ បានផលផ្លែស្រូវច្រើនយ៉ាងណា ខាងទាយកអ្នកឱ្យទានក្នុងស្រែ គឺព្រះសង្ឃប្រតិបត្តិត្រឹមត្រូវល្អ មានសីលបរិសុទ្ធក៏បានផលបុណ្យច្រើនយ៉ាងនោះដែរ ។

**ស~** ព្រះសង្ឃលោកមានគុណប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~** ព្រះសង្ឃមានគុណ ២ យ៉ាងគឺ **អត្តហិតគុណ** ១ **បរហិតគុណ** ១ ។

**ស~** អត្តហិតគុណនោះ ប្រែថាដូចម្តេច ? ចែកជាប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ~** អត្តហិតគុណនោះ ប្រែថា គុណជាប្រយោជន៏ដល់ខ្លួនលោក ចែកជា ៤ យ៉ាងគឺ **សុបដិបន្នោ** លោកប្រតិបត្តិល្អ ១ **ឧជុបដិបន្នោ** លោកប្រតិបត្តិត្រង់ ១ **ញាយបដិបន្នោ** លោកប្រតិបត្តិដើម្បីត្រាស់ដឹង ១ **សាមីចិបដិបន្នោ** លោក ប្រតិ-បត្តិត្រឹមត្រូវតាមផ្លូវសីល សមាធិ បញ្ញា ១ ( រួមជា ៤ ) ។

**ស~** ចុះបរហិតគុណនោះ ប្រែថាដូចម្តេច ? ចែកទៅមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ឆ**~ បរហិតគុណនេះ ប្រែថា គុណជាប្រយោជន៏ដល់អ្នកដទៃ ចែកទៅមាន ៤យ៉ាងគឺ **អាហុនេយ្យោ** លោកគួរទទួលចតុប្បច្ច័យដែលគេបូជា ១ **បាហុនេយ្យោ** លោកគួរទទួលអាគន្តុកទាន ដែលគេរៀបដើម្បីភ្ញៀវមកថ្មីហើយបូជា ១ **ទក្ខិណេយ្យោ** លោកគួរទទួលទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា ១ **អញ្ជលិករណីយោ** លោកគួរទទួលអញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ១ ( រួមជា ៤ ) ។

**ស**~ ចុះបាលី **នត្ថិ មេ** ទាំង៣បទ ដែលពុទ្ធបរិស័ទសូធ្យសូមយកព្រះត្រ័យរតន៏ជាទីពឹងនោះ តើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជ្រាបបាន និងជួយធ្វើជាទីពឹងបាន ដូចពាក្យសច្ច-កិរិយានោះមែនឬទេ ?

**ឆ**~ ឱ! ពាក្យសួរនេះ ពិបាកឆ្លើយ ព្រោះព្រះពុទ្ធបរិនិ-ព្វានបាត់ទៅហើយ ព្រះធម៌គ្មានរូបរាងកាយដៃជើងនឹងជួយ បើសង្ឃឹមផ្ដេកចិត្តទៅលើព្រះពុទ្ធរូបសព្វថ្ងៃ ជាដុំថ្មមិនចេះនិយាយស្ដីថាអ្វី ព្រះធម៌ ដែលនៅក្នុងស្លឹករិត ឬសៀវភៅគ្រាន់តែជាស្នាមគំនូសតួអក្សរកត់ត្រាពុទ្ធវចនៈទុក សង្ឃឹមទៅលើព្រះសង្ឃក៏ជាមនុស្សកូនចៅអ្នកស្រុក មានព្រះសង្ឃខ្លះលោកមិនចេះទាំងប្រែបាលី "**នត្ថិ មេ**" នោះថាដូចម្ដេច

ផង យ៉ាងនេះគួរឱ្យឆ្ងល់ណាស់ដែរ ប៉ុន្តែ ចូរប្រយ័ត្នចិត្តកុំឱ្យជ្រុលគំនិតហួស ក្រែងជ្រលួសទៅលើផ្លូវខុស និងកាយទៅជាមនុស្សមិច្ឆាទិដ្ឋិ អ្នកស្លាប់គំនិតត្រូវប្រយ័ត្ន ដូចពាក្យបរម្បរាថា " ថ្វាយបង្គំព្រះពុទ្ធ ប្រយ័ត្នប៉ះលើដុំថ្មថ្វាយបង្គំព្រះធម៌ ប្រយ័ត្នប៉ះលើស្លឹករឹត ថ្វាយបង្គំព្រះសង្ឃ មិនបានជាតិតប៉ះលើកូនអ្នកស្រុក " ពាក្យនេះ ពោលទុកបញ្ជាក់គំនិត ឱ្យចេះគិតរកគុណព្រះរតនត្រ័យ កុំឱ្យទើចិត្តនៅត្រឹមដុំថ្មស្លឹករឹតតែប៉ុណ្ណោះ ឯអ្នកមានគំនិតល្អនោះត្រូវយល់ថាត្រ័យសរណគមន៍ គឺព្រះរតនត្រ័យៗ ក៏គឺព្រះពុទ្ធ ព្រះ-ធម៌ព្រះសង្ឃៗ គឺសភាពដែលពិត ដែលមានប្រាកដដល់ចិត្តអ្នកធ្វើទីពឹងៗ លើសភាពដែលពិតនោះ នឹងបានប្រាកដដូចបំណង ព្រោះតែចិត្តខ្លួនពិតផងដែរ កុំថាឡើយត្រឹមតែសិរីសួស្តីជ័យមង្គលប៉ុណ្ណោះ សូម្បីតែសេចក្តីសុខក្នុងស្ថានសួគ៌និព្វាន ដែលតំលៃកាត់មិនបាន អ្នកធ្វើកម្មដ្ឋានគេយកព្រះរតនត្រ័យមានព្រះពុទ្ធជាដើមជាទីពឹង មកធ្វើជាមូលកម្មដ្ឋាន ។ នោះក៏ជួយគេឱ្យបានសម្រេចមគ្គផល ដល់ព្រះនិព្វានដូចប្រាថ្នា ហេតុនេះក៏សូមឆ្លើយខ្លីថា នឹងបានឬមិនបានដូចបំណងក៏មកពីអ្នកធ្វើពិត និងមិនពិតប៉ុណ្ណោះឯង ។ល។

**ស~** ចុះបាលីថា " **ឧត្តមង្គេន** " ទាំង៣បទដែលពុទ្ធបរិ-ស័ទសូធ្យសូមខមាទោសនឹងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃៗ នោះ នឹងជ្រាបបាន ឬអត់ទោសឱ្យគេបាន ដូចគេសូមខមាទោសនោះឬទេ ? មែនឬអ្វី ?

**ឆ~** សេចក្តីនេះ ដូចគ្នានឹង " **នត្ថិ មេ** "មិនប្លែកគ្នាប៉ុន្មាន ទេ ប៉ុន្តែត្រូវដឹងថា ទោសមានច្រើនប្រការ គឺលោកវជ្ជទោស ឬវដ្តទោស ទោសដែលមានជាធម្មតាលោក ឬទោសដែលមានសម្រាប់វដ្ត ដូចកើតចាស់ឈឺ ស្លាប់ជាដើមនេះ មិនមែនសូមព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ អត់ទោសឱ្យបានទេ បើជាបញ្ញត្តិវជ្ជទោស គឺទោសកើតឡើងព្រោះព្រះអង្គបញ្ញត្តិ ដូចត្មះតិះដៀលព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម នោះទើបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃអត់ទោសឱ្យបាន ដោយខ្លួនប្រកាស គឺសូមខមាទោសនោះឯង ។

**ស~** ចុះអត់ទោសដូចម្តេចកើត បើព្រះពុទ្ធចូលនិព្វានបាត់ទៅហើយ នៅតែព្រះពុទ្ធរូបថ្ម សំណ ស្ពាន់ មាស ប្រាក់ ។ល។ ដូចសព្វថ្ងៃនេះ ព្រះធម៌នៅតែសូរសំឡេង ឮដោយសារ លោកសូធ្យប៉ុណ្ណោះ គ្មានរូបសោះ ព្រះសង្ឃទៀតសោត ក៏មិនដឹងជាខ្លួនមានទោសខុសនឹងព្រះសង្ឃអង្គណា?

**ឆ~** មានរឿងបញ្ជាក់នេះ ពន្យល់ទុកក្នុងគម្ពីរសារត្ថ-សង្គហៈថា បើបុគ្គលណាមានទោសកំហុស នឹងព្រះអរិយបុគ្គល អង្គណាមានព្រះពុទ្ធជាដើមក្ដី ខុសនឹងមាតាបិតា គ្រូអាចារ្យខ្លួនឯង ហើយដឹងខ្លួនថា ខ្លួនខុសមានទោសហើយ ត្រូវឱ្យបុគ្គលនោះ សូមខមាទោសទើបរួចចាកទោសបាន ថាបើលោកនេះដើរទៅបាត់ក្ដី ចូលនិព្វានខន្ធឬនិព្វានធាតុទៅក្ដី ទទួលអនិច្ចកម្ម ឬអនិច្ចធម្មទៅហើយក្ដី ត្រូវនិមន្តសង្ឃដទៃបាន ៤ អង្គមកប្រកាសសូមខមាទោសតាមទោសដែលខ្លួនធ្វើខុស នឹងព្រះអរិយបុគ្គលនោះ ពុំនោះសោតទេ ឱ្យសូមខមាទោសនឹងអដ្ឋិធាតុលោកឬនឹងជើងថ្ករ គឺកន្លែងបូជាសពលោកនោះ ទើបរួចចាកទោសបាន នេះសសេចក្ដីឱ្យឃើញថា ប្រាកដជាអត់បាន ទើបលោកអ្នកប្រាជ្ញបូរាណលោកសំដែងបាលី "**នត្ថិ មេ**" នឹង "**ឧត្តមង្គេន**" តាំងទុកមកសម្រាប់សូធ្យសូមទីពឹង និងសូមខមាទោស ដូច្នេះឯងជាយូរអង្វែងណាស់មកហើយ ។

## ប្រស្នាបត្តិទានៈ និងបត្តានុមោទនៈ

**ស~** ខ្ញុំឆ្ងល់ពីការចែកបុណ្យគ្នាពន់ពេក បានខ្ញុំមិនចង់ធ្វើបុណ្យក្រែងមិនបាន បើបុណ្យនោះមានរូបដូចផ្លែឈើ ឬ

មានរូបដូចមាស ប្រាក់ជាដើមខ្ញុំក៏មិនឆ្ងល់ដែរ ។ ក្នុងពុទ្ធសាសនា មានច្បាប់ថា អ្នកធ្វើទានបើបានចែកបុណ្យឱ្យគេក៏នឹងបានផលបុណ្យថែមរឹតតែច្រើនឡើងៗជាទ្វេគុណ ក្នុង "បត្តិទានៈ" ឯក្នុង "បត្តានុមោទនៈ" ក៏មានច្បាប់ថា អ្នកទទួលអនុមោទនាត្រេកអរតាមទានគេនោះ ក៏បានទទួលផលបុណ្យ ដោយទទេឥតថ្លៃនោះផងដែរ តើនឹងបានបុណ្យរំលែកចែកគ្នាបានដូចម្ដេចកើត បើបុណ្យនោះគ្មានរូបសោះគ្រាន់តែជានាមធម៌ប៉ុណ្ណោះ សូមលោកអ្នកមានប្រាជ្ញសង្គ្រោះកែខៃ ឧបមា ឧបមេយ្យសេចក្ដីនេះ ឱ្យខ្ញុំជាអ្នកល្ងង់ខ្លៅស្ដាប់បាន ខ្ញុំក៏នឹងសុខចិត្តយល់ព្រមធ្វើបុណ្យនឹងគេផងមើល ?

**ឆ~** ខ្ញុំក៏មិនមែនជាអ្នកប្រាជ្ញធំដុំដែរ ប៉ុន្តែ អត់ទ្រាំឆ្លើយតបនឹងសេចក្ដីឆ្ងល់របស់អ្នកសួរនេះពុំបានក៏ឆ្លើយទៅ មុននឹងឆ្លើយតបបញ្ហានេះ ខ្ញុំសូមសួរអ្នកបន្តិច អ្នកឯងដែលធ្វើបុណ្យដែរឬទេ ?

**ស~** ទេ! ខ្ញុំមិនដែលធ្វើបុណ្យទានអ្វីទេ !

**ឆ~** បើដូច្នោះ អ្នកឯងដែលឃើញគេរៀនអក្សរឬទេ?

**ស~** ខ្ញុំដែលឃើញដែរ !

**ឆ~** អើបើដូច្នោះ អ្នកចូរពិនិត្យពិចារណាអក្សរ ដែលសិស្សចេះតទៅពីគ្រូនោះ មើលកាលចំណេះអក្សរ និងលេខជាដើម ឆ្លងតាមខ្សែវិញ្ញាណទៅជាប់នឹងសិស្សនៅត្រង់ណា? មើលឃើញឬទេ ?

**ស~** មើលមិនឃើញទេ !

**ឆ~** អើបើដូច្នោះ ចូរអ្នកឯងចាំស្តាប់ខ្ញុំនឹងពន្យល់ប្រាប់ !

**ស~** បាទ !

**ឆ~** បុណ្យនោះ ជានាមធម៌គ្មានរូបក៏ពិតមែន ប៉ុន្តែ កើតមកពីវត្ថុទានមានរូប ហេតុនោះ គេអាចដឹងបាន អាចកំណត់ទំហំបុណ្យបាន អាចចែកចំណែកបុណ្យនោះទៅអ្នកដទៃផងបាន អ្នកដទៃដែលនឹងទទួលយកបុណ្យនោះ ក៏ទទួលយកបានដោយត្រេកអរ ដូចអ្នករៀនអក្សរ គ្រូដែលបង្រៀនអក្សរគេតទៅនោះ គេអាចកំណត់វិជ្ជាដែលគេចេះបាន ហើយចំណេះនោះ មិនអស់ទៅណារឹតតែចម្រើន ចេះចាំឡើងលើសដើមទៅទៀត ជាទ្វេគុណមែនឬទេ ?

**ស~** បាទមែនហើយ

**ឆ~** បើដូច្នោះ ខ្ញុំឧបមា ឧបមេយ្យពីសេចក្តីចែកបុណ្យនិងទទួលបុណ្យនេះ អ្នកស្តាប់បាន យល់បាន បាត់ឆ្ងល់ហើយឬនៅ ?

**ស**~ បាទ ! ខ្ញុំស្តាប់បាន យល់បាន បាត់ឆ្ងល់ហើយ ខ្ញុំសូមអរគុណដល់អ្នកតាំងពីថ្ងៃនេះតទៅ ខ្ញុំនឹងធ្វើបុណ្យទានឧទ្ទិសផលចែកជូនដល់លោកអ្នកមានគុណខ្ញុំពុំខានឡើយ ។

**ចប់ដោយសង្ខេបតែប៉ុណ្ណេះ ៗ**

# សំនួរ~ចម្លើយបឋមសញ្ញាណ
# សំរាប់អ្នកសិក្សាដំបូង

**សំនួរ** : ពាក្យថា ឧបាសក ឧបាសិកា ជាភាសាអ្វី ? មានអត្ថន័យដូចម្តេច ?

**ចម្លើយ** : ពាក្យថា ឧបាសក ឧបាសិកា ជាភាសាបាលី ប្រែថា បុរស ឬ ស្ត្រី អ្នកអង្គុយជិតព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឬចូលទៅប្តេជ្ញាចិត្ត ថ្វាយខ្លួនចំពោះព្រះភ័ក្ត្រភិក្ខុ ឬសាមណេរថា "ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ទីរលឹក" ហើយសមាទានសីល ៥ ឬសីល ៨ រួចរក្សានូវគ្រប់សិក្ខាបទនៃសីលទាំងនោះ ដោយត្រឹមត្រូវ មិនមែនគ្រាន់តែចូលទៅអង្គុយជិតគ្នា ដូចជាជនដែលអង្គុយជិតគ្នាតាមធម្មតានោះ

ទេ ព្រោះមានវិគ្គហៈបញ្ជាក់ថា **រតនត្តយំ ឧបាសតីតិ ឧបាសកោ**(ជនោ) ប្រែថា ជនឯណាចូលទៅអង្គុយជិតព្រះរតនត្រ័យ ជននោះឈ្មោះថា ឧបាសក (បើស្រ្តីថា ឧបាសិកា) ។

សូមបញ្ជាក់ថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រ័យនោះ គឺមិនមែនចូលទៅអង្គុយជិត ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ ទោះបីជននោះស្ថិតនៅទីឆ្ងាយក៏ដោយ តែមានសន្ដានចិត្តជិតជាប់ក្នុងគុណព្រះរតនត្រ័យជានិច្ច យកព្រះត្រ័យរត្ន័ជាសរណវត្ថុប្រចាំជីវិតនៃខ្លួនជាអចិន្ត្រៃយ៍ ទើបឈ្មោះថា ឧបាសក-ឧបាសិកា ។

**សំនួរ** : សរណគមន៏ បើចែកដោយឈ្មោះមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ? ចូរអធិប្បាយ !

**ចម្លើយ** : សរណគមន៏ បើចែកដោយឈ្មោះមាន ២ យ៉ាងគឺលោកិយសរណគមន៏ ១ លោកុត្តរសរណគមន៏ ១ ។

**លោកិយសរណគមន៍** គឺសរណគមន៏ជាលោកីយ៏ ជារបស់បុថុជ្ជន ដែលគ្រាន់តែសង្កត់សង្កិននូវកិលេសមានពុទ្ធគុណជាអារម្មណ៏ជាដើម ជាអ្នកមានសទ្ធា មានប្រាជ្ញាជា

សម្មាទិដ្ឋិ បំពេញនូវកងកុសលមាន បុញ្ញកិរិយាវត្ថុទាំង ១០ ជាដើម ។

**លោកុត្តរសរណគមន៍** គឺសរណគមន៍ជាលោកុត្តរៈ ជារបស់ព្រះអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ដែលលោកឃើញនូវសច្ចៈទាំង ៤ ហើយកំចាត់បង់នូវកិលេស មានព្រះនិព្វានជាអារម្មណ៍ ។

**សំនួរ :** បុព្វហេតុអ្វី ដែលនាំឱ្យសរណគមន៍សៅហ្មង? ចូររៀបរាប់ ?

**ចម្លើយ:** បុព្វហេតុដែលនាំឱ្យសរណគមន៍សៅហ្មងមាន ៣ យ៉ាងគឺ

**១~ អញ្ញាណៈ** មិនដឹងថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានគុណដូចម្តេចៗ ។

**២~ សំសយៈ** ចេះតែសង្ស័យក្នុងព្រះរតនត្រ័យ ទាំង ៣ មិនដាច់ស្រេច ។

**៣~ មិច្ឆាញាណទស្សនៈ** ឃើញខុសក្នុងព្រះរតនត្រ័យទាំង ៣ ។

បុព្វហេតុទាំង ៣ នេះ គ្រាន់តែមន្ទិលសៅហ្មងមិនសូវមានអានិសង្សច្រើន តែមិនដល់ថ្នាក់ដាច់សរណគមន៍ទេ ។

**សំនួរ** : ចុះលោកុត្តរសរណគមន៍ដូចម្ដេចដែរ ?

**ចម្លើយ** : លោកុត្តរសរណគមន៍ មិនចេះសៅហ្មងទេ ហើយក៏មិនចេះដាច់ដែរ ។

**សំនួរ** : អង្គរបស់សរណគមន៍ មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

**ចម្លើយ** : អង្គរបស់សរណគមន៍មាន ៣ យ៉ាងគឺ ÷

**១- សទ្ធា** : សេចក្ដីជឿជាក់ក្នុងគុណព្រះរតនត្រ័យ ។

**២- បញ្ញា** : ការដឹងច្បាស់ក្នុងគុណព្រះរតនត្រ័យ ។

**៣- ជីវិតបរិច្ចាគ** : ស៊ូលះបង់ជីវិតមិនលះបង់ ធម៌ ។

**សំនួរ** : ពាក្យថា ទាយកជាភាសាអ្វី? មានអត្ថន័យ ដូចម្ដេច ?

**ចម្លើយ** : ពាក្យថា ទាយក ជាភាសាបាលីដែរ បើស្ត្រី ហៅថា ទាយិកា ប្រែថា អ្នកឱ្យ គឺតាមតែឱ្យវត្ថុអ្វីក៏ដោយ តែក្នុងព្រះពុទ្ធសាសនា លោកសំដៅយកការឱ្យ ២យ៉ាង ÷

**១- អាមិសទាន** ការឱ្យបច្ច័យ ៤ គឺឱ្យគ្រឿងស្លៀក ដណ្ដប់ ឱ្យអាហារភោជន ឱ្យទីដេក ទីអង្គុយ ឱ្យថ្នាំកែរោគ ជាដើម ។

**២- ធម្មទាន** ការឱ្យធម៌ជាទាន បានដល់ការសម្ដែង ធម៌ឱ្យគេស្ដាប់ បង្រៀនធម៌ឱ្យគេបានយល់ជាផ្លូវប្រតិបត្តិ

ល្អ ។

**សំនួរ** : ជនដែលមានឈ្មោះថា ឧបាសក ឧបាសិកា ហើយ តើត្រូវធ្វើកិច្ចវត្តប្រតិបត្តិដូចម្តេចខ្លះ ?

**ចម្លើយ** : ត្រូវធ្វើកិច្ចវត្តប្រតិបត្តិជាច្រើន គឺត្រូវធ្វើទានរក្សាសីល ចំរើនភាវនាតាមសមគួរដល់កាល ឬធ្វើបច្ច័យ ៤ មានធ្វើចីវរ ធ្វើចង្ហាន់ជាដើម ប្រគេនភិក្ខុ ឬសាមណេរ ត្រូវរក្សាសីល ៥ ជានិច្ច រក្សាសីល ៨ ចំពោះថ្ងៃឧបោសថ ១ ខែ ៨ ដង គឺថ្ងៃ ៥ កើត ៥ រោច ៨ កើត ៨ រោច ១៤ កើត ១៤ រោច ១៥ កើត ១៥ រោច (ឬ ១៣ រោច ១៤រោច) តាមខែខ្វះ ខែពេញ ហើយត្រូវចំរើនភាវនានូវ សមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋានក្នុងថ្ងៃឧបោសថនោះ ។

**សំនួរ** : ដូចម្តេចដែលហៅថា បច្ច័យ ?

**ចម្លើយ** : វត្ថុជាទីអាស្រ័យនៃមនុស្សសត្វ ហើយប្រព្រឹត្តទៅហៅថា បច្ច័យ ។

**សំនួរ** : បច្ច័យមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ចម្លើយ** : បច្ច័យមាន ៤ យ៉ាងគឺ **ចីវរប្បច្ច័យ** គឺគ្រឿងស្លៀកដណ្តប់ ១ **បិណ្ឌបាតប្បច្ច័យ** គ្រឿងបរិភោគ ១

**សេនាសនប្បច្ច័យ** គ្រឿងដេកអង្គុយ ១ **គិលានប្បច្ច័យ** ថ្នាំកែរោគ ១ ។

**សំនួរ** ៖ បច្ច័យទាំង ៤នេះ តើយើងត្រូវឱ្យដល់អ្នកណា ?

**ចម្លើយ** ៖ បច្ច័យទាំង ៤ នេះយើងត្រូវឱ្យដល់មនុស្ស ឬសត្វណាក៏បាន តែក្នុងព្រះពុទ្ធសាសនាថែងថា បើយើងឱ្យដល់អ្នកមានសីល មានផលានិសង្សច្រើនជាងគេ ។

**សំនួរ** ៖ បើត្រូវការធ្វើបច្ច័យ ៤ ប្រគេនព្រះសង្ឃ តើត្រូវធ្វើដូចម្តេច ? ចូររៀបរាប់ខ្លី១មកមើល !

**ចម្លើយ** ៖ បើត្រូវការធ្វើបច្ច័យ ៤ ធ្វើតិចក៏បាន ធ្វើច្រើនក៏បាន តាមធនធានរបស់ខ្លួន បើធ្វើតិចក៏ឱ្យគ្រប់ដូចជា កូនកន្សែងជូតមុខ ១ ចង្ហាន់មួយស្រាក់ កន្ទេល ១ ថ្នាំកែរោគមួយបន្ទះក៏បាន បើធ្វើឱ្យច្រើនក្នុងបច្ច័យនីមួយ១ ឱ្យបានធំដុំជាងនេះទៅទៀត ក៏រឹតតែបានផលច្រើនតាមចំនួន ។

**សំនួរ** ៖ បើរកបច្ច័យ ៤ ទោះតិចក្តី ច្រើនក្តី បានគ្រប់មុខហើយ បើចង់ប្រគេនតែ ១ អង្គតើបានឬទេ ? ឬចាំតែគ្រប់ ៤ អង្គទើបបាន ?

**ចម្លើយ** ៖ ប្រគេនភិក្ខុ ១ អង្គក៏បានដល់ ៤ អង្គក៏បាន បើមួយអង្គប្រគេនតែមួយប្រដាប់ បើ ៤ អង្គត្រូវប្រគេន ៤ ប្រដាប់ បើភិក្ខុ១អង្គបានផលតិចជាងភិក្ខុ ៤អង្គតាមចំនួន។

ភិក្ខុ ១អង្គ ហៅតាមវោហារក្នុងវិន័យពុទ្ធសាសនាថា បុគ្គល ភិក្ខុ ៤ អង្គហៅថា សង្ឃ ហើយលោកពោលថា ធ្វើចំពោះបុគ្គលបានផលតិច ធ្វើចំពោះសង្ឃបានផលច្រើន ប៉ុន្តែចូរចាំឱ្យជាក់ថា បើធ្វើនឹងភិក្ខុមួយអង្គ បើធ្វើឱ្យត្រូវតាមគន្លងច្បាប់ព្រះពុទ្ធសាសនា ក៏អាចឈ្មោះថា ធ្វើនឹងសង្ឃ ហើយមានផលានិសង្សច្រើនដូចធ្វើនឹងព្រះសង្ឃដែរ ។

**សំនួរ** : ហេតុដូចម្តេច បានជាធ្វើនឹងភិក្ខុ ១ អង្គ ឈ្មោះថាធ្វើនិងសង្ឃដូចភិក្ខុ ៤ អង្គដែរ ? ចូរពន្យល់ឱ្យល្អមស្តាប់បាន !

**ចម្លើយ** : ក្នុងវិន័យពុទ្ធសាសនា លោកសំដែងអំពី ទានមានន័យទូលាយណាស់ តែក្នុងទីនេះ សូមពន្យល់បែប ខ្លីថា អ្នកត្រូវធ្វើបច្ច័យណាមួយ ឬក៏គ្រប់បច្ច័យទាំង ៤ កាលបើចាត់ចែងទេយ្យទានសព្វគ្រប់តាមចំនួនដែលត្រូវធ្វើ ហើយ គប្បីទៅកាន់វត្តអារាមពិតព្រះពុទ្ធដីកា ព្រះចៅ-អធិការថា "សូមព្រះសង្ឃចាត់ភិក្ខុ ១ អង្គ តាមតែអង្គណាក៏បាន ឱ្យនិមន្តទៅទទួលសង្ឃទាន នៅផ្ទះខ្ញុំព្រះករុណា នៅវេលាព្រឹកម៉ោង ៨ នេះ" ។ បើនិមន្តដូច្នេះ ទោះបីភិក្ខុតែ ១ អង្គ ដែលសង្ឃចាត់មកនោះ ក៏ឈ្មោះថា

ធ្វើចំពោះសង្ឃពេញទី ហើយត្រូវទទួលផលានិសង្សច្រើន ដូចធ្វើចំពោះព្រះសង្ឃ តែបើចំពោះសង្ឃតាំងពី ៤ អង្គ ឡើង ទៅ រឹតតែវិសេស វិសាលថែមទៀត ។

**<u>សំនួរ</u>** ៖ កាលបើសង្ឃចាត់ភិក្ខុ ១ អង្គ ឬ ៤ អង្គ តាម សេចក្ដីនិមន្តហើយ តើទាយកត្រូវធ្វើកិច្ចដូចម្ដេចទៀត ?

**<u>ចម្លើយ</u>**៖ កាលបើលោកនិមន្តមកដល់ផ្ទះហើយ ទាយក ម្ចាស់ទានត្រូវតាំងចិត្តថា ជាព្រះសង្ឃ ហើយធ្វើ បដិ-សណ្ឋារយ៉ាងរាក់ទាក់ និមន្តលោកចូលទៅគង់លើអាសនៈ ថ្វាយបង្គំ ប្រគេនភេសជ្ជៈ រួចនាំគ្នានមស្សការព្រះរតនត្រ័យ និងសមាទានសីល ។ បន្ទាប់មក ត្រូវម្ចាស់ទានវេរដោយ ខ្លួនឯង ឬ ក៏ឱ្យអាចារ្យវេរជំនួស ។

**<u>សំនួរ</u>** ៖ របៀបវេរបច្ច័យ ៤ នោះ តើត្រូវធ្វើដូចម្ដេច ខ្លះ? សូមពន្យល់ឱ្យល្អមស្ដាប់បាន !

**<u>ចម្លើយ</u>** ៖ របៀបវេរបច្ច័យ ៤ នោះ បើធ្វើ ៤ ប្រដាប់ ដំបូង ត្រូវយកទេយ្យទានទាំង ៤ ប្រដាប់ ដែលត្រូវប្រគេន លោក ៤ អង្គ ដែលហៅថាសង្ឃនោះ ដាក់ចំពោះព្រះភ័ក្ត្រ លោក រួចម្ចាស់ទាន ព្រមទាំងអ្នកមកជួយបុណ្យលើក ទេយ្យទានឡើង កាន់នៅដៃរៀង១ខ្លួន រួចអ្នកដែលនាំវេរ

សូធ្យ **នមោ ៣ បទ**ព្រមគ្នា ហើយសូធ្យបាលីវេររួចអ្នកឯទៀតថាតាម ។ ឯបាលីវេរមាននៅខាងដើមស្រាប់ ។ លុះវេរដោយវាចាចប់ ទាយកត្រូវកាន់ទេយ្យទានទាំងនោះចូលទៅប្រគេនលោកគ្រប់ទាំង ៤ អង្គ ឬ ១ អង្គ តាមដែលខ្លួនត្រូវការធ្វើបែបណា ត្រូវប្រគេនបែបនោះ ។ កាលបើឧបាសកប្រគេនទេយ្យទាន លោក ៤ អង្គ ឬ ១ អង្គនោះ ហើយលោកសូធ្យអនុមោទនា តាមធម្មតារបស់លោក ។ នៅពេលលោកសូធ្យអនុមោទនាចប់ហើយ ម្ចាស់ទាននិងអ្នកឧបត្ថម្ភក៏បុណ្យត្រូវសូធ្យឧទ្ទិសផលតទៅជាកិច្ចបញ្ចប់បុណ្យបច្ច័យបួនតែប៉ុណ្ណោះ ។

**សំនួរ** : ដូចម្តេច ដែលហៅថា សីល ?

**ចម្លើយ** : ដែលហៅថាសីល គឺកិរិយាវៀរចាកអំពើ បាបដោយកាយ ឬ វាចា ។

**សំនួរ** : អ្វីជាតួសីល ? សំអាងទៅលើអ្វី ?

**ចម្លើយ** : ចេតនាជាតួសីល សមដូចពុទ្ធភាសិតថា "**ចេតនាហំ ភិក្ខវេ សីលំ វទាមិ** " ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនា ជាតួសីល ។

**សំនួរ** : ចេតនាជាហេតុឱ្យកើតសីលមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ ?

**ចម្លើយ** : ចេតនាជាហេតុឱ្យកើតសីលមាន ៣យ៉ាងគឺ

១~ **សម្បត្តវិរតិ** វៀរចំពោះវត្ថុដែលដល់ព្រម គឺជួប សត្វដែលល្មមសម្លាប់ក៏មិនសម្លាប់ ទ្រព្យល្មមលួចបានក៏មិន លួច ប្រពន្ធកូនគេគួរនឹងប្រព្រឹត្តកាមបាន ក៏មិនប្រព្រឹត្ត សំដី ឯណាដែលល្មមកុហកកើតក៏មិនកុហក មិននិយាយ សុរា ល្មមនឹងផឹកកើតក៏មិនផឹក វត្ថុទាំង ៥ យ៉ាងនេះដល់ព្រម ចំពោះមុខ ក៏មិនប្រព្រឹត្តកន្លងទាំងអស់ គឺថាមិនធ្វើ ឬវៀរ ចាកគ្រប់មុខ ។

២~ **សមាទានវិរតិ** វៀរដោយបានសមាទានអំពី ភិក្ខុសាមណេរ ឬគ្រហស្ថដែលគេបានសមាទានមុន ហើយ សមាទានអំពីគេតមកទៀត បើជួបប្រទះនឹងបញ្ចវេរាទាំង ៥ ណាមួយ ក៏មិនប្រព្រឹត្តកន្លងខ្លាចដាច់សីល ក្រែងមានកម្ម ពៀរតទៅមុខ ។

៣~ **សមុច្ឆេទវិរតិ** ការវៀររបស់អរិយបុគ្គល គឺ វៀរដោយផ្តាច់បង់នូវកិលេស ជាមួយនឹងអរិយមគ្គដែល កើតឡើង សីលក៏កើតជាមួយគ្នាក្នុងពេលនោះ កិលេសក៏ អស់ទៅដែរ ។

**សំនួរ** : សីលរបស់ឧបាសកមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ចម្លើយ** : សីលរបស់ឧបាសកមាន ៣យ៉ាងគឺ ÷

**១~ និច្ចសីល** គឺសីល ៥ ដែលត្រូវរក្សាជានិច្ចជាកាល គឺរាល់ថ្ងៃ រាល់យប់ ។

**២~ ឧបោសថសីល** គឺសីល ៨ ដែលត្រូវរក្សា ១ យប់ ១ ថ្ងៃ ហើយក្នុង ១ ខែ មានតែ ៨ ដង ។

**៣~ អតិរេកសីល** គឺសីល ១០ ដែលត្រូវរក្សាដោយបុគ្គលអ្នកមានសទ្ធាខ្លាំងក្លា ដែលអាចរក្សាបាន ព្រោះមានពុទ្ធានុញ្ញាតថា បុគ្គលដែលចង់បួសជាសាមណេរ ឬភិក្ខុ ប៉ុន្តែទៅបួសពុំរួច ដោយរវល់ជាប់បំរើមាតាបិតាកំព្រាជាដើម បើចង់រក្សាសីល ១០ ក៏អាចរក្សាបាន ។

**សំនួរ** : និច្ចសីលក្តី ឧបោសថសីលក្តី បើចែកតាមវិរ-តិចេតនាជាគ្រឿងវៀរ តើមានប៉ុន្មានគឺអ្វីខ្លះ ?

**ចម្លើយ** : និច្ចសីល លោកចែកជាវិរតិ ២ យ៉ាង គឺ សម្បត្តវិរតិ វៀរចាកបញ្ចវេរា មានបាណាតិបាតជាដើម ដោយចេតនារបស់ខ្លួន មិនបាច់សមាទានអំពីអ្នកដទៃ ។ សមាទានវិរតិ វៀរចាកដោយសមាទាន អំពីអ្នកដទៃ ភិក្ខុ ឬសាមណេរ ឬក៏ឧបាសក អ្នកមានសីល ។ ឯឧបោសថសីលជាសមាទានវិរតិតែមួយយ៉ាង គឺលុះត្រាតែសមាទានអំពីអ្នកដទៃទើបបាន ។

**សំនួរ** : និច្ចសីល គឺសីល ៥ នេះ ព្រះអង្គបញ្ញត្តិចំពោះបុគ្គលណា ?

**ចម្លើយ** : និច្ចសីលនេះ ព្រះអង្គមិនបានបញ្ញត្តិចំពោះបុគ្គលណាទេ ពីព្រោះសីលនេះ មានមកពីមុនព្រះពុទ្ធជាម្ចាស់បានត្រាស់ម្ល៉េះ ។

**សំនួរ** : ចុះឧបោសថសីល ព្រះអង្គប្រារព្ធនឹងបុគ្គលណាដែរ ?

**ចម្លើយ** : ឧបោសថសីលព្រះអង្គប្រារព្ធ នឹងសាក្យ-មហានាម ។

**សំនួរ** : តើសីលកើតពីអ្នកឱ្យ ឬពីអ្នកសូម ?

**ចម្លើយ** : សីលកើតពីអ្នកសូម បើអ្នកសូមវៀរចាកទោសគ្រប់សិក្ខាបទទាំងអស់ សីលក៏ពេញបរិបូណ៌ ព្រោះសីលកើតដោយចេតនាហៅថា ចេតនាកម្ម ។

**សំនួរ** : បើសីលកើតពីអ្នកសូម ហេតុអ្វីក៏ចាំទៅសូមពីលោកទៀត ?

**ចម្លើយ** : បានជាទៅសូមពីលោក ដើម្បីឱ្យកើតសេចក្ដីគោរពក្នុងព្រះរតនត្រ័យទាំង ៣ផង ឱ្យកើតបុញ្ញកិរិយាវត្ថុផ្សេង១ផង និងបានស្ដាប់ឱវាទអំពីលោកផង ។

**សំនួរ** : បុគ្គលរក្សាសីលមានធមិអ្វី សំរាប់គ្រប់គ្រង មិនឱ្យដាច់បាន ?

**ចម្លើយ** : មានលោកបាលធមិ ២ យ៉ាង សំរាប់ទ្រទ្រង់ រក្សាមិនឱ្យដាច់គឺ

**១~ ហិរិ** : ខ្មាស ឬ អៀន នឹងអំពើទុច្ចរិត ប្រៀបដូច ជាដុំដែកមួយដុំប្រឡាក់លាមកគេមិនហ៊ានកាន់ព្រោះខ្ពើម ។

**២~ ឱត្តប្ប** : តក់ស្លុតខ្លាចអំពើទុច្ចរិត ប្រៀបដូចជា ដែកមួយដុំ ដែលគេដុតភ្លើងឱ្យក្ដៅ គេមិនហ៊ានប៉ះកាន់ ព្រោះខ្លាចក្ដៅរលាកដៃគេ ។

ធមិទាំង ២ នេះ អាចរក្សាបុគ្គល អ្នករក្សាសីល មិនឱ្យ សីលធ្លុះធ្លាយ ពពាល ពព្រុសបាន ។

**សំនួរ** : អ្នករក្សាឧបោសថសីល មានកិច្ចប៉ុន្មានយ៉ាង ដែលត្រូវធ្វើក្នុងថ្ងៃឧបោសថនោះ? គឺអ្វីខ្លះ?ចូរអធិប្បាយ!

**ចម្លើយ** : មានកិច្ច ៣ យ៉ាងគឺ

**១~ កាលេន ធម្មស្សវន** : ត្រូវស្ដាប់ធមិតាម កាលដ៏គួរ ដើម្បីនឹងរម្ងាប់បង់នូវតណ្ហា ។

**២~ កាលេន ធម្មសាកច្ឆា** : ត្រូវសាកសួរធម្ម វិន័យតាមកាលគួរ ដើម្បីកំចាត់បង់នូវសេចក្ដីសង្ស័យ ។

**៣~ ភាលេន សមថោ :** អ្នករក្សាឧបោសថ ត្រូវចំរើននូវមូលកម្មដ្ឋានទាំង ៦ ណាមួយតាមកាលគួរ ដើម្បីសង្កត់សង្កិននូវនីវរណធម៌ទាំង ៥ មានកាមឆន្ទជាដើម ក្នុងថ្ងៃរក្សាឧបោសថសីលនោះ ។

**សំនួរ** : តើឧបាសកត្រូវមានវិន័យកាន់ឬទេ? បើមានចូររាប់មកមើល ?

**ចម្លើយ** : មាន គឺកុសលកម្មបថ ១០ យ៉ាងនេះឯង សំដៅយកកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣។ ទាំង ១០ យ៉ាងនេះ ចាត់ជាវិន័យរបស់ឧបាសកហ្នឹងឯង ។

**សំនួរ** : អ្នកប្រព្រឹត្តតាមកុសលកម្មបថ មានអានិសង្សប៉ុន្មាន ? គឺអ្វីខ្លះ ?

**ចម្លើយ** : អ្នកប្រព្រឹត្តតាមកុសលកម្មបថ មានអានិសង្ស ៥ យ៉ាងគឺ ÷

**១~ អត្តាបិ អត្តានំ ន ឧបវទតិ** ខ្លួនឯងមិនបានតិះដៀលនូវខ្លួនឯងបាន ។

**២~ អនុវិច្ច វិញ្ញូ បសំសន្តិ** អ្នកប្រាជ្ញតែងសរសើរ ។

**៣~ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** នឹង

មានកិត្តិសព្ទរន្ទឺខ្ទរខ្ទាយទៅ ។

**៤. អសម្មូឡ្ហោ កាលំ ករោតិ** ពេលដែលជិតស្លាប់មិនវង្វេងស្មារតី ។

**៥. កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** លុះបែកធ្លាយកាយនឹងមានសុគតិប្រព្រឹត្តទៅក្នុងខាងមុខ ។

**សំនួរ** ៖ កុសលកម្មបថ ១០ និង អកុសលកម្មបថ ១០ បើចែកទៅទៀតមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ ?

**ចម្លើយ** ៖ កុសលកម្មបថ និង អកុសលកម្មបថ បើចែកទៅទៀត មាន ៨០ គឺកុសលកម្មបថ ៤០ អកុសលកម្មបថ ៤០ ។

## កុសលកម្មបថចែកជា ៤០ គឺ

## បាណាតិបាតមាន ៤ យ៉ាង

**១.អត្តនា ច បាណាតិបាតា បដិវិរតោ ហោតិ** ជាអ្នកវៀរចាកបាណាតិបាតដោយខ្លួនឯង ។

**២. បាណាតិបាតា វេរមណិយា សមាទបេតិ** ជាអ្នកបបួលអ្នកដទៃវៀរចាកបាណាតិបាត ។

**៣. បាណាតិបាតា វេរមណិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងការវៀរចាក បាណាតិបាត ។

៤~ **បាណាតិបាតា វេរមណិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរនូវកិរិយាវៀរចាកបាណាតិ-បាត ។

## អទិន្នាទានមាន ៤ យ៉ាងគឺ

១~ **អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ** ជាអ្នកវៀរចាកអទិន្នាទានដោយខ្លួនឯង ។

២~ **បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ** ជាអ្នកបបួលអ្នកដទៃឱ្យវៀរចាកអទិន្នា-ទាន ។

៣~ **អទិន្នាទានា វេរមណិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេវៀរចាកអទិន្នាទាន ។

៤~ **អទិន្នាទានា វេរមណិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរនូវកិរិយា វៀរចាក អទិន្នាទាន ។

## កាមេសុមិច្ឆាចារមាន ៤ យ៉ាងគឺ

១~ **អត្តនា ច កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ** ជាអ្នកវៀរចាកកាមេសុមិច្ឆាចារ ដោយខ្លួនឯង ។

**២- បរញ្ច កាមេសុមិច្ឆាចារា វេរមណិយា សមាទបេតិ** ជាអ្នក បបួលអ្នកដទៃឱ្យវៀរចាក កាមេសុមិច្ឆាចារ ។

**៣- កាមេសុមិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងកិរិយាវៀរចាក កាមេសុមិច្ឆាចារ ។

**៤- កាមេសុមិច្ឆាចារា វេរមណិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរក្នុងកិរិយាវៀរចាក កាមេសុមិច្ឆាចារ ។

**មុសាវាទមាន ៤ យ៉ាងគឺ**

**១- អត្តនា ច មុសាវាទា បដិវិរតោ ហោតិ** ជាអ្នកវៀរចាកកិរិយាពោលនូវពាក្យកុហកដោយខ្លួនឯង ។

**២- បរញ្ច មុសាវាទា វេរមណិយា សមា-ទបេតិ** ជាអ្នកបបួលអ្នកដទៃឱ្យវៀរចាក កិរិយាពោលនូវពាក្យកុហក ។

**៣- មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេវៀរចាកកិរិយា ពោលនូវពាក្យកុហក ។

**៤- មុសាវាទា វេរមណិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរនូវកិរិយាវៀរចាក នូវពាក្យ កុហក ។

## បិសុណវាចាមាន ៤ យ៉ាងគឺ

**១~ អត្តនា ច បិសុណាវាចាយ បដិវិរតោ ហោតិ** ជាអ្នកវៀរចាក ការញុះញង់ដោយខ្លួនឯង ។

**២~ បរញ្ច បិសុណាវាចាយ វេរមណិយា ច សមាទបេតិ** ជាអ្នកបបួលអ្នកដទៃឱ្យវៀរចាក កិរិយាពោលនូវពាក្យញុះញង់ ។

**៣~ បិសុណាវាចាយ វេរមណិយា ច សម~នុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេវៀរចាក កិរិយាពោលនូវពាក្យញុះញង់ ។

**៤~ បិសុណាវាចាយ វេរមណិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរក្នុងកិរិយាវៀរចាក ការពោលពាក្យញុះញង់ ។

## ផរុសវាចាមាន ៤ យ៉ាងគឺ

**១~ អត្តនា ច ផរុសវាចាយ បដិវិរតោ ហោតិ** ជាអ្នកវៀរចាក ផរុសវាចាដោយខ្លួនឯង ។

**២~ បរញ្ច ផរុសវាចាយ វេរមណិយា ច សមាទបេតិ** ជាអ្នកត្រេកអរក្នុងកិរិយា បបួលអ្នកដទៃឱ្យវៀរចាកផរុសវាចា ។

**៣~ ផរុសវាចាយ វេរមណីយា ច សមនុ~ញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងកិរិយាវៀរចាក ផរុសវាចា ។

**៤~ ផរុសវាចាយ វេរមណីយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរក្នុងកិរិយា វៀរចាក ផរុសវាចា ។

## សម្ផប្បលាបៈមាន ៤ យ៉ាងគឺ

**១~ អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ** ជាអ្នកវៀរចាក កិរិយាពោល នូវពាក្យរោយរាយ ឥតប្រយោជន៍ដោយខ្លួនឯង ។

**២~ បរញ្ច សម្ផប្បលាបា វេរមណីយា សមាទបេតិ** ជាអ្នកបបួលអ្នកដទៃឱ្យវៀរចាកកិរិយា ពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

**៣~ សម្ផប្បលាបា វេរមណីយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងកិរិយាវៀរចាក កិរិយា ពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

៤~ **សម្ផប្បលាបា វេរមណីយា ច វណ្ណំ ភាសតិ** ជាអ្នកពោល សរសើរក្នុងកិរិយាវៀរចាក កិរិយាពោលនូវពាក្យរោយរាយឥតប្រយោជន៍ ។

**អនភិជ្ឈាមាន ៤ យ៉ាងគឺ**

១~ **អត្តនា ច អនភិជ្ឈាលុ បដិវិរតោ ហោតិ** ជាអ្នកមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃដោយខ្លួនឯង ។

២~ **បរញ្ច អនភិជ្ឈាយ សមាទបេតិ** ជាអ្នកបបួលអ្នកដទៃ មិនឱ្យសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ។

៣~ **អនភិជ្ឈា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងកិរិយា មិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ ។

៤~ **អនភិជ្ឈាយ ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរក្នុងកិរិយាមិនសម្លឹងរំពៃចំពោះទ្រព្យអ្នកដទៃ

**អព្យាបាទមាន ៤ យ៉ាងគឺ**

១~ **អត្តនា ច អព្យាបាទោ ហោតិ** ជាអ្នកមិនគុំគួនគេ ដោយខ្លួនឯង ។

២~ **បរញ្ច អព្យាបាទេ សមាទបេតិ** ជាអ្នកបបួលអ្នកដទៃ មិនឱ្យគុំគួនគេ ។

៣~ **អព្យាបាទេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរក្នុងកិរិយា មិនគុំគួន ។

**៤- អព្យាបាទស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ ក្នុងកិរិយាមិនគុំគួនគេ ។

**សម្មាទិដ្ឋិមាន ៤ យ៉ាងគឺ**

**១- អត្តនា ច សម្មាទិដ្ឋិកោ ហោតិ** ជាអ្នកសម្មាទិដ្ឋិ ដោយខ្លួនឯង ។

**២- បរញ្ច សម្មាទិដ្ឋិយា ច សមាទបេតិ** ជាអ្នកបបួល អ្នកដទៃឱ្យយល់ត្រូវ ។

**៣- សម្មាទិដ្ឋិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ ក្នុងកិរិយាយល់ត្រូវ ។

**៤- សម្មាទិដ្ឋិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ ក្នុងកិរិយាយល់ត្រូវ ។

**ចប់កុសលកម្មបថ ៤០ តែប៉ុណ្ណោះ**

❋ ❋ ❋

**អកុសលកម្មបថចែកជា ៤០ គឺ**

**បាណាតិបាតមាន ៤ យ៉ាងគឺ**

**១- អត្តនា ច បាណាតិបាតី ហោតិ** ជាអ្នកសម្លាប់សត្វដោយខ្លួនឯង ។

**២. បរេញ្ញ បាណាតិបាតេ សមាទបេតិ** ជាអ្នកបបួល ឬប្រើអ្នកដទៃឱ្យសម្លាប់សត្វ ។

**៣. បាណាតិបាតេ សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ នឹងគេសម្លាប់សត្វ ។

**៤. បាណាតិបាតស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវកិរិយាសម្លាប់សត្វ ។

**អទិន្នាទានមាន ៤ យ៉ាងគឺ**

**១. អត្តនា ច អទិន្នាទាយី ហោតិ** ជាអ្នកកាន់យកនូវទ្រព្យ ដែលគេមិនបានឱ្យដោយខ្លួនឯង ។

**២. បរេញ្ញ អទិន្នាទានេ សមាទបេតិ** អ្នកបបួលឬប្រើគេ ឱ្យកាន់យកនូវទ្រព្យ ដែលគេមិនបានឱ្យដោយកាយ ដោយវាចា ។

**៣. អទិន្នាទានេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេលួចបានមក ។

**៤. អទិន្នាទានស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ ក្នុងការលួច ។

**កាមេសុមិច្ឆាចារៈមាន ៤ យ៉ាងគឺ**

**១. អត្តនា ច កាមេសុមិច្ឆាចារី ហោតិ** ជា

អ្នកប្រព្រឹត្តខុស ក្នុងកាមទាំងឡាយដោយខ្លួនឯង ។

**២~ បរញ្ច កាមេសុមិច្ឆាចារេ សមាទបេតិ** បបួលអ្នកដទៃ ឱ្យប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**៣~ កាមេសុមិច្ឆាចារេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ ក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

**៤~ កាមេសុមិច្ឆាចារស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

## មុសាវាទមាន ៤ យ៉ាងគឺ

**១~ អត្តនា ច មុសាវាទោ ហោតិ** ជាអ្នកពោលកុហកដោយខ្លួនឯង ។

**២~ បរញ្ច មុសាវាទេ សមាទបេតិ** បបួលអ្នកដទៃ ឱ្យកុហកពោលដោយពាក្យកុហក ។

**៣~ មុសាវាទេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ នឹងគេពោលដោយពាក្យកុហក ។

**៤~ មុសាវាទស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវពាក្យកុហក ។

## បិសុណាវាចាមាន ៤ យ៉ាងគឺ

**១~ អត្តនា ច បិសុណាវាចា ហោតិ** ជាអ្នកពោលនូវពាក្យ ញុះញង់អុជអាលដោយខ្លួនឯង ។

**២~ បរញ្ច បិសុណាវាចាយ សមាទបេតិ** ជាអ្នកបបួលគេ ឬប្រើគេឱ្យញុះញង់អុជអាល ។

**៣~ បិសុណាវាចាយ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ នឹងគេញុះញង់អុជអាល ។

**៤~ បិសុណាវាចាយ ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរនូវពាក្យញុះញង់អុជអាល ។

**ផរុសវាចាមាន ៤ យ៉ាងគឺ**

**១~ អត្តនា ច ផរុសវាចា ហោតិ** ជាអ្នកពោលពាក្យជេរប្រទេចដោយខ្លួនឯង ។

**២~ បរញ្ច ផរុសវាចាយ សមាទបេតិ** ជាអ្នកបបួលគេ ឬប្រើគេឱ្យជេរប្រទេចផ្ដាសា ។

**៣~ ផរុសវាចាយ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ នឹងជេរប្រទេចផ្ដាសា ។

**៤~ ផរុសវាចាយ ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវពាក្យជេរប្រទេចផ្ដាសា ។

## សម្ផប្បលាបៈមាន ៤ យ៉ាងគឺ

១~ **អត្តនា ច សម្ផប្បលាបោ ហោតិ** ជាអ្នកពោលពាក្យ រោយរាយឥតប្រយោជន៍ដោយខ្លួនឯង ។

២~ **បរញ្ច សម្ផប្បលាបេ សមាទបេតិ** ជាអ្នកបបួលគេ ឬ ប្រើគេឱ្យនិយាយនូវពាក្យរោយរាយឥតប្រយោជន៍។

៣~ **សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេនិយាយពាក្យរោយរាយឥតប្រយោជន៍។

៤~ **សម្ផប្បលាបស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវពាក្យរោយរាយឥតប្រយោជន៍។

## អភិជ្ឈាមាន ៤ យ៉ាងគឺ

១~ **អត្តនា ច អភិជ្ឈា ហោតិ** ជាអ្នកសម្លឹងរំពៃទ្រព្យអ្នកដទៃដើម្បីខ្លួន ដោយខ្លួនឯង ។

២~ **បរញ្ច អភិជ្ឈា សមាទបេតិ** ជាអ្នកបបួលគេ ឬប្រើគេឱ្យ សម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ។

៣~ **អភិជ្ឈាយ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេ សម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ។

**៤. អភិជ្ឈាយ ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរនូវ កិរិយាសម្លឹងរំពៃចំពោះទ្រព្យរបស់អ្នកដទៃ ។

**ព្យាបាទៈមាន ៤ យ៉ាងគឺ**

**១. អត្តនា ច ព្យាបាទោ ហោតិ** ជាអ្នកគុំគួន គេដោយខ្លួនឯង ។

**២. បរញ្ច ព្យាបាទេ សមាទបេតិ** ជាអ្នកបបួលឬប្រើអ្នកដទៃ ឱ្យគុំគួនគេ ។

**៣. ព្យាបាទេ ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរនឹងគេគុំគួនអ្នកដទៃ ។

**៤. ព្យាបាទស្ស ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវពាក្យគុំគួន ។

**មិច្ឆាទិដ្ឋិមាន ៤ យ៉ាងគឺ**

**១. អត្តនា ច មិច្ឆាទិដ្ឋិ ហោតិ** មានទិដ្ឋិយល់ខុសដោយខ្លួនឯង ។

**២. បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ** ជាអ្នកបបួលពន្យល់អ្នកដទៃ ឱ្យយល់ខុស ។

**៣. មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ** ជាអ្នកត្រេកអរ ក្នុងការយល់ខុស។

៤- **មិច្ឆាទិដ្ឋិយា ច វណ្ណំ ភាសតិ** ជាអ្នកពោលសរសើរ នូវមិច្ឆាទិដ្ឋិ ។

**ចប់អកុសលកម្មបថ ៤០ តែប៉ុណ្ណោះ**

## **ពុទ្ធឱវាទ ៣ បទ**

**ស-** ពុទ្ធសាសនា ប្រែថាដូចម្ដេច ?

**ឆ-** ពុទ្ធសាសនា ប្រែថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

**ស-** ព្រះពុទ្ធទ្រង់ប្រដៅដូចម្ដេចខ្លះ ?

**ឆ-** ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មានច្រើនបែបច្រើនយ៉ាងណាស់ បើរាប់ជាខន្ធមានដល់ ៨,៤000 ព្រះធម្មក្ខន្ធ តែបើបំប្រួញឱ្យខ្លីពុទ្ធវចនៈមានតែ ៣ បទ ដូចមានត្រា ទុកក្នុងបាលីជាគោលតទៅនេះ ÷

**១-** បទទី ១ **សព្វបាបស្ស អករណំ** ប្រដៅមិនឱ្យធ្វើអំពើបាបគ្រប់ជំពូក ។

**២-** បទទី ២ **កុសលស្សូបសម្បទា** ប្រដៅឱ្យបំពេញ តែបុណ្យកុសល ។

**៣~** បទទី ៣ **សចិត្តបរិយោទបនំ** ប្រដៅឱ្យដុស ខាត់ចិត្តរបស់ខ្លួនឱ្យផូរផង់ ។

**ឯតំ ពុទ្ធាន សាសនំ** នេះជាព្រះពុទ្ធសាសនា ។

**ស~** ពុទ្ធសាសនា ទាំង៣បទនេះ បើចាត់ចូលក្នុងបិដក តើចាត់ចូលបែបណា ?

**ឆ~** បទទី ១ ចាត់ចូលក្នុងវិន័យបិដក ដែលស្តីអំពីច្បាប់ ពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ។

បទទី ២ ចាត់ចូលក្នុងសុត្តន្តបិដក ដែលស្តីអំពី ពុទ្ធវចនៈដាស់តឿនឱ្យធ្វើអំពើល្អ ។

បទទី ៣ ចាត់ចូលក្នុងអភិធម្មបិដក ដែលស្តីអំពី ធម៌ បរមត្ថជាគ្រឿងដុសខាត់ចិត្តឱ្យផូរផង់ ។

## សំនួរក្នុងបទទី ១

**ស~** ពាក្យថា បាប ជាភាសាអ្វី ? ប្រែថាដូចម្តេច ?

**ឆ~** ពាក្យថា បាប ជាភាសាបាលីផង ជាភាសាសំស្ក្រឹត ផង បើប្រែ តាមអត្ថានុរូបថា "កម្មដែលញ៉ាំងសត្វឱ្យ ដល់នូវទុក្ខលំបាក ឬដល់នូវសេចក្តីវិនាសហិនហោច " បើ ប្រែតាមអត្ថប្បដិរូបថា "អំពើអាក្រក់,អំពើលាមក" ប៉ុន្តែ ពាក្យសព្វថ្ងៃ សឹងតែក្លាយជាភាសាសម្រាប់ជាតិខ្មែរទៅ

ហើយ គេនិយាយស្មើរតែគ្រប់គ្នា តែការយល់រាក់ ឬជ្រៅ ទៅតាមការចេះដឹងនៃមនុស្សម្នាក់ៗតែសព្វខ្លួន ។

**ស~** អំពើអាក្រក់ដែលហៅថាបាបនោះ តើអំពើអ្វីខ្លះ?

**ឆ~** អំពើអាក្រក់ដែលហៅថា បាបនោះ គឺអំពើ អា-ក្រក់ប្រព្រឹត្តដោយកាយ វាចា និងចិត្ត ដែល លោកហៅថា ប្រព្រឹត្តខុសក្នុងអកុសលកម្មបថជាដើមនោះ!

**ស~** អ្នកដែលអាចធ្វើបាបទៅកើត គឺធ្វើដោយមានអ្វី ជាសមុដ្ឋាន ?

**ឆ~** អ្នកដែលអាចធ្វើបាបទៅកើត គឺធ្វើដោយមាន អកុសលចិត្តជាសមុដ្ឋាន។ អកុសលចិត្ត គឺចិត្តប្រកបដោយ លោភៈ ទោសៈ មោហៈ ដែលបណ្តាលឱ្យមនុស្សហ៊ានធ្វើ មិនញញើត ដោយប្រាសចាកធម៌ ២ ហិរិ និង ឱត្តប្បៈ ។

**ស~** ពាក្យថា បាប មានពាក្យអ្វីខ្លះជាវេវចនៈ ?

**ឆ~** ពាក្យវេវចនៈ និងពាក្យបាបគឺ អកុសល,អធម៌, ទុច្ចរិត, លាមកធម៌, កណ្ហកម្ម........។ល។

ពាក្យទាំងឡាយដែលជាវេវចនៈនោះ គឺមានសូរស័ព្ទ ផ្សេងគ្នា តែអត្ថន័យដូចគ្នា មានខ្លឹមសារតែមួយ ។

**ស~** អ្នកសាងអំពើបាបនោះ នឹងទទួលផលយ៉ាងណា?

**៦.** អ្នកសាងអំពើបាបនោះ នឹងទទួលផលអាក្រក់ គឺសេចក្តីទុក្ខលំបាកតាំងពីបច្ចុប្បន្នជាតិ រហូតដល់បរលោកនាយ គឺលោកខាងមុខទៀត ក្រោយពីខ្លួនធ្វើមរណកាលទៅ ដូចពុទ្ធភាសិតថា **ទុក្ខោ បាបស្ស ឧច្ចយោ** ការសន្សំបាប រមែងត្រូវរងនូវសេចក្តីទុក្ខ **និរយំ បាបកម្មន្តា** អ្នកធ្វើបាបរមែងធ្លាក់នរក ហើយមួយទៀតបាបនោះ យើងមិនត្រូវមើលងាយថា អញធ្វើតែបន្តិចបន្តួច និងមិនឱ្យផលឡើយ ឱ្យសោះ ព្រោះព្រះពុទ្ធជាម្ចាស់បានត្រាស់ថា ÷

**មាវមញ្ញេថ បាបស្ស ន មត្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ បូរតិ**
**ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ។**

បុគ្គលមិនគួរមើលងាយបាប ថាបាបបន្តិចបន្តួចដែលយើងធ្វើហើយ នឹងមិនឱ្យផលនោះឡើយ ព្រោះមនុស្សពាលដែលសន្សំបាបបន្តិចម្តងៗ គង់តែពោរពេញទៅដោយបាប ដូចជាក្អមទឹក ដែលបើកមាត់ចំហរ ដាក់ក្នុងទីវាលដែលកំពង់ភ្លៀង ទឹកភ្លៀងអាចធ្លាក់ចូលក្នុងក្អមបន្តិចម្តងៗ ក្អមនោះក៏គង់តែពេញដោយទឹកភ្លៀងពុំខាន ។

**ស-** អ្នកធ្វើបាប បើលបធ្វើក្នុងទីកំបាំងមិនឱ្យនរណាឃើញ តើទទួលផលបាបដែរឬទេ ?

**ច-** បើលួចធ្វើក្នុងទីកំបាំង ក៏នៅតែទទួលផលអាក្រក់ព្រោះអំពើបាប គេមិនគិតថា ទីកំបាំង ទីវាលទេ ក៏ត្រូវទទួលផលដូចគ្នាដែរ គឺត្រូវក្តៅក្រហាយ និងសោយសោកក្នុងលោកនេះ និងលោកខាងមុខ ដូចពុទ្ធភាសិតថា ÷

**ចោរោ យថា សន្ធិមុខេ គហិតោ**

**សកម្មុនា ហញ្ញតិ បាបធម្មោ**

**ឯវំ បជា បេច្ច បរម្ហិ លោកេ**

**សកម្មុនា ហញ្ញតិ បាបធម្មោ ។**

ចោរមានធម៌លាមក ត្រូវគេចាប់បានត្រង់មាត់ច្រករមែងក្តៅក្រហាយ ព្រោះកម្មរបស់ខ្លួនយ៉ាងណា ពួកសត្វមានធម៌លាមកទៅខាងមុខ រមែងក្តៅក្រហាយ ព្រោះកម្មរបស់ខ្លួនក្នុងលោកខាងមុខ ក៏យ៉ាងនោះដែរ ។

**ឥធ សោចតិ បេច្ច សោចតិ**

**បាបការី ឧភយត្ថ សោចតិ**

**សោ សោចតិ សោ វិហញ្ញតិ**

**និស្វា កម្មកិលិដ្ឋមត្ថនោ ៥**

អ្នកធ្វើបាបរមែងសោយសោកក្នុងលោកនេះ និងសោយសោកក្នុងលោកខាងមុខទៀត ឈ្មោះថា សោយសោកក្នុងលោកទាំងពីរ អ្នកនោះរមែងសោកស្តាយក្តៅក្រហាយព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួន ។

មួយទៀត អំពើបាប បើធ្វើខ្លួនឯងត្រូវតែសៅហ្មងខ្លួនឯង ព្រោះបាបមិនអាចចែកគ្នាបាន បើបុណ្យអាចចែកគ្នាបាន ព្រោះថាបាបគ្មានអ្នកទទួល ។

**ស~** អ្នកធ្វើបាបក្នុងបច្ចុប្បន្ននេះ នឹងត្រូវទទួលផលអាក្រក់ក្នុងលោកនេះ ឬក៏ចាំតែទៅបរលោក ?

**ច~** អ្នកធ្វើបាប ត្រូវទទួលផលក្នុងបច្ចុប្បន្នផង ក្នុងលោកខាងមុខផង ។ អ្នកធ្វើបាបហើយទទួលផលបច្ចុប្បន្ន ឧទាហរណ៍ ដូចជាមនុស្សម្នាក់ដើរលួចឆក់ទ្រព្យសម្បត្តិគេហើយត្រូវរាជការចាប់ចងយកធ្វើទោស ដាក់គុក ដាក់ច្រវ៉ាក់ឥតត្រាប្រណី រងទុក្ខខ្លោចផ្សា នេះជាផលនៃបាបកម្មដែលខ្លួនបានប្រព្រឹត្តនាលោកនេះ ដល់ទៅបរលោកក៏សោយទុក្ខឥតល្ហែ ក្នុងនរកអវីចិថែមទៀត វៀរលែងតែបុគ្គលនោះ បានរំលត់អកុសលធម៌ទាំងអស់ គឺថា សំវេចមគ្គ

ផលជាន់ខ្ពស់ហើយបរិនិព្វានទៅ ទើបផលនៃបាបដេញតាមលែងទាន់ យ៉ាងដូចព្រះអង្គុលិមាលត្ថេរជាដើម ។ បើអកុសលធម៌ នៅតែមានក្នុងចិត្តនៃអ្នកធ្វើបាបដរាបណា ដរាបនោះបាបនៅតែបន្តឱ្យផលតទៅទៀត គឺថាបាបបានឱកាសក្នុងជាតិណា ក៏ឱ្យផលក្នុងជាតិនោះ ។

អធិប្បាយអំពីបាប និងផលនៃបាបក៏ល្មមយល់បានហើយ យើងសូមបន្តសំនួរទៅមុខទៀត ។

## សំនួរក្នុងបទទី ២

**ស~** ព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងថា ឱ្យបំពេញកុសល តើពាក្យថាកុសលជាភាសាអ្វី ? ប្រែថាដូចម្ដេច ?

**ឆ~** ពាក្យថាកុសល ជាភាសាបាលី ប្រែតាមអត្ថានុរូបថា "កម្មដែលកាត់ផ្ដាច់នូវសេចក្ដីអាក្រក់ គ្រោតគ្រាតដូចជាស្បូវភ្លាំង" បើប្រែតាមអត្ថប្បដិរូបថា "អំពើត្រឹមត្រូវ អំពើល្អ" ប៉ុន្តែ គេច្រើននិយាយភ្ជាប់គ្នាថា បុណ្យកុសលដូច្នេះក៏មាន ។ ដូច្នេះតទៅយើងយកពាក្យ បុណ្យមកអធិប្បាយ ឱ្យស្របគ្នានឹងពាក្យបាប ក្នុងបទទី ១ នៃបទឱវាទថា មិនត្រូវធ្វើបាប និងបទទី ២ ថាត្រូវធ្វើបុណ្យ ។

**ស-** ពាក្យថាបុណ្យ ជាភាសាអ្វី ? ប្រែដូចម្ដេច ? មានបទវិគ្រោះយ៉ាងណា ?

**ច-** បុណ្យជាភាសាបាលីសំស្ក្រឹត. ភាសាបាលីថា បុញ្ញ ប៉ុន្តែខ្មែរ តែងនិយាយតាមភាសាសំស្ក្រឹតថា បុណ្យ ។ ភាសាបាលីនិងសំស្ក្រឹតប្រែដូចគ្នា បុណ្យនេះ បើប្រែតាម អត្ថា-នុរូបថា "ធម្មជាតិជម្រះនូវចិត្ត (ឱ្យស្អាត) ថា "អំពើដែលសំរេចហើយ ដោយកាយវាចាចិត្តដ៏ស្អាត" ។ បើប្រែតាមអត្ថប្បដិរូប អាចប្រែបានច្រើនយ៉ាងដូចពាក្យថាកុសលដែរ ។ បុណ្យមកពី បទវិគ្គហៈថា **សន្តានំ បុនាតិ សោធេតីតិ បុញ្ញំ** កុសលធម៌ឯណាដែលញ៉ាំងសន្តានចិត្តឱ្យបរិសុទ្ធបាន កុសលធម៌ នោះឈ្មោះថា បុណ្យ ។

**ស-** អ្នកដែលអាចធ្វើបុណ្យ តើធ្វើដោយអ្វីជាសមុដ្ឋាន?

**ច-** អ្នកដែលអាចធ្វើបុណ្យ គឺធ្វើដោយមានកុសលចិត្តជាសមុដ្ឋាន ។ រីឯកុសលចិត្តនោះ គឺចិត្តដែលប្រកបដោយអលោភៈ អទោសៈ និងអមោហៈ ។ កុសលចិត្តទាំងនេះ ដែលដឹកនាំមនុស្សឱ្យមានសទ្ធាជ្រះថ្លា អាចធ្វើកុសលផ្សេងៗបាន ។

**ស-** កុសលចិត្តដែលដឹកនាំមនុស្សឱ្យធ្វើបុណ្យនោះ តើធ្វើបុណ្យដូចម្ដេចខ្លះ ?

**ច~** មនុស្សធ្វើបុណ្យដែលហៅថា អំពើល្អនោះមាន បរិច្ចាគទ្រព្យ ធ្វើទាន រក្សាសីល ៥ សីល ៨ ឬអតិរេកសីល សីល ១០ ប្រព្រឹត្តតាមកុសលកម្មបថ ១០ និងបំពេញបុញ្ញកិរិយាវត្ថុ ១០ យ៉ាងជាដើម ។

ក្នុងទីនេះ សូមបញ្ជាក់អំពីបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាង ដើម្បីបំពេញន័យ ដូចខាងក្រោម :

**១~ ទានៈ** ការបរិច្ចាគទ្រព្យធ្វើទាន

**២~ សីល** ការរក្សាសីល

**៣~ ភាវនា** ការចំរើន ឬ អប់រំផ្លូវចិត្ត

**៤~ អបចាយនៈ** ការគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ ឬ បុគ្គលគួរគោរពបូជា

**៥~ វេយ្យាវច្ចៈ** ការខ្វល់ខ្វាយបំរើក្នុងអំពើល្អ

**៦~ បត្តិទានៈ** ការចែកចំណែកបុណ្យឱ្យអ្នកដទៃ

**៧~ បត្តានុមោទនា** ការត្រេកអរចំពោះចំណែកបុណ្យ អ្នកដទៃ

**៨~ ធម្មស្សវនៈ** ការស្តាប់ធមិ

**៩~ ធម្មទេសនា** ការសំដែងធមិ

**១០~ ទិដ្ឋុជុកម្ម** ការធ្វើទិដ្ឋិឱ្យត្រង់ កុំឱ្យវៀចវេរ

បុញ្ញកិរិយាវត្ថុ ១០ យ៉ាង មនុស្សមានចិត្តជាកុសលអាចបំពេញបាន ។

**ស-** មានពាក្យអ្វីដែលជាវេវចនៈនឹងពាក្យថា បុណ្យ ?

**ច-** ពាក្យដែលជាវេវចនៈ នឹងបុណ្យគឺ កុសលកម្ម, សុចរិត , កល្យាណធម៌ , ធម្មកម្ម , សុក្កធម៌ ។ល។ មានប៉ុណ្ណេះជាដើម ។

**ស-** ហេតុដែលឱ្យកើតបុណ្យមានប៉ុន្មានយ៉ាង? អ្វីខ្លះ?

**ច-** ហេតុដែលនាំឱ្យកើតបុណ្យមាន ៣ យ៉ាងគឺ

**១- បសាទោ** មានចិត្តជ្រះថ្លា

**២- សំវេគោ** មានចិត្តតក់ស្លុត

**៣- តេសុចរិតា** មានសេចក្ដីស្អាតដោយ កាយ វាចា ចិត្ត ។

មនុស្សយើង កាលបើមានចិត្តជ្រះថ្លាចំពោះកុសល បានកំចាត់បង់នូវមច្ឆរិយៈ ទើបលះបង់ទ្រព្យសម្បត្តិធ្វើជាទានជាហេតុឱ្យកើតបុណ្យ ។

កាលបើមានសេចក្ដីតក់ស្លុតចំពោះសត្វនិងសង្ខារ ហើយមានសេចក្ដីសង្វេគ ឱ! អ្វីក៏មិនទៀងទាត់ដែរ សុទ្ធតែធ្លាក់ចុះក្នុងព្រះត្រៃលក្ខណ៍ទាំងអស់ ហើយមិនប្រមាទដែលជាផ្លូវនៃព្រះនិព្វាន ជាហេតុឱ្យកើតបុណ្យមួយដែរ ។

ម្យ៉ាងទៀត បើបុរសស្ត្រីណា ប្រកបដោយសុចរិត ៣ ប្រការគឺ កាយសុចរិត វចីសុចរិត មនោសុចរិត ក៏ជាហេតុឱ្យកើតបុណ្យមួយដែរ ។

**ស-** ចុះអ្នកធ្វើបុណ្យមានអានិសង្សប៉ុន្មានយ៉ាង ? ក្នុងអនាគតជាតិទៅ ចូររាប់មកមើល !

**ច-** អ្នកធ្វើបុណ្យមានអានិសង្ស ៥យ៉ាង ក្នុងអនាគតជាតិទៅគឺ

**១- តិក្ខបញ្ញាវិសារទោ** មានប្រាជ្ញាភ្លឺថ្លាមោះមុត

**២- សុវណ្ណតា** មានពណ៌សម្បុរល្អ

**៣- សុរូបតា** មានរូបស្អាតស្រស់ឆើត

**៤- សុសណ្ឋានា** មានទ្រង់ទ្រាយល្អ

**៥- ចក្កវត្តិរាជា ហោតិ** និងបានជាស្តេចចក្រពត្តិក្នុងជាតិណាមួយ ។

**ស-** ក្នុងជាតិនេះ អ្នកធ្វើបុណ្យបានទទួលផលដូចម្តេច ? ក្នុងបរលោកដូចម្តេច ?

**ច-** ក្នុងជាតិនេះ អ្នកធ្វើបុណ្យបានទទួលផលគឺសេចក្តីសុខចំរើន មានមនុស្សទូទៅរាប់អានស្រលាញ់ចូលចិត្ត កិត្តិសព្ទលាន់ឮក្នុងទិសទាំង ៤។ លុះធ្វើកាលកិរិយាទៅ បានទៅកើតក្នុងសុគតិភព ដូចមានពុទ្ធភាសិតសំដែងថា ÷

**ឥធ មោទតិ បេច្ច មោទតិ**
**កតបុញ្ញោ ឧភយត្ថ មោទតិ**

ប្រែ អ្នកបានធ្វើបុណ្យហើយ រមែងរីករាយសប្បាយក្នុងលោកទាំងពីរ គឺរីករាយសប្បាយក្នុងលោកនេះ លុះរំលាយខន្ធទៅកាន់លោកខាងមុខ រមែងរីករាយសប្បាយទៀត ។

ដូច្នេះ សាធុជនទាំងឡាយ គប្បីឱហាតសង្វាតធ្វើបុណ្យទោះតិចក្តី ច្រើនក្តី ព្រោះថា មានតែបុណ្យទេសំរាប់ទីពឹងក្នុងលោកខាងមុខ សមដូចពុទ្ធភាសិតថា **បុញ្ញានិ បរ~លោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ** បុណ្យជាទីពឹងពុំនាក់របស់សត្វលោកទាំងឡាយក្នុងលោកខាងមុខ ។

បានសេចក្តីថា សត្វទាំងឡាយដែលស្លាប់ទៅ មិនអាចស្ពាយគំនរទ្រព្យតាមបានទេ របស់ដែលស្ពាយជាស្បៀងអាហារមានតែ១គត់គឺ បុណ្យដែលយើងបានធ្វើ បានសន្សំនេះឯង ។

**ស~** ចុះមនុស្សតែម្នាក់ បើធ្វើបាបផង ធ្វើបុណ្យផង តើមនុស្សនោះ នឹងត្រូវទទួលផលបាបផលបុណ្យដូចម្តេច ?

**ឆ~** មនុស្សធ្វើបាបផង ធ្វើបុណ្យផងលាយគ្នា រមែងទទួលផលនៃបាប និងបុណ្យពុំខាន តែពុំមែនទទួលព្រមគ្នា

តែម្តងទេ បើបាបច្រើនជាង មានកម្លាំងជាង បាបក៏ឱ្យផល មុន តែថាបើបុណ្យច្រើនជាង មានកម្លាំងជាង បុណ្យក៏ឱ្យ ផលមុន ។

**ស~** ចុះបើបាបឱ្យផល ឬ បុណ្យឱ្យផលមុន តើបាប ឬ បុណ្យដែលគេបានធ្វើហើយ វាទៅឯណាទៅ ?

**ច~** បើបាប ឬ បុណ្យឱ្យផលមុន បាបឬបុណ្យនោះ មិន វលាយទៅណាទេ គ្រាន់តែសម្ងំចាំឱកាស និងឱ្យផល បើឱ-កាសបើកឱ្យពេលណា ពេលនោះ បាបឬបុណ្យ ក៏ចាប់ឱ្យ ផលភ្លាម តែបើមនុស្សបន្ថែមអំពើបាបកាន់តែខ្លាំងឡើង បាបក៏កាន់តែឱ្យផល បុណ្យសម្ងំនៅសិន បើមនុស្សបន្ថែម បុណ្យកាន់តែខ្លាំង កាន់តែច្រើន បាបក៏សម្ងំនៅ អស់បុណ្យ ពេលណា បាបដល់ភ្លាម ការនេះគ្រាន់តែផ្លាស់ប្តូរទៅតាម កំលាំងកម្មនីមួយ ៗ តែប៉ុណ្ណោះ ។

ព្រះសាស្តាទ្រង់បានជ្រាបច្បាស់ណាស់ថា សត្វដែលធ្វើ បាប ឬធ្វើបុណ្យ គ្មានអ្វីក្រៅពីអកុសលចិត្ត និងកុសលចិត្ត ដឹកនាំឱ្យធ្វើទេ ហេតុនេះបានជាព្រះអង្គសំដែងក្នុងបទទី ៣ ដូចតទៅ ។

## សំនួរក្នុងបទទី ៣

បទទី ៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងថា ឱ្យដុស ខាត់ចិត្តរបស់ខ្លួនឱ្យស្អាតផូរផង់ ។

**ស-** ឱ្យដុសខាត់ចិត្ត ឬជម្រះចិត្ត ត្រូវធ្វើដូចម្ដេច?

**ចៈ**-ការដុសលាងចិត្តឬជំរះចិត្ត គឺត្រូវដុសលាង ឬធ្វើយ៉ាងណាត្រាតែចិត្តបានស្អាត ។

**ស-** បើចិត្តគ្មានរូបផង ហេតុអ្វីក៏ថាចិត្តអាចប្រឡាក់បាន ?

**ចៈ** ពិតមែនតែចិត្តគ្មានរូប តែក៏អាចប្រឡាក់បានដែរ គឺប្រឡាក់ដោយអ្វី ដែលគ្មានរូបដូចគ្នា ប៉ុន្ដែគេមិនសូវនិយាយថា ចិត្តប្រឡាក់ទេគេនិយាយថា ចិត្តសៅហ្មង គឺចិត្តមិនស្អាត ដោយសារតែអារម្មណ៍អាក្រក់ ចូលមកលាយឡំ ។

**ស-** ចិត្តដែលសៅហ្មងដោយអារម្មណ៍ចូលមកលាយ-ឡំនោះ យ៉ាងណាខ្លះ ?

**ចៈ** ចិត្តជាធម្មជាតិមួយ នៅក្នុងរូបកាយនៃមនុស្ស និងសត្វដែលមានភារៈទទួលនូវអារម្មណ៍ទាំង ៦ គឺរូប សម្លេង ក្លិន រស សម្ផស្ស និងធម្មារម្មណ៍តាមទ្វារទាំង ៦ គឺភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ និង មនោ បើអារម្មណ៍នោះអាក្រក់ ក៏បណ្ដាលឱ្យចិត្តអាក្រក់ បើអារម្មណ៍នោះល្អ ក៏បណ្ដាលឱ្យចិត្តនោះល្អដែរ ។ ចិត្តតាមធម្មជាតិជាធម្មជាតិល្អ តែបើបែរជាអាក្រក់ទៅវិញ ក៏ដោយសារតែអារម្មណ៍ ពីខាងក្រៅអាក្រក់ចូលមកប៉ះពាល់ អារម្មណ៍ដែលធ្វើឱ្យចិត្តសៅហ្មង លោកហៅថា កិលេស ឬ ឧបក្កិលេស ។

**ស~** កិលេសដែលចូលមកធ្វើចិត្តឱ្យសៅហ្មងនោះ ដូចម្តេចខ្លះ ?

**ឆ~** កិលេស បើពោលដោយសង្ខេបមាន ៣ យ៉ាង ៦ យ៉ាង ១០ យ៉ាង ១៦ យ៉ាង បើពោលដោយពិស្តារមាន ១.៥០០ ។

កិលេសទាំងនេះ តែងចូលមកញ៉ាំញីចិត្តឱ្យសៅហ្មង ហើយជំរុញចិត្តឱ្យហ៊ានធ្វើបំពានទៅលើអំពើខុស អំពើអាក្រក់ តាមទ្វារទាំង ៣ គឺ កាយ វាចា និង មនោ ។

**ស~** ចុះបើកិលេសមានចំនួនច្រើនយ៉ាងនេះ ពេលដែលវាចូលមកញ៉ាំញីចិត្តឱ្យសៅហ្មង វាចូលមកទាំងអស់ឬដូចម្តេច?

**ឆ~** ទេ មិនមែនចូលមកព្រមគ្នាទាំងអស់ទេ បើកិ-លេសណាមួយចូលមកហើយ កិលេសឯទៀត មិនអាចចូលមកបាន ព្រោះអីចិត្តមានកន្លែងទទួលអារម្មណ៍តែមួយៗ ប៉ុន្តែ កិលេសដែលមានចំនួនច្រើនទាំងនោះចេញចូលមិនឈប់ មានអាការៈដូចជាផ្លាស់វេនគ្នា គឺ ១ ចេញ ១ ចូល មិនមានឱកាសទំនេរ ចិត្តនោះក៏ចេះតែប្រឡាក់ ចេះតែសៅហ្មងជានិច្ចទៅ ជាហេតុប្រព្រឹត្តធ្វើអំពើបាបអកុសលដរាបតទៅ ។

**ស-** ចុះកិច្ចដែលត្រូវដុសលាងចិត្ត សំអាតចិត្តឱ្យបានស្អាតបាតនោះ តើត្រូវយកអ្វីមកជំរះ មកដុសខាត់ ?

**ច-** កិច្ចដែលត្រូវដុសលាងជំរះចិត្តឱ្យបានស្អាតបាតនោះ ធៀបដូចជារូបកាយយើងដែលមានរូប បើត្រូវដុសលាងគេយករបស់មានរូប ដូចជាសាប៊ូជាដើម មកដុសលាងទើបបានស្អាតល្អ ឯចិត្តជារបស់គ្មានរូប គេក៏ត្រូវយករបស់គ្មានរូបដូចគ្នា មកជំរះដុសលាងឱ្យស្អាតបាតដែរ គឺគេយកធម៌ដែលឥតរូប ដែលមិនមែនជាកិលេស មកកំចាត់កិលេសធម៌នោះចេញ ទើបចិត្តនោះអាចត្រឡប់ទៅជាបរិសុទ្ធស្អាតបាន ឧទាហរណ៍ ដូចជាកិលេសគឺ ទោសៈ សេចក្តីខឹងក្រោធ ធ្វើចិត្តឱ្យសៅហ្មង បើត្រូវការកំចាត់ទោសៈ គេត្រូវយកមេត្តាធម៌មកកំចាត់ គឺអប់រំចិត្ត ធ្វើចិត្តឱ្យមានសេចក្តីអាណិតអាសូរ សន្តោសប្រណី ចំពោះអ្នកឯទៀតនោះ ទើបទោសៈរលត់ទៅ បើមោហៈ គឺការវង្វេងងងឹតល្ងង់ ធ្វើចិត្តឱ្យល្អក់កករ ត្រូវយកបញ្ញា គឺការអប់រំចិត្តឱ្យចេះពិចារណា ទើបមោហៈអាចរលត់ទៅឯងៗបាន ។

ព្រះសម្ពុទ្ធបានជ្រាបថា កិលេសធម៌មានច្រើនជាអនេក ដែលធ្វើចិត្តសត្វឱ្យសៅហ្មង មិនមែនតែមួយទេ ហេតុនេះ

បានជាព្រះអង្គសំដែងនូវធម៌ច្រើនប្រភេទ សំរាប់ជាមធ្យោបាយជំរះចិត្តឱ្យស្អាត ឬ ក៏សំរាប់កំចាត់នូវកិលេសទាំងនោះ ដោយសណ្ឋានច្រើនយ៉ាង ច្រើនបែបដូចគ្នាប្រៀបដូចគ្រូពេទ្យបង្កើតថ្នាំច្រើនមុខ សំរាប់ផ្សំឱ្យត្រូវចំសមុដ្ឋានរោគ ដែលកើតក្នុងរាងកាយនៃមនុស្សលោក ។ ឯរោគក្នុងរាងកាយនៃមនុស្សសត្វ ក៏មានរាប់ពាន់មុខដែរ ហើយចេះតែ កើតថ្មីៗថែមទៀត។ ព្រះបរមគ្រូបានជ្រាបរោគក្នុងចិត្តនៃ មនុស្សសត្វ គឺកិលេសធម៌នេះឯង ដែលគេចាត់ជារោគមាន ពិសកំណាចឃោរឃៅ ព្រមទាំងសមុដ្ឋានរបស់វា ទើបទ្រង់ប្រទាននូវឱសថដ៏ស័ក្តិសិទ្ធិ គឺព្រះធម៌ដ៏ច្រើនប្រភេទ សំរាប់កំចាត់រោគនោះៗ ។ ព្រះធម៌ដែលទុកជាឱសថមានច្រើនអនេក តែរាប់គោល៧ខ្លះដូចខាងក្រោម ÷

- **អប្បមាទធម៌** ការមិនធ្វេសប្រហែស ប្រាសចាកស្មារតី

- **កុសលមូល** គឺអលោភៈ អទោសៈ អមោហៈ

- **ត្រៃសិក្ខា** គឺសីល សមាធិ បញ្ញា

- **ការពិចារណានូវព្រះត្រៃលក្ខណ៍** គឺអនិច្ចំ ទុក្ខំ និង អនត្តា

- **សតិប្បដ្ឋាន ៤** មានកាយានុបស្សនាសតិប្បដ្ឋានជាដើម

- **ពោជ្ឈង្គ ៧** មានសតិសម្ពោជ្ឈង្គជាដើម

- **មគ្គមានអង្គ ៨** មានសម្មាទិដ្ឋិជាដើម

- **សមថភាវនា** និង **វិបស្សនាភាវនា**

ធម៌មានប៉ុណ្ណេះជាដើម អាចកំចាត់នូវកិលេសធម៌ក្នុងចិត្តបាន ។

**ស~** បើបានជំរះចិត្តឱ្យស្អាតបរិសុទ្ធផូរផង់ហើយ តើចិត្តនោះនឹងនាំឱ្យកើតផលប្រយោជន៍យ៉ាងណាខ្លះ ?

**ឆ~** ចិត្តបរិសុទ្ធហើយ អាចនាំឱ្យសម្រេចប្រយោជន៍ គឺសេចក្ដីសុខច្រើនប្រការណាស់ ក្នុងឥធលោក និងបរលោក រហូតដល់បរមសុខ ក្នុងព្រះនិព្វានជាអវសានជាតិ ដូចមានរៀបរាប់សង្ខេប តទៅ ÷

**ចិត្តេ បរិសុទ្ធេ សុគតិ បាតិកង្ខា**

កាលបើចិត្តបរិសុទ្ធហើយ សុគតិ គួរគប្បីប្រាថ្នាចុះ ។

**ចិត្តំ ទន្តំ សុខាវហំ** ចិត្តដែលបុគ្គលទូន្មានល្អហើយ រមែងនាំមកនូវសេចក្តីសុខ ។

**ស~** សុគតិ ប្រែថាដូចម្តេច ? មានប៉ុន្មានយ៉ាង ?

**ឆ~** សុគតិ ប្រែថា ដំណើរល្អមាន ២ យ៉ាងគឺ

**១~ បតិបត្តិសុគតិ** ដំណើរល្អក្នុងផ្លូវប្រតិបត្តិ សេចក្តីថា បុគ្គលដែលមានចិត្តស្អាតបរិសុទ្ធហើយ តែងប្រព្រឹត្តល្អ គឺ ធ្វើតែអំពើល្អ សុចរិត ។

**២~ គតិសុគតិ** ដំណើរល្អក្នុងសុគតិភព សេចក្តីថា អ្នកប្រតិបត្តិត្រឹមត្រូវដោយសុចរិតហើយ លុះធ្វើកាលកិរិយាទៅ រមែងទៅកើតកំណើតមនុស្សខ្លះ ទេវតាខ្លះ ។

**ស~** ចុះបើអ្នកមានចិត្តសៅហ្មង ប្រព្រឹត្តតែទុច្ចរិតធម៌ តើនឹងទៅជាអ្វី ?

**ឆ~** បើអ្នកមានចិត្តសៅហ្មង ប្រព្រឹត្តតែទុច្ចរិតធម៌ លុះធ្វើមរណកាលទៅ រមែងទៅកើតក្នុងទុគ្គតិ មានកើតក្នុង នរក ប្រេត អសុរកាយ តិរច្ឆានជាដើម ។

ចិត្តរបស់មនុស្សយើង ជាសភាវឃ្លេងឃ្លោងមិននៅនឹងមួយកន្លែង ហើយតែងទទួលអារម្មណ៍ពីខាងក្រៅតាមទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ដែលបង្កឱ្យចិត្តបរិសុទ្ធ ឬ

សៅហ្មងបាន សមដូចពុទ្ធភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទក-និកាយថា

**ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ**

ប្រែថា ចិត្តនេះឃ្លេងឃ្លោង ញាប់ញ័រ ពិបាករក្សា និងហាមឃាត់បានដោយលំបាក មានតែអ្នកមានប្រាជ្ញាទេដែលពត់លត់ដំ ចិត្តឱ្យត្រង់ស្អាតបាន ដូចជាជាងកូនសរ ពត់តម្រង់កូនសរ ឱ្យត្រង់គួរដល់បាញ់ចំចំណុចក្នុងទិសទាំង ៤ ដូច្នោះដែរ ។

**និគមវចនៈ**

ព្រះសាស្តាជាម្ចាស់លោកបានត្រាស់សំដែងធម៌ទាំង ៣បទនេះ ÷

**១~** ហាមមិនឱ្យសត្វប្រព្រឹត្តអាក្រក់

**២~** ឱ្យសត្វបំពេញតែកុសលគ្រប់យ៉ាង

**៣~** ឱ្យសត្វជំរះចិត្តឱ្យបរិសុទ្ធស្អាតចាកមន្ទិល នេះជាពុទ្ធសាសនា

គោលបំណងជាចម្បង គឺព្រះអង្គចង់ដឹកនាំឱ្យសត្វលោកចេញពីភពទាំងបី ដែលជាកន្លែងកើតស្លាប់មិនចេះចប់ មិន

ចេះហើយ ប្រកបដោយទុក្ខសោកក្រៃលែង ឱ្យបានដល់បរមសុខ គឺអមតៈ មហានិព្វាន គ្រប់ៗគ្នា ។

សំដែងអំពីពុទ្ធឱវាទទាំង ៣ បទសូមសាធុជនទាំងឡាយជួបតែសេចក្តីសុខចំរើនជានិរន្តរ៍ តទៅ ។

## សត្តមហាឋាន

បទបឋ្យាវត្ត

**បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិស្សកំ**

**តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនាឃរំ ។**

**បញ្ចមំ អជបាលញ្ច មុច្ចលិន្ទេន ឆដ្ឋមំ**

**សត្តមំ រាជាយតនំ សត្តាហំ មុនិ សេវិតំ។**

**ឯតេ សត្ត មហាឋានា ជម្ពូទីបេ បតិដ្ឋិតា**

**បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ។**

( ប្រែបទពាក្យ ៨ )

ទី១ បល្ល័ង្កដែលព្រះសាស្តា ចំរើនអានាបានស្សតិ

ទី២ ឮសានពីដើមពោធិ ហៅថាអនិមិស្សកចេតិយ ។

ទី៣ គឺទីដែលព្រះជិនស្រី ព្រះអង្គឃ្នាតខ្មីទ្រង់យាងចង្ក្រម

ទី៤ គឺទីដែលព្រះបរម ចំរើនអភិធម្មជាធម៌បរមត្ថ ។

ទី៥ គឺទីដែលព្រះភគវន្ត ទ្រង់គង់ស្ងប់ស្ងាត់ក្រោមអជ្ជបាល
ទី៦ ទីវិសេសវិសាល សរិតសំរាលក្បែរស្រះមុជ្ជលិន្ទ ។
ទី៧ គឺទីព្រះមុនិន្ទ សង្រួមកាយិន្ទ្រិយ៍រាជាយតនា
ទីទាំងប្រាំពីរដែលពោលនោះណា ជាទីថ្លៃថ្លាមានពិតប្រាកដ ។
ក្នុងជម្ពូទ្វីបនេះជាកំណត់ ប្រាជ្ញលោកសន្មតហៅថាឋានធំ
ព្រោះជាកន្លែងដ៏ល្អឧត្តម ជាទីមនោរម្យដល់មនុស្សទេវតា ។
ជាទីសំរាប់អ្នកមានសទ្ធា នាំគ្នាវន្ទាយកបុណ្យកុសល
ខ្ញុំសូមក្រាបថ្វាយបង្គំឆ្ពោះដល់ ឋានធំនិមលនោះពីចម្ងាយ ។

# អដ្ឋមហាឋាន

បទបឋ្យាវត្ត

**បឋមំ លុម្ពិនីជាតំ ទុតិយំ ពោធិមុត្តមំ**
**តតិយំ ធម្មចក្កញ្ច ចតុត្ថំ បាលិលេយ្យកំឧ**
**បញ្ចមំ ច នាឡាគិរី ឆដ្ឋមំ បាដិហារិយំ**
**សត្តមំ សិរិទេវិញ្ច អដ្ឋមំ បរិនិព្វុតំ ឧ**
**ឯតេ អដ្ឋ មហាឋានា ជម្ពូទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោឧ**

(ប្រែបទពាក្យ ៨)

ឋានធំទាំងឡាយ ៨កន្លែង ជាទីស្ងប់ស្ងែងដល់ពពួកសត្វ
ទី១ ឧទ្យានជាឋានព្រៃស្ងាត់ គឺព្រៃសាលរតន៍ដែលទ្រង់ប្រសូត្រ ។
ទី២ ប្រសើរដែលព្រះទ្រង់ស្រួត ត្រាស់ក្រោមដើមពោធិព្រឹក្សឧត្តម
ទី៣ កន្លែងដែលព្រះបរម សំដែងព្រះធម្មឈ្មោះធម្មចក្រ ។
ប្រោសភិក្ខុ ៥អង្គគឺពួកបញ្ចវគ្គ គឺយ៍ដែលជាអ្នកបម្រើព្រះអង្គ

ដោយព្រះទ័យថ្លៃមិនអាចលះបង់ ហើយយាងតម្រង់ពីដើមជ្រៃទៅ។
ទី៤ គឺទីដែលទ្រង់គង់នៅ ក្នុងព្រៃជ្រៅឈ្មោះថាបាលិលេយ្យ
ទីនោះគ្មានមនុស្សមានតែសត្វព្រៃ គឺដំរីថ្លៃបំរើព្រះអង្គ ។
ទី៥ គឺទីដែលព្រះពុទ្ធអង្គ ផ្ចាញ់សត្វទ្រនង់នាឡាគិរី
ទីនោះមានមនុស្សបែកពួកជាទ្វី ទៅមើលពិធីនៃព្រះសម្ពុទ្ធ ។
ទី៦ កាលព្រះសព្វញ្ញុត ញាណជាមកុដត្រៃលោកាចារ្យ
ផ្ចាញ់និគ្រន្ថដោយបាដិហារ្យ ឈ្មោះល្បីអស្ចារ្យគ្មាននរណាដល់។
ទី៧ កាលព្រះទសពល គង់លើមណ្ឌលថ្មព្រះឥន្ទ្រា
ទ្រង់បានសំដែងនូវព្រះធម្មា ប្រាកដនាមថាធម៌អភិធម្ម ។
សងគុណមាតាដែលមានគុណធំ លើព្រះបរមសម្ពុទ្ធថ្លៃថ្លា
ទី៨ កាលអង្គព្រះសាស្តា ផ្ទុំក្រោមដើមសាលព្រឹក្សទាំងគូ
ពេលនោះឯងហើយព្រះសព្វញ្ញូ ព្រះអង្គជាគ្រូយាងចូលនិព្វាន
ឋានធំ ៨កន្លែងនោះមាន ប្រតិស្ឋានជម្ពូទ្វីបា ។
ជាទីដែលពួកមនុស្សនិងទេវតា មានចិត្តជ្រះថ្លាគួរទៅយង់យល់
ខ្ញុំសូមឱនកាយបង្គំឆ្ពោះដល់ ឋានធំនិមល ៨នេះឯង ។
សូមសុខចំរើនកើនយូរអង្វែង ទុក្ខទោសចំបែងកុំកើតមានឡើយ។

# សិរីឱន

(បទព្រហ្មគីតិ)

សិរិឱនលំទោនកាយ ហត្ថាថ្វាយបង្គំផ្ចង់
ចិត្តស្មោះចំពោះត្រង់ អង្គព្រះមុនិន្ទពិនលោកា។
កាលទ្រង់គង់ទៅឡើយ ព្រះគុណអើយតែងមេត្តា

ប្រោសសត្វមនុស្សទេវតា រាល់វេលាពុំដែលខាន ។
ឥឡូវព្រះពុទ្ធអង្គ នឹងទ្រាំគង់យូរពុំបាន
យាងចូលកាន់និព្វាន ខានទូន្មានយើងរាល់គ្នា ។
សាវ័កព្រះជាម្ចាស់ គង់ច្រើនណាស់នៅត្រៀបត្រា
បាត់តែអង្គសាស្តា ពីគ្រានោះលុះឥឡូវ ។
រឿងនេះសែនវិវេក គួរសង្វេគពេកណាស់កូវ
ព្រះរូបគង់ច្រងូវ សត្វត្រូវពឹងយកនិស្ស័យ ។
ពេញបូណ៌វិសាខា ថ្ងៃនេះណាព្រះម្ចាស់ថ្លៃ
ប្រសូត្រចេញចាកផ្ទៃ និងក្សត្រថ្លៃចេញបព្វជ្ជា ។
បានត្រាស់ពោធិញាណ ចូលនិព្វានឋានសោភា
ពេញបូណ៌វិសាខា មានចរិតបួននេះឯង ។
កាលស្ដេចនិព្វានទៅ សាវ័កនៅគិតកោតក្រែង
រៀបធ្វើគ្រឿងតាក់តែង រាល់វេលាតែរៀងរាប់ ។
មកដល់ឥឡូវនេះ យើងខ្ញុំនេះវន្ទាក្រាប
នឹកដល់ព្រះទ្រង់ភាព ជាបុញ្ញលាភទាន់សាសនា ។
ខ្ញុំបានគោរពហើយ ព្រះគុណអើយខ្ញុំប្រាថ្នា
ទាន់ព្រះមេត្តេយ្យា ត្រាស់ឯក្រោយដោយប្រពៃ ។
ពាក្យប៉ងបំណងណាត់ កុំបីភ្លាត់ឡើយម្ចាស់ថ្លៃ
សូមទាន់ព្រះមេត្តេយ្យ គ្រាន់អាស្រ័យទៅនិព្វាន ។

# ភាសិតោវាទ

**ឱកាស** ខ្ញុំសូមគោរព !

**យោ បន[១] ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ ។**

[១] - ច្បាប់ខ្លះ យោ បន ភិក្ខុ

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រតិបត្តិតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្ដីគោរពរាប់អានបូជានូវព្រះតថាគតដោយបដិបត្តិបូជា ជាបូជាដ៏ឧត្ដម ។

**សព្វបាបស្ស អករណំ កុសលស្សូបសម្បទា**
**សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ ។**

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**ខន្តី បរមំ តបោ តីតិក្ខា និព្វានំ បរមំ**
**វទន្តិ ពុទ្ធា ន ហិ បព្វជិតោ បរូបឃាតី**
**សមណោ ហោតិ បរំ វិហេឋយន្តោ ។**

អំណត់គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

**អនូបវាទោ អនូបឃាតោ បាតិមោក្ខេ ច**
**សំវរោ មត្តញ្ញុតា ច ភត្តស្មឹ បន្តញ្ច**
**សយនាសនំ អធិចិត្តេ ច អាយោគោ ឯតំ**
**ពុទ្ធាន សាសនំ ។**

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាតិមោក្ខ ១ ការដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

**សីលសមាធិគុណានំ ខន្តី បធានការណំ**

្ល

**សព្វេបិ កុសលា ធម្មា ខន្ត្យាយេវ**
**វឌ្ឍន្តិ តេ ។**

សេចក្តីអត់ធន់ជាហេតុ ជាទីតាំងនៃគុណ គឺសីល និង សមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសល ទាំងអស់នេះ តែងចំរើនដោយសេចក្តីអត់ធន់មែនពិត ។

**កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ**
**គរហាកលហាទីនំ មូលំ ខណតិ ខន្តិកោ ។**

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយ ទាំងអស់ បុគ្គលអ្នកអត់ធន់នោះឈ្មោះថា ជីករំលើងនូវឫស ទាំងឡាយ មានពាក្យតិះដៀល និងការឈ្លោះប្រកែក ជា ដើម ។

**ខន្តិ ធីរស្ស លង្ការោ ខន្តិ តបោ តបស្សិ-**
**នោ ខន្តិ ពលំ វ យតីនំ ខន្តិ ហិតសុ-**
**ខាវហា ។**

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តី អត់ធន់ ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ធន់ជាកម្លាំង របស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ ធន់ជាគុណជាតិនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

**ខន្តិកោ មេត្តវា លាភី យសស្សី សុខ-
សីលវា បិយោ ទេវមនុស្សានំ មនាបោ
ហោតិ ខន្តិកោ ។**

អ្នកអត់ធន់ ជាអ្នកមានមិត្តសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្ដីសុខជាប្រក្រតី អ្នកអត់ធន់រមែងជាទីស្រលាញ់ ជាទីគាប់ចិត្តនៃទេវតា និងមនុស្សទាំងឡាយ ។

**អត្តនោបិ បរេសញ្ច អត្ថាវហោ ច ខន្តិ-
កោ សគ្គមោក្ខគមំ មគ្គំ អារូឡ្ហោ ហោតិ
ខន្តិកោ ។**

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទីទៅកាន់ស្ថានសួគ៌ និងព្រះនិព្វាន ។

**សត្ថុនោ វចនោវាទំ ករោតិយេវ ខន្តិកោ
បរមាយ ច បូជាយ ជិនំ បូជេតិ ខន្តិកោ ។**

អ្នកអត់ធន់ ឈ្មោះថាធ្វើតាម នូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្ដាមែនពិត អ្នកអត់ធន់ឈ្មោះថា បូជានូវព្រះវិជិតមារ ដោយការបូជាដ៏ ឧត្តម ។

**ទុល្លភព្ភ មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្ល**
**ភោ ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរម**
**ទុល្លភោ ។**

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិ-
យាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិ-
យាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹង
ព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់
សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង ។

**សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា**
**សុខា សង្ឃស្ស សាមគ្គី សមគ្គានំ តបោ**
**សុខោ ។**

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តី
សុខ កិរិយាសំដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តី
សុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នា ទាំង-
ឡាយ នាំមកនូវសេចក្តីសុខ ។

**សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស**
**បស្សតោ អព្យាបជ្ឈំ សុខំ លោកេ**
**បាណភូតេសុ សញ្ញមោ ។**

សេចក្តីស្ងប់ស្ងាត់របស់អ្នកដែលត្រេកអរ ( ក្នុងទីស្ងាត់ ) ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញ ( នូវធម៌ ) នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន គឺកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

**សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ**
**អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ ។**

ភាវៈ ប្រាសចាករាគៈ គឺកិរិយាកន្លងនូវកាមទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិ-មានៈ នាំមកនូវសេចក្តីសុខដ៏ឧត្តម ។

**កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ ។**

កិរិយាត្រលប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្តីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្ម ជាការលំបាក កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយជាការលំបាក ។

**សត្ថុនោ សទ្ធម្មំ សុត្វា សព្វស្មឹ ជិនសាសនេ**
**កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន**
**គច្ឆតិ ។**

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា ( ដែល

រាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះ រមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

**បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ**
**បទោសេ ភិក្ខុ ឱវាទំ អឌ្ឍរត្តេ ទេវបញ្ហានំ**
**បច្ចូសេវ កតេ កាលេ ភព្វាភព្វេ វិលោកនំ**
**ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោតិ ។**

ព្រះសម្មាសម្ពុទ្ធជាចម្បងជាងអស់អ្នកប្រាជ្ញទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះ គឺក្នុងពេលព្រឹក ទ្រង់ស្ដេចយាងទៅបិណ្ឌបាត ១ ក្នុងពេលល្ងាច ទ្រង់សម្ដែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិត ភ្លឺ[1] ទ្រង់ប្រមើលនូវសត្វលោក ដែលគួរត្រាស់ដឹង និងមិន គួរត្រាស់ដឹង១ ។

**កុក្កុដេ គព្ភវាសោ ច សោណោ ចុនរនិក្ខមិ**
**ឧសភេ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ ។**

---

[1] ក្នុងអដ្ឋកថា ធម្មបទសំដែងថា ព្រះអង្គប្រមើលមើលឧប្បនិស្ស័យ សត្វ ១ ថ្ងៃ ១យប់ ២ដង ក្នុងពេលជិតភ្លឺម្ដង ពេលល្ងាចម្ដង ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្ដាប់មាត់ចក្រវាឡមកដល់គន្ធកុដិ ពេលល្ងាចទ្រង់ប្រមើលពីគន្ធកុដិរហូតដល់កណ្ដាប់ចក្រវាឡ ។

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូត្រចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិនៅក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

**កុក្កុដេ សព្វញ្ញូ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ**
**និព្វានគមនំ សប្បេ សហស្សំ បញ្ចមូសិកេ ។**

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញូពុទ្ធក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្រក្នុងឆ្នាំថោះ ទ្រង់យាងចូលព្រះនិព្វាននៅក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥,000គត់ក្នុងឆ្នាំជូត ។

**ឱក្កន្តោ ច គុរុវារស្មឹ សុក្រវារេ ច និក្ខមិ**
**សម្ពុទ្ធោ ពុធវារស្មឹ អង្គារេ បរិនិព្វុតោ ។**

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជា ព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

**អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ**
**វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ ។**

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ប្រសូត្រក្នុងថ្ងៃពេញបូណ៌មី ខែ

វិសាខ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃ ពេញបូណ៌មី ខែវិសាខ បរិនិព្វាន ក្នុងថ្ងៃពេញបូណ៌មី ខែវិសាខ ។

**និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ**
**បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ**
**ចតុរាសីតិសហស្ស ធម្មក្ខន្ធា សុទេសិតា**
**អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ បាណិនំ ។**

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គលជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះសថូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ ម៉ឺន ៤ ពាន់ ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយ ដោយប្រពៃផង ជាវត្ថុគឺព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងស្ថានដែលប្រព្រឹត្តទៅ ដើម្បីជាបុញ្ញខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

**ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ**
**ឋបេត្វា សម្មាសម្ពុទ្ធេន វុត្តប្បការេន បដិបត្តិ**
**បូជាយ បូជំ ករោន្តេន លោកិយលោកុត្តរ-**
**សម្បត្តិសិទ្ធិំ កាតព្វំ ឱកាស អារាធនំ ករោមិ ។**

បុគ្គលគួរដកលស់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែង ហើយទុកក្នុងចិត្ត ហើយធ្វើការបូជា ដោយបតិបត្តិបូជា

ដោយនូវប្រការ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង ហើយ គួរធ្វើឱ្យសំរេចនូវសម្បត្តិជាលោកិយ និងលោកុត្តរៈ ខ្ញុំសូមគោរព អារាធនាទុកដោយប្រការដូច្នេះ ។

**ឱកាស សិរីសក្យមុនិសព្វញ្ញុពុទ្ធស្ស ពលវប្ប-ច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អម្ពុម្ហិ សប្បសំវច្ឆរេ គិម្ហ ឧតុម្ហិ វិសាខមា-សេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ ភុម្មវារេ ភុម្មយាមេ អនុរាធនក្ខត្តទិវសេ បរិព្វានំ អហោ-សិ អនុបាទិសេសាយ និព្វានធាតុយា ៕**

ខ្ញុំសូមគោរព! សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ ជាតិថីពេញបូណ៌មីខាងខ្នើតនៃ ខែវិសាខក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង ។

(តពីនេះទៅត្រូវបកសករាជប្រាប់ថ្ងៃ ខែ ឆ្នាំ ដែលកន្លងហើយ និងបច្ចុប្បន្ន និងអនាគតដរាបដល់ចប់)

**បច្ឆិមពុទ្ធវចនៈ**

**យោ វោ អានន្ទ មយា ធម្មោ**

**ច វិនយោ ច ទេសិតោ បញ្ញត្តោ**

ម្នាលអានន្ទ សភាវឯណាព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថា-គតបានសំដែងហើយ បានបញ្ញត្តិហើយ ដល់អ្នកទាំងឡាយ ។

**សោ វោ មមច្ចយេន សត្ថា**

សភាវគឺព្រះធម៌ និងព្រះវិន័យនោះ លុះអំណើះតតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**អហំ ឯកកោវ បរិនិព្វានយិស្សាមិ**

តថាគតជាព្រះពុទ្ធមួយអង្គឯងពិត នឹងបរិនិព្វានទៅ ។

**អហញ្ចុ បនិទានិ ឯកកោវ**

**ឱវាទាមិ អនុសាសេមិ**

តែថាឥឡូវនេះ តថាគតជាព្រះពុទ្ធមួយអង្គឯងពិត តែងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

**មយិ បរិនិព្វុតេ**

កាលបើតថាគត បរិនិព្វានទៅហើយ ។

**ឥមានិ ចតុរាសីតិធម្មក្ខន្ធសហស្សានិ**

**តុម្ហេ ឱវទិស្សន្តិ អនុសាសិស្សន្តិ**

ព្រះធម្មក្ខន្ធ ប្រាំបីម៉ឺនបួនពាន់នេះ នឹងទូន្មានប្រៀនប្រដៅនូវអ្នកទាំងឡាយជាខាងក្រោយ ។

**យោ កោចិ អានន្ទ ភិក្ខុ វា ភិក្ខុនី វា**
**ឧបាសកោ វា ឧបាសិកា វា**
**ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិ**
**បដិបន្នោ អនុធម្មចារី**

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិធម្មវិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាមធម៌វិន័យជាប្រក្រតី ។

**សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ**
**បូជេតិ បរមាយ បូជាយ បដិបត្តិបូជាយ**

បុគ្គលទាំងអស់នោះ បានឈ្មោះថា ធ្វើសក្ការៈនឹងតថាគត ធ្វើនូវសេចក្តីគោរពតថាគត រាប់អាននូវតថាគត បូជានូវតថាគត ដោយបដិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

**ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ**
**ភិក្ខវេ ខយវយធម្មា សង្ខារា អប្បមាទេន**
**សម្បាទេថាតិ ឥទម្បច្ឆិមពុទ្ធវចនំ**

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងផ្តាំនូវអ្នកទាំងឡាយឱ្យបានដឹងគ្រប់គ្នា នៃភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅ និងសាបសូន្យទៅជាធម្មតា។ អ្នករាល់គ្នាចូរញ៉ាំងប្រយោជន៍ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្តែតបណ្តោយក្នុងធម៌វិន័យពាក្យប្រៀនប្រដៅមានប្រមាណប៉ុណ្ណេះជាដើមនេះ ឈ្មោះថា បច្ឆិមពុទ្ធវចនៈ ជាពាក្យផ្តាំ ពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង។

**ឧភិន្នមន្តរេ យំ វុត្តំ ឯតំ មជ្ឈិមពុទ្ធវចនំ**

ពាក្យប្រដៅឯណា ដែលទ្រង់ត្រាស់ពោលជាចន្លោះនៃបឋមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈទាំងពីរនេះ ពាក្យប្រដៅនោះ ឈ្មោះថាមជ្ឈិមពុទ្ធវចនៈ គឺពាក្យប្រដៅជាកណ្តាលរបស់ ព្រះពុទ្ធជាបរមគ្រូ (នៃយើង) ។

**ចប់បច្ឆិមពុទ្ធវចនៈ**

# របៀបធ្វើមាឃបូជា និង វិសាខបូជា

(ដោយភិក្ខុ **បញ្ញាសារោ នុយ សុភគ្គា**)

## ១~ មាឃបូជា

### រតនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្សការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វ-ទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មា-សម្ពុទ្ធំ អាទរេន នមស្សាម ។**

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខ-ស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។**

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកម្ចាត់បង់នូវទុក្ខទាំងពួង ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះ-អង្គសូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវក~សង្ឃោ យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាម ៗ**

ព្រះអរិយសង្ឃណា លោកប្រតិបត្តិដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង)

## <u>ប្រកាសមាឃបូជា</u>

ថ្ងៃនេះជាតិថី ពេញបូរមីនៃខែមាឃ មានព្រះច័ន្ទពេញវង់ ត្រូវនឹងថ្ងៃនៃសាវ័កសន្និបាត របស់ព្រះសក្យមុនីអរហន្តសម្មាសម្ពុទ្ធ ជាបរមគ្រូនៃយើង សាវ័កសន្និបាតនោះ ប្រកបដោយអង្គ ៤ គឺថ្ងៃពេញបូរមី ខែមាឃ មានព្រះចន្ទចរចូលមាឃនក្ខត្តឫក្ស នេះជាអង្គទី ១ ព្រះភិក្ខុសង្ឃមានចំនួន ១.២៥០ អង្គ ឥតមានអ្នកណានិមន្ត ឬណាត់ពេលគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នាក្នុងសំណាក់ នៃព្រះបរមគ្រូនាវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋនៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២ ព្រះភិក្ខុសង្ឃទាំង ១២

៥០ អង្គនោះ សុទ្ធតែជាឯហិភិក្ខុដូចគ្នាទាំងអស់ នេះជាអង្គទី ៣ ព្រះភិក្ខុសង្ឃទាំង ១២៥០ អង្គនោះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ នេះជាអង្គទី ៤ ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្តែង នូវឱវាទបា្បតិមោក្ខ ក្នុងទីប្រជុំនៃព្រះភិក្ខុសង្ឃនោះ។ ការប្រជុំ សាវ័កបែបនេះ ហៅថា "**ចតុរង្គសន្និបាត**" គឺការប្រជុំប្រកប ដោយអង្គ ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនី បរមគ្រូនៃយើង មានតែម្តងប៉ុណ្ណោះ។ មួយទៀត កាលដែលព្រះបរមសាស្តា នៃយើងទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែបើគិតតាមចំនួនថ្ងៃ នៅខ្វះ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់ នូវព្រះជន្មាយុសង្ខារថា ម្នាលភិក្ខុទាំងឡាយគិតពីថ្ងៃនេះទៅ នៅខ្វះតែ ៣ ខែទៀតទេតថាគតនឹងរំលត់ខន្ធចូលកាន់ ព្រះនិព្វាន។ ការកំណត់ជន្មាយុនេះ នៅថ្ងៃ ១៥ កើត ខែមាឃដែរ។ តិថីនេះជាឧបលក្ខិតសម័យ មួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថប្រជុំគ្នាធ្វើសក្ការៈបូជា ចំពោះព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ ជាបរម ពុទ្ធោវាទ និងព្រះអរិយសង្ឃជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកជួបជុំគ្នា បានរៀបគ្រឿងសក្ការបូជា មានទៀនធូប និងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ គង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា យើងខ្ញុំសូមថ្វាយនូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះ-អង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គលរបស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយត្រឹមស្មើដោយព្រះអង្គឡើយ ទោះបីព្រះអង្គចូលបរិនិព្វានបាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ថាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដដែរ ។

សូមព្រះដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តាទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើង

ខ្ញុំព្រះអង្គ បានប្រកបដោយ ឥដ្ឋមនុញ្ញផលវិបុលសុខ និង សេចក្ដីចំរើន ដ៏ធំទូលាយ អស់កាលជាអង្វែងទៅ ។

## <u>នមោ ៨ បទ</u>

បទបវ្យារវដ្ដ

**នមោ អរ- ហតោសម្មា**
**សម្ពុទ្ធស្ស មហេសិនោ**

ខ្ញុំសូមបង្គំ ឆ្ពោះព្រះអរហន្ត- សម្ពុទ្ធភគវន្ត កាលស្វែងរកធម៌
គឺពោធិញ្ញាណ ប្រសើរបវរ បានត្រាស់ដឹងធម៌ ដោយអរិយមគ្គ ។

**នមោ ឧត្ត- ម ធម្មស្ស**
**ស្វាក្ខា តស្សេ- វ តេនិធ**

សូមថ្វាយបង្គំ ព្រះធម៌ឧត្ដម ដែលព្រះបរមគ្រូ សម្ពុទ្ធសម្ដែង
ដោយប្រពៃពិត ប្រាកដជាក់ស្ដែង ព្រះធម៌នោះឯង ទុកជាសាសនា ។

**នមោ មហា- សង្ឃស្សាបិ**
**វិសុទ្ធសី- ល ទិដ្ឋិនោ**

សូមថ្វាយបង្គំ ព្រះសង្ឃប្រសើរ ដែលលោកបានធ្វើ ទិដ្ឋិ និងសីល
ឱ្យបានបរិសុទ្ធ ផុតចាកមន្ទិល គឺទិដ្ឋិសីល លោកស្អាតអស់ហើយ ។

**នមោ ឱមា- ត្យារទ្ធស្ស**
**រតនត្តយ- ស្ស សាធុកំ**

សូមថ្វាយបង្គំ ប្រជុំត្រ័យរត្ន័ ប្រារព្ធដោយបទ មានបីប្រការ

ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃនេះណា ប្រសើរថ្លៃថ្លា ថ្លឹងថ្លែងពុំបាន ។

**នមោ ខ្មិម- ភាគី តស្ស**

**តស្ស ខត្ត- ត្តយស្សាមិ**

សូមថ្វាយបង្គំ ភ្នំរត្នបី ពិសេសពិសី ប្រសើរថ្កើនថ្កាន

ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃសព្វស្ថាន តេជះកល្យាណដោយគុណគូគាប់ ។

**នមោ ភារា- ប្បភាវេន**

**វិគច្ឆន្តុ ឧបទ្ទវា**

សូមថ្វាយបង្គំ ត្រ័យរតន៍សោភា ឧបទ្រពនានា ចូរវិនាសបាត់

ដោយអានុភាព បុណ្យជួយកំចាត់ ធ្វើក្ដីវិបត្តិ ឱ្យស្ងាត់សូន្យទៅ ។

**នមោ ភារា- នុភាវេន**

**សុវត្ថិ ហោ- តុសព្វទា**

សូមថ្វាយបង្គំ ត្រ័យរតន៍ទាំងបី សូមសុខសួស្ដី កើតសព្វវេលា

ដោយអានុភាព ធ្វើការវន្ទា គោរពបូជា ព្រះត្រ័យរតនៈ ។

**នមោ ភារៈ- ស្ស តេជេន**

**វិធិម្ហិ ហោ- មិ តេជវា**

សូមថ្វាយបង្គំ ត្រ័យរតន៍សោភា តេជះចេស្ដា ចូរមានដល់ខ្ញុំ

ក្នុងពិធីធ្វើការថ្វាយបង្គំ តេជះបុណ្យធំ ចូរកើតឡើងហោង ។

## <u>គាថាប្រារព្ធមាឃបូជា</u>

**មាឃនក្ខត្តយុត្តាយ បុណ្ណាយ បុណ្ណមាយំ យោ**

| | |
|---|---|
| អរហំ សម្មាសម្ពុទ្ធោ | ភគវា គោតមវ្ហយោ |
| សុទ្ធានន្តនយោ ញាណោ | សត្ថា លោកេ អនុត្តរោ |
| វិហរន្តោ រាជគ្គហេ | មគធានំ គិរិព្វជេ |
| វិហារេ វេឡុវនេ វ | កលន្ទកនិវាបិយេ |
| សង្ឃស្ស សន្និបាតម្ហិ | ឧត្តមេ ចតុរង្គិកេ |
| អឌ្ឍតេលសេហិ ភិក្ខុ~ | សតេហិ បរិវារិតោ |
| តីហិ គាថាហិ សង្ខិបំ | សព្វំ ពុទ្ធាន សាសនំ |
| សមោសារេហិ ឱវាទំ | បាតិមោក្ខំ អនុត្តរំ |
| តមេវម្ភូតសម្ពុទ្ធំ | សខីណាសសាវកំ |
| ចិរកាលមតីតម្បិ | បសាទេន អនុស្សរំ |
| អយម្បិ បរិសា សព្វា | បសន្នា ធម្មគាមិនី |
| សម្បត្តា តាទិសំ តាសំ | សុនក្ខត្តំ សុមង្គលំ |
| ទីបធូបាទិសក្ការេ | អភិសង្ខ យថាពលំ |
| តេហិ បូជេ តវេហដ្ឋ~ | តុដ្ឋា ឥធ សមាគតា |
| អភិវន្ទតិ បូជេតិ | ភគវន្តំ សសាវកំ |
| កាលេន សម្មុខី ភូតំ | អតីតារម្មណត្តនា |
| ឱសារេន្តំ បាតិមោក្ខំ | វិសុទ្ធត្តម្មុបោសថេ |
| ឥតោ ជេន សុបុញ្ញេន | សោត្ថិ ហោតុសទាបិ នោ |
| សាសនំ សត្ថុ អម្ហាកំ | ចិរំ ទិប្បតុ តាទិនោ ៗ |

(ប្រែឃ្លោងពាក្យ ៧ កាព្យ)

ព្រះមានព្រះភាគអង្គណា ទ្រង់ព្រះនាមថា **ព្រះគោតម**
កម្ចាត់កិលេសទាំងតូចធំ មិនមានរូបរំសន្ទាននៅ ។
ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ឥតគ្រូដទៃប្រៀនប្រដៅ
ទ្រង់មានចរិយាឥតហ្មងសៅ ករុណាឆ្ពោះទៅសព្វគ្រប់គ្នា ។
និងបញ្ញាគុណចាក់ធ្លុះធ្លាយ ជ្រៅឆ្ងាយទូលាយអនន្តា
ព្រះអង្គជាគ្រូក្នុងលោកា ឥតមានគ្រូណាប្រៀបផ្ទឹមបាន ។
ទ្រង់គង់នៅក្នុងវត្តព្រះវេឡុវន័ ជាទីកលន្ទកនិវាបស្ថាន
ជិតក្រុងរាជគ្រឹះដែនបុរាណ ដែលប្រាកដមានក្នុងមគធា ។
ភិក្ខុអរហន្តដ៏ពណ្ណរាយ ពាន់ពីររយឬយហាសិបណា
ចូលទៅគង់គាល់ត្រៀបត្រា កបដោយឋានាដ៏ឧត្តម ។
ហើយទើបព្រះអង្គទ្រង់សន្និបាត សម្ដែងឱវាទបា្បតិមោក្ខសម
ចំពោះភិក្ខុសង្ឃដ៏ឧត្តម ដែលមកជួបជុំនៅពេលនេះ ។
ជាសាសនានៃព្រះពុទ្ធម្ចាស់ គ្រប់អង្គតែងត្រាស់ឥតមានមោះ
យ៉ាងសង្ខេបខ្លីល្មមពិរោះ ដោយគាថានោះតែបីបទ ។
ក្នុងថ្ងៃពេញបូណ៌មីមាឃា កបនក្ខត្តាល្អប្រាកដ
ហើយប្រជុំភិក្ខុកំណត់ ទ្រង់សម្ដែងបទវិនយា ។
ជាច្បាប់សម្រាប់ភិក្ខុខ្ជី ពោលគឺបាលីបាតិមោក្ខា
មានអត្ថបរិសុទ្ធដ៏ថ្លៃថ្លា សូធ្យថ្ងៃឧបោសថាតាមបវេណី ។
មួយទៀតកាលអង្គព្រះសុគត សម្រេចឥរិយាបថក្រុងវេសាលី
មានភិក្ខុចោមរោមជាប្រក្រតី ទ្រង់ប្រោសសេចក្ដីឱ្យដឹងដាន ។
ថានៅតែបីខែទៀតទេ ទ្រង់នឹងបែររេចូលនិព្វាន

បរិស័ទទាំងពួងយើងខ្ញុំមាន ក្តីជ្រះថ្លាបានទាន់គ្រប់ធមិ ។
យើងខ្ញុំសូមលើកព្រះសម្ពុទ្ធ និងសង្ឃជាបុត្រខីណាស្រព
និព្វានកន្លងយូរថ្ងៃយប់ នឹកមិនមានឈប់ដោយជ្រះថ្លា ។
យើងខ្ញុំបានដល់នក្ខត្តឬក្ស មង្គលអឹកៈធឹកធំណាស់ណា
បាននាំគ្នាធ្វើសក្ការា ទៀនធូបជាអាទិ៍តាមប្រឹងប្រែង ។
យើងខ្ញុំមានចិត្តត្រេកអរីករាយ ជួបជុំខ្វល់ខ្វាយទីនេះឯង
ដើម្បីសក្ការៈតាក់តែង បូជាកោតក្រែងដោយផ្ចិតផ្ចង់ ។
សូមថ្វាយបង្គំ សូមបូជា ឆ្ពោះព្រះភគវាសាវ័កសង្ឃ
តាមកាលឆ្ពោះភ័ក្រ្តនៃព្រះអង្គ និព្វានយូរលង់នោះហើយក្តី ។
កាលដែលសម្តែងព្រះបាតិមោក្ខ ខែមាឃមានជោគបុណ្ណមី
ព្រះចន្ទ័ចាំងថែងរឿងរង្សី ឧបោសថពិសីបរិសុទ្ធា ។
ដោយបុណ្យបូជាដោយសទ្ធា សួស្តីសោភាមានគ្រប់គ្រា
សាសនាសាស្តាយើងរាល់គ្នា ថ្កុំថ្កើងចិរាយូរអង្វែង ។

(ចប់គាថាមាឃបូជា)

## <u>នមស្សការកាលទ្រង់ប្រជុំឱវាទបាតិមោក្ខ</u>

**អរហាពន្លេច ទេសេន្ត៌ សន្និបាតេ ចតុរង្គិកំ**
**ឱវាទបាតិមោក្ខម្ហិ មាឃនក្ខត្តទិវសេ ។**
**បរិសុទ្ធន្តមោវាទំ លោកជេដ្ឋេន ភាសិតំ**
**សុណន្តន្តំ ខណពន្លេច ខីណាសវំ នមាមិហំ ។**

(ប្រែឃ្លោងពាក្យ ៨ កាព្យ)

សូមថ្វាយបង្គំ ព្រះអរហំ គង់ក្នុងចតុរង្គសន្និបាត
ត្រាស់សម្តែងធមិដ៏ល្អស្អាត ពោលគឺឱវាទបា្បតិមោក្ខ ។
ក្នុងថ្ងៃដែលជានក្ខត្តឫក្ស ព្រះចន្ទអឹកៈធឹកផ្កាយគគោក
ថ្ងៃពេញបុណ្ណមីមាឃមានជោគ ដែលលោកសន្មតឧបោសថា ។
ព្រមទាំងឱវាទល្អស្អាតកន្លង ដែលព្រះជាច្បងជាងលោកទាំង៣
ព្រមទាំងព្រះសង្ឃពុំមានចំណោង កិលេសកម្មកងទិដ្ឋិតណ្ហា
ជាខីណាស្រេពស្តាប់ធមិទេសនា នៃព្រះសាស្តាគ្រានោះឯងហោង ។

**<u>នមស្សការកាលទ្រង់ដាក់ជន្នាយុសង្ខារ</u>**

**អាទិច្ចពន្ធុសព្វញ្ញុំ មាឃនក្ខត្តទិវសេ**
**ឱស្សជ្ជន្នាយុសង្ខារំ ឱវាទន្តម្បិ ភិក្ខូនំ ។**
**និយ្យានិកន្តមោវាទំ ទិន្នំ អាទិច្ចពន្ធុនា**
**សុណន្តន្តំ ខណពោធ គណុត្តមំ នមាមិហំ ។**

(ប្រែឃ្លោងពាក្យ ៨ កាព្យ)

សូមថ្វាយបង្គំព្រះមារជិត ពូជពង្សអាទិត្យឫទ្ធិមហិមា
កាលទ្រង់ដាក់អាយុសង្ខារា បន្ថយជន្មាមិននៅយូរយារ ។
ហើយទ្រង់ទេសនាប្រោសប្រៀនប្រដៅ ភិក្ខុគង់នៅចាំស្តាប់ត្រៀបត្រា
ក្នុងថ្ងៃពេញបូណ៌មាឃមាសា ថ្ងៃនោះក៏ជាឧបោសថពិត ។
ព្រមទាំងឱវាទដែលនាំចម្លង អ្នកបានត្រាប់ត្រងឱ្យរួចទុក្ខពិត
ដែលព្រះជាពូជពង្សវង្សអាទិត្យ ទ្រង់បានពិនិត្យប្រទាននោះណា ។
ព្រមទាំងគណារិយបុគ្គល ឧត្តមសោតសល់ឥតឧបមា

ដែលលោកបានស្តាប់ត្រាប់ធមិទេសនា ក្នុងកាលនោះណាជាពេលប្រសើរ ។

**នមការានុភាវេន        ឯវំវុត្តនយេន បិ**

**សុខំ សិរី ច វុឌ្ឍី ច សោត្ថិ មេ ហោតុ សព្វទាឰ**

ដោយអានុភាពនៃការវន្ទា        តាមចិត្តសទ្ធាឆ្ពោះគុណត្រ័យរតន៍
ដូចខ្ញុំពណ៌នាដោយពាក្យហ្មត់ចត់    គ្រប់ទាំង៥បទនេះឯងមែនពិត ។
សូមសេចក្តីសុខចំរើនសក្តិសិទ្ធ        សិរីជិតព្រមទាំងសួស្តី
កើតមានដល់ខ្ញុំគ្រប់ទិនរាត្រី        គ្រប់កាលកុំបីចន្លោះសោះឡើយ ។

(ចប់កិរិយានមស្សការទាំងពីរ)

## គាថានមស្សការចំពោះព្រះពុទ្ធ ២៨ ព្រះអង្គ

**វន្ទេ តណ្ហង្ករំ ពុទ្ធំ        វន្ទេ មេធង្ករំ មុនឹ**
**សរណង្ករំ មុនឹ វន្ទេ        ទីបង្ករំ ជិនំ នមេ**
**វន្ទេ កោណ្ឌញ្ញសត្ថារំ    វន្ទេ មង្គលនាយកំ**
**វន្ទេ សុមនសម្ពុទ្ធំ        វន្ទេ រេវតនាយកំ**
**វន្ទេ សោភិតសម្ពុទ្ធំ    អនោមទស្សិំ មុនឹ នមេ**
**វន្ទេ បទុមសម្ពុទ្ធំ        វន្ទេ នារទនាយកំ**
**បទុមុត្តរំ មុនឹ វន្ទេ        វន្ទេ សុមេធនាយកំ**
**វន្ទេ សុជាតសម្ពុទ្ធំ        បិយទស្សិំ មុនឹ នមេ**
**អត្ថទស្សិំ មុនឹ វន្ទេ        ធម្មទស្សិំ ជិនំ នមេ**

**វន្ទេ សិទ្ធត្ថសត្ថារំ　　វន្ទេ តិស្សមហាមុនឹ**
**វន្ទេ ផុស្សមហាវីរំ　　វន្ទេ វិបស្សិនាយកំ**
**សិខី មហាមុនឹ វន្ទេ　　វន្ទេ វេស្សភូនាយកំ**
**កកុសន្ធំ មុនឹ វន្ទេ　　វន្ទេ កោនាគមនំ ជិនំ**
**កស្សបំ សុគតំ វន្ទេ　　វន្ទេ គោតមនាយកំ**
**អដ្ឋវីសតិ មេ ពុទ្ធា　　និព្វានាមតទាយកា**
**នមេ តេ សិរសា និច្ចំ　តេ មំ រក្ខន្តុ សព្វទា ។**

ប្រែពាក្យវដ្ដឆន្ទ

ខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ　　មាននាមប្រាកដ ព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំ ព្រះបរមបវរ　　ព្រះមេធង្ករ ជាសម្ពុទ្ធា ។
សូមក្រាបបង្គំ ប្រណម្យវន្ទា　　នូវព្រះភគវា ព្រះសរណង្ករ
សូមថ្វាយបង្គំ ព្រះទីបង្ករ　　មានញាណបវរបារមីពោរពេញ ។
សូមថ្វាយបង្គំ នូវព្រះកោណ្ឌញ្ញ　ព្រះអង្គបំពេញ ធមិជាកុសល
ខ្ញុំសូមបង្គំ នូវព្រះទសពល　　ព្រះនាមមង្គល ជាសម្ពុទ្ធៈ ។
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ　　ព្រះនាមសុមនៈ សម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំ ព្រះបរមសុគត　　ព្រះនាមប្រាកដ ព្រះរេវតៈ ។
ខ្ញុំសូមបង្គំ ព្រះបរមពុទ្ធៈ　　មានញាណសោភៈ ព្រះនាមសោភិត
ខ្ញុំសូមបង្គំ ប្រណម្យប្រណីត　　ឆ្ពោះព្រះវិជិត អនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសី　ចំពោះព្រះមុនី ព្រះនាមបទុម

ខ្ញុំសូមឱនកាយ ថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទៈ ។
សូមថ្វាយបង្គំ ព្រះបទុមុត្តរៈ មានញាណសោភៈ វរៈពុទ្ធោ
ខ្ញុំសូមបង្គំ នូវព្រះភគវា ទ្រង់ព្រះនាម សុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំ ប្រណមក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធ ព្រះនាមសុជាត
ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថ បិយទស្សី ។
ខ្ញុំសូមបង្គំ ឆ្ពោះព្រះជិនស្រី អត្ថទស្សី បារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំ ឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះ ធម្មទស្សី ។
ខ្ញុំសូមបង្អោន លំទោនសិរសី បង្គំជិនស្រី ព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំ នូវព្រះមុនីរតន៍ ព្រះនាមប្រាកដ តិស្សៈសាស្តា ។
ខ្ញុំសូមបង្គំ នូវព្រះសម្មា- សម្ពុទ្ធនាមថា ផុស្សៈមុនី
ខ្ញុំសូមបង្គំ ប្រណម្យអញ្ជលី ឆ្ពោះព្រះមុនី ព្រះនាមវិបស្សី ។
សូមថ្វាយបង្គំ ព្រះបរមជិនស្រី ព្រះនាមសិខី សពេជ្រពុទ្ធា
ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំ លើកហត្ថទាំងគូ ឆ្ពោះព្រះជាគ្រូ ព្រះនាមកកុសន្ធ
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈ កោនាគមនោ ។
ខ្ញុំសូមឱនកាយ វាចាមនោ បង្គំពុទ្ធោ ព្រះនាមកស្សបៈ
ខ្ញុំសូមលំទោន បង្អោនសិរៈ ឆ្ពោះព្រះសមណៈព្រះនាមគោតម ។
គម្រប់ម្ភៃ ប្រាំបីព្រះបរម សម្ពុទ្ធជាធំ កំពូលលោកា
ទូទាំងត្រ័យភពជាម្លប់សាខា មនុស្សទេវតាមារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រកក្រោមម្លប់ព្រះឆាយ បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខ ក្នុងឋានសួគ៌ា ឬឋានព្រហ្មានិងព្រះនិព្វាន ។

ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ ព្រះធម៌ប្រធាន ជាយាននាំសត្វ
តេជះយើងខ្ញុំ ប្រណមថ្វាយថ្វាត់ នូវព្រះពុទ្ធរតន៍គ្រប់៧ព្រះអង្គ ។
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គ ម្ភៃប្រាំបី
សូមអានុភាព ពីព្រះជិនស្រី ម្ភៃប្រាំបី ព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ ព្រះអង្គសម្តែង ទាំងព្រះគម្ពែង សង្ឃជាសាវ័ក
សូមសុខចំរើនកើនឡើងតាមថ្នាក់ កុំឱ្យមានអាក់អន់អាប់ឡើយណា ។
សូមឱ្យខ្ញុំបានដល់ឋានទេវតា ដូចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាត

**បច្ចយោ ហោតុ !**

## ២- វិសាខបូជា

### រតនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្សការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វ-ទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មា-សម្ពុទ្ធំ អាទរេន នមស្សាម ។**

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខ-ស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន នមស្សាម ។**

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកម្ចាត់បង់នូវទុក្ខទាំងពួង

ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន យើងខ្ញុំព្រះ-
អង្គសូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**សុប្បដិបន្នោ ឧតស្ស ភគវតោ សោ សាវក-
សង្ឃោ យោ សព្វទុក្ខស្ស បហានាយ
បដិបន្នោ តំ សង្ឃំ អាទរេន នមស្សាមិ ៗ**

ព្រះអរិយសង្ឃណា លោកប្រតិបត្តិដើម្បីកម្ចាត់បង់ នូវ
សេចក្តីទុក្ខទាំងពួង ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃ
ព្រះភគវន្តមុនីអង្គនោះ លោកប្រតិបត្តិដោយប្រពៃពិតមែន
យើងខ្ញុំព្រះអង្គសូមថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះ ដោយ
គោរព ។

(ក្រាបថ្វាយបង្គំម្តង)

## ប្រកាសវិសាខបូជា

ថ្ងៃនេះជាតិថី ពេញបូរមីខែវិសាខ មានព្រះចន្ទពេញវង់ ត្រូវនឹងថ្ងៃ ដែលព្រះសក្យមុនី សម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់ប្រសូត្រ ទ្រង់បានត្រាស់ ជាព្រះសព្វសញ្ញុពុទ្ធ ប្រាកដឡើងក្នុងលោក នឹងថ្ងៃដែលទ្រង់រំលត់ខន្ធ ចូលកាន់បរិនិព្វាន ។

តិថីនេះ ជាឧបលក្ខិតសម័យដ៏ឧត្តម ក្នុងព្រះពុទ្ធ សាសនា គឺជាថ្ងៃសំរាប់ពុទ្ធមាមកជន ទាំងបព្វជិតទាំង គ្រហស្ថ ប្រជុំគ្នាធ្វើសក្ការៈបូជា ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងខ្ញុំទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកជួបជុំគ្នា បាបរៀបគ្រឿងសក្ការៈបូជា មានទៀនធូប និងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូប ស្នងព្រះអង្គគង់ជាប្រធាន ហាក់ដូចជាព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា យើងខ្ញុំសូមថ្វាយនូវគ្រឿងសក្ការៈទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ អង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំងបី ដោយសេចក្តីគោរព ។

បពិត្រ! ព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជាហរបុគ្គល របស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនិងព្រះអង្គឡើយ ទោះបីព្រះអង្គទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែង ទៅហើយក៏ពិត មែន ប៉ុន្តែទ្រង់បានប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌ វិន័យដ៏ បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទាំងព្រះគុណ របស់ព្រះអង្គក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះរូបស្ទួងព្រះអង្គ ក៏នៅមានប្រាកដដែរ ។ សូមព្រះ ដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តាប្រោស ទទួលនូវ គ្រឿងសក្ការៈបូជារបស់យើងខ្ញុំព្រះអង្គ ដែលបានរៀបចំ ថ្វាយ ក្នុងទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើងខ្ញុំព្រះអង្គបាន ប្រកបដោយ ឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្តីចំរើន ដ៏ ធំទូលាយ អស់កាលយូរអង្វែងទៅហោង ។

## នមោ ៨ បទ

បទបំព្យាវដ្ត

**នមោ អរ~ ហតោសម្មា**

**សម្ពុទ្ធស្ស មហេសិនោ**

ខ្ញុំសូមបង្គំ ឆ្ពោះព្រះអរហន្ត- សម្ពុទ្ធភគវន្ត កាលស្វែងរកធម៌
គឺពោធិញ្ញាណ ប្រសើរបវរ បានត្រាស់ដឹងធម៌ ដោយអរិយមគ្គ។

**នមោ ឧត្ត~ ម ធម្មស្ស**

**ស្វាក្ខា តស្សេ~ វ តេនិធ**

សូមថ្វាយបង្គំ ព្រះធម៌ឧត្តម ដែលព្រះបរមគ្រូ សម្ពុទ្ធសម្ដែង
ដោយប្រពៃពិត ប្រាកដជាក់ស្ដែង ព្រះធម៌នោះឯង ទុកជាសាសនា។

**នមោ មហា~ សង្ឃស្សាបិ**

**វិសុទ្ធសី~ ល ទិដ្ឋិនោ**

សូមថ្វាយបង្គំ ព្រះសង្ឃប្រសើរ ដែលលោកបានធ្វើ ទិដ្ឋិ និងសីល
ឱ្យបានបរិសុទ្ធ ផុតចាកមន្ទិល គឺទិដ្ឋិសីល លោកស្អាតអស់ហើយ។

**នមោ ឧមា~ ត្យារទ្ធស្ស**

**រតនត្តយ~ ស្ស សាធុកំ**

សូមថ្វាយបង្គំ ប្រជុំត្រ័យរត្ន័ ប្រារព្ធដោយបទ មានបីប្រការ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃនេះណា ប្រសើរថ្លៃថ្លា ថ្លឹងថ្លែងពុំបាន។

**នមោ ឱម~ កាតី តស្ស**

**តស្ស វត្ថុ~ ត្តយស្សាបិ**

សូមថ្វាយបង្គំ ភ្នំវត្ថុបី ពិសេសពិសី ប្រសើរថ្កើនថ្កាន
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃសព្វស្ថាន តេជៈកល្យាណដោយគុណគួគាប់ ។

**នមោ ការា~ ប្បភាវេន**

**វិគច្ឆន្តុ ឧបទ្ទវា**

សូមថ្វាយបង្គំ ត្រ័យរតន៍សោភា ឧបទ្រពនានា ចូរវិនាសបាត់
ដោយអានុភាព បុណ្យជួយកំចាត់ ធ្វើក្តីវិបត្តិ ឱ្យស្ងាត់សូន្យទៅ ។

**នមោ ការា~ នុភាវេន**

**សុវត្ថិ ហោ~ តុសព្វទា**

សូមថ្វាយបង្គំ ត្រ័យរតន៍ទាំងបី សូមសុខសួស្តី កើតសព្វវេលា
ដោយអានុភាព ធ្វើការវន្ទា គោរពបូជា ព្រះត្រ័យរតនៈ ។

**នមោ ការ~ ស្ស តេជេន**

**វិធិម្ហិ ហោ~ មិ តេជវា**

សូមថ្វាយបង្គំ ត្រ័យរតន៍សោភា តេជៈចេស្តា ចូរមានដល់ខ្ញុំ
ក្នុងពិធីធ្វើ ការថ្វាយបង្គំ តេជៈបុណ្យធំ ចូរកើតឡើងហោង ។

## <u>គាថាប្រារព្ធវិសាខបូជា</u>

**វិសាខបុណ្ណមាយំយោជាតោ អន្តិមជាតិយា ។**

**បត្តោ ច អភិសម្ពោធឹ ។ អថោចិ បរិនិព្វុតោ។**

**លោកេ អនុត្តរោ សត្ថា ទយា ញ្ញាណនិ្ធិ-
វាសយោ ។ នាយកោ មោក្ខមគ្គស្មិំ តិវិធត្ថុ
បទេសកោ ។ មហាការុណិកំ នាថំ មយន្តំ
សរណំ គតា ។ អាមិសេហិច បូជេន្តា ធម្មេហិ
បដិបត្តិយា ។ ឥមន្នានិ សុនក្ខត្តំ អភិមង្គល
សម្មតំ ។**

( ប្រែឃ្លោងពាក្យ ៤ កាព្យ )

សាស្តាអង្គណា អនុត្តរាក្នុងលោក
ដឹកនាំទៅរក មគ្គផលនិព្វាន ។
ហឫទ័យករុណា និងបញ្ញាញាណ
ឥតមានអ្វីផ្ទឹមបាន ដូចសមុទ្រជលស័យ ។
ទ្រង់ប្រាប់ប្រយោជន៍ យ៉ាងហោចត្រឹម៣
ឱ្យមានសិរី ប្រុសស្រីគ្រប់គ្នា ។
ព្រះអង្គប្រសូត្រ ចាកឧទរា
ជាតិចុងក្រោយណា វិសាខបុណ្ណមី ។
នឹងបានត្រាស់ដឹង ដំណឹងសិរី
និងនិព្វានក្តី បុណ្ណមីវិសាខៈ ។
យើងខ្ញុំទាំងឡាយ ថ្វាយកាយជីវិតៈ
ឆ្ពោះលោកនាថៈ ការុណិកៈអង្គនោះ ។
និងសូមបូជា ឈ្នះមារទ្រង់យស

ដោយអាមិសស្រស់ និងបដិបត្តិធម៌ ។
ឥឡូវនេះណា នក្ខត្តាដ៏ល្អ
សន្មតចប់ធម៌ អភិមង្គលនេះហោង ។

(ចប់គាថា វិសាខបូជា)

## គាថានមស្សការចំពោះព្រះពុទ្ធ ២៨ ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ អនោមទស្សឹ មុនឹ នមេ
វន្ទេ បទុមសម្ពុទ្ធំ វន្ទេ នារទនាយកំ
បទុមុត្តរំ មុនឹ វន្ទេ វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ បិយទស្សឹ មុនឹ នមេ
អត្ថទស្សឹ មុនឹ វន្ទេ ធម្មទស្សឹ ជិនំ នមេ
វន្ទេ សិទ្ធត្ថសត្ថារំ វន្ទេ តិស្សមហាមុនឹ
វន្ទេ ផុស្សមហាវីរំ វន្ទេ វិបស្សិនាយកំ
សិខឹ មហាមុនឹ វន្ទេ វន្ទេ វេស្សភូនាយកំ

**កកុសន្ធំ មុនឹ វន្ទេ វន្ទេ កោនាគមនំ ជិនំ**
**កស្សបំ សុគតំ វន្ទេ វន្ទេ គោតមនាយកំ**
**អដ្ឋវីសតិ មេ ពុទ្ធា និព្វានាមតទាយកា**
**នមេ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទាឲ**

ប្រែពាក្យវដ្ដឆន្ទ

ខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ មាននាមប្រាកដ ព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំ ព្រះបរមបវរ ព្រះមេធង្ករ ជាសម្ពុទ្ធា ។
សូមក្រាបបង្គំ ប្រណម្យវន្ទា នូវព្រះភគវា ព្រះសរណង្ករ
សូមថ្វាយបង្គំ ព្រះទីបង្ករ មានញាណបវរបារមីពោរពេញ ។
សូមថ្វាយបង្គំ នូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញ ធម៌ជាកុសល
ខ្ញុំសូមបង្គំ នូវព្រះទសពល ព្រះនាមមង្គល ជាសម្ពុទ្ធៈ ។
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ព្រះនាមសុមនៈ សម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំ ព្រះបរមសុគត ព្រះនាមប្រាកដ ព្រះរេវតៈ ។
ខ្ញុំសូមបង្គំ ព្រះបរមពុទ្ធៈ មានញាណសោភៈព្រះនាមសោភិត
ខ្ញុំសូមបង្គំ ប្រណម្យប្រណីត ឆ្ពោះព្រះវិជិត អនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយឱនកាយសិរសី ចំពោះព្រះមុនី ព្រះនាមបទុម
ខ្ញុំសូមឱនកាយ ថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរមព្រះនាមនារទៈ ។
សូមថ្វាយបង្គំ ព្រះបទុមុត្តរៈ មានញាណសោភៈ វរៈពុទ្ធា
ខ្ញុំសូមបង្គំ នូវព្រះភគវា ទ្រង់ព្រះនាម សុមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំ ប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធ ព្រះនាមសុជាត
ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថ បិយទស្សី ។

ខ្ញុំសូមបង្គំ ឆ្ពោះព្រះជិនស្រី　　　អត្ថទស្សី បារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំ ឆ្ពោះព្រះទ្រង់យស　　　ព្រះនាមចំពោះ ធម្មទស្សី ។
ខ្ញុំសូមបង្អោន លំទោនសិរសី　　　បង្គំជិនស្រី ព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំ នូវព្រះមុនីរតន៍　　　ព្រះនាមប្រាកដ តិស្សៈសាស្ដា ។
ខ្ញុំសូមបង្គំ នូវព្រះសម្មា-　　　សម្ពុទ្ធនាមថា ផុស្សៈមុនី
ខ្ញុំសូមបង្គំ ប្រណម្យអញ្ជលី　　　ឆ្ពោះព្រះមុនី ព្រះនាមវិបស្សី ។
សូមថ្វាយបង្គំ ព្រះបរមជិនស្រី　　　ព្រះនាមសិខី សពេជ្រពុទ្ធា
ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា　　　ឆ្ពោះព្រះភគវាព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំ លើកហត្ថទាំងគូ　　　ឆ្ពោះព្រះជាគ្រូ ព្រះនាមកកុសន្ធ
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ　　　ឆ្ពោះព្រះពុទ្ធៈ កោនាគមនោ ។
ខ្ញុំសូមឱនកាយ វាចាមនោ　　　បង្គំពុទ្ធោ ព្រះនាមកស្សបៈ
ខ្ញុំសូមលំទោន បង្អោនសិរៈ　　　ឆ្ពោះព្រះសមណៈព្រះនាមគោតម ។
គម្រប់ម្ភៃ ប្រាំបីព្រះបរម　　　សម្ពុទ្ធជាធំ កំពូលលោកា
ទូទាំងត្រ័យភពជាម្លប់សាខា　　　មនុស្សទេវតាមារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រកក្រោមម្លប់ព្រះឆាយ　　　បានសុខសប្បាយគ្រប់រូបរាល់គ្នា
បានទៅសោយសុខ ក្នុងឋានសួគ៌ា　　　ឬឋានព្រហ្មានិងព្រះនិព្វាន ។
ដោយបុណ្យបារមីនៃព្រះទ្រង់ញាណ　　　ព្រះធម៌ប្រធាន ជាយាននាំសត្វ
តេជៈយើងខ្ញុំ ប្រណមថ្វាយថ្វាត់　　　នូវព្រះពុទ្ធរ័ត្នគ្រប់៧ព្រះអង្គ ។
ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ　　　សាវ័កគ្រប់អង្គ ម្ភៃប្រាំបី
សូមអានុភាព ពីព្រះជិនស្រី　　　ម្ភៃប្រាំបី ព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ ព្រះអង្គសម្ដែង　　　ទាំងព្រះគម្ពែង សង្ឃជាសាវ័ក
សូមសុខចំរើនកើនឡើងតាមថ្នាក់　　　កុំឱ្យមានអាក់អន់អាប់ឡើយណា ។
សូមឱ្យខ្ញុំបានដល់ឋានទេវតា　　　ដូចក្ដីប្រាថ្នា កុំបីឃ្លៀងឃ្លាត

~ ២៨៣ ~

**បច្ចយោ ហោតុ !**

## ពុទ្ធបាទលក្ខណៈ

ព្រះបាទនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានលក្ខណៈដ៏ប្រសើរ វិសេសអស្ចារ្យ ប្លែកពីមនុស្សសាមញ្ញទាំងអស់គឺ ៖

១- ព្រះមហាបុរស មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។

២- ត្រង់ផ្ទៃព្រះបាទទាំងគូ ខាងក្រោមមានរូបកងចក្រកើតឡើង ប្រកបដោយខ្នងកង់និងដុំ ព្រមទាំងកាំ ១000 មានចន្លោះស្មើគ្នាគ្រប់អន្លើ ។

៣- ព្រះមហាបុរស មានព្រះបណ្ហិ គឺកែងវែង ។

៤- មានព្រះអង្គុលី គឺម្រាមព្រះហស្ថ និង ម្រាមព្រះបាទវែងៗ ។

៥- មានផ្ទៃព្រះហស្ថ និង ផ្ទៃព្រះបាទទន់ល្មើយ ។

៦- មានផ្ទៃព្រះហស្ថ និងផ្ទៃព្រះបាទ ប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ។

៧- មានព្រះបាទដូចជាអណ្តែតឡើងខាងលើ ។

៨- មានព្រះជង្ឃា គឺស្មងរៀវមូលត្រសូលស្រដៀង និងស្មងសត្វទ្រាយ ។

## ពុទ្ធបទចេតិយ

រីឯស្នាមព្រះបាទ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះសោត ក៏មានមហិទ្ធិឫទ្ធិដ៏អស្ចារ្យ អាចញុំាងប្រយោជន៍ឱ្យសំរេចដល់សត្វ លោកទាំងអស់ បើសត្វលោកធ្វើសេចក្តីគោរពនមស្សការ ដោយចិត្តជ្រះថ្លា ។

ស្នាមព្រះបាទនោះ បើព្រះអង្គប្រតិស្ឋានទុកក្នុងទីឋានណាមួយហើយ ក៏អាចតាំងនៅស្ថិតស្ថេរអស់កាលយូរអង្វែងឥតមានធម្មជាតិអ្វី មកធ្វើឱ្យវិនាសអន្តរាយបានឡើយ ។

ក្នុងគម្ពីរបាលី បានសំដែងសេចក្តីសរសើរ ចំពោះស្នាមព្រះបាទ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងនេះថា ÷

**ពុទ្ធានំ ហិ បទចេតិយំ អធិដ្ឋហិត្វា អក្កន្តដ្ឋា~នេយេវ បញ្ញាយតិ ន អញ្ញត្ថ យេសញ្ច អត្ថាយ អធិដ្ឋិតំ ហោតិ តេ ច នំ បស្សន្តិ តេសំ បន អទស្សនករណត្ថំ ហត្ថិអាទយោ វា អតិក្កមន្តុ មហាមេឃោ វា បវស្សតុ វេរម្ភវាតា វា បហរន្តុ ន នំ កោចិ មក្ខេតុំ សក្កោតិ ។**

មែនពិត បទចេតិយ គឺស្នាមព្រះបាទរបស់ព្រះពុទ្ធទាំងឡាយ រមែងឃើញមានប្រាកដ តែក្នុងទីដែលទ្រង់

អធិដ្ឋានហើយ ជាន់ទុកប៉ុណ្ណោះឯង មិនឃើញប្រាកដ ក្នុងទីដទៃទៀតឡើយ បើ(ស្នាមព្រះបាទណា) ដែល ព្រះអង្គទ្រង់អធិដ្ឋានហើយ ដើម្បីជាប្រយោជន៍ដល់ជន ទាំងឡាយ ពួកជនទាំងឡាយនោះ រមែងបានឃើញជាក់នូវ ស្នាមព្រះបាទនោះ ដោយពិត (ពុំខានឡើយ) សេចក្តី អស្ចារ្យវិសេសថា ទោះបីហ្វូងសត្វទាំងឡាយ មានដីរ ជាដើម ជាន់រំលប់ចោលក្តី មហាមេឃបង្អុរភ្លៀងធំចុះ មករំលាយចេញក្តី វេរម្ភវាតគឺខ្យល់ដែលវល់ ឬខ្យល់កំបុត ត្បូង បក់ប្រហារត្រឡប់ប្រសព្វគ្នា អំពីទិស ផ្សេងៗឱ្យរលុប ឬក្អួចវិលឆ្វេលផ្ដាច់ទៅក្តី(នូវស្នាមព្រះ បាទ) ដើម្បីធ្វើមិន ឱ្យពួកជនទាំងឡាយនោះបានឃើញ(ក៏ធ្វើឱ្យវិនាសមិនកើត ឡើយ) គឺថា ឥតមានសភាវៈអ្វីមួយ ដែលមានឫទ្ធិអំណាច អាច លុបលាងចោលនូវស្នាមព្រះបាទ នោះបានឡើយ ។

## មហាបុរិសលក្ខណៈ ៣២ ប្រការ

ព្រះភគវន្ត អរហន្ត សម្មាសម្ពុទ្ធ បរមគ្រូរបស់យើងទាំង ឡាយ ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ÷

**១- សុបតិដ្ឋិតបាទោ** ព្រះមហាបុរស មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។

**២- ហេដ្ឋាបាទតលេសុ ចក្កានិ ជាតានិ** ត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ និង ដុំព្រមទាំងកាំ ១000 មានចន្លោះស្មើគ្នាគ្រប់អន្លើ ។

**៣- អាយតបណ្ហិ** ព្រះមហាបុរស មានព្រះបណ្ហិ គឺកែងវែង ។

**៤- ទីឃង្គុលី** មានព្រះអង្គុលី គឺម្រាមព្រះហស្ថ និងម្រាមព្រះបាទវែងៗ ។

**៥- មុទុតលុនហត្ថបាទោ** មានផ្ទៃព្រះហស្ថ និងផ្ទៃព្រះបាទ ដ៏ទន់ល្មើយ ។

**៦- ជាលហត្ថបាទោ** មានផ្ទៃព្រះហស្ថ និងផ្ទៃព្រះបាទ ប្រទាក់ក្រឡាដូចជាសំណាញ់ ។

**៧- ឧស្សង្ខបាទោ** មានព្រះបាទដូចជាអណ្តែតឡើងខាងលើ ។

**៨- ឯណជង្ឃោ** មានព្រះជង្ឃាគឺស្មងរៀវមូលត្រសូលស្រដៀងនិងស្មងសត្វទ្រាយ ។

**៩~ ឋិតកោ ច អនោនមន្តោ** កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះអាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្តទាំងពីរបាន ។

**១០~ កោសោហិតវត្ថគុយ្ហោ** មានព្រះអង្គាវយវៈដែលត្រូវលាក់កំបាំងដោយសំពត់បិតនៅក្នុងស្រោម ។

**១១~ សុវណ្ណវណ្ណោ** មានស្បែកសម្បុរថ្ងៃ (លឿងភ្លឺអន្លង់) ដូច ជាសម្បុរនៃមាស ។

**១២~ សុខុមច្ឆវី** មានព្រះឆវីគឺសម្បុរថ្ងៃ ល្អិតផូរផង់រលីងស្រិល រអិលធូលីធ្លាក់មកមិនជាប់ព្រះកាយ ។

**១៣~ឯកេកលោមោ** មានព្រះលោមាតែមួយសរ-សៃៗ គឺក្នុងរណ្ដៅរោម ១ មានរោម ១ ។

**១៤~ ឧទ្ធគ្គលោមោ** មានព្រះលោមាមានចុង ង ឡើង លើព្រះលោមាដែលដុះឡើងហើយ មានចុងឡើងលើជាទក្ខិណាវដ្ត វិលវង់ព័ទ្ធពេនទៅខាងស្តាំ មានសម្បុរខៀវដូចជាសម្បុរនៃផ្កាអញ្ជ័ន ក្ងួចមូលដូចជាកុណ្ឌល ។

**១៥~ ព្រហ្មុជុគត្តោ** មានព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម ។

**១៦~ សត្តុស្សទោ** មានព្រះមំសៈសាច់ ៧អន្លើពេញ

បរិបូណ៌ គឺត្រង់ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ ចង្កួយស្មាទាំងពីរ និងព្រះសូរង ។

**១៧~ សីហបុព្វឌ្ឍកាយោ** មានព្រះកាយពាក់កណ្តាលខាងលើដូចជាកាយនៃរាជសីហ៍ ។

**១៨~ ចិត្តន្តរំសោ** មានព្រះបិដ្ឋិ គឺខ្នងដ៏បរិបូណ៌ (គឺថាសាច់ជាចន្លោះនៃស្លាបប្រចៀវទាំងពីរ) ។

**១៩~ និគ្រោធបរិមណ្ឌលោ** មានទ្រង់ទ្រាយព្រះកាយដូចជា បរិមណ្ឌលនៃដើមជ្រៃ កាយរបស់មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសក៏ប្រវែងនោះដែរ គឺមានកាយ និងព្យាមស្មើគ្នា ។

**២០~ សមវដ្ដក្ខន្ធោ** មានព្រះសូរងមូលសម ។

**២១~ រសគ្គសគ្គី** មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារដ៏ លើសលែងសំរាប់ទទួលរសអាហារ ។

**២២~ សីហហនុ** មានព្រះហនុកា (ចង្កា) ដូចជាចង្កានៃរាជសីហ៍ ។

**២៣~ ចត្តាឡីសទន្តោ** មានព្រះទន្ត ៤០ គត់ ។

**២៤~ សមទន្តោ** មានព្រះទន្តរាបស្មើ ។

**២៥~ អវិវរទន្តោ** មានព្រះទន្តជិតស្និទ្ធ ។

**២៦~ សុសុក្កទាឋោ** មានព្រះទាឋា គឺចង្កូមទាំង ៤ សស្អាត ។

**២៧~ បហូតជិវ្ហោ** មានព្រះជិវ្ហា ដ៏ធំវែង ។

**២៨~ ព្រហ្មស្សរោ ករវិកភាណី** មានព្រះសូរសព្ទ ដូចជាសម្លេងនៃព្រហ្ម កាលបើបញ្ចេញវាចាលាន់លឺពិរោះ ដូចជាសម្លេងនៃសត្វករវិក ។

**២៩~ អភិនីលនេត្តោ** មានព្រះនេត្រខៀវស្រស់ ។

**៣០~ គោបខុមោ** មានដួងព្រះនេត្រដូចជាភ្នែកនៃកូនគោ ។

**៣១~ ឧណ្ណា ភមុកន្តរេ ជាតា** មានព្រះឧណ្ណា-លោម គឺរោមប្រជុំចិញ្ចើមដុះត្រង់ចន្លោះនៃព្រះភមុកា (ចិញ្ចើម) មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ។

**៣២~ ឧណ្ហីសសីសោ** មានព្រះសិរ ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។

មហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះ ក្នុងលក្ខណសូត្រ គឺជាតួព្រះពុទ្ធវាចា ហូរចេញពីព្រះឱស្ឋទិព្វថ្លៃ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទេសនា ប្រោសប្រាប់ភិក្ខុទាំង

ឡាយ នៅនាវត្តជេតពនរបស់ អានាថបណ្ឌិកសេដ្ឋី ជិតក្រុង សាវត្ថីនោះឯងហោង ។

## ពុទ្ធភាសិត

ដោយសម្ដេចព្រះសង្ឃរាជ **ជួន~ណាត**

អំពើអាក្រក់ឆក់ចិត្តឱ្យងាយធ្វើ

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**

**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ**

អសាធុកម្ម គឺអំពើរបស់អសប្បុរសទាំងឡាយ ជាអំពើឥត-ប្រយោជន៍ដល់ខ្លួន គេងាយធ្វើទេ ឯអំពើជាសាធុកម្មរបស់សប្បុរស ដែលជាអំពើផ្ដល់ផលប្រយោជន៍(ដល់ខ្លួន)អំពើនោះឯង គេពិបាកធ្វើណាស់ គឺមិនងាយនឹងធ្វើកើត ។

## កំណាព្យ ពាក្យ ៩

កម្មអាក្រក់ តែងទាញឆក់ ចិត្តជនផង
ឱ្យកន្លង ផុតប្រយោជន៍ របស់ខ្លួន
គេពុំខ្លាច គេអាចហ៊ាន ធ្វើផ្ទួនៗ
ទោះបីខ្លួន បានវិនាស ក៏ពុំរាង ។
រីកម្មណា ជាសាធុ ល្អប្រពៃ
មានកម្រៃ អាចនាំខ្លួន ឱ្យចៀសវាង
ផុតចាកទោស ឥតរឱស ក៏អ្នកនាង

ខ្លះច្រើនឃ្លាង កម្របាន ធ្វើកម្មនោះ ។

**សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ**

**បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ ។**

សាធុកម្ម គឺអំពើធ្វើជាកុសល ជនជាសប្បុរសងាយធ្វើកើត សាធុកម្ម ជនចិត្តបាបពិបាកធ្វើណាស់ គឺមិនងាយនឹងធ្វើកើតទេ អំពើបាបជនចិត្តបាបងាយធ្វើកើត អំពើបាបអរិយជន គឺជនអ្នកប្រសើរដោយសីលធម៌ពិបាកធ្វើណាស់ គឺមិនងាយនឹងហ៊ានប្រថុយធ្វើឡើយ ។

## កំណាព្យ ពាក្យ ៩

| | | |
|---|---|---|
| សាធុជន | ស្រលាញ់បុណ្យ | ងាយធ្វើបុណ្យ |
| ឯទុរជន | ចិត្តទំរន់ | ធ្វើពុំកើត |
| បើបាបវិញ | គេងាយធ្វើ | ពុំញញើត |
| អ្នកប្រាជ្ញឆើត | ធ្វើពុំកើត | ព្រោះខ្ពើមបាប ។ |

## ផលានិសង្សសុចរិត

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ**

**ធម្មោ សុចិណ្ណោ សុខមាវហាតិ**

**ឯសានិសំសោ ធម្មេ សុចិណ្ណេ**

**ន ទុគ្គតឹ គច្ឆតិ ធម្មចារី**

សុចរិតធម៌តែងរក្សានូវអ្នកប្រព្រឹត្ត សុចរិតធម៌នោះឯង សុចរិតធម៌ដែលគេសន្សំល្អហើយ តែងនាំយកសេចក្ដីសុខមកផ្ដល់ផលឱ្យ នេះជាអានិសង្សនៃធម៌ដែលគេអប់រំសន្សំហើយ អ្នកប្រព្រឹត្តធម៌រមែងតែង មិនទៅកាន់ទុគ្គតិឡើយ ។

## កំណាព្យ ពាក្យ ៩

ធម៌សុចរិត តាមការណ៍ពិត តែងរក្សា
នូវជនណា ដែលប្រព្រឹត្ត នូវធម៌នោះ
ធម៌សុចរិត ដែលបណ្ឌិត សន្សំស្មោះ
ពុំដែលផ្ទោះ តែងនាំសុខ មកផ្ដល់ឱ្យ ។
នេះគឺជា អានិសង្ស ការផ្ចង់ចិត្ត
ខំប្រព្រឹត្ត សន្សំធម៌ ពុំដែលធ្ លោយ
វីបុគ្គល អ្នកប្រព្រឹត្ត ធម៌ពុំខ្សោយ
លុះជាតិក្រោយ តែងបានសោយ សុខសួគ៌ា ។
រឿងពីព្រេង ព្រះសំដែង ប្រាប់បញ្ជាក់
ថាមានអ្នក ប្រព្រឹត្តធម៌ សុចរិតា
ពួជធម្មបាល ឥតមានសល់ រូបជនណា
ទាំងអស់គ្នា សុទ្ធតែមាន អាយុវែង ។
ជនណាបាន ប្រព្រឹត្តធម៌ នេះទៀងទាត់
ពុំដែលភ្លាត់ តែងរស់នៅ យូរអង្វែង
ដូចភាសិត ដែលព្រះពុទ្ធ ទ្រង់សំដែង

ជននោះឯង តែងបានសុខ ប្រសើរហោង ។

❋ ❋ ❋

## សេចក្ដីបរិសុទ្ធិ និង មិនបរិសុទ្ធិ

**អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ**

**អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ**

**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ**

បាបដែលគេធ្វើហើយខ្លួនឯង នឹងសៅហ្មងខ្លួនឯង បាបដែលគេមិនធ្វើហើយខ្លួនឯង រមែងបរិសុទ្ធខ្លួនឯង បរិសុទ្ធ ឬមិនបរិសុទ្ធ ប្រាកដជាក់ច្បាស់ឯង១ៗឯអ្នកដទៃមិនអាចសំអាតឱ្យអ្នកដទៃបានឡើយ ។

❋ ❋ ❋

## កំណាព្យ បទកាកគតិ

វីបុណ្យនិងបាប រែងមានសុភាព កើតពីការធ្វើ គឺខ្លួនរាល់គ្នា សំរេចអំពើ ជននោះរងផល ។ ផលសុខផលទុក្ខ រែងតែចេញមុខ តាមពេលត្រូវផ្ដល់ ចេញតាមលំអាន កុសលាកុសល ឥតអ្វីណាផ្ដល់ ក្រៅពីនេះទេ ។ ស្អាត និងមិនស្អាតជាក់ច្បាស់ពេញខ្នាត នៃកម្មបុព្វេ ឥតអ្នកដទៃ ក្រៅពីខ្លួនទេ ជនខ្លះធ្វេសទ្វេ មិនជឿកម្មផល ។ ទោះកម្មចេញមុខ ឱ្យសុខ

ឱ្យទុក្ខ ក៏ដឹងមិនដល់ ពុំដឹងថាកម្ម ទេតើផ្ដល់ផល ពុំគួរតែឆ្ងល់ ពុំយល់ច្នោះឡើយ។ ព្រះពុទ្ធទ្រង់ប្រាប់ គួរតាំងចិត្តស្ដាប់ កុំធ្វើតោះតើយ ត្រូវប្រើការគិត ពិនិត្យរឿយៗ ចិត្តស្ងៀមព្រងើយ ធ្វើម្ដេចនឹងយល់ ។

## គារវបុគ្គល ១០ពួក

**ពុទ្ធោ បច្ចេកពុទ្ធោ ច អរហា អគ្គសាវកោ**
**មាតា បិតា គរុ សត្ថា ទាយកោ ធម្មទេសកោ**
**បណ្ឌិតេហិ ឥមេ ទស ន ទុព្ភន្តីតិ ជានិយា។**

(បទព្រហ្មគីតិ)

ព្រះពុទ្ធព្រះបច្ចេក និងឯកអគ្គារហា
អគ្គសាវកា និងមាតាបិតាផង។
គ្រូនិងសាស្ត្រាចារ្យ និងទាយកឥតមោះហ្មង
និងអ្នកទេស្នាផង កុំយង់ឃ្នងឆ្គងប្រមាថ។
បុគ្គលទាំងដប់នេះ ប្រាជ្ញគួរិះរេសំអាត
ត្រូវកុំបីប្រមាថ គួរឱហាតឱ្យចងចាំ។
ថាមិនត្រូវប្រទុស្ត ឬរឹងរូសធ្វើឱ្យឆ្គាំ-
ឆ្គងខុសក្រែងនឹងនាំ- ឱ្យបានទុក្ខឃើញផ្ទាល់ភ្នែក។

ខ្ញុំតែងពាក្យកាព្យនេះ ដោយរិះរេមិនរារែក
មិនតែងចេញឱ្យប្លែក ពីគាថាបាលីឡើយ ។
អ្នកណាបានគោរព បុគ្គលដប់ពុំតោះតើយ
តាមបែបខាងលើហើយ អ្នកនោះរែងជួបក្តីសុខ ។
មានរឿងតំណាលថា ពួកទេព្តានិរទុក្ខ
ព្រះឥន្ទជាប្រមុខ តែងសំពះទិសទាំងដប់ ។
គឺទិសទាំងប្រាំបី ទិសក្រោមលើដោយសព្វគ្រប់
លើកដៃម្រាមទាំងដប់ ប្រណមឆ្ពោះជននានា ។
ដែលគេបានប្រព្រឹត្ត សុចរិតឥតសង្កា
ទោះនៅត្រង់ទីណា ក៏ដោយចុះឥតរើសមុខ ។
ថាសូមឱ្យជននោះ បានរវាតឃ្លាតចាកទុក្ខ
តាំងពីនេះទៅមុខ សូមបានសុខអាយុវែង ។
ព្រោះហេតុនោះបានជា ព្រះភគវាទ្រង់សម្តែង
ថាជនទាំងនោះឯង ទោះទេព្តាក៏រាប់អាន ។
ទេព្តាទាំងតូចធំ តែងបង្គំមករាល់ប្រាណ
ឆ្ពោះជនទាំងប៉ុន្មាន ដែលបានកាន់សីល និងធម៌ ។
ហេតុនេះសាធុជន កុំទំរន់គួរត្រេកអរ
ឆ្ពោះធម៌ដ៏បវរ ដែលព្រះពុទ្ធទ្រង់សរសើរ ។

# យរាវាសធម៌

**សំនួរ** : ដូចម្ដេចដែលហៅថា **យរាវាសធម៌** ?

**ចម្លើយ** : ដែលហៅថា **យរាវាសធម៌** គឺជាធម៌ ឬច្បាប់របស់គ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ សម្រាប់កាន់ ឬប្រតិបត្តិតាម ។

**១~ សច្ចៈ** សេចក្ដីទៀងត្រង់ដល់គ្នា នឹងគ្នា ។

**២~ ទមៈ** ទូន្មានចិត្តឱ្យទន់ភ្លន់មិនហឹង្សា ។

**៣~ ខន្តី** អត់ធន់គ្រប់យ៉ាង ក្នុងភារកិច្ចគ្រប់មុខ ។

**៤~ ចាគៈ** លះបង់ទ្រព្យសម្បត្តិដល់អ្នកដទៃដែលគួរឱ្យ ។

**អត្ថាធិប្បាយ** គ្រហស្ថទាំងឡាយ ដែលជាអ្នកគ្រប់គ្រងផ្ទះសម្បែង តែងតែមានភរិយា បុត្រធីតា ដែលជាសមាជិកគ្រួសាររៀងៗខ្លួន។ សមាជិកទាំងនោះតែងមានអត្តចរិតផ្សេងៗពីគ្នា ទោះបីអ្នកទាំងនោះមានឈាមជ័រ

តែមួយក៏ដោយ ។ ខ្លះមាននិស្ស័យចូលចិត្តតែសប្បាយហើយ និយាយច្រើន ខ្លះចូលចិត្តកំប្លែងលេងក្រមាច់ក្រមើម ខ្លះ ចំណូលខាងភូតភរកុហកគេ កុហកឯង ប្រើល្បិចគ្រប់យ៉ាង ខ្លះទៀតជាមនុស្សស្មោះត្រង់ ទៀងត្រង់ហើយប្រាថ្នាតិច ចូលចិត្តការស្ងប់ស្ងាត់ មិនចង់បានមានអ្វីឱ្យហួសហេតុដែល ផ្ទុយពីចរិយាសម្បត្តិរបស់មាតាបិតា។ ដោយហេតុ មនុស្ស ដែលកើតក្នុងគ្រួសារតែមួយ ហើយមានអធ្យាស្រ័យ និង លក្ខណៈផ្សេងៗពីគ្នា តាមការប្រព្រឹត្ត ការយល់ឃើញផ្ទាល់ ខ្លួនម្នាក់ៗដូច្នោះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែង អំពីសច្ចធម៌នេះ ថាជាធម៌សម្រាប់ទំនាក់ទំនងគ្នាល្អវិសេស អាចបង្កើតសាមគ្គីភាពក្នុងគ្រួសារនីមួយៗបាន។

បើគ្រួសារនីមួយៗ បានតាំងនៅស៊ុបមាំក្នុងសច្ចធម៌ គឺសេចក្ដីទៀងត្រង់រវាងគ្នានឹងគ្នាហើយ ក៏តោងមាន ទមៈធម៌ គឺការទូន្មានចិត្តឱ្យបានល្អ ដែលគេហៅថាលត់ដំ គឺធ្វើចិត្តឱ្យស្ងប់ស្ងាត់ ទន់ភ្លន់ កុំឱ្យមានការក្រេវក្រោធ រំលោភលើគ្នាថែមទៀត ។ គឺជាសភាវតែងតែត្រិះរិះនូវ អារម្មណ៍ផ្សេងៗមិនឈប់ឈរ តែងតែរំភើបញាប់ញ័រ ពិបាកនឹងការពារ ឬទប់ទល់ឱ្យនៅនឹងមួយកន្លែងបាន។ អ្នកប្រាជ្ញបានពោលថា បុគ្គលណា បានទូន្មានចិត្តឱ្យ

ល្អប្រពៃហើយ បុគ្គលនោះឈ្មោះថាបានសេចក្តីសុខ ដែលជាចំណង់ធំបំផុតរបស់មនុស្សលោក។ ពិតមែនតែចិត្តជាអរូបី យើងមិនអាចមើលឃើញដោយចក្ខុទេ តែវាអាចបង្គាប់បញ្ជាលើរូបរាងកាយទាំងមូលបាន។ យ៉ាងនេះហើយ បានជាព្រះសាស្តាប្រដៅសត្វលោកឱ្យអប់រំចិត្តឱ្យមានសភាពទន់ភ្លន់ល្អ ឱ្យវៀរចាកអកុសលទាំងពួងមានការប្រព្រឹត្តអាក្រក់ដោយកាយ ឬវាចាជាដើម ទៅលើមនុស្សសត្វដែលនៅជុំវិញខ្លួនយើង។ ចិត្តនេះ ទោះបីរបឹងរឹងរូសដូចម្តេចក្តី ក៏គេអាចទូន្មាន ឬអប់រំឱ្យបានល្អដែរ មិនខុសពីជាងធ្នូពត់តម្រង់កូនសរឱ្យត្រង់ដែលអាចបាញ់ចំគោលដៅ ក្នុងទិសទាំងបួនដូចសេចក្តីប្រាថ្នាបាន។ បើលំអិតចិត្តបានហើយ ទើបបំពេញកិច្ចការសម្រេចបាន ក៏អាស្រ័យទៅលើការធ្វើ ដោយសេចក្តីព្យាយាម និងសេចក្តីអត់ធន់ ដែលលោកហៅថាខន្តី គឺការអំណត់តស៊ូ ធ្វើមិនខ្លាចនឿយលំបាកគ្រប់យ៉ាង ក្នុងការបំពេញកិច្ចការនោះៗ។ ការងារទាំងឡាយមិនអាចសម្រេចដោយឯងៗ ដោយគ្រាន់តែគិត ឬនឹកចង់នោះទេ លុះត្រាតែធ្វើហើយអំណត់ទៀតទើបសម្រេច។ ខន្តីលោកចាត់ជាតបៈធម៌ដ៏ខ្ពង់ខ្ពស់ក្រៃលែង សម្រាប់កំចាត់អកុសលធម៌ទាំងឡាយ មានហឹង្សាជាដើម និងជាអលង្ការដ៏ប្រសើររបស់បុរសស្ត្រីផង។ កាលបើ មានអំណត់អត់ឱនចំពោះគ្នានឹងគ្នាហើយ ក៏ត្រូវមានការចែកចាយទ្រព្យ

សម្បត្តិរបស់ខ្លួនតទៅទៀត ដែលលោកហៅថាចាគៈនេះឯង ។ ចាគៈគឺជាការលះបង់កំណាញ់ ហើយយកទ្រព្យសម្បត្តិឱ្យទៅជាទាន ដល់អ្នកដែលគួរនឹងឱ្យ ពីព្រោះគ្រហស្ថត្រូវបែងចែកសម្បត្តិរបស់ខ្លួនជា ៥ ផ្នែកគឺ :

១- ចិញ្ចឹមខ្លួន និងមាតាបិតា បុត្រភរិយាទាសកម្មករឱ្យបានសេចក្តីសុខ ។

២- ទំនុកបំរុងកល្យាណមិត្តឱ្យបានល្អ ។

៣- កំចាត់អន្តរាយដែលកើតមកអំពីភ័យផ្សេងៗ ។

៤- ធ្វើពលី ៥យ៉ាង មានញាតិពលីជាដើម ។

៥- ឱ្យទានដល់សមណព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ។

អ្នកស្វែងរកទ្រព្យសម្បត្តិបានមកដោយផ្លូវល្អ ផ្លូវសុចរិតហើយ គួរតែចេះកាន់យកនូវប្រយោជន៍នៃទ្រព្យនោះឱ្យបាន មិនត្រូវទុកទ្រព្យឱ្យនៅទំនេរទេ។ បុគ្គលណាចាយវាយប្រើប្រាស់ទ្រព្យសម្បត្តិចិញ្ចឹមខ្លួន និងមាតាបិតាជាដើម បុគ្គលនោះឈ្មោះថា កាន់យកនូវប្រយោជន៍នៃទ្រព្យនោះទុកបាន។ ប្រើប្រាស់ទ្រព្យសម្បត្តិក្នុងផ្លូវឥតប្រយោជន៍ ដូចជាលេងល្បែងភ្នាល់ និងផ្គាប់ផ្គន់ស្រីជាដើម ឈ្មោះថាមិនបានកាន់យកនូវប្រយោជន៍នៃទ្រព្យសម្បត្តិនោះឡើយ ។

ចិញ្ចឹមមិត្តសម្លាញ់ឱ្យបានសុខ គឺថាយើងរើសយកតែកល្យាណមិត្ត ឯបាបមិត្ត យើងមិនត្រូវចែកចាយឱ្យទេ

ឡើតអី អសេវនធមិជារឿងធំ បំផុតនៃជីវិតមនុស្សយើង សូម្បី តែព្រះពុទ្ធជាម្ចាស់សំដែងក្នុងមង្គលសូត្រ ៣៨ប្រការ ក៏ ចាប់យកការសេពគប់ជាមុនដែរ ដូចបទថា **អសេវនា ច ពាលានំ បណ្ឌិតានញ្ច ច សេវនា** ជាដើម ប្រែសេចក្តីថា ចូរអ្នកកុំសេពគប់នឹងមនុស្សពាល ឱ្យសេព-គប់តែបណ្ឌិតទើបសន្មតថា ជាមង្គលគឺសេចក្តីចម្រើន។ ហេតុនេះ បានជាព្រះអង្គឱ្យសង្គ្រោះតែមិត្តល្អៗ ដែលអាចពឹងពាក់ ឬ ជួយធុរៈយើងគ្រប់គ្រាក្នុងគ្រាក្រ ។

ចំណាយទ្រព្យសម្បត្តិ កំចាត់អន្តរាយដែលកើតពីហេតុផ្សេងៗ នោះគឺបំបាត់អន្តរាយដែលកើតអំពីភ័យគ្រប់យ៉ាង មានអគ្គីភ័យ ភ័យអំពីភ្លើងឆេះ ចោរភ័យ ភ័យអំពីចោរលួច ឧទកភ័យ ភ័យអំពីទឹកលិចជាដើម ដោយកម្លាំងទ្រព្យដែលអាចចាត់វិធានការណ៍ការពារយ៉ាងម៉ឺងម៉ាត់ មិនឱ្យកើតឡើងបាន។

ត្រូវជួយសង្គ្រោះញាតិ ទៅតាមលំដាប់ថ្នាក់នៃជួរទាំងសងខាងដែលហៅថាញាតិពលី ។

ត្រូវធ្វើបុណ្យឧទ្ទិសផលដល់បុព្វបុរសទាំងឡាយ មានមាតាបិតាជាដើម ដែលចែកស្ថានទៅកាន់បរលោកហើយហៅថា បុព្វបេតពលី ។

ត្រូវបង់ពន្ធដារជូនរដ្ឋ តាមប្រពៃណីនៃច្បាប់ប្រទេសនីមួយៗ ហៅថា រាជពលី ។

ទេវតាដែលជាសម្មាទិដ្ឋិរក្សាគ្រប់គ្រងលោកធាតុទាំងមូល ឱ្យតាំងនៅសេចក្តីសុខគ្រប់កន្លែង។ អ្នកម្ចាស់ទីកន្លែងត្រូវតែធ្វើបុណ្យឧទ្ទិសផលឱ្យតាមគតិនិយម ចំពោះទេវតាទាំងនោះ ហៅថា ទេវតាពលី ។

សមណព្រាហ្មណ៍ ដែលប្រកបដោយសីលាចារវត្ត ជាអ្នកបំពេញកិច្ចក្នុងផ្លូវព្រះពុទ្ធសាសនា ឬបំពេញសាធារណប្រយោជន៍ដល់មហាជនទូទៅ ក៏គួរទទួលឋានៈជាបុគ្គលដែលត្រូវគោរពបូជាដែរ ។

ការធ្វើអត្ថាធិប្បាយអំពីឃរាវាសធម៌ទាំង ៤ប្រការ ដែលទាក់ទង ទៅនឹងការបែងចែកទ្រព្យសម្បត្តិរបស់គ្រហស្ថ ក៏សមគួរដល់កាលវេលានឹងបញ្ចប់តែប៉ុណ្ណេះ សូមសាធុជនទាំងឡាយ ជួបប្រទះតែសេចក្តីសុខ-ចម្រើន អស់កាលជានិរន្តរ៍តទៅ ។

## កំណាព្យរំលឹក

ឃរាវាសធម៌ ៤ប្រការ
ដែលព្រះសាស្តាទ្រង់សម្តែង
បើអ្នកប្រព្រឹត្តយ៉ាងជាក់ស្តែង
អ្នកនោះឯងរមែងជួបក្តីសុខ ។
បើមិនប្រព្រឹត្តឱ្យទៀងទាត់

គង់តែនឹងភ្លាត់ជួបក្តីទុក្ខ
ហិនហោចខ្លោចផ្សាតទៅមុខ
មិនបានក្តីសុខទេលោកអើយ! ។

# ពុទ្ធសាសនសុភាសិត

(ដោយព្រឹទ្ធាចារ្យ **ឌុយ អឿន**)

ខ្ញុំសូមរំលឹកអ្នកអានទាំងអស់គ្នាថា សម្រាប់ពុទ្ធសាសនសុភាសិតនេះ គឺត្រូវប្រើបញ្ញា និង វិចារណញ្ញាណក្នុងកាលអាន ព្រោះថាភាសិតនេះ ជាមូលន័យ មិនមានអភិប្រាយសេចក្ដី ប៉ុន្តែជាសារៈប្រយោជន៍មហិមា សម្រាប់មនុស្សនិករ អ្នកប្រាថ្នាប្រយោជន៍សេចក្ដីសុខ សេចក្ដីចំរើនជានិច្ចនិរន្តរ៍ហើយប្រតិបត្តិ ។

## <u>អត្តវគ្គ</u>

## (ពួកធម៌និយាយអំពីខ្លួន)

០១. ឈ្នះខ្លួនឯងប្រសើរជាង ។

០២.ខ្លួនដែលបុគ្គលទូន្មានល្អហើយជាពន្លឺរបស់បុរស ។

០៣ . ខ្លួនជាគតិ របស់ខ្លួនឯង ។

០៤. ខ្លួនជាទីស្រលាញ់ក្រៃលែង ។

០៥. សេចក្ដីស្រលាញ់អ្វីស្មើ នឹងខ្លួនមិនមានឡើយ ។

០៦. ពួកអ្នកឃើញតែប្រយោជន៍ខ្លួន ហៅថាមនុស្ស អសោចិ៍ ។

០៧. អ្នកណារក្សាខ្លួនបាន ខាងក្រៅរបស់អ្នកនោះ ឈ្មោះថាខ្លួនបាន រក្សាហើយ ។

០៨. បណ្ឌិតគប្បី ធ្វើខ្លួនឱ្យផូរផង់ ចាកគ្រឿងសៅហ្មងចិត្តទាំងឡាយ ។

០៩. ចូរចោទខ្លួនដោយខ្លួនឯង ។

១០. ចូរពិចារណាខ្លួន ដោយខ្លួនឯង ។
១១. ចូររើខ្លួនឡើងចាកភក់ ដូចជាដំរីជាប់ភក់ហើយរើខ្លួនឡើងបាន ។
១២. ចូរអ្នករក្សានូវខ្លួនឱ្យរឿយៗ ចូរកុំដុតខ្លួនឡើយ ។
១៣. កុំសម្លាប់ខ្លួនឯងឡើយ ។
១៤ . បុរសមិនត្រូវឱ្យនូវខ្លួន ។
១៥ . បុរសមិនគប្បីលះបង់នូវខ្លួន ។
១៦. បុគ្គលមិនគួរប្រព្រឹត្តហួសខ្លួន ។
១៧. មិនគួរធ្វើប្រយោជន៍ខ្លួន ឱ្យសាបសូន្យដោយ ច្រើនព្រោះតែប្រយោជន៍អ្នកដទៃឡើយ ។
១៨. បើដឹងថាខ្លួនជាទីស្រលាញ់ មិនត្រូវប្រកបខ្លួននោះដោយអំពើអាក្រក់ឡើយ ។
១៩. តិះដៀលខ្លួនឯងដោយហេតុណា មិនគួរធ្វើហេតុនោះឡើយ ។
២០. បើបណ្ឌិតដឹងថា ខ្លួនជាទីស្រលាញ់គួររក្សាខ្លួននោះឱ្យបានល្អ ស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយកុំខានឡើយ ។
២១.បណ្ឌិតគួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិនហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ (ធ្វើយ៉ាងនេះ) នឹងមិនលំបាកឡើយ ។

២២. បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឱ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

២៣.ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនហើយ រមែងបាននូវទីពឹងដែលគេបានដោយកម្រ ។

២៤. បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញាដូចពេជ្រសម្រាប់កាត់កែវមណីដែលកើតអំពីថ្មដូច្នោះឯង ។

២៥. ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់នូវអត្តភាព របស់បុគ្គលណាដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះឈ្មោះថាធ្វើខ្លួនឯងឱ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើ បុគ្គលនោះឱ្យវិនាសដូច្នោះ ។

២៦. អ្នកធ្វើបាបដោយខ្លួនឯងរមែងសៅហ្មងដោយខ្លួនឯង មិនធ្វើបាបដោយខ្លួនឯងតែងបរិសុទ្ធស្អាតដោយ ខ្លួន-ឯង សេចក្តីបរិសុទ្ធនិងមិនបរិសុទ្ធមានចំពោះខ្លួន អ្នកដទៃ នឹងធ្វើអ្នកដទៃឱ្យបរិសុទ្ធពុំបានទេ ។

២៧.បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះប្រ-យោជន៍របស់អ្នកដទៃសូម្បីច្រើនបើដឹងច្បាស់ប្រយោជន៍

របស់ខ្លួនហើយគប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន
នោះ ។

២៨. សេចក្ដីស្រលាញ់ដទៃ ស្មើដោយខ្លួនមិនមាន ទ្រព្យ
ដទៃ ស្មើដោយស្រូវមិនមាន ពន្លឺដទៃស្មើដោយប្រាជ្ញា
មិនមាន ភ្លៀងហ្នឹងឯងជាស្រះដ៏ឧត្ដម ។

២៩. ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ
តែងពត់ព្រួយឱ្យត្រង់អ្នកចាំងឈើតែងចាំងឈើ
ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួនដូច្នោះដែរ ។

៣០. អ្នកប្រព្រឹត្តល្អតែងទូន្មានខ្លួន ។

៣១.អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាមអស់មួយ
ពាន់៧ដង គឺមួយលាន ចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់
ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នក
ដែលឈ្នះក្នុងសង្គ្រាម ។

៣២. បើបុគ្គលធ្វើដំណើរទៅសព្វទិស ដោយបំណងថា
នឹងស្វែងរកបុគ្គលណាមួយដែលស្រលាញ់អ្នកដទៃ
ជាងខ្លួនឯង ប្រាកដជាពុំបានឡើយ កាលបើដឹង
ថាសត្វទាំងឡាយសុទ្ធតែស្រលាញ់ខ្លួនឯងជាង
អ្នកដទៃ ដូច្នេះហើយបុគ្គលអ្នកស្រលាញ់ខ្លួន កុំ
គប្បីបៀតបៀនអ្នកដទៃឡើយ ។

**ចប់អត្តវគ្គ**

## អប្បមាទវគ្គ

## (ពួកធម៌និយាយអំពីសេចក្តីមិនប្រមាទ)

៣៣. សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ ។

៣៤. អ្នកប្រាជ្ញតែងរក្សាសេចក្តីមិនប្រមាទ ដូចជាគេរក្សាទ្រព្យដ៏ប្រសើរបំផុត ។

៣៥. បណ្ឌិតទាំងឡាយ តែងសរសើរសេចក្តីមិនប្រមាទ។

៣៦. បណ្ឌិតទាំងឡាយតែងរីករាយក្នុងសេចក្តីមិនប្រមាទ។

៣៧. អ្នកមិនប្រមាទ ឈ្មោះថាមិនស្លាប់ ។

៣៨. អ្នកមិនប្រមាទចេះសង្កេតពិនិត្យ តែងដល់នូវសុខដ៏ទូលាយ ។

៣៩. បណ្ឌិតអ្នកមិនប្រមាទ រមែងទទួលបានប្រយោជន៍ទាំងពីរ ។

៤០. អ្នកទាំងឡាយចូរញ៉ាំងកិច្ចគ្រប់យ៉ាង ឱ្យសម្រេចដោយសេចក្តីមិនប្រមាទ ។

៤១. អ្នកទាំងឡាយចូរជាអ្នកត្រេកអរក្នុងសេចក្តី មិនប្រមាទ។

៤២. យស (សេចក្តីរុងរឿង) តែងចំរើនកុះករដល់ បុគ្គលអ្នកមានសេចក្តីប្រឹងប្រែង មានស្មារតី មានការងារ

ស្អាត (ឥតទោស) ជាអ្នកពិចារណារួចទើបធ្វើជាអ្នក
សង្រួម ជាអ្នករស់នៅដោយធម៌ មិនមានសេចក្ដីប្រមាទ ។

៤៣. អ្នកប្រាជ្ញ គប្បីសាងកោះគឺអរហត្តផលជាកោះ ដែល
ជំនន់គឺកិលេសជន់ពន្លិចមិនបាន ដោយសេចក្ដីប្រឹង-
ប្រែងផងដោយសេចក្ដីមិនប្រមាទផង,ដោយការ
សង្រួមផង ដោយការទូន្មាននូវឥន្ទ្រិយ៍ផង ។

៤៤. កាលណាបណ្ឌិតបន្ទោរបង់ សេចក្ដីប្រមាទ ដោយ
សេចក្ដីមិនប្រមាទកាលនោះ លោកឡើងកាន់
ប្រាសាទ គឺបញ្ញាជាបុគ្គលមិនមានសោក រមែងឃើញ
ពួកសត្វដែលមានសោក ធីរជនតែងឃើញពួកជនពាល
ដូចជាបុគ្គល ដែលឈរលើកំពូលភ្នំ ហើយក្រឡេក
មើលពួកជន ដែលស្ថិតនៅលើផែនដីដូច្នោះឯង ។

៤៥. បណ្ឌិតមានប្រាជ្ញាមោះមុត កាលពួកបុគ្គលកំពុង
ប្រមាទ លោកមិនប្រមាទ កាលពួកបុគ្គលកំពុង
ដេកលក់លោកភ្ញាក់រឭកច្រើនលោករមែង លះបង់
ចោលនូវបុគ្គល បែបនោះដូចសេះលឿន ដែលទៅ
ចោលនូវសេះមានកម្លាំងទន់ទាបដូច្នោះឯង ។

៤៦. ភិក្ខុអ្នកត្រេកអរនៅក្នុងសេចក្ដីមិនប្រមាទ ឬឃើញ

ភ័យក្នុងសេចក្ដីប្រមាទ តែងដុតចោលនូវសំយោជនៈ
ទាំងតូច ទាំងធំ ដូចភ្លើងឆេះរាលនូវកំទេច ទាំងតូច
ទាំងធំ ដូច្នេះឯង ។

៤៧. ភិក្ខុអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ ឬ ឃើញភ័យ
ក្នុងសេចក្ដីប្រមាទ ជាអ្នកមិនគួរអោយសាបសូន្យចាក
គុណធម៌ ឈ្មោះថាឋិតនៅក្នុងទីជិតព្រះនិព្វាន ។

៤៨. អ្នកទាំងឡាយចូរឃើញ នូវសេចក្ដីប្រមាទថាជាភ័យ
ផង ឃើញនូវសេចក្ដីមិនប្រមាទ ថាជាគុណជាតិដ៏
ក្សេមផង ហើយចូរចម្រើន មគ្គមានអង្គ៨ ជាពុទ្ធានុ
សាសនី (ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ) ។

**(ចប់)**